# លិខិតជូនមិត្តអ្នកអាន

ភាគបញ្ចប់នៃរឿងសាមកុក បានមកដល់ដៃមិត្តអ្នកអានហើយ។ ខ្ញុំសប្បាយចិត្ត ដោយខ្ញុំបញ្ចប់បេសកកម្មក្នុងការចម្លងរឿងនេះឡើងវិញ ដោយជោគជ័យ ដើម្បីបានជាប្រយោជន៍ដល់ការអានរបស់ប្រជាពលរដ្ឋយើង។

ដោយពិត តាំងពីឆ្នាំ១៩៩៨ ពេលខ្ញុំនៅជានិស្សិតឆ្នាំទី៣ នៃមហាវិទ្យាល័យអក្សរសាស្ត្រ មនុស្សសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខ្ញុំបានស្រឡាញ់រឿងសាមកុក តាមរយៈការពណ៌នាដ៏រស់រវើករបស់លោកសាស្ត្រាចារ្យបណ្ឌិត ស៊ុំ ឈុំប៊ុន អំពីតួអង្គកំពូលពីរនាក់នៅក្នុងរឿងនេះ គឺខុងបេង និងជីវយី។ ប៉ុន្តែនៅសម័យនោះ ការស្វែងរកសៀវភៅនេះ ជាការពិបាកណាស់ សូម្បីតែលោកបណ្ឌិតខ្លួនឯងក៏មិនដឹងដែរ។ នៅឆ្នាំ២០០២ ខ្ញុំដឹងថា គេបានចម្លងសៀវភៅរឿងសាមកុក ពីបណ្ណាល័យជាតិមកចងក្រងជាសៀវភៅយ៉ាងក្រាសចំនួនបួនក្បាល ដោយលក់ថ្លៃ១៥ដុល្លារក្នុងមួយក្បាល។ វាថ្លៃខ្លាំងណាស់សម្រាប់ខ្ញុំ ព្រោះវាជិតស្មើនឹង៥០% នៃប្រាក់ខែរបស់ខ្ញុំនៅពេលនោះទៅហើយ។ ខ្ញុំក៏គ្មានឱកាសបានអានរឿងនេះរហូតដល់ឆ្នាំ២០១០។

នៅឆ្នាំ២០១០ ខ្ញុំបានទៅបណ្ណាគារមួយនៅអតីតសាលមហោស្រពទន្លេបាសាក់ ដែលឆេះអស់ទៅកាលពីឆ្នាំ១៩៩៣ ហើយបច្ចុប្បន្នមានទីតាំងនៅទល់មុខនឹងវិមានរដ្ឋសភាជាតិ។ នៅទីនោះ ខ្ញុំបានឃើញគេដាក់តាំងលក់សៀវភៅរឿងសាមកុក ចំនួនដប់ភាគ ដែលគេបានវាយកុំព្យូទ័រចម្លងឡើងវិញ ដោយលក់ក្នុងមួយក្បាលថ្លៃពីរដុល្លារម្ភៃប្រាំសេន។ ខ្ញុំបានទិញសៀវភៅទាំងដប់ភាគនោះយកមកអាន ព្រមជាមួយគ្នា មិត្តរួមការងារបានចម្លងមកឲ្យខ្ញុំនូវខ្សែភាពយន្តភាគរឿងសាមកុក ដែលមានទំហំជាងមួយរយជីហ្កាបៃ ខ្ញុំបានមើលរឿងនោះរហូតដល់ចប់។ មួយរយៈក្រោយមកទៀត គេបានចម្លងឲ្យខ្ញុំនូវខ្សែភាពយន្តភាគរឿងសាមកុក ដែលថតតាម

បច្ចេកវិជ្ជាថ្មី ហើយមានទំហំតូចជាងមុន ត្រឹមតែជាងម្ភៃជីហ្កាបៃ ខ្ញុំក៏បានតាមដានមើលរហូតដល់ចប់ទៀត។

ការបកប្រែឈ្មោះតួអង្គនៅក្នុងខ្សែភាពយន្តទាំងពីរមានលក្ខណៈខុសគ្នា ហើយវាខុសពីឈ្មោះតួអង្គដែលគេចារឹកក្នុងសៀវភៅទៅទៀត។ ប៉ុន្តែឈ្មោះមិនសំខាន់ទេ សំខាន់គឺខ្លឹមសាររឿង ដែលផ្តល់ជាមេរៀនសម្រាប់យើង។

ខ្ញុំបានធ្វើការប្រៀបធៀបខ្សែភាពយន្តទាំងពីរដែលខ្ញុំបានមើល ជាមួយនឹងសៀវភៅដែលខ្ញុំបានអាន។ ខ្ញុំឃើញថា ការថតជាខ្សែភាពយន្តមិនអាចថតដល់ចំណុចលម្អិត ដែលគេពណ៌នាក្នុងសៀវភៅបានទេ។ បើអ្នកបានអាន នោះអ្នកនឹងមានអារម្មណ៍ដូចជាបានប្រឡូកផ្ទាល់នៅក្នុងរឿងនោះដែរ ឬក៏ដូចអ្នកដែលបានតាមមើលរឿងរ៉ាវដែលកំពុងកើតឡើងពិតៗយ៉ាងដូច្នោះ។

ប៉ុន្តែមានចំណុចខ្សោយមួយ សៀវភៅដែលខ្ញុំចម្លងចេញមកនេះបាត់វគ្គ បាត់ឃ្លាល្បះច្រើនណាស់។ ចំពោះឃ្លាល្បះដែលពិបាកយល់ ខ្ញុំបានរៀបចំសម្រួលតាមការយល់របស់ខ្ញុំឡើងវិញ ដើម្បីឲ្យងាយអាន និងយល់បាន។ ប៉ុន្តែការបាត់តួអង្គសំខាន់ៗដោយមិនដឹងមូលហេតុ ខ្ញុំមិនអាចសម្រួលបានទេ គឺទុកឲ្យនៅជាចម្ងល់ដដែល។

មានចំណុចសំខាន់មួយ ដែលខ្ញុំមិនភ្លេចជម្រាបមិត្តអ្នកអាន គឺឈ្មោះតួអង្គ *ហៃហ៊្វូអៀន* ត្រូវបានជូឡុង មេទ័ពរបស់ *ឡៅពី* សម្លាប់នៅពេលការពារ *អាតៅ* ជាបុត្រ *ឡៅពី* ពីការដេញតាមរបស់កងទ័ពចូឆូ នៅក្នុងភាគទី៤ ឬទី៥ ដែលខ្ញុំចាំមិនច្បាស់។ ប៉ុន្តែឈ្មោះ *ហៃហ៊្វូអៀន* នេះត្រូវបានសម្លាប់ម្តងទៀតនៅក្នុងភាគទី៨ ដោយមេទ័ពរបស់ *ឡៅពី* ឈ្មោះ *ហងតុង*។ ដោយឈ្មោះតួអង្គក្នុងរឿងនេះមានច្រើន ហើយស្រដៀងគ្នាផង ខ្ញុំគិតថាមានការភ័ន្តច្រឡំនៅចំណុចណាមួយមិនខាន។ ខ្ញុំបានពិនិត្យឃើញថាមេទ័ពរបស់ចូឆូមានពីរនាក់ដែលមានឈ្មោះ *អៀន* ដូចគ្នា គឺ *ហៃហ៊្វូអៀន*

និង ម៉ាអៀន។ ដូច្នេះខ្ញុំបានដូរឈ្មោះ ហែហ្វ៊ូអៀន ដែលសម្លាប់ដោយដូឡុង នោះទៅជាឈ្មោះ ម៉ាអៀន វិញ។

សូមមិត្តអ្នកអានមេត្តាខន្តី អភ័យទោស ចំពោះកំហុសឆ្គងទាំងឡាយ និងសូមស្វាគមន៍រាល់ការផ្តល់មតិ ដើម្បីកែលម្អឲ្យបានប្រសើរឡើង។

“សូមឲ្យចំណេះដឹងដែលបានពីរឿងនេះ បានជាប្រយោជន៍ដល់ការការពារជាតិយើង”។

ណុល ដារ៉ា

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៧៧

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ខុងបេង**ទូលព្រះចៅ**ឡៅសៀន** ទៅច្បាំងនឹងស្រុកឡុកសៀ ព្រះចៅ**ឡៅសៀន**ឃាត់ **ជៀវជីវ**ហោរាក៏ឃាត់ ព្រោះឃើញផ្កាយ**ខុងបេង**សៅហ្មង **ខុងបេង**ពុំស្តាប់ **គួនហ៊ុន**ឈឺបច្ចុប្បន្នរោគស្លាប់ រហូតដល់**ឡុកស៊ុន**មេទ័ពស្រុកកាំងតាំងលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ ព្រះចៅ**ចូយ៉យ**ឲ្យតាំងទ័ពទៅស្រុកហាប់ប៉ា)។*

**ខណៈនោះ** **ខុងបេង**តាំងទំនុកបម្រុង សេនាទាហានប្រៀនបង្ហាត់នូវគុនអាវុធឲ្យស្ទាត់ចំណាន បានទាំងបម្រុងស្បៀងអាហារបរិបូរ អំឡុងយូរពេលបីឆ្នាំសង្គ្រាមក៏ឈប់ អស់អាណាប្រជានុរាស្ត្រគ្រប់ខេត្តខណ្ឌ និងក្នុងក្រុងសែឈ្វន និងហាន់តុង ក៏សឹងជាសុខសម្រាន្តបានធ្វើស្រែចម្ការ ធញ្ញាហារក៏បរិបូរចម្រើនរាល់តំបន់ ព្រះចៅ**ឡៅសៀន**សោយរាជ្យបាន១១ឆ្នាំ (ព.ស៧៧៦) ជាទេសកាលខែផល្គុន **ខុងបេង**ក៏ចូលទៅក្រាបបង្គំគាល់ទូលលាព្រះចៅ**ឡៅសៀន**ថា ទូលព្រះបង្គំជាខ្ញុំនឹងសុំទំនុកបម្រុងផែនដីឲ្យនៅជាសុខ ក៏បានរៀបទុកដាក់ពលយោធាត្រៀមអាហារស្បៀងអស់រវាងបីឆ្នាំមកហើយ ឥឡូវទូលព្រះបង្គំជាខ្ញុំសុំថ្វាយបង្គំលាព្រះអង្គលើកកងទ័ពទៅប្រាបប្រាមសឹកសត្រូវនៅខាងដែនស្រុកឡុកអៀង ដែលជាចម្រូងចម្រាសនឹងគ្នាឲ្យវារាបទាប បើទៅធ្វើការនេះមិនបានតាមសុភាពដូចចិត្តបំណង ទូលព្រះបង្គំជាខ្ញុំក៏មិនប៉ងនឹងវិលត្រឡប់មកមើលមុខអ្នកស្រុកសែឈ្វនទេ។ ព្រះចៅ**ឡៅសៀន**បានទ្រង់ព្រះសណ្តាប់ ក៏មានព្រះទ័យតក់ស្លុតរន្ធត់ក្នុងព្រះអង្គ ទើបទ្រង់ត្រាស់ឃាត់ថា វេលានេះស្រុករបស់យើងក៏រាបទាបជាសុខទាំងភូមិស្រុកក៏ផ្សាយទូលាយធំ សមគួរនឹងគ្រប់គ្រងរងរក្សាអាណាប្រជាជនណាស់ហើយ មិនបាច់ឡើយនឹងទៅប្រាថ្នាបៀតបៀនគេឲ្យព្រួយលំបាកខ្លាំង ឯស្រុកឡុកអៀង និងស្រុកកាំងតាំងក៏មិនបានជាខ្លាំងនឹងលើកទ័ពមកញាំញីដល់ទីដែន

យើងបាន មហាឧបរាជគួរតែនៅសម្រាន្តសម្រាកកុំឲ្យព្រួយលំបាកកាយដោយកិច្ចកង្វល់នេះ ក៏ឃើញថាជាការល្មមសមគួរណាស់ គួរឬនឹងខំស្វះស្វែងទៅឲ្យនឿយព្រួយដូច្នេះ?

**ខុងបេង**ក្រាបទូលថា ព្រះចៅ**ឡៅពី**ជាព្រះវររាជបិតារបស់ព្រះអង្គ លោកក៏ទ្រង់មានព្រះតេជះគុណូបការជប់លៀងទូលព្រះបង្គំជាខ្ញុំមកជាច្រើនណាស់ ទ្រង់មានព្រះរាជតម្រាស់ផ្តាំទុកថា តទៅមុខត្រូវតែរិះគិតតាំងចិត្តនឹងបង្ក្រាបសឹកសត្រូវទៅខាងស្រុកឡុកអៀង ឲ្យរាបទាបឲ្យបាន ហើយត្រូវលើកជាទីឋានស្រុកហ្លួងតែមួយឲ្យដូចពីបុរាណ ឯកិច្ចការទាំងប៉ុន្មានតាមបណ្តាំ ក៏ពុំទាន់បានសមដូចប្រាថ្នាសោះ ទូលព្រះបង្គំជាខ្ញុំនៅមិនទាន់អស់ចិត្តគិតនឹងធ្មេចភ្នែកក៏មិនជិតគ្រប់វេលា ហេតុនេះបានជាសុំក្រាបថ្វាយបង្គំលាព្រះអង្គ លើកទ័ពទៅធ្វើការនេះឲ្យសម្រេចចុះ។

**ជៀវជីវ**ហោរា បានឮ**ខុងបេង**ទូលដូច្នោះ ក៏ឆ្លើយថា ទូលព្រះបង្គំជាខ្ញុំបានពិនិត្យឃើញផ្កាយប្រចាំស្រុកយើងមានរស្មីសៅហ្មងមិនល្អ ឃើញផ្កាយប្រចាំស្រុកទិសឧត្តរមានពន្លឺរុងរឿង ម្យ៉ាងទៀតបណ្តាជនក្នុងស្រុកយើងក៏រន្ទឺល្បីថា ពេលកណ្តាលយប់ស្ងាត់បានឮស្នូរស្លឹកឈើដែលខ្យល់បក់ផាត់មកត្រូវនោះ ឮបីដូចសំឡេងមនុស្សយំទ្រហឹងអឺងកង ដែលមហាឧបរាជនឹងមានបំណងលើកទ័ពទៅគ្រានេះ សុំឲ្យតម្រិះឈប់បង្អង់សិនចុះ។ ព្រះចៅ**ឡៅសៀន**មិនមានព្រះបន្ទូលតបថាប្រការម្តេច។

**ខុងបេង**តាំងនិយាយនឹង**ជៀវជីវ**ថា ខ្លួនយើងបានទទួលព្រះបណ្តាំព្រះចៅ**ឡៅពី**ទុកមកថា នឹងយកចិត្តគិតទំនុកបម្រុងផែនដីឲ្យបានរាបទាប ដែលអ្នកនឹងមកយកនិមិត្តមនោសារេដ៏ទុព្វលភាពមករារាំងទទឹងទាស់វិញមិនត្រូវទេ យើងត្រូវតែលើកទ័ពទៅធ្វើការរណរង្គសង្គ្រាមតាមព្រះបណ្តាំទើបគួរ ហើយ**ខុងបេង**ក៏យកធូបទៀនទៅអុជបូជាព្រះសពព្រះចៅ**ឡៅពី** ក្រាបអញ្ជលីប្រមណ្ឌ ហើយយំទូលថា ខ្លួនទូលព្រះបង្គំជាខ្ញុំបានទទួលព្រះបណ្តាំព្រះអង្គ ឲ្យទៅបង្ក្រាបបច្ចាមិត្តដែលជាសត្រូវរាជសម្បត្តិឲ្យរាបទាប នោះទូលព្រះបង្គំជាខ្ញុំសារភាពខ្លួនដោយសត្យ បានលើកទ័ពទៅកម្ចាត់សត្រូវនៅទីភ្នំគីសាន់ដល់ប្រាំលើកហើយ ក៏នៅមិនទាន់បានសម្រេចតាមប្រាថ្នា គ្រានេះទូលព្រះបង្គំជាខ្ញុំសុំអាសាលើកទ័ពទៅទៀត បើទូលាយ

ចង្អៀតយ៉ាងណាសូមព្រះបារមីជួយឧបត្ថម្ភគាំពារ បើធ្វើការនេះមិនសមតាមប្រាថ្នាទេ ក៏នឹងមិនរេត្រឡប់មុខមកវិញឡើយ ថាហើយក៏ថ្វាយបង្គំលាព្រះចៅ**ឡៅសៀន**ចេញដំណើរទៅស្រុកហាន់តុង ហើយក៏ឲ្យប្រុងប្រៀបចាត់ពលនិករបាន៣៤ម៉ឺនព្រមទាំងគ្រឿងសាស្ត្រាវុធគ្រប់ពួកកង។

ខណៈនោះ មានបម្រើមកជម្រាប**ខុងបេង**ថា **គួនហ៊ិន**មានជំងឺបច្ចុប្បន្នរោគទទួលអនិច្ចកម្មទៅហើយ **ខុងបេង**ដឹងឮដូច្នោះហើយ ក៏ឲ្យស្លុតស្លន់វិញ្ញាណប្រះប្រាណវិយោគសោកាល័យទាល់តែដួលសន្លប់ទៅ។ អស់នាហ្មឺនទាំងពួងក៏នាំគ្នាស្ទុះទៅគ្រាប់លើកឡើងបានដឹងស្មារតី **ខុងបេង**ក៏ស្រដីទាំងទឹកភ្នែកថា **គួនហ៊ិន**នេះជាទាហានឯកចម្បង ទាំងមានចិត្តសុចរិតសត្យត្រង់កន្លងលើសគេធម្មតា ដូច**គួនអ៊ូ**ជាបិតាសត្យានុសត្យពិតត្រង់ណាស់ គួរហើយនឹងទៅជួយទំនុកបម្រុងផែនដីតទៅ។ ឥឡូវ**គួនហ៊ិន**ស្លាប់ហើយ បាននរណាឡើយនឹងជួយកម្លាំងបាន ដូចស្លាប់អស់ទាហានពាក់កណ្ដាល។ លុះព្រឹកឡើង **ខុងបេង**ឲ្យ**កៀងអ៊ុយ, អ៊ុយអៀន**នាំទាហានជាកងមុខ ឲ្យ**លីអ៊ិន**នាំស្បៀង **ខុងបេង**ជាកងហ្លួងបំបែកនាយទាហានលើកចេញទៅជាប្រាំកង ទៅជួបគ្នានៅទីភ្នំគីសាន់។

បម្រើសេះល្បាតក៏នាំព័ត៌មានចូលទៅ យកសេចក្ដីក្រាបទូលព្រះចៅ**ចូយ៉យ**ដ្បិត**ខុងបេង**នាំទាហានប្រមាណ៤០ម៉ឺន លើកមកភ្នំគីសាន់ទៀតហើយ។ ព្រះចៅ**ចូយ៉យ**ទើបប្រឹក្សានឹង**សុម៉ាអ៊ី**ថា រវាងបីឆ្នាំមកហើយ កងទ័ពស្រុកសៃឈ្នួនមិនបានលើកមកធ្វើអន្តរាយស្រុកយើងសោះ គ្រានេះ**ខុងបេង**លើកមកជិតនឹងដល់ភ្នំគីសាន់ហើយ អ្នកនឹងគិតប្រការម្ដេច? **សុម៉ាអ៊ី**ទូលថា ទូលព្រះបង្គំជាខ្ញុំបានពិនិត្យមើលផ្កាយ និងតម្រាឃើញថា ខាងស្រុកយើងមានផ្កាយរុងរឿងភ្លឺស្អាតណាស់ ឯផ្កាយសម្រាប់ស្រុកសៃឈ្នួននៅមានពន្លឺសៅហ្មង ដែល**ខុងបេង**លើកទ័ពមកគ្រានេះ បីដូចជាមកយកភ័យទៅដាក់ខ្លួន ព្រះអង្គកុំទ្រង់ព្រះវិតក្កឡើយ ទុកងារទូលព្រះបង្គំជាខ្ញុំនឹងសុំអាសាលើកពលទៅតទល់យកជ័យជម្នះឲ្យបាន តែទូលព្រះបង្គំជាខ្ញុំសុំយក**ហែហ៊ុយប៉ា, ហែហ៊្វហ៊ុយ, ហែហ៊្វអ៊ុយ, ហែហ៊្វហោ** បួននេះ ដែលជាបុត្រ

**ហៃហ៊្វូអៀន**ទៅផង នឹងបានជាចិត្តមួយជួយធ្វើការសង្គ្រាមសងសឹក**ខុងបេង**ដែលសម្លាប់បិតានោះចេញ។

ព្រះចៅ**ចូយ៉យ**ត្រាស់តបថា កាលពីគ្រាមុននោះ **ហៃហ៊្វូលឹម**ជាបុត្រ**ហៃហ៊្វូទុន**លើកទ័ពទៅយុទ្ធនាក៏ថ្លោះការវិលមកវិញ មានសេចក្ដីខ្មាសមុខលែងនៅធ្វើការក្នុងស្រុកក្រុងរហូតមក វេលានេះអ្នកនឹងយកបុត្រ**ហៃហ៊្វូអៀន**ទាំងបួននាក់ទៅធ្វើការទៀត យើងក្រែងដូច**ហៃហ៊្វូលឹម**ទេដឹង? **សុម៉ាអ៊ី**ទូលថា ឯចិត្តបុត្រ**ហៃហ៊្វូអៀន**ទាំងបួននាក់នេះជាទាហានក្លាហានណាស់ នឹងធ្វើការអ្វីៗឃើញថាអង់អាច ហើយក៏មានសេចក្ដីគំនុំឈឺចិត្តគិតតែនឹងសងសឹកព្យាបាទ**ខុងបេង**វិញជាដរាប ឃើញថាមុខជាមិនកោតញញើតសត្រូវដូច**ហៃហ៊្វូលឹម**ទេ ទើបព្រះចៅ**ចូយ៉យ**ត្រាស់ថា បើអ្នកឃើញបានការហើយ នឹងយកទៅធ្វើការក៏តាមចិត្តចុះ ឯការទាំងពួងដែលនឹងទៅនោះ បើឃើញនរណាមានសេចក្ដីគិតមុតមាំខ្លាំងពូកែគួរនឹងតថ្វីដៃនឹងគេបាន អ្នកក៏ចូររាប់អានតាំងលើកតម្កើងឲ្យមានយសសក្តិខ្ពង់ខ្ពស់តាមរូបទ្រង់ដ៏សមគួរទៅចុះ។

**សុម៉ាអ៊ី**បានឮព្រះក្រសែដូច្នោះ ក៏ថ្វាយបង្គំលាព្រះចៅ**ចូយ៉យ**នាំបុត្រ**ហៃហ៊្វូអៀន**ទាំងបួននាក់ លើកកងទ័ពចេញទៅស្រុកទៀងអាន់។ វេលានោះ**សុម៉ាអ៊ី**កេណ្ឌពលបានប្រមាណ៤០ម៉ឺន ព្រមទាំងគ្រឿងសាស្ត្រាវុធ ចាត់ឲ្យ**ហៃហ៊្វូប៉ា** និង**ហៃហ៊្វូហ៊ុយ**នាំពលមួយប៉ែកញែកជាទ័ពមុខ លុះបានសុភឫក្សមង្គលក៏លើកពលចេញទៅដល់ទន្លេហ៊ុយហោ ទើប**ហៃហ៊្វូប៉ា** និង**ហៃហ៊្វូហ៊ុយ**ឆ្លងទៅតាំងបន្ទាយនៅក្បែរមាត់ទន្លេពីរបន្ទាយ ឲ្យធ្វើកំពែងសម្រាប់ការពារសត្រូវ ឯ**សុម៉ាអ៊ី**នោះក៏ទៅតាំងបន្ទាយនៅត្រើយម្ខាង ហើយឲ្យធ្វើស្ពានឆ្លងទន្លេជាប្រាំបួនតំបន់ **កោឈុយ, ស៊ុនឡេ**ក៏និយាយនឹង**សុម៉ាអ៊ី**ថា កងទ័ពស្រុកសៃឈ្មួនលើកមកតាំងនៅទីភ្នំគីសាន់ ខ្ញុំបាទគិតក្រែងតែ**ខុងបេង**នឹងលបទៅវាយយកខេត្តឡុងសេ បើជាខូចដែនឡុងសេទៅហើយ សត្រូវក៏មានកម្លាំងច្រើនឡើង ត្រូវតែលោកគិតការពារស្រុកនេះឲ្យបាន។ **សុម៉ាអ៊ី**យល់ឃើញត្រូវ ទើបតបថា អ្នកនិយាយនេះគួរណាស់ បើដូច្នោះត្រូវអ្នកឯងទាំងពីរនាក់នាំទាហានទៅចាត់ការកបន្ទាយនៅមាត់ផ្លូវ ដែលទៅលើស្រុកឡុងសេ។

ខណៈកាល**ខុងបេង**លើកទ័ពទៅនោះ ឲ្យតាំងបន្ទាយវាយចម្រូងទៅតាមផ្លូវ តាំងពីគយកៀមកោះទៅទល់ដល់ទីភ្នំគីសាន់ ប្រមាណ១៤ ឬ១៥បន្ទាយ ប្រាថ្នានឹងឲ្យងាយធ្វើការសឹកជាប់ឆ្នាំ ហើយឲ្យតាំងបន្ទាយមាំនៅភ្នំគីសាន់ប្រាំបន្ទាយ ទើប**ខុងបេង**ប្រឹក្សានឹងនាយកងនាយទ័ពទាំងពួងថា **សុម៉ាអ៊ី**តាំងនៅត្រើយទិសបូព៌ កងមុខនោះតាំងនៅទិសបស្ចិម ឲ្យធ្វើស្ពានឆ្លងជាច្រើនតំបន់ ហើយឲ្យទាហានទៅស្កាត់នៅមាត់ផ្លូវប៉ាក់ង្ហួន ប្រាថ្នាមិនឲ្យទ័ពយើងទៅធ្វើអន្តរាយស្រុកឡុងសេបាន ឯកងទ័ពយើងតាំងនៅគ្រានេះ ជាលើទឹក យើងត្រូវធ្វើផែមួយរយប្លាយ ហើយជញ្ជូនយកស្មៅចំបើងទៅដាក់គរជាប្រឆេះភ្លើងទុកលើផែទាំងអស់ ហើយចាត់ពល៥ពាន់ដែលមានថ្វីដៃជំនាញស្ទាញស្ទាត់ក្នុងការទូកនាវាបម្រុងខ្លួនត្រៀមទុក ហើយចាត់ទាហានឲ្យលើកតាមទៅវាយបន្ទាយប៉ាក់ង្ហួន ឯកងទ័ពយើងនឹងចូលវាយបន្ទាយមុខដែលតាំងនៅក្បែរទឹកនោះឲ្យព្រមគ្នា ឃើញថា**សុម៉ាអ៊ី**គង់នឹងកង្វល់មុខក្រោយ ហើយសឹមយើងឲ្យស្រាយផែបណ្តែតចុះទៅដល់ស្ពានកាលណា ទើបឲ្យទាហានដុតប្រឆេះភ្លើងឡើង ស្ពានទាំងនោះក៏គង់នឹងទម្លាយឆេះឡើងខូចទាំងអស់ ទោះវានឹងឲ្យពលរេហ៍ជូនទៅជួយលត់យ៉ាងណាក៏មិនទាន់ការ។ បើ**សុម៉ាអ៊ី**ថ្លោះការដូច្នោះ ហើយ មុខជាយើងបានសម្រេចដូចប្រាថ្នា។ នាយទ័ពនាយកងទាំងពួងយល់ឃើញត្រូវផង ទើបចាត់ការរៀបចំពលទាហានឲ្យទៅកាប់ឈើឫស្សីធ្វើផែ ហើយឲ្យយកស្មៅ និងចំបើងខសទៅគរវាយពីលើផែជាស្រេចទាំងអស់ តាមបង្គាប់ប**ខុងបេង**គ្រប់ប្រការ។

បម្រើសេះល្បាតឃើញហើយ ក៏នាំព័ត៌មានទៅប្រាប់**សុម៉ាអ៊ី**ថា **ខុងបេង**គិតកលសឹកនឹងឲ្យជាកង្វល់មុខក្រោយ ហើយនឹងបណ្តែតផែចុះទៅទម្លាយស្ពានយើងទាំងអស់ហើយ ត្រូវតែគិតការពារកុំឲ្យកងទ័ពយើងអន្តរាយបាន។ **សុម៉ាអ៊ី**ក៏ឲ្យបម្រើសេះទៅប្រាប់**កោឈុយ** និង**ស៊ុនឡេ**ថា បើទាហាន**ខុងបេង**លើកមកវាយកាលណា កុំឲ្យពួកយើងភ្ញាក់ផ្អើល ឲ្យ**កោឈុយ, ស៊ុនឡេ**នាំទាហានចេញទៅពួនបង្កប់នៅកណ្តាលផ្លូវ បើឃើញទាហាន**ខុងបេង**លើកមកកាលណា ត្រូវឲ្យចេញចោមវាយប្រញាប់ យើងនឹងលើកទ័ពជូនទៅជួយច្បាំងមិនឲ្យទាហាន**ខុងបេង**តាំងទីនៅ

បាន ហើយឲ្យរកខ្លួន**ហែហ៊្វប៉ា, ហែហ៊្វហ៊ុយ**មកបង្គាប់ថា បើបានឮសំឡេងស្រែកហ៊ោខាងតំបន់ប៉ាក់ងួនកាលណា អ្នកទាំងពីរត្រូវនាំទាហានបង្កប់នៅក្រៅបន្ទាយទិសខាងត្បូង បើឃើញ**ខុងបេង**លើកមកវាយបន្ទាយមុខ សឹមឲ្យលើកចូលចោមវាយកុំឲ្យតាំងខ្លួនបាន ហើយបង្គាប់**ទៀវហង, ងាក់លឹម**ឲ្យនាំទាហានធ្នូម្នាក់មួយពាន់ ចុះទៅបង្កប់នៅជើងស្ពានទាំងសងខាងចុងដើម បើឃើញទាហាន**ខុងបេង**លែងផែបណ្ដែតមក ត្រូវឲ្យបាញ់ធ្នូតម្រង់ទៅ កុំឲ្យវាដុតភ្លើងឲ្យឆេះទាន់នឹងទម្លាយស្ពានបាន ហើយបង្គាប់**សុម៉ាស៊ូ, សុម៉ាជៀវ**ជាបុត្រថា ខ្លួនបិតានឹងលើកទ័ពទៅតំបន់ប៉ាក់ងួន ចៅទាំងពីរត្រូវនៅរក្សាបន្ទាយជួសបិតា បើសត្រូវលើកមកលុកបន្ទាយមុខ ត្រូវឲ្យនាំគ្នាលើកទាហានឆ្លងទៅវាយខ្ទប់ឲ្យបានជ័យជម្នះ។ លុះបង្គាប់ឲ្យចាត់ចែងសម្រេចហើយ **សុម៉ាអ៊ី**ក៏នាំទាហានលបចេញខាងក្រោយបន្ទាយ ត្រូវកាត់ផ្លូវទៅពួនបង្កប់នៅជិតតំបន់ប៉ាក់ងួន។

លុះដល់ពេលព្រឹក ទើប**ខុងបេង**ចាត់ប្រើ**អ៊ុយអៀន, ម៉ាតាយ**ឲ្យនាំទាហានលើកទៅវាយនឹងយកបន្ទាយប៉ាក់ងួន ឲ្យ**ង៉ីអ៊ី, ង៉ីប៉ាន់** នាំទាហានសម្រាប់ផែ ហើយឲ្យ**អងប៉េង, ទៀវង៉ី, កៀងអ៊ុយ, ម៉ាតាយ**លើកឆ្លងទន្លេទៅតាមផ្លូវ លុះដល់ពេលព្រលប់នឹងលើកចូលវាយបន្ទាយប៉ាក់ងួន។ **កោឈុយ, ស៊ុនឡេ** ក៏ក្លែងខ្លួនរត់ដោះចោលបន្ទាយ នាំពលទាំងឡាយចេញទៅពួនបង្កប់នៅខាងជើងភ្នំមួយអន្លើ **អ៊ុយអៀន**និង**ម៉ាតាយ**ឃើញដូច្នោះ ក៏ឃាត់ហាមទាហានមិនឲ្យចូលបន្ទាយ ព្រោះគិតក្រែងជាកលសឹក ទទួលឮទាហានស្រែកហ៊ោទាំងពីរកង ខាងស្ដាំនោះ**សុម៉ាអ៊ី** ខាងឆ្វេងនោះ**កោឈុយ** និង**ស៊ុនឡេ**នាំទាហានវាយខ្ទប់ប្រសព្វចូលមកកាប់សម្លាប់ទាហានស្រុកសៃឈួនខូចខាតច្រើនណាស់។ **អ៊ុយអៀន, ម៉ាតាយ**ទប់ទល់មិនបាន ក៏នាំទាហានដែលសល់នោះពុះទម្លាយពីចំណោម រត់ចេញទៅដល់ក្បែរមាត់ទន្លេមួយ ទទួលប្រទះនឹង**ង៉ីអ៊ី** ៗក៏ទទួលជួយ**អ៊ុយអៀន, ម៉ាតាយ**ចុះផែឆ្លងទៅត្រើយម្ខាង ឯ**ង៉ីប៉ាន់**នោះលែងផែបណ្ដែតចុះទៅជិតនឹងដល់ស្ពាន ទទួលទាហាន**សុម៉ាអ៊ី**បាញ់ធ្នូចម្រុះមកបីដូចគ្រាប់ភ្លៀង ព្រួញធ្នូក៏ត្រូវ**ង៉ីប៉ាន់**ស្លាប់ ទាហានកងទ័ពក៏ស្លាប់លើផែច្រើនណាស់ ផែខ្លះក៏អណ្ដែតប៉ះទៅជាប់នឹងច្រាំង **ទៀវហង**និង**ងាក់លឹម**នូវអស់ពួក

កងទ័ព ក៏ចាប់បានពួកទាហានស្រុកសៃឈ្នួនទុក ខ្លះលោតហែលទឹករួចទៅខ្លះ ធ្លាក់ទឹកស្លាប់ខ្លះ។

ឯ**អងប៉េង, ទៀវងី, កៀងអ៊ុយ, ម៉ាតុង, លៀវហ៊្វ** និង**ទៀវអេក**ទាំង៦នាក់ លើកទ័ពមកជិតបន្ទាយមុខ**សុម៉ាអ៊ី** ក៏ប្រឹក្សាគ្នាថា កងទ័ពដែលមហាឧបរាជឲ្យទៅវាយបន្ទាយប៉ាក់ងួននោះ ក៏នៅមិនទាន់ដឹងការហេតុអ្វីសោះ មកដល់ពេលនេះយាមមួយបា្លយហើយ យើងនឹងលើកចូលវាយទៅឬប្រការម្តេច? ប្រឹក្សាគ្នាមិនផុតមាត់ ទទួលបម្រើសេះមកប្រាប់ថា កងទ័ពដែលលើកទៅវាយបន្ទាយប៉ាក់ងួននោះ ហើយនិងផែប្រឆេះភ្លើងនោះខូចអន្តរាយនឹងសត្រូវអស់ទៅហើយ មហាឧបរាជឲ្យតាមរកអស់លោកជានាយទ័ពនាយកងឲ្យលើកត្រឡប់ទៅវិញ នាយទាហានទាំង៦នាក់ឮដូច្នោះ ក៏ភ័យស្លុតស្មារតីនឹងថយត្រឡប់ ស្រាប់តែឮសំឡេងស្រែកហ៊ោ ហើយឃើញពន្លឺភ្លើងទាំងបួនទិស។ ឯ**សុម៉ាស៊ូ, សុម៉ាជៀវ, ហែហ៊្វប៉ា, ហែហ៊្វហ៊ុយ**ក៏បញ្ជាទាហានវាយខ្ទប់ប្រសព្វចូលមក កាប់សម្លាប់ទាហានស្លាប់យ៉ាងច្រើន ប្រមាណពាក់កណ្តាល នាយទាហាន៦នាក់តទល់ពុំបាន ក៏នាំទាហានដែលសល់នោះពុះពារទម្លាយរត់ចេញរួចទៅ លុះដល់បន្ទាយធំក៏ចូលទៅជម្រាប**ខុងបេង**តាមរឿងរ៉ាវគ្រប់ប្រការ។

**ខុងបេង**ដឹងដូច្នោះក៏កើតទោសមនស្សជាទុក្ខក្រៃពេកណាស់ ឲ្យត្រួតពិនិត្យរាល់វេហ៍ពល ហើយឲ្យរវាំងរក្សាបន្ទាយដោយមាំមួន ទទួល**ប៊ីហ៊ុយ**មកពីស្រុកសៃឈ្នួន **ខុងបេង**ក៏តែងសំបុត្រមួយច្បាប់ទៅដល់**ស៊ុនគួន**បង្គាប់ប្រើ**ប៊ីហ៊ុយ**ឲ្យនាំទៅ **ប៊ីហ៊ុយ**ទទួលយកសំបុត្រហើយនាំទៅដល់ស្រុកកាំងតាំង ភ្នាក់ងារចូលទៅគាល់ព្រះចៅ**ស៊ុនគួន** ៗទទួលយកសំបុត្រទៅហែកស្រោមមើលឃើញសេចក្តីថា ទូលព្រះបង្គំ**ខុងបេង** សូមគោរពមកព្រះចៅ**ស៊ុនគួន**ព្រោះស្រុកឡុកអៀងរៀវរោយមកតាំងពីគ្រាព្រះចៅ**ហៀនតេ** ដោយហេតុ**ចូឆូ**ជាសត្រូវផែនដី គិតប្រទូសរ៉ាយព្រះមហាក្សត្រ ធ្វើឲ្យវិបត្តិខត្តិយវង្ស អស់នាហ្មឺននិងបណ្តារាស្ត្រនៅក្នុងក្រុង និងខេត្តក្រៅ ក៏បង្កើតសេចក្តីក្តៅក្រហាយ ឯ**ចូឆូ**ក៏ស្លាប់អន្តរាយទៅហើយ នៅឡើយតែកូនចៅជាសន្តាន វាធ្វើឲ្យបានជាចលាចលតៗមក ឯខ្លួនទូលព្រះបង្គំក៏បានទទួល

យកព្រះបណ្ដាំព្រះចៅ**ឡៅពី**ជាទីប្តេជ្ញា ទ្រង់ត្រាស់ថា ឲ្យជួយកម្ចាត់ពួកបច្ចាមិត្ត សត្រូវរាជសម្បត្តិនេះចេញឲ្យបាន ទូលព្រះបង្គំក៏រិះគិតអានលើកពលនិករទៅធ្វើសង្គ្រាមជាច្រើនគ្រាហើយ គ្រានេះទូលព្រះបង្គំបានលើកទ័ពទៅទៀត ក៏ខូចខាតរេហ៍ពលច្រើនណាស់ ឯស្រុកកាំងតាំង និងស្រុកសៃឈ្នួន បីដូចខ្លួនមួយដោយបានចងព្រះរាជមេត្រីជាសម្ព័ន្ធមិត្តឋិតថេរមកតាំងពីរាជ្យព្រះចៅ**ឡៅពី** ការដែលមានបែកសាមគ្គីខ្លះក៏បណ្ដាលមកពីរូបអ្នកដទៃ តែសេចក្ដីនោះក៏បានលើកលុបទោសអស់ទៅហើយ នៅឡើយតែគុណគឺសេចក្ដីល្អតទៅ គ្រានេះសុំឲ្យព្រះចៅ**ស៊ុនគួន** មានព្រះទ័យគិតឈ្វេងយល់ដល់ទៅព្រះចៅ**ឡៅពី**ខ្លះ ព្រោះលោកជាពូជព្រះរាជវង្ស សូមទ្រង់អនុគ្រោះជួយឲ្យសេនាទាហានស្រុកកាំងតាំង ទៅតច្បាំងនឹងស្រុកឡុកអៀង ជាទ័ពសន្ទាប់ថែមកម្លាំងទ័ពស្រុកសៃឈ្នួន បើបានសម្រេចវេលាណា នឹងបែងរំលែកចែកស្មើភាគគ្នាជាពាក្យសត្យានុសត្យ។

ព្រះចៅ**ស៊ុនគួន**ជ្រាបអាថ៌សេចក្ដីតាមន័យក្នុងសំបុត្រនោះហើយ ក៏មានព្រះទ័យត្រេកអរណាស់ត្រាស់ប្រាប់**ប៊ីហ៊ុយ**ថា យើងបានគិតក្នុងចិត្តជាដរាបថា នឹងលើកទ័ពទៅបង្ក្រាប**ចូយ៉យ**ឲ្យបាន ទទួលឥឡូវមានសំបុត្រ**ខុងបេង**មក សុំទាហានទៅជួយក៏ជាតម្រូវដោយចិត្តប្រាថ្នាយើង ទើបត្រាស់បង្គាប់ឲ្យ**ឡុកស៊ុន** និង**ជូកាត់កិន**ឲ្យនៅរក្សាមាត់កំពុងស្រុកកាំងហែទុកឲ្យមាំ ហើយឲ្យចាត់ពលប្រមាណ ៣០ម៉ឺន មានព្រមដោយគ្រឿងសាស្ត្រាវុធគ្រប់គ្រាន់។ លុះវេលាព្រឹក ត្រាស់ហៅ**ប៊ីហ៊ុយ**ចូលគាល់ ហើយទ្រង់ឲ្យរៀបលៀងអាហារព្រមទាំងមន្ត្រីខ្ញុំរាជការទាំងពួង ព្រះចៅ**ស៊ុនគួន**ក៏សួរ**ប៊ីហ៊ុយ**ថា **ខុងបេង**លើកទ័ពទៅធ្វើសង្គ្រាមនោះ បានចាត់នរណាឲ្យធ្វើជាមេកងទ័ពមុខ? **ប៊ីហ៊ុយ**ទូលថា **ខុងបេង**ចាត់**អ៊ុយអៀន**ជាមេកងទ័ពមុខ។ ព្រះចៅ**ស៊ុនគួន**ទ្រង់ព្រះសម្រួលហើយត្រាស់ថា ឯ**អ៊ុយអៀន**នោះមានកម្លាំងខ្លាំងក្លាក៏មែន តែដួងចិត្តគាត់នោះមិនមែនជាមនុស្សទៀងត្រង់សុចរិតសោះ រមែងគិតទុរយសជាដរាប បើប្រសិនណាអស់បុណ្យវាសនា**ខុងបេង**ទៅហើយ **អ៊ុយអៀន** ណាឡើយនឹងមិនប្រែចិត្តក្បត់ពីព្រះចៅ**ឡៅសៀន** កាលណោះឯង ឯខ្លួនយើងនឹងលើកទ័ពទៅជួយ**ខុងបេង**វេលានេះ។

តាមចេញទៅដល់មុខបន្ទាយ ឯ**ជិនឡុង**ឃើញ**តៃប៊ុន**ចេញមកក៏ក្លែងស្រែកជេរថា វើយអា**តៃប៊ុន**! ហេតុម្ដេចបានជាឯងលួចយកសេះរបស់អញមក? បើឯងខ្លាចសេចក្ដីស្លាប់ ត្រូវប្រញាប់ប្រគល់សេះមកឲ្យអញវិញដោយស្រួល បើនៅរឹងទទឹងអញនឹងកាត់ក្បាលឯងចេញឥឡូវនេះ។ ហើយក៏បរសេះចូលទៅបន្លំក្នុងពួកទាហានឲ្យ**ជិនបេង**ជាប្អូនបរសេះចេញមកតយុទ្ធនឹង**តៃប៊ុន**បានមួយភ្លែង **តៃប៊ុន**ក៏យកដាវកាប់ត្រូវ**ជិនបេង**ធ្លាក់ពីលើសេះស្លាប់ **ជិនឡុង** និងទាហានក៏ធ្វើជាថយទ័ពបែកទៅ **តៃប៊ុន**ក៏កាត់ក្បាល**ជិនបេង**នាំចូលមកជូន**ខុងបេង**ហើយថា ខ្ញុំបាទបានក្បាល**ជិនឡុង**មកជូនលោក។

**ខុងបេង**ឃើញដូច្នោះក៏ខឹងណាស់ថា **ជិនឡុង**នោះអញក៏ស្គាល់មុខ ស្គាល់ទាំងថ្វីដៃ ហេតុអ្វីឯងមកក្លែងតែងកលឧបាយបញ្ឆោតអញឲ្យទុកចិត្ត នឹងបានឲ្យឯងនៅធ្វើជាកលសឹក យកសេចក្ដីអាថ៌កំបាំងលបចេញទៅប្រាប់**សុម៉ាអ៊ី**ឬ? បើឯងមិនឆ្លើយឲ្យត្រង់ទេ អញនឹងកាត់ក្បាលឯងឥឡូវនេះ ហើយដាក់នៅមុខបន្ទាយ។ **តៃប៊ុន**ឮហើយក៏ស្រែកយំ អង្វរសុំជីវិតថា ខ្លួនខ្ញុំបាទបញ្ឆោតលោកមែនហើយ ព្រះគុណអើយ! សូមមេត្តាកុំសម្លាប់ចុះ ខ្ញុំបាទនឹងសុំចំណុះចុះចូលនៅតបគុណលោកដោយសុចរិតតទៅ។

**ខុងបេង**ថា បើឯងស្រឡាញ់ជីវិតពិតជាផៅនឹងអញមិញប្រាកដ អញក៏អត់មិនសម្លាប់ឯងទេ តែត្រូវឲ្យឯងសរសេរសំបុត្រឲ្យសុទ្ធជាលាយដៃឯង ណាត់ពេលឲ្យស្ដែងដល់**សុម៉ាអ៊ី**ឲ្យចេញមកលុកបន្ទាយអញ បើអញចាប់បានខ្លួន**សុម៉ាអ៊ី**ក៏ឲ្យរង្វាន់បំណាច់ តាំងឲ្យឯងធំសម្រេចលើនាយទាហាន។ **តៃប៊ុន**ក៏បានទទួលពាក្យទើបសរសេរសំបុត្រតាមពាក្យ**ខុងបេង**ថា **ខុងបេង**ក៏ទទួលយកសំបុត្រសញ្ញាមកហើយឲ្យយកខ្លួន**តៃប៊ុន**ទៅឃុំក្នុងគុកទុក។ **អ្នកគៀន**សួរ**ខុងបេង**ថា ហេតុម្ដេចបានជាលោកជ្រាបថា **តៃប៊ុន**ធ្វើកលឧបាយមកបញ្ឆោតលោក? **ខុងបេង**ថា **សុម៉ាអ៊ី**នោះរមែងប្រើមនុស្សមានថ្វីដៃខ្លាំងពូកែ ឯ**ជិនឡុង**ក៏ខ្លាំងពូកែ **សុម៉ាអ៊ី**ឲ្យធ្វើជានាយទាហាន យើងបានពិគ្រោះមើលកល**ជិនឡុង**ចេញមកច្បាំងនឹង**តៃប៊ុន**បានមួយភ្លែងក៏ត្រូវស្លាប់ដូច្នោះ ថាខុសសង្កេតនឹងជាតិទាហានឯក។

អស់មន្ត្រីនាយទាហានទាំងពួងបានស្តាប់ដូច្នោះ ក៏នាំគ្នាសរសើរ**ខុងបេង**ថា មានសតិបញ្ញារកនរណាផ្ទឹមគ្មាន ទើប**ខុងបេង**ហៅ**គីទុន**នាយទាហានដែលមានតម្រិះប្រាជ្ញា ចេះនិយាយវាចារឆ្លៀវឆ្លាត ចូលមកខ្សឹមបង្គាប់សេចក្ដីស្ងាត់ រួចប្រគល់សំបុត្រនោះឲ្យទៅ**គីទុន** ៗទទួលពាក្យ និងសំបុត្រហើយក៏ទៅបន្ទាយ**សុម៉ាអ៊ី** លុះដល់ហើយក៏ប្រាប់ពួកល្បាតថា យើងជាបម្រើកាន់សំបុត្រសម្ងាត់ពី**តែប៊ុន** ឲ្យយកមកជូន**សុម៉ាអ៊ី**មេទ័ពធំ។ ពួកទាហានក៏ចូលទៅជម្រាប**សុម៉ាអ៊ី**។

**សុម៉ាអ៊ី**ឮដូច្នោះ ក៏ឲ្យហៅបម្រើកាន់សំបុត្រនោះចូលទៅ ហើយសួរថា ហេតុម្ដេចខ្លួនឯងជាចេះនាំសំបុត្រនេះបាន? ជាសំបុត្រ**តែប៊ុន**មែនឬអ្វី? **គីទុន**ឆ្លើយជម្រាបថា ខ្លួនខ្ញុំបាទនិង**តែប៊ុន**ជាជាតិអ្នកស្រុកឡុកអៀងដូចគ្នា លុះខ្ញុំបាទឃ្លាតចាកទៅនៅស្រុកសៃឈួន ក៏បានចូលទៅធ្វើជាកូនទាហានមកក្នុងទ័ព**ខុងបេង** ឥឡូវ**តែប៊ុន**ធ្វើសេចក្ដីគាប់ប្រសើរនឹង**ខុងបេង**ជាច្រើន **ខុងបេង**ក៏តាំងឲ្យ**តែប៊ុន**ធ្វើនាយទាហានឯក បានជា**តែប៊ុន**ប្រើខ្ញុំបាទឲ្យនាំសំបុត្រនេះមកជូនលោក។ **សុម៉ាអ៊ី**ទទួលសំបុត្រនោះមកបើកមើល ឃើញសេចក្ដីថា ខ្ញុំបាទ**តែប៊ុន** សូមគំនាប់មកលោកមេទ័ពធំ គឺ**សុម៉ាអ៊ី** ដ្បិតកិច្ចការទាំងពួង ដែលខ្ញុំបាទទៅគិតជាកលឧបាយនោះ បានសម្រេចជាស្រួលហើយ ស្អែកពេលយាមពីរយប់ សូមឲ្យលោកលើកទ័ពទៅលុកបន្ទាយ**ខុងបេង**ចុះ ខ្ញុំបាទនឹងដុតភ្លើងឲ្យឆេះឡើងក្នុងបន្ទាយ ហើយត្រូវឲ្យវាយខ្ទប់ពីក្រោយចូលទៅ។

**សុម៉ាអ៊ី**ឃើញសេចក្ដីសំបុត្រដូច្នោះ ក៏ចេះតែមើលទៅមើលមកជាច្រើនសាចំណាំបានជាលាយដៃ**តែប៊ុន**មិនមានសេចក្ដីសង្ស័យ ទើបឲ្យរៀបតុលៀងអាហារហៅ**គីទុន**ឲ្យបរិភោគ្គារ ហើយថា អ្នកឯងត្រូវវិលត្រឡប់ទៅប្រាប់**តែប៊ុន**ឲ្យត្រៀមការទុកឲ្យស្រេចចុះ ស្អែកយាមពីរយប់ យើងនឹងលើកពលទៅលុកបន្ទាយ**ខុងបេង**ឲ្យបាន បើស្រេចការគ្រានេះ យើងឲ្យឯងធ្វើទាហានឯក។ **គីទុន**ទទួលពាក្យហើយក៏លាទៅប្រាប់**ខុងបេង**គ្រប់ប្រការ។

**ខុងបេង**បានឮដូច្នោះក៏មានសេចក្ដីត្រេកអរ។ លុះពេលព្រឹកឡើង ក៏កាន់គ្របីចេញមកកណ្ដាលទីវាលគំនាប់ទេពតា ហើយក៏វាយមន្តប្រើទៅជាច្រើន ហើយ

ហៅ**ទៀវងី, ម៉ាតុង, ម៉ាតាយ, អ៊ុយអៀន, កៀងអ៊ុយ** ឲ្យចូលមកខ្សឹបប្រាប់ជាសម្ងាត់ លុះពេលរសៀល**ខុងបេង**ក៏នាំទាហានប្រមាណ៥០នាក់ឡើងទៅលើកំពូលភ្នំ ប្រាថ្នានឹងមើលការទាំងពួង ឯនាយទាហានទាំង៦នាក់នោះ ក៏រៀបចាត់ការត្រៀមទុកសម្រេចតាមពាក្យ**ខុងបេង**បង្គាប់។

វេលាថ្ងៃនោះ **សុម៉ាអ៊ី**ក៏រៀបចំបម្រុងពលទាហាន ហើយក៏នាំ**សុម៉ាស៊ូ, សុម៉ាជៀវ**ជាបុត្រគិតទៅលុកបន្ទាយ**ខុងបេង**។ **សុម៉ាស៊ូ**ឆ្លើយថា ដែលបិតានឹងធ្វើការគ្រានេះ កុំអាលជឿសំបុត្រ**តែប៊ុន**ពេក ខ្ញុំបាទក្រែងបែរគំនិតតាំងរិះគិតត្រូវកលទេដឹង? បើបិតាគិតខ្លីក្រែងអន្តរាយដល់ខ្លួន សុំឲ្យបិតាប្រើនាយទាហានឲ្យលើកទៅលុកវិញស្រួលជាង ខ្លួនបិតានៅរាំងពីក្រោយជាជំនួយទៅវិញ បើអាប់ចុនយ៉ាងណាមិញ នឹងបានកែខៃដោយងាយ។ **សុម៉ាអ៊ី**យល់ឃើញត្រូវ ទើបប្រើ**ជិនឡុង**ឲ្យនាំពលមួយម៉ឺនជាកងមុខ ឲ្យលើកទៅប្លន់បន្ទាយ**ខុងបេង**។ **ជិនឡុង**ក៏បរពលទៅដល់កណ្ដាលផ្លូវ **សុម៉ាអ៊ី**ក៏លើកទ័ពជំនួយទៅក្រោយ ទទួលកើតខ្យល់ព្យុះបណ្ដោយឲ្យធ្លាក់ជាភ្លៀងលាយគ្នា **សុម៉ាអ៊ី**គិតថា ការគ្រានេះគឺទេវតាជួយយើងហើយ មុខជានឹងសម្រេចសេចក្ដីប្រាថ្នា។ លុះដល់ពេលយាមពីរប្លាយ **ជិនឡុង**ក៏លើកពលទៅជិតដល់បន្ទាយ**ខុងបេង** ហើយក៏បរពលចូលទៅក្នុងបន្ទាយ មិនឃើញមនុស្សទាំងឡាយដល់ម្នាក់សោះ ក៏ភ័យណាស់គិតថា គ្រានេះគឺ**ខុងបេង**ត្រូវកលពិតប្រាកដហើយ បើនឹងថយទ័ពទៅក្រោយឲ្យដល់មុខបន្ទាយក៏បាន លុះថយទៅស្រាប់តែឮសំឡេងស្រែកហ៊ោគឹកកងទាំងបួនទិស ភ្លើងក៏ឆេះសន្ធឹកសន្ធាប់ព័ទ្ធរាលជុំកងទ័ពជិតមក ហើយឃើញ**អងប៉េង, ទៀវងី, ម៉ាតុង, ម៉ាតាយ** លើកពលទាំងឡាយចោមរោមចូលមកជុំជិត ដេញប្រកាប់សម្លាប់ទាហានខ្លួនវិនាសដេរដាស **ជិនឡុង**ក៏ប្រឹងរាំងការនៅក្នុងចំណោមទ័ព**ខុងបេង**។

**សុម៉ាអ៊ី**ឃើញពន្លឺភ្លើង និងឮសំឡេងស្រែកហ៊ោកក្រើកដី នៅមិនច្បាស់សេចក្ដីថា**ជិនឡុង**បានបន្ទាយហើយឬនៅ ក៏រឹតតែបណ្ដោញទាហានឲ្យទន្ទ្រានចូលទៅជួយ**ជិនឡុង** ស្រាប់តែឮសំឡេងហ៊ោពីខាងផ្លូវខាងក្រោយខ្នង ភ្លើងក៏ឆេះព័ទ្ធស្កាត់ជុំវិញ **សុម៉ាអ៊ី**ក្រឡេកទៅឃើញ**កៀងអ៊ុយ, អ៊ុយអៀន** បរពលបំពានចូល

ចោមជិតមក កាប់សម្លាប់ពួកពលរបស់ខ្លួនស្លាប់ច្រើនណាស់ ឯ**ជិនឡុង** និងទាហានមួយម៉ឺននោះ ស្លាប់អស់ទាំងនាយទាំងពលមិនសល់ម្នាក់ គឺត្រូវនឹងធ្នូបាញ់ប្រទាក់ចាក់កាប់ដោយគ្រឿងសាស្ត្រាវុធផ្សេងៗ។ **សុម៉ាអ៊ី**ក៏នាំពលរបស់ខ្លួនដែលសល់រត់ច្របល់ពារទម្លាយចូលបន្ទាយបាន ភ្លៀងខ្យល់ទាំងប៉ុន្មានក៏ស្ងប់ឈប់ឈឹង មេឃក៏ស្វាងរៀបរឿងព្រះសុរិយាឯព្រឹក។

**ខុងបេង**នោះ លុះបានជ័យជម្នះហើយ ក៏វាយឃ្មោះគោះគងទូងភេរីហៅពលយោធាត្រឡប់ចូលបន្ទាយ នាយទាហានទាំងឡាយក៏នាំគ្នាជម្រាបសួរ**ខុងបេង**ថា កាលពេលយាមមួយប្លាយ បណ្ដាលឲ្យកើតព្យុះភ្លៀងឡើងនោះគឺប្រសាសន៍បានសេកមន្តវិជ្ជាយ៉ាងម្ដេច? **ខុងបេង**តបថា យើងបានឡើងទៅលើកំពូលភ្នំ ហើយយើងសេកមន្តអាគមហៅខ្យល់ ហៅភ្លៀងឲ្យមានមកបានជាធ្វើនេះសម្រេចដូចចិត្ត នាយទាហានទាំងអស់ឮហើយ ក៏នាំគ្នារីងរឹតតែសរសើរ**ខុងបេង**ថា ប្រសាសន៍មានវិជ្ជានេះវិសេសលើសមនុស្សចំពោះដូចទេវតា **ខុងបេង**ក៏ឲ្យនាំខ្លួន**តែប៊ុន**ទៅប្រហារជីវិតបង់ ហើយថែមគិតការដែលនឹងធ្វើឲ្យបានជ័យជម្នះ**សុម៉ាអ៊ី**តទៅទៀត។ លុះព្រឹកព្រហាម ក៏ប្រើទាហានឲ្យទៅស្រែកទ្រគោះបញ្ឈឺចិត្ត**សុម៉ាអ៊ី**ផ្សេងៗនៅមុខបន្ទាយ ឯ**សុម៉ាអ៊ី**ក៏មិនបានឲ្យចេញច្បាំង។

លុះកន្លងមកថ្ងៃមួយ **ខុងបេង**ជិះរទេះតូចនាំទាហានទៅពិនិត្យមើលលើភ្នំគីសាន់ ឃើញច្រកភ្នំមួយអន្លើមានទំនងស្រួលណាស់ មានផ្លូវមុខក្រោយចង្អៀតល្មមតែចុះសេះមួយដើរ ឯទីកណ្ដាលនោះធំទូលាយជាទីកំបាំងស្ងាត់ មនុស្សនឹងនៅបានប្រមាណមួយពាន់ប្លាយ **ខុងបេង**មានសេចក្ដីត្រេកអរណាស់ ព្រោះធ្វើការស្ងាត់បាន ទើបនាំពលវិលទៅបន្ទាយ ហើយសួរអ្នកស្រុកនោះថា តំបន់ច្រកភ្នំនោះឈ្មោះអ្វី? អ្នកស្រុកប្រាប់ថា ឈ្មោះហៅលោកុក ទើប**ខុងបេង**ឲ្យហៅ**តយ៉យ, អាវតុង**ចូលមកខ្សឹបបង្គាប់ ឲ្យនាំជាងមួយពាន់ទៅពួនធ្វើគោយន្តនៅទីហៅលោកុកនោះ។ **តយ៉យ, អាវតុង**ក៏ចាប់ជាងមួយពាន់ ហើយទៅធ្វើការតាម**ខុងបេង**បង្គាប់។ **ខុងបេង**ក៏ឲ្យ**ម៉ាតាយ**នាំពលប្រាំរយទៅចាំរក្សានៅមាត់ច្រកផ្លូវភ្នំហៅលោកុកនោះ កុំឲ្យនរណាចូលចេញឃើញការដែលធ្វើនោះបាន។

ខណៈកាលដែលជាងនៅពួនធ្វើការនោះ **ខុងបេង**ក៏ឲ្យត្រួតមើលក្នុងមួយថ្ងៃពីរដង ទើប**ទៀវងី**និយាយនឹង**ខុងបេង**ថា ឯស្បៀងអាហារដែលប្រមូលទុកនៅទីគយកៀមកោះនោះ ខ្ញុំបាទឃើញថាគោក្របីនឹងរកគ្មាន បើនឹងដឹកជញ្ជូនមកឲ្យកងទ័ពយើងក៏សែនពិបាក ព្រោះផ្លូវដាច់ស្រយាលខ្លាំងណាស់ ហេតុនេះសុំប្រសាសន៍តម្រិះការឲ្យជូនស្បៀងនោះបានដោយស្រួល។

**ខុងបេង**បានឮដូច្នោះក៏អស់សំណើចហើយថា អ្នកកុំព្រួយព្រះចិត្តថ្វីនឹងការនោះ យើងបានចាត់ចែងឲ្យជាងធ្វើគោយន្តសម្រាប់នឹងឲ្យជញ្ជូនស្បៀងទាំងយប់ទាំងថ្ងៃ មិនឲ្យលំបាកដោយគោក្របីនោះទេ ហើយ**ខុងបេង**ក៏យកតម្រាបែបគោយន្តមកបង្ហាញឲ្យមើល។ **ទៀវងី**និងអស់នាហ្មឺនទាំងពួងឃើញដូច្នោះ ក៏នាំគ្នានិយាយថា ការនេះចម្លែកមែន អស់យើងខ្ញុំរាល់គ្នាទើបតែបានឃើញគ្រានេះ ហើយនាំគ្នាកោតសរសើរ**ខុងបេង**ថា សតិបញ្ញាមហាឧបរាជគិតធ្វើការនេះបានដូចទេវតាមកបណ្ដាលឲ្យកើតមែន។

លុះកន្លងទៅបានដប់បួនដប់ប្រាំថ្ងៃ ពួកជាងក៏ធ្វើការនោះហើយ **តយ៉យ, អាវតុង**ក៏នាំគោយន្តមួយពាន់ដើរទៅជូន**ខុងបេង** ៗមើលហើយក៏ធ្វើយន្តឲ្យកម្រើកពួកទាហានចូលទៅរុញពីក្រោយឲ្យល្មមតែលឿនចាកទី ហើយគោយន្តនោះក៏ដើរលឿនទៅឡើងលើភ្នំ ចុះពីលើភ្នំទៅក្នុងជ្រោះជ្រលងដងអូរទំនាបដូចគោរស់។ **ខុងបេង**ថា បើឲ្យវាដើរតែខ្លួនមួយទៅបានប្រមាណបីរយសិន (១២ គ.ម) បើដើរទៅទាំងហ្វូងតាមផ្លូវបានដល់ប្រាំពីរ ឬប្រាំបីរយសិន (២៨ ឬ៣០ គ.ម) ក្នុងមួយថ្ងៃ។ នាហ្មឺនទាំងពួងឃើញដូច្នោះ ក៏រឹតតែសរសើរ**ខុងបេង**ជាច្រើនឡើងទៀត ទើប**ខុងបេង**ប្រើទាហានឲ្យនាំគោយន្តនោះ ទៅអូសរទេះស្បៀងឯគយកៀមកោះនាំមកដល់បន្ទាយភ្នំគីសាន់ជាច្រើនសា ឯក្នុងកងទ័ព**ខុងបេង**នោះមិនបានដាច់ស្បៀងអាហារសោះ។

បម្រើសេះល្បាតឃើញដូច្នោះ ក៏នាំសេចក្ដីនោះទៅប្រាប់**សុម៉ាអ៊ី** ៗដឹងដូច្នោះក៏ភ័យណាស់ថា យើងបង្អង់ទុកមិនចេញច្បាំងនោះ ព្រោះប្រាថ្នានឹងឲ្យកងទ័ព**ខុងបេង**ដាច់ស្បៀង ឥឡូវ**ខុងបេង**ឲ្យធ្វើគោយន្តទឹមរទេះនាំស្បៀងបញ្ជូនមក

មិនដាច់ដូច្នេះ មុខជាសង្គ្រាមនេះនឹងយឺនយូរវែងឆ្ងាយ។ បើដូច្នេះត្រូវប្រើឧបាយឲ្យទាហានទៅវាយដណ្តើមយកគោយន្តនោះមកមើលបែបយ៉ាង នឹងបានធ្វើជាតំណាងឲ្យនាំស្បៀងយើងខ្លះ ហើយបង្គាប់**ឡេងហង, ងាក់លឹម** នាំពលប្រាំរយស្រូតកាត់ទៅតាមផ្លូវចាំកុក ឲ្យចូលវាយយកគោយន្តមកឲ្យបានបីបួនប្រាំរូប។ **ទៀវហង, ងាក់លឹម**ក៏នាំពលប្រាំរយ សុទ្ធតែតែងខ្លួនបន្លំជាទាហានស្រុកសៃឈ្មួន ស្រូតកាត់ផ្លូវចាំកុកទៅពួនបង្កប់នៅទីនោះ លុះឃើញទាហាន**ខុងបេង**នាំរទេះស្បៀងមកដល់ក៏ចោមវាយយក នោះ**កោសៀង** និងទាហានទាំងពួងតទល់ពុំឈ្នះ ក៏ប្រាសចោលរទេះស្បៀងនោះបែករត់ទៅ **ទៀវហង, ងាក់លឹម**ក៏ឲ្យទាហានដណ្តើមយកគោយន្តបានប្រាំរូប លុះនាំទៅដល់បន្ទាយក៏ចូលទៅបង្ហាញ**សុម៉ាអ៊ី** ៗឃើញគោយន្តនោះដូចរស់ក៏មើល ហើយថា **ខុងបេង**នោះគិតឲ្យធ្វើការនេះស្រួលណាស់ ហើយ**សុម៉ាអ៊ី**ឲ្យរកជាងមកប្រមាណមួយរយនាក់ ឲ្យរើមើលប្រដាប់គោយន្តនោះ ឲ្យឃើញធំតូចវែងខ្លីក្រាស់ស្តើងព្រមហើយ ក៏ឲ្យជាងធ្វើគោយន្តនោះប្រហែល៥០ថ្ងៃ ក៏បានគោយន្តដល់ពីរពាន់ ទើបឲ្យ**ងឹមអ៊ុយ**នាំពលមួយពាន់ យកគោយន្តទៅជញ្ជូនស្បៀងឯស្រុកឡុងសេមិនដែលដាច់។

ឯ**កោសៀង**កាលដែលបែកទៅនោះ លុះឃើញទាហាន**សុម៉ាអ៊ី**ទៅបាត់ហើយក៏បររទេះស្បៀងនោះទៅដល់បន្ទាយ ហើយចូលទៅជម្រាប**ខុងបេង**ថា ទោសខ្ញុំបាទខុសឆ្គងណាស់ ព្រោះទាហាន**សុម៉ាអ៊ី**វាយដណ្តើមយកគោយន្តទៅបានប្រាំរូប។ **ខុងបេង**បានឮដូច្នោះក៏អស់សំណើចហើយថា ដែល**សុម៉ាអ៊ី**បានគោយន្តទៅនោះ យើងមានសេចក្តីត្រេកអរណាស់ មុខជាយើងនឹងបានស្បៀងមកទុកជាច្រើនហើយតើ! នាយទាហានទាំងអស់ឮហើយក៏សួរ**ខុងបេង**ថា ហេតុម្តេចបានជាប្រសាសន៍ថាបានស្បៀងទៅវិញ? **ខុងបេង**ថា ដែលទាហាន**សុម៉ាអ៊ី**វាយដណ្តើមគោយន្តទៅបាននោះ សមប្រកបនឹងគំនិតគិតរបស់យើង ព្រោះ**សុម៉ាអ៊ី**មុខជាឲ្យធ្វើគោយន្តទៅជញ្ជូនស្បៀងហើយ យើងត្រូវប្រើឧបាយឲ្យទៅវាយដណ្តើមយកស្បៀងឲ្យបាន។

លុះកន្លងមកប្រហែល២០ថ្ងៃ បម្រើសេះល្បាតមកជម្រាប**ខុងបេង**ថា ឥឡូវ**សុម៉ាអ៊ី**ឲ្យធ្វើគោយន្តទឹមរទេះទៅជញ្ជូនស្បៀងមកច្រើនណាស់។ **ខុងបេង**បានឮ

ដូច្នោះក៏មានសេចក្ដីត្រេកអរ ទើបបង្គាប់**អងប៉េង**ឲ្យនាំពលមួយពាន់ តែងខ្លួនបន្លំជាទាហាន**សុម៉ាអ៊ី** ហើយទៅពួនបង្កប់នៅកណ្ដាលផ្លូវ។ លុះពេលយប់ស្ងាត់ហើយទាហាន**សុម៉ាអ៊ី**បររទេះគោយន្តនាំស្បៀងមកដល់ទីណា ត្រូវតាំងវាយគ្នាចូលទៅប្រាប់ថា **សុម៉ាអ៊ី**ឲ្យមកជួយការពារស្បៀង បើពួកកងប្រចាំជូននោះឃើញប្រទះនៅទីណាជឿថាប្រាកដហើយ ត្រូវឲ្យពួកយើងចូលទៅព្រមគ្នា ហើយដេញកាប់ពួកវាឲ្យអស់ រួចជញ្ជូនយករទេះនោះមក បើ**សុម៉ាអ៊ី**ឲ្យលើកទ័ពតាម ត្រូវឲ្យគ្នាយើងទះគន្លឹះកុំឲ្យដើរបាន ទោះបីទាហាន**សុម៉ាអ៊ី**នឹងបររទេះស្បៀងទៅក៏មិនទាន់ការ សឹមឲ្យលើកគ្នាជាកងទ័ពខ្មោចទៅលង**សុម៉ាអ៊ី**ឲ្យភ័យ ហើយរត់ទៅ រួចសឹមយើងយកគន្លឹះគោយន្តនោះទុកតាមដើម ហើយទឹមបររទេះស្បៀងយកមកដោយងាយ។ ហើយ**ខុងបេង**បង្គាប់**ទៀវង៉ី**ឲ្យនាំពល៥០០ តែងខ្លួនគួរមុខបន្លំជាទ័ពខ្មោច ដៃមួយកាន់ទង់ ដៃមួយកាន់គ្រប៉ី ឲ្យយករំសេវ និងស្ពាន់ធម៌ដាក់ផ្ទាំងស្ពាយទៅពួនបង្កប់គ្រប់គ្នា បើឃើញ**សុម៉ាអ៊ី**តាម**អងប៉េង**មកត្រូវឲ្យអុជរំសេវ និងស្ពាន់ធម៌គ្រប់គ្នាឡើង ហើយឲ្យស្រែកគំរាមគ្រហឹមលងជាទ័ពខ្មោចចេញមក បើទាហាន**សុម៉ាអ៊ី**រត់ទៅ ទើបឲ្យអណ្ដាតគន្លឹះគោយន្តចេញ ហើយទឹមរទេះបរមក ហើយបង្គាប់**កៀងអ៊ុយ**ឲ្យនាំពលមួយម៉ឺនទៅចាំជួយការពាររទេះស្បៀងកុំឲ្យវាអន្តរាយ។ ឯ**ទៀវអេក** និង**លៀវហ្វ៊ូ**នោះឲ្យនាំពលប្រាំពាន់ ទៅពួនបង្កប់ស្កាត់វាយទាហាន**សុម៉ាអ៊ី**កុំឲ្យជួយគ្នាបាន ឯនាយទាហានទាំងពួងទទួលបញ្ជាហើយ ក៏លើកគ្នាទៅតាមបង្គាប់**ខុងបេង**។

ឯ**ង៉ឹមអ៊ុយ** ដែលនាំរទេះស្បៀងទៅដាក់កណ្ដាលផ្លូវ ទទួលពេលយប់ស្រាប់តែឮសូរមាត់ទាហានចេញពីព្រៃមកប្រាប់ថា **សុម៉ាអ៊ី**ឲ្យលើកទ័ពមកជួយការពារស្បៀង ក៏គិតថាជាការពិតមិនសង្ស័យ។ លុះដល់ពេលយាមមួយប្លាយ **អងប៉េង** និងទាហានទាំងឡាយបានចំណាប់ ក៏ដេញកាប់សម្លាប់ពួករទេះស្បៀងស្លាប់ច្រើនណាស់។ **ង៉ឹមអ៊ុយ**ឃើញដូច្នោះក៏ភ័យណាស់ ទើបបរសេះចូលទៅច្បាំងនឹង**អងប៉េង**បានបីភ្លែង **អងប៉េង**លើកលំពែងចាក់ត្រូវ**ង៉ឹមអ៊ុយ**ធ្លាក់ពីលើសេះស្លាប់ ទាហានដែលរស់រួចទាំងប៉ុន្មានក៏បែករត់ទៅនោះ **អងប៉េង**ក៏ឲ្យទាហានបររទេះស្បៀងមក។

ឯកងពលប្រចាំជូនស្បៀងដែលបែករត់ទៅដល់បន្ទាយប៉ាក់ងួន ក៏យកសេចក្ដីទៅជម្រាប**កោឈុយ**គ្រប់ប្រការ **កោឈុយ**ឮដូច្នោះភ័យណាស់ ទើបនាំពលចេញទៅដេញទាហាន**ខុងបេង**។ **អងប៉េង**ឃើញដូច្នោះក៏ឲ្យទាហានទះគន្លឹះអណ្ដាតគោយន្តទាំងអស់ ហើយនាំគ្នាធ្វើរត់ទៅ។ **កៅឈុយ**មិនបានដេញតាម ប្រឹងឲ្យទាហានបររទេះគោយន្តក៏មិនដើរចាកទី លុះនឹងឲ្យជញ្ជូនស្បៀងក៏មិនទាន់ការ **កោឈុយ**មានសេចក្ដីសង្ស័យណាស់ទទួលឮសំឡេងស្រែកហ៊ោអឺងកង ហើយឃើញ**អងប៉េង, កៀងអ៊ុយ, អ៊ុយអៀន**នាំទាហានវាយខ្ទប់ប្រសព្វចូលមកជាបីទិស **កោឈុយ**តទល់ពុំឈ្នះ ក៏នាំទាហានប្រះរត់ទៅ។

**អងប៉េង**ក៏ឲ្យទាហានត្រឡប់គន្លឹះអណ្ដាតគោយន្ត ទឹមបររទេះនាំស្បៀងមកបានដូចដើម **កោឈុយ**ឃើញដូច្នោះក៏មានសេចក្ដីខឹងណាស់ ទើបនាំទាហានរើត្រឡប់តាមវាយកងទ័ពដណ្ដើមយករទេះស្បៀងវិញ ស្រាប់តែឮសំឡេងហ៊ោពីលើភ្នំ ហើយឃើញផ្សែងភ្លើងផុសឡើង ទាហានទាំងពួងស្រែកគំរាមចេញមក **កោឈុយ**ឃើញពួកនោះស្លៀកពាក់ប្លែកណាស់ សំយាកសក់មុខមាត់ដូចខ្មោចព្រៃ ហើយគិតថាទេវតា និងបិសាច ក្លែងមកជួយ**ខុងបេង**ប្រាកដហើយបានជាដូច្នេះ។

ឯ**សុម៉ាអ៊ី**ដឹងថា ស្បៀងនិងកងទ័ព**កោឈុយ**ជាអន្តរាយដូច្នោះ ក៏នាំទាហានទាំងអស់ទៅជួយ លុះទៅដល់ច្រកបុរហបភ្នំកណ្ដាលផ្លូវ ស្រាប់តែឮស្វូផាវស្រែកហ៊ោគឹកកង ខាងស្ដាំនោះឃើញ**ទៀវអេក** ខាងឆ្វេងឃើញ**លៀវហ្វ៊ួ**នាំទាហានវាយប្រសព្វខ្ទប់ចូលមក **សុម៉ាអ៊ី**និងទាហានទាំងពួងក៏មិនដឹងខ្លួន ក៏បែករត់ទៅ កាល**សុម៉ាអ៊ី**រត់ទៅនោះ **ទៀវអេក**បាំងទាហានទុកមិនឲ្យតាម**សុម៉ាអ៊ី**ទៅ **សុម៉ាអ៊ី**បំផាយសេះទៅតែម្នាក់ឯង **លៀវហ្វ៊ួ**បំផាយសេះតាមទៅជិតនឹងទាន់**សុម៉ាអ៊ី** **លៀវហ្វួ**លើកដាវកាប់ហួសទៅត្រូវដើមឈើជាប់ដាវ **សុម៉ាអ៊ី**បរសេះទៅទិសខាងត្បូង **លៀវហ្វ៊ួ**កន្ត្រាក់ដាវបានដេញតាមទៅទៀតមិនទាន់ បានតែមួកមាសរបស់**សុម៉ាអ៊ី**ដែលរបូតធ្លាក់ លុះត្រឡប់បរសេះវិលមកដល់មាត់ផ្លូវ ក៏ប្រទះនឹង**កៀងអ៊ុយ, អ៊ុយអៀន, ទៀវង៉ី, អងប៉េង** ទើបឲ្យអស់ពលបរទេះស្បៀងទៅដល់បន្ទាយ ហើយអធិប្បាយរឿងរ៉ាវដែលបានធ្វើការនោះឲ្យ**ខុងបេង**ស្ដាប់គ្រប់ប្រការ ឯ**លៀវហ្វ៊ួ**ពណ៌នាសេចក្ដី

ហើយ ក៏ជូនម្ជូកមាសរបស់**សុម៉ាអ៊ី**ទៅឲ្យ**ខុបេង**។ **អ៊ុយអៀន**ឃើញដូច្នោះក៏មានចិត្តឫស្យា សម្លាក់**លៀវហ៊្វ**មិនដាក់ភ្នែក។ **ខុងបេង**ឃើញកិរិយា**អ៊ុយអៀន**ឫស្យាដាក់**លៀវហ៊្វ**ដូច្នោះ ក៏ធ្វើបែបព្រងើយ។

កាល**សុម៉ាអ៊ី**រត់ទៅនោះ លុះទៅដល់បន្ទាយហើយក៏មានសេចក្តីវិបរិតកើតទុក្ខខ្លាំងណាស់ ព្រោះខូចខាតរេហ៍ពលនិងស្បៀងអាហារច្រើនណាស់។ ខណៈនោះមានព្រះតម្រាស់ព្រះចៅ**ចូយ៉យ**ប្រាប់មកថា **ស៊ុនគួន**លើកទ័ពជាបីផ្លូវនឹងមកធ្វើអន្តរាយស្រុកយើងហើយ ឲ្យ**សុម៉ាអ៊ី**តាំងបន្ទាយវាយទ័ពឲ្យខ្ជាប់មាំមួន កុំឲ្យចេញខ្លួនច្បាំងនឹង**ខុងបេង** យើងនឹងប្រឹងប្រែងចាត់រេហ៍ពលឲ្យមកជួយផ្តល់ថែមទៀតដើម្បីនឹងរារាំងខាំងទ័ព**ស៊ុនគួន**។ **សុម៉ាអ៊ី**ឃើញសេចក្តីសំបុត្រដូច្នោះក៏ព្រួយណាស់ រឹតតែមានទុក្ខស្ទះនឹងឱរា ចេះតែឲ្យខំត្រួតត្រារក្សាបន្ទាយមិនឲ្យទាហានចេញច្បាំងនឹង**ខុងបេង**។

ព្រះចៅ**ចូយ៉យ**ត្រាស់ប្រើ**ឡៅសៀវ**នាំពលទៅទល់ទ័ពខាងស្រុកកាំងហែ ឲ្យ**ទៀវអ៊ី**នាំពលទៅជួយស្រុកសុងយ៉ុង ខ្លួនព្រះចៅ**ចូយ៉យ**និង**ម៉ាន់ថង**លើកកងទ័ពទៅតាំងនៅស្រុកហាប់ប៉ា។ **ម៉ាន់ថង**ក៏នាំពលយោធាទៅត្រួតត្រាមើលតាមមាត់ទន្លេ ឃើញកងទ័ពទូកស្រុកកាំងតាំងនៅមាត់ឈូងទិសបូព៌ច្រើនណាស់ ក៏ត្រឡប់វិលទៅទូលព្រះចៅ**ចូយ៉យ** ហើយថាកងទ័ព**ស៊ុនគួន**មានប្រមាថថា យើងទើបលើកពលមកដល់យប់នេះ សុំឲ្យចាត់កងទ័ពលើកទៅលុកទ័ពទូក**ស៊ុនគួន** មុខជានឹងបានដោយងាយ។

ព្រះចៅ**ចូយ៉យ**ទ្រង់យល់ឃើញត្រូវ ទើបឲ្យ**ទៀវគីវ**នាំពលប្រាំពាន់ កាន់គប់ភ្លើងចុះទូកតូចរហ័សទៅជាច្រើន ឲ្យ**ម៉ាន់ថង**នាំពលលើកទៅលុកបន្ទាយគោកក្បែរមាត់ច្រាំងស្រុកកាំងហែ នោះ**ម៉ាន់ថង**និង**ទៀវគីវ**ក៏នាំពលញែកគ្នាទៅ លុះដល់ពេលយាមពីរប្លាយ ក៏លើកចោមចូលវាយបន្ទាយគោក បន្ទាយទឹក ហើយយកគប់ភ្លើងដុតឆេះឡើងគ្រប់កន្លែង ទាហានស្រុកកាំងតាំងមិនទាន់ដឹងខ្លួន ខូចទូកនូវគ្រឿងសាស្ត្រាវុធនិងស្បៀងអាហារច្រើនណាស់ ឯ**ជូកាត់កិន**ដែលនៅរក្សាបន្ទាយមុខក្បែរមាត់ទឹកស្រុកកាំងហែនោះក៏បែករត់ទៅ **ម៉ាន់ថង, ទៀវគីវ** លុះវាយបែក

បន្ទាយគោកបន្ទាយទឹកនេះហើយ ក៏នាំពលត្រឡប់មកទូលព្រះចៅ**ចូយ៉យ**ជ្រាបគ្រប់ប្រការ។

ឯ**ឡុកស៊ុន**ដែលតាំងទ័ពនៅបន្ទាយឡុកខៅ លុះបានដឹងការហើយក៏ប្រឹក្សាគ្នានឹងនាយទ័ពនាយកងទាំងពួងថា យើងនឹងឲ្យមានសំបុត្រទៅសុំកងទ័ពព្រះចៅ**ស៊ុនគួន**ឯស្រុកស៊ុនសៀ ឲ្យលើកមកវាយចុងទ័ព**ចូយ៉យ** ហើយយើងនឹងនាំពលចូលវាយខ្ទប់មុខកងទ័ព**ចូយ៉យ**ឲ្យបែកទៅ។ នាយទ័ពនាយកងទាំងពួងយល់ឃើញត្រូវ ទើបឲ្យតែងសំបុត្រតាមរឿងរ៉ាវដែលបឹក្សា ហើយប្រើបម្រើទៅច្រូតកាត់តម្រង់ នោះពួកកងល្បាតចាប់បានបម្រើកាន់សំបុត្រ ក៏បញ្ជូនទៅកងទ័ពធំ។ ព្រះចៅ**ចូយ៉យ**ឲ្យយកសំបុត្រទៅមើលឃើញសេចក្ដីហើយក៏ជ្រាបតាមដំណើរ ទើបត្រាស់ថា **ឡុកស៊ុន**នោះជាមនុស្សមានតម្រិះប្រាជ្ញាមុតមាំណាស់ ហើយឲ្យយកបម្រើនោះទៅដាក់គុកទុក ទើបឲ្យបម្រើសេះទៅបង្គាប់**ឡៅសៀវ**ថា ឲ្យលើកទាហានទៅចាំស្កាត់ដើមផ្លូវ កុំឲ្យ**ស៊ុនគួន**លើកមកធ្វើអន្តរាយខាងចុងទ័ពយើងបាន។

ឯ**ជូកាត់កិន** ឃើញទាហាន**ចូយ៉យ**លើកត្រឡប់ទៅហើយ ក៏នាំរេហ៍ពលចូលបន្ទាយ។ ខណៈនោះជាទេសកាលក្ដៅ ពលទាំងឡាយដែលមានរបួសពិការ ក៏ឈឺចាប់អត់ស្បៀងអាហារ ស្លាប់ច្រើនណាស់ ទើប**ជូកាត់កិន**តែងសំបុត្រចាត់បម្រើឲ្យទៅជូន**ឡុកស៊ុន**សេចក្ដីថា ដែលនឹងតាំងទ័ពនៅច្បាំងនោះ ឃើញថានេះលំបាកខ្លាំងណាស់ លោកនិងខ្ញុំត្រូវនាំគ្នាវិលទៅស្រុកកាំងតាំងវិញសិនស្រួលជាង។ **ឡុកស៊ុន**ឃើញសំបុត្រដូច្នោះ ក៏បង្គាប់អ្នកកាន់សំបុត្រនោះថា ឯងវិលទៅជម្រាបចៅហ្វាយឯងចុះថា អញគំនាប់មក សុំកុំឲ្យ**ជូកាត់កិន**ព្រួយព្រះចិត្តអ្វីឡើយ ឲ្យប្រុងប្រយ័ត្ននៅតែក្នុងបន្ទាយឲ្យមាំមួនចុះ ការទាំងប៉ុន្មានអញគិតទុកស្រេចអស់ហើយ។ បម្រើនោះក៏វិលទៅប្រាប់**ជូកាត់កិន**តាមដំណើរ **ជូកាត់កិន**សួរថា ឃើញ**ឡុកស៊ុន**ធ្វើម្ដេចខ្លះ? បម្រើឆ្លើយថា ខ្ញុំបាទឃើញ**ឡុកស៊ុន**ដាំស្ពៃ ជីរ និងត្រឡាចល្ពៅនៅក្បែរជើងបន្ទាយច្រើនណាស់ ហើយ**ឡុកស៊ុន**នាំពលចេញទៅហាត់សមអាវុធ និងហាត់សេះនៅមុខបន្ទាយ។

**ជូកាត់កិន**ឮដូច្នោះក៏ភ័យណាស់ថា **ឡុកស៊ុន**ចេញមកគិតធ្វើការសង្គ្រាមហើយ ហេតុអ្វីទៅជាដាំបន្លែបង្ការលេងទៅវិញដូច្នោះ ទើបនាំទាហានទៅបន្ទាយ**ឡុកស៊ុន**ហើយសួរថា លោកលើកទ័ពមកគិតនឹងតច្បាំងឬប្រការម្ដេច? **ឡុកស៊ុន**តបថា ខ្ញុំបានធ្វើសំបុត្រទៅសុំកងទ័ពព្រះចៅ**ស៊ុនគួន**ឲ្យលើកមកជួយទ័ពសន្ទប់ខ្ទប់ជួយវាយ តែឥឡូវអ្នកល្បាត**ចូយ៉យ**ចាប់បម្រើកាន់សំបុត្រនោះបានទៅហើយ ការដែលគិតទុកក៏ខូចទៅ ឥឡូវខ្ញុំបកថែមទៅទៀតដល់ព្រះចៅ**ស៊ុនគួន**ថា នឹងសុំលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញ។ **ជូកាត់កិន**ថា ទៅឥឡូវនេះ បើលោកគិតដូច្នោះមានតែស្រូតប្រញាប់ទៅ។ **ឡុកស៊ុន**ថា យើងនឹងលើកទៅឥឡូវនេះ ទាហាន**ចូយ៉យ**ដឹងនឹងលើកតាមចោមវាយ លោកជាកងមុខ ត្រូវតែចាត់ទូកចម្បាំងឲ្យឃើញជាទីលើកទៅច្បាំងនឹងសត្រូវ ទើបខ្ញុំលើកត្រឡប់ទៅស្រួល។ **ជូកាត់កិន**ទទួលពាក្យ**ឡុកស៊ុន**ត្រឡប់ទៅដល់បន្ទាយ ហើយរៀបចំទូកចម្បាំងទុកព្រមស្រេច។

បម្រើសេះល្បាតឃើញដូច្នោះ ក៏នាំសេចក្ដីនោះចូលទៅទូលព្រះចៅ**ចូយ៉យ**ៗជ្រាបហើយថា រីតម្រិះប្រាជ្ញា**ឡុកស៊ុន**នោះជ្រៅកំបាំងណាស់ បើយើងនឹងលើកទៅតស៊ូវេលានេះក៏បារម្ភខ្លាចក្រែង**ឡុកស៊ុន**ប្រើកលឧបាយ ទើបប្រើទាហានទាំងឡាយឲ្យរក្សាបន្ទាយឲ្យខ្ជាប់ខ្ជួន លុះកន្លងមកប្រាំថ្ងៃទាហានល្បាតចូលទៅទូលព្រះចៅ**ចូយ៉យ** ៗឮដូច្នោះក៏នៅមិនទាន់ជឿ ឲ្យបម្រើទៅស៊ើបមើលឃើញពិតដូចពាក្យល្បាតមកនិយាយ ទើបបង្គាប់នាយទ័ពនាយកងឲ្យរក្សាបន្ទាយទុកដោយមាំមួន ព្រះចៅ**ចូយ៉យ**ក៏បោះទ័ពខ្ជាប់នៅស្រុកហាប់ប៉ា ប្រាថ្នានឹងចាំមើលកលការកងទ័ពស្រុកកាំងតាំង។

*លោកអ្នកអានអាចរកមើលសៀវភៅផ្សេងទៀតតាមរយៈគេហទំព័រ*

www.khmerliterature.wordpress.com

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៧៨

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ខុងបេង**ប្រើឧបាយឲ្យទាហានទៅល្បួងអ្នកស្រុកឡុកអៀង ជួយដាំដំណាំ អ្នកស្រុកក៏បាក់ចិត្តស្រឡាញ់**ខុងបេង**ច្រើន **សុម៉ាស្ទូ**ដឹងការ ញុះ**សុម៉ាអ៊ី**ជាបិតាឲ្យចេញច្បាំង។ល។ **ខុងបេង**ជាប់ចំណោមភ្លើងខ្លួននឹងដល់នូវសេចក្តីស្លាប់ រៀបពិធីតអាយុ **អ៊ុយអៀន**ដើរចូលទៅខូចពិធី។ **ខុងបេង**ធ្វើកាលកិរិយា។ **អ៊ុយអៀន**ប្រែក្បត់ **ម៉ាតាយ**សម្លាប់**អ៊ុយអៀន, ជៀវអ្វួន**ឡើងមហាឧបរាជ **ទៀវងី**ប្រែក្បត់ ព្រះចៅ**ឡៅសៀន**ខ្វាល់ឲ្យសម្លាប់**ទៀវងី ជៀវអ្វួន**សុំទោសស្តេចឲ្យងារជារាស្ត្រ)។*

**ឯខុងបេង** កាលតាំងទ័ពនៅភ្នំគីសាន់នោះ លុះបានឃើញ**សុម៉ាអ៊ី**មិនលើកពលចេញច្បាំងសោះជាយូរលង់ណាស់ ក៏គិតថា ការសឹកនេះគង់នឹងយូរវេលា ទើបប្រើពលទាហានគ្មានងារឲ្យចេញទៅល្បួងចងចិត្តអ្នកស្រុក បណ្តាដែលមាននៅជិតទីក្រុងឡុកអៀង ពលទាហានខ្លះក៏ព្រមព្រៀងចូលទៅជួយដាំត្រសក់ឃ្លោកត្រឡាចល្ពៅនៅក្នុងចម្ការ។ លុះលាស់លេចជាផ្លែផ្កាហើយ ពួកទាហាននោះសុំបែងជាបីចំណែក គឺចំណែកពីរឲ្យទៅម្ចាស់ចម្ការ ចំណែកមួយបានមកពួកទាហាន ហើយពួកទាហាន**ខុងបេង**សឹងតែជាមនុស្សស្លូតសុភាពរៀបរយ មិនឲ្យទៅកំហែងបំភិតបំភ័យអ្នកស្រែចម្ការនោះឡើយ ម្ល៉ោះហើយអស់បណ្តារាស្ត្រទាំងនោះ ក៏ស្រុះស្រួលបបួលគ្នាសរសើរស្រឡាញ់ពេញចិត្តនឹង**ខុងបេង**ជាច្រើនណាស់។

វេលានោះ **សុម៉ាស្ទូ**បុត្រ**សុម៉ាអ៊ី**ក៏ស្រដីជម្រាប**សុម៉ាអ៊ី**ថា វេលានេះទាហាន**ខុងបេង**លើកគ្នាទៅស្វែងចងចិត្តគំនិតរាស្ត្រអ្នកស្រុកស្រែចម្ការ នាំគ្នាដាំសារពើដំណាំគ្រប់មុខ បានស្រូវអាហារយកមកទុកបរិភោគជាកម្លាំងច្រើនណាស់ ហើយរាស្ត្រទាំងអស់នោះ ក៏ស្រុះស្រួលបបួលគ្នាសរសើរស្រឡាញ់ពេញចិត្តនឹង**ខុងបេង**ជាច្រើន ដែលបិតានឹងស្ងៀមនៅដូច្នេះ មិនគិតរិះចេញទៅតច្បាំងនោះ មុខជា

សត្រូវនៅមានកម្លាំងខ្លាំងតាំងតែកម្រើកឡើងច្រើនហើយ។ **ស៊ុម៉ាអ៊ី**ក៏ឆ្លើយតបថា ព្រះចៅ**ចូយ៉យ**ឲ្យតាំងទ័ពទុកសិន បើយើងនឹងលើកចេញទៅសង្កត់សង្កិនតាមពលក្តារ ក្រែងខុសនឹងអាជ្ញាព្រះរាជតម្រាស់។

ខណៈនោះទទួល**អ៊ុយអៀន**កាន់យកមួកមាសរបស់**ស៊ុម៉ាអ៊ី** ដែលជាប់ទើរលើមែកឈើនោះមកស្រែកជេរជាពាក្យត្អះតិះដៀលនៅមុខបន្ទាយ **ស៊ុម៉ាអ៊ី**ក៏មិននិយាយឆ្លើយថាយ៉ាងម្តេច នោះអស់នាហ្មឺននិងទាហានទាំងពួងដែលឮ ក៏នាំគ្នាឈឺចិត្តខឹងណាស់ទាំងអស់គ្នា ក៏តែងតួស្លៀកពាក់ក្រិសនិងអាវុធសាស្ត្រា ប្រាថ្នានឹងចេញទៅច្បាំងនឹង**អ៊ុយអៀន**។ **ស៊ុម៉ាអ៊ី**ក៏ស្រដីរារាំងឃាំងឃាត់ថា កុំអាលចេញទៅឡើយ ព្រោះបុរាណពោលទុកថា ហេតុការណ៍តែបន្តិច គេចនាំឲ្យខូចការធំអស់ទៅ។ ពួកទាហានទាំងពួងក៏ស្តាប់ពាក្យ**ស៊ុម៉ាអ៊ី**ឃាត់ហាម **អ៊ុយអៀន**ចេះតែស្រែកឡកចំអកទាល់តែដល់ពេលព្រលប់ មិនបានឃើញអ្នកឯណាចេញមុខមកតវ៉ាសោះ ក៏នាំគ្នាទាំងអស់ចូលទៅបន្ទាយវិញ។

**ខុងបេង** ឲ្យ**ម៉ាតាយ**នាំទាហានទៅរកឈើមកធ្វើបន្ទាយនៅមាត់ផ្លូវហៅលោកុក ហើយឲ្យជីករំលុងយកឈើពុក និងស្មោះចំបើងទៅគរដាក់ក្នុងរំលុង រួចយករំសេវនិងស្ពាន់ធម៌ទៅបាចសាចពីលើជាឈ្នួនជាប់ទុកទៅ យកដី និងស្មៅទៅវាយលប់ពីលើ ឯក្នុងទីភ្នំហៅលោកុកនោះ ឲ្យធ្វើពាងតូចៗ ហើយញាត់ដីទុក រួចយករំសេវ និងស្ពាន់ធម៌ទៅលាយដាក់ក្នុងពាងក្រឡនោះ ហើយតឈ្នួនទុកគ្រប់ក្រឡលុះដល់ពេលយប់ឲ្យដុតគោមប្រាំពីរអន្លើទុកជាសម្គាល់ **ម៉ាតាយ**ក៏ឲ្យធ្វើតាមពាក្យ**ខុងបេង**បង្គាប់។

**ខុងបេង**បង្គាប់**អ៊ុយអៀន**ឲ្យនាំទាហានប្រាំពាន់ ទៅស្រែកដៀលត្អះពីមុខបន្ទាយ**ស៊ុម៉ាអ៊ី** បើ**ស៊ុម៉ាអ៊ី**ចេញច្បាំង ត្រូវអ្នកឯងតស៊ូការពាររារាំងទុកឲ្យដល់ព្រលប់ រួចត្រូវបញ្ឆោតឲ្យដេញចូលមកចុះ ឲ្យចំលើគោមសម្គាល់ យើងនឹងបានចាប់យកខ្លួនឲ្យបាន ទើបបង្គាប់**កោសៀង**ឲ្យចាត់ទាហាននាំគោយន្តចេញទៅ ក្នុងមួយកងៗប្រហែល៤០ឬ៥០ បើឃើញ**ស៊ុម៉ាអ៊ី**ចេញមកតយុទ្ធត្រូវឲ្យចោលគោយន្តចេញ ហើយឲ្យទាហានលើកទៅជាកងៗទៅពួនបង្កប់ បើឃើញសត្រូវលើកចេញ

មកត ត្រូវឲ្យទាហានយើងធ្វើជាថយក្រោយរត់ចេញ កាលណាឃើញ**សុម៉ាអ៊ី**ចេញមកឯង សឹមនាំគ្នាលើកពារសំរុកចូលទៅឲ្យព្រម។ នាយទាហានទាំងអស់ក៏ទទួលចាត់ការធ្វើតាម**ខុងបេង**បង្គាប់គ្រប់ប្រការ។ **ខុងបេង**ក៏នាំពលមួយកងទៅតាំងនៅចង្កេះភ្នំពីលើខ្យល់។

ឯ**ហែហ៊្វហោ, ហែហ៊្វហ៊ុយ**បានឃើញដូច្នោះ ក៏ចូលទៅប្រាប់**សុម៉ាអ៊ី**ថា **ខុងបេង**ឲ្យតាំងបន្ទាយនៅលើចង្កេះភ្នំ និងក្បែរមាត់ផ្លូវហៅលោកុក ហើយតាំងទ័ព និងធ្វើរូងដីតូចៗរាយនៅជាច្រើន ខ្ញុំបាទយល់ឃើញថា ការសឹកគ្រានេះមុខជាយូរយឺតយូរណាស់ សុំឲ្យប្រសាសន៍រិះគិតកាត់បង់ឲ្យទាន់ការ បើទុកទៅឲ្យហួសវេលាមុខជាកម្ចាត់ចេញមិនងាយ។ **សុម៉ាអ៊ី**ថា ដែលសត្រូវធ្វើការទាំងអម្បាលនេះ គឺសុទ្ធតែជាឧបាយ**ខុងបេង**ទាំងអស់ បើយើងនឹងលើកចេញទៅតដោយស្មោះក៏ក្រែងថ្លោះការ។

**ហែហ៊្វហោ, ហែហ៊្វហ៊ុយ**ឆ្លើយថា បើសិនណា**ខុងបេង**នឹងប្រើកលដូចម្ដេច ខ្ញុំបាទពីរនាក់ នឹងសុំអាសាចេញវាយទម្លាយយកជ័យជម្នះតបស្នងព្រះតេជគុណឲ្យបាន។ **សុម៉ាអ៊ី**តបថា បើអ្នកទាំងពីរនឹងទទួលយកអាសា យើងក៏មានអំណរណាស់ហើយ តែត្រូវឲ្យអ្នកនាំទាហានម្នាក់មួយពាន់នាក់ លើកចេញទៅវាយជាពីរផ្លូវចុះ។ **ហែហ៊្វហោ, ហែហ៊្វហ៊ុយ**ក៏នាំទាហានចេញពីបន្ទាយទៅប្រទះនឹងល្បាតសេះប្រាប់ថា ឥឡូវសត្រូវយករទេះស្បៀងបានទៅច្រើនណាស់ហើយ។ **ហែហ៊្វហោ, ហែហ៊្វហ៊ុយ**ឮដូច្នោះ ក៏បញ្ចូលគ្នាលើកទៅជាកងមួយ ចូលទៅវាយយកគោយន្តនិងស្បៀងនាំមកឲ្យ**សុម៉ាអ៊ី**ជាច្រើនណាស់។

លុះពេលព្រឹកឡើង **ហែហ៊្វហោ, ហែហ៊្វហ៊ុយ**ក៏លើកពលចេញទៅច្បាំងទៀត ចាប់កូនទាហានបានប្រមាណមួយរយនាក់ ហើយនាំទៅជូន**សុម៉ាអ៊ី**ក្នុងបន្ទាយ។ **សុម៉ាអ៊ី**ក៏សួរដំណឹងកូនទាហាននោះថា **ខុងបេង**គិតការសឹកយ៉ាងដូចម្ដេចខ្លះ? ទាហានពួកនោះឆ្លើយថា **ខុងបេង**មិនបានឃើញលោកខាងនេះចេញទៅច្បាំងក៏មានចិត្តកំរើបគិតធ្វើសឹកនេះឲ្យយឺតយូរទៅ បានជាឲ្យអស់យើងខ្ញុំទាំងឡាយលើកគ្នាដើរទៅស្វែងដាំបន្លែបង្ការជាឃ្លោក ត្រឡាចផ្សេងៗ យើងខ្ញុំទាំងឡាយ

វង្វេងប្រមាថណាស់ បានជាកងទ័ពលោកម្ចាស់ខ្ទប់ចាប់បាន។ **សុម៉ាអ៊ី**ឮព័ត៌មានដូច្នោះ ក៏អស់សំណើចហើយថា អញមិនត្រូវការធ្វើបាបឯងរាល់គ្នាទេ ថាហើយក៏បើកលែងពួកនោះអស់ទៅ។

**ហែហ៊្វហោ**ជម្រាប**សុម៉ាអ៊ី**ថា ការចាប់ឈ្លើយបានមកហើយ ហេតុអ្វីបានជាប្រសាសន៍លែងអស់ទៅវិញដូច្នេះ? **សុម៉ាអ៊ី**តបថា អ្នកឯងក្មេងសេចក្តីខ្លីគំនិតណាស់ ទើបមិនកន្លងនឹងតម្រិះប្រាជ្ញាយើងបាន ដែលយើងបើកលែងទាហាន**ខុងបេង**ទៅវិញដូច្នេះ ប្រាថ្នានឹងឲ្យល្បីឈ្មោះចិត្តយើងមិនមានសេចក្តីអាឃាតព្យាបាទកូនទាហានតូចតាចសោះ ទោះបីជាខ្មាំងនឹងគ្នាទាំងអស់ ក៏ចំពោះប្រាថ្នាតែរូបនាយកងនាយទ័ពណាដែលធំៗ ដែលយើងនិយមធ្វើដូច្នេះ គឺជាកលឧបាយដូចកាលគ្រា**លីបង**ច្បាំងនឹង**គួនអ៊ូ**នៅស្រុកកេងជីវ។ **លីបង**ចាប់ទាហាន**គួនអ៊ូ**ទាំងប៉ុន្មានៗសឹងតែលែងទៅវិញទាំងអស់។ **ហែហ៊្វហោ**ឮដូច្នោះក៏យល់ឃើញត្រូវ ទើប**សុម៉ាអ៊ី**បង្គាប់នាយទាហានគ្រប់ពួកគ្រប់កងថា បើនរណាចាប់បានទាហាន**ខុងបេង**ហើយត្រូវឲ្យលែងទៅវិញ ហើយឲ្យត្រួតត្រាសេនាទាហានទុកឲ្យព្រម។

ឯ**ខុងបេង**តាំងឲ្យ**កោសៀង**នាំគោយន្តជញ្ជូនស្បៀង ទៅទុកឯបន្ទាយមាត់ផ្លូវហៅលោកុកជាសព្វថ្ងៃមិនឲ្យដាច់។ **ហែហ៊្វហោ, ហែហ៊្វហ៊ុយ**ក៏ចេះតែនាំកងទ័ពទៅចាំចាប់ដណ្តើមយកគោយន្តនិងស្បៀងជានិរន្តរ។ លុះកន្លងមកក្នុងថ្ងៃមួយនោះ **ហែហ៊្វហោ, ហែហ៊្វហ៊ុយ**លើកទៅវាយដណ្តើមយកចាប់ទាហាន**ខុងបេង**បានប្រហែល៥០នាក់ ក៏នាំទៅឲ្យ**សុម៉ាអ៊ី**ឯបន្ទាយ។ **សុម៉ាអ៊ី**ក៏ដណ្តឹងសួរពួកទាហានទាំងនោះថា **ខុងបេង**ឥឡូវនេះនៅឯណា? ពួកទាហានទាំងនោះឆ្លើយថា **ខុងបេង**ទៅតាំងបន្ទាយនៅចង្កេះភ្នំសៀមកុក ប្រើទាហានឲ្យជញ្ជូនស្បៀងទៅទុកក្នុងបន្ទាយថ្មីដែលនៅមាត់ផ្លូវហៅលោកុក។ **សុម៉ាអ៊ី**ឮដូច្នោះ ក៏ឲ្យលែងទាហាន៥០នាក់នោះទៅវិញ ហើយបង្គាប់ទាហានទាំងពួងថា ពេលព្រឹកស្អែកឡើង ត្រូវឲ្យអ្នករាល់គ្នាលើកទ័ពទៅវាយយកបន្ទាយ**ខុងបេង**មួយនៅភ្នំគីសាន់ យើងនឹងលើកទ័ពជាជំនួយទៅជួយ។

**ស៊ុម៉ាស៊ូ**ឆ្លើយតបថា បន្ទាយធំរបស់**ខុងបេង**នោះនៅខាងក្រោយ ដែល**ខុងបេង**ទៅតាំងបន្ទាយនៅលើចង្កេះភ្នំសៀមកុកនោះ ងាកចូលមកបន្ទាយមុខ ហេតុអ្វីបិតាមិនបង្គាប់ឲ្យទៅវាយបន្ទាយមុខសិន ក៏ប្រញាប់ទៅវាយឯបន្ទាយក្រោយវិញ ក្រែង**ខុងបេង**លើកទៅជួយ ទាហានយើងមិនថ្លោះការទេឬ? **ស៊ុម៉ាអ៊ី**ថា បន្ទាយឯភ្នំគីសាន់នោះជាបន្ទាយមាំមួនណាស់ បើយើងលើកទៅវាយមុខជា**ខុងបេង**និងទាហានទាំងពួងលើកជួយបន្ទាយធំជាប្រាកដ សឹមយើងលើកញែកគ្នាទៅចោមវាយបន្ទាយផ្លូវហៅលោកុក និងចង្កេះភ្នំសៀមកុកឲ្យបាន ហើយនឹងឲ្យដុតបំផ្លាញស្រូវអង្ករស្បៀងអាហារចេញ បើ**ខុងបេង**ខូចស្បៀងអស់ហើយ កូនអើយយើងធ្វើសឹកមានជ័យជម្នះងាយណាស់។ លុះព្រឹកឡើង **ស៊ុម៉ាអ៊ី**ចាត់ប្រើ**ទៀវហាង, ងាក់លឹម**ឲ្យនាំពល៥ពាន់ជាកងក្រោយ ឯនាយទាហានក្រៅពីនោះក៏ឲ្យនាំពលលើកចេញទៅជាកងៗទៅខាងមុខ **ស៊ុម៉ាអ៊ី**ក៏លើកជូនតាមទៅទៀត។

ឯ**ខុងបេង**ដែលតាំងបន្ទាយនៅចង្កេះភ្នំសៀមកុកនោះ លុះត្រឡប់ចុះទៅឃើញ**ស៊ុម៉ាអ៊ី**លើកទ័ពមកជាច្រើនកង ក៏បង្គាប់ទាហានទាំងពួងថា បើឃើញកងទ័ព**ស៊ុម៉ាអ៊ី**លើកទៅវាយបន្ទាយយើងឯភ្នំគីសាន់ ត្រូវអស់អ្នកនាំទាហានចុះទៅ ធ្វើបែបជានឹងលើកទៅជួយការពារបន្ទាយធំ រួចសឹមលើកវិលត្រឡប់គេចទៅវាយបន្ទាយ**ស៊ុម៉ាអ៊ី**ឯក្រោយឲ្យបាន ឯបន្ទាយមាត់ផ្លូវហៅលោកុក និងបន្ទាយលើភ្នំសៀមកុកនេះ ត្រូវទុកជាភ្នាក់ងារយើងនឹងរិះគិតធ្វើការឲ្យសម្រេចចុះ។ នាយទាហានទាំងអស់នោះក៏ចេញទៅចាត់ការតាមនាទីរៀងខ្លួនត្រៀមទុកស្រេច។

**ស៊ុម៉ាអ៊ី**នោះ លុះឃើញកងទ័ពមុខលើកផុតបន្ទាយហៅលោកុកទៅហើយ ទទួលពេលល្ងាចឃើញទាហាន**ខុងបេង**តាំងនៅជាកងៗ បែបនាំគ្នាទៅជួយបន្ទាយភ្នំគីសាន់ **ស៊ុម៉ាអ៊ី**និងបុត្រទាំងពីរក៏នាំពលចូលទៅនឹងវាយយកបន្ទាយហៅលោកុក។ **អ៊ុយអៀន**ឃើញដូច្នោះ ក៏បរពលវាំលំពែងចេញមកស្រែកថា រើយ**ស៊ុម៉ាអ៊ី**ឯងនឹងរត់ទៅមិនរួចពីដៃអញទេ។ **ស៊ុម៉ាអ៊ី**ឮដូច្នោះក៏ខឹងខ្លាំងណាស់ បរសេះចូលប្រយុទ្ធនឹង**អ៊ុយអៀន**បានបីភ្លែង **អ៊ុយអៀន**ធ្វើជាញាក់សេះថយរត់ចេញទៅតាមផ្លូវដែលមានគោមសម្គាល់។ **ស៊ុម៉ាអ៊ី** និងបុត្រទាំងពីរក៏បំបោលសេះតាមចូលទៅដល់មាត់

ផ្លូវហៅលោកុក មិនឃើញមានមនុស្សម្នាសោះ ទើបឲ្យទាហានចូលទៅមើលត្រង់ច្រកប្រហប ទាហានវិលត្រឡប់មកវិញប្រាប់ថា ហៅលោកុកនេះឃើញមានសុទ្ធតែផ្ទះ និងពាងដីតូចៗ តាំងនៅតាមចង្កេះភ្នំ មិនបានឃើញទាហាន**ខុងបេង**ដល់ម្នាក់សោះ។ ទើប**សុម៉ាអ៊ី**នាំបុត្រ និងពួកទាហានចូលទៅដល់បន្ទាយកាត់ផ្លូវ ឃើញពាងតូចៗ មានសុទ្ធតែស្នៅ និងចំបើងនៅជាច្រើន ទើបថា ទីនេះ**ខុងបេង**គិតនឹងផ្លាស់ប្រែយកស្បៀងមកលាក់ទុក ឯក្នុងជ្រោះភ្នំនេះចំពោះមានតែផ្លូវចូលចេញតាមច្រកពីរផ្លូវប៉ុណ្ណោះ បើ**ខុងបេង**តែងទាហានមកបង្កប់ស្កាត់នៅមាត់ផ្លូវសងខាងនេះហើយមុខជាយើងនឹងបានសេចក្ដីលំបាកវេទនាមិនជាការទេ។ កំពុងនិយាយមិនទាន់ផុតមាត់ ស្រាប់តែឮសូរផាវ និងទាហានស្រែកហ៊ោអឺងកងឡើង ហើយចោលគប់ភ្លើងចុះមកពីលើភ្នំដូចគេបាចសាច។ ភ្លើងនោះក៏ផ្ដួចឆេះតាមឈ្នួនរំសេវគ្រប់ពាងក្រឡផ្ទះដីតូចៗឡើងព្រមគ្នា ពួកទាហាន**សុម៉ាអ៊ី**ស្លាប់នឹងភ្លើងឆេះច្រើនណាស់ ព្រោះស្ទុះចេញមិនទាន់។ **សុម៉ាអ៊ី**ឃើញដូច្នោះក៏ស្លុតអស់ស្មារតីវិញ្ញាណ ធ្លាក់ពីលើសេះទៅពានលើគុម្ពឈើ ស្ទុះភ្លឺភ្លើទៅឱបបុត្រទាំងទ្វេទ្រហោរយំសោកាថា គ្រានេះជីវិតយើងទាំងអស់គ្នានឹងអស់ហើយ កូនអើយ! អាពុកនិងកូនមុខជានឹងស្លាប់ក្នុងទីនេះជាប្រាកដ ថាហើយរកផែលឡើងសេះរបូតធ្លាក់ពីលើសេះអស់រយៈបីបួនគ្រា នឹងរត់ដកឃ្លាទៅឯណាក៏ពុំបាន ចេះតែប្រះប្រាណយំសោក។ ក្នុងខណៈនោះ ទទួលធ្លាក់ខ្យល់ព្យុះបក់បោកមកត្រូវភ្លើង រឹតតែឆេះឡើងគគុកគគាត់ហាក់នឹងក្រឡាប់ព្រះធរណី ភ្លៀងក៏ធ្លាក់ចុះមកពេញទីគិរីទីបព្វតារលត់អស់ភ្លើងដែលឆេះនោះ ទឹកក្នុងជ្រោះ ក៏ជន់លិចដីព្រៃព្រឹក្សាប្រហែលមួយហត្ថ **សុម៉ាអ៊ី**ក៏ស្រែកថា ជាបុណ្យវាសនារបស់យើងច្រើនណាស់ បានជាទេវតាជាម្ចាស់បណ្ដាលឲ្យធ្លាក់ភ្លៀងមកជួយយើង ហើយ**សុម៉ាអ៊ី**ក៏នាំបុត្រទាំងពីរចេញទៅដល់មាត់ផ្លូវ ទទួលប្រទះនឹង**ទៀវហង, ងាក់លឹម**ដែលជាកងក្រោយលើកតាមមកទាន់។

**ម៉ាតាយ**ឃើញដូច្នោះក៏គិតថា បើនឹងតច្បាំងក្នុងគ្រានេះក៏ពុំបាន ព្រោះពលទាហានយើងតិច គិតក្រែងក៏លើកទ័ពថយទៅ។ **សុម៉ាអ៊ី**និងកូនទាំងពីរ ក៏ស្រូតត្រឡប់ទៅដល់បន្ទាយ ស្រាប់តែឃើញកងទ័ព**ខុងបេង**នៅពេញក្នុងបន្ទាយ ក៏នាំគ្នា

បែករាថយទៅ នោះពួកកងទ័ព**ខុងបេង**ក៏តាំងតែដេញតាមតច្បាំងនឹងកងទ័ព**សុម៉ាអ៊ី**ចម្ងាយផ្លូវប្រហែលមួយរយសិន (៤ គ.ម) ខណៈនោះ**សុម៉ាអ៊ី**ប្រទះគ្នានឹង**កោឈុយ, ស៊ុនឡេ** ក៏នាំគ្នាព្រួតតតាំងច្បាំងនឹងកងទ័ព**ខុងបេង**ជាពន្លឹក ទាហាន**ខុងបេង**ប្រឹងអស់ដៃក៏ថយទ័ពត្រឡប់ទៅរក្សាបន្ទាយ**សុម៉ាអ៊ី**ទុក។ **សុម៉ាអ៊ី**ក៏នាំទាហានទ័ពក្រោយមុខទៅតាំងបន្ទាយថ្មីចម្ងាយពីបន្ទាយចាស់ប្រហែលពីររយសិន (៨ គ.ម)។

ឯកងទ័ពមុខ**សុម៉ាអ៊ី**ដែលទៅវាយបន្ទាយ**ខុងបេង**នៅភ្នំគីសាន់នោះ លុះដឹងថា**សុម៉ាអ៊ី**ខូចបន្ទាយហើយ ក៏នាំគ្នាលើកទ័ពត្រឡប់ទៅវិញ ទទួលកងទ័ព**ខុងបេង**វាយប្រសព្វខ្ទប់ពីក្រោយមកជុំទាំងបួនទិស ក៏ដេញកាប់សម្លាប់ទាហាន**សុម៉ាអ៊ី**ស្លាប់អស់ប្រហែលដប់សូន្យ សល់នៅប្រហែលមួយសូន្យម្ភៃ ក៏នាំគ្នារត់ដោះតែខ្លួនទៅរក**សុម៉ាអ៊ី**ឯបន្ទាយថ្មី។

វេលានោះ **ខុងបេង**នៅលើកំពូលភ្នំ ក្រឡេកឃើញ**អ៊ុយអៀន**បញ្ឆោត**សុម៉ាអ៊ី**ឲ្យដេញចូលមកក្នុងច្រកប្រហបភ្នំហៅលោកុកក៏គិតថា គ្រានេះមុខជា**សុម៉ាអ៊ី**នឹងស្លាប់នៅក្នុងភ្លើងជាប្រាកដហើយ លុះឃើញភ្លៀងធ្លាក់ចុះមករលត់ភ្លើងអស់ ឃើញ**សុម៉ាអ៊ី**រួចចេញទៅពីច្រកភ្នំ **ខុងបេង**ដកដង្ហើមធំហើយថា ធម្មតាមនុស្សទាំងពួងនឹងធ្វើអ្វី ក៏រមែងសម្រេចសេចក្តីគិតគឺប្រាជ្ញា បើការនោះមិនបានសម្រេចតាមប្រាជ្ញា ក៏ព្រោះអ្នកនោះមានអកុសលកម្មប្រចាំនៅ ថាហើយក៏នាំទាហានទាំងពួងចុះទៅពីលើភ្នំត្រឡប់ទៅកាន់បន្ទាយធំឯភ្នំគីសាន់។

**សុម៉ាអ៊ី**ក៏ឲ្យប្រកាសដល់សេនាទាហានតូចធំទាំងពួងថា បើឃើញទាហាន**ខុងបេង**លើកមកកុំឲ្យចេញច្បាំង ត្រូវទប់តាំងរក្សាតែបន្ទាយឲ្យមាំមួនទៅចុះ បើនរណារឹងមិនស្តាប់ប្រញាប់ចេញច្បាំង យើងនឹងកាត់ក្បាលដោយអហង្ការ។ លុះនៅមកថ្ងៃមួយ ទើប**កោឈុយ**និយាយនឹង**សុម៉ាអ៊ី**ថា ឥឡូវ**ខុងបេង**ឲ្យតាំងបន្ទាយវាយពាមផ្លូវចូលមកមានបន្ទាយពីរ ហើយឲ្យទាហានមកស្រែកជេរទ្រគោះតិះដៀលរាល់វេលា **សុម៉ាអ៊ី**ក៏ថា ត្រូវតែរក្សាបន្ទាយទុកឲ្យខ្ជាប់ខ្ជួនមួនមាំចុះកុំឲ្យចេញច្បាំងឡើយ។

**ខុងបេង**មិនបានឃើញ**សុម៉ាអ៊ី**ប្រើទាហានចេញច្បាំងសោះ តាំងពីនោះមកជាយូរថ្ងៃ ទើបឲ្យយកសំពត់ទ្រនាប់ក្នុងស្បែកជើងស្រីទៅច្រកក្នុងហិប ហើយដាក់សំបុត្រមួយច្បាប់បញ្ចុះទៅជាមួយ ទាហានរែកយកទៅឲ្យ**សុម៉ាអ៊ី**ក្នុងបន្ទាយ។ **សុម៉ាអ៊ី**ឲ្យបើកហិបមើលឃើញសំពត់កំណាត់ និងសំបុត្រនោះមកបើកមើលឃើញសេចក្ដីថា **សុម៉ាអ៊ី**ជានាហ្មឺនមានបណ្ដាស័ក្តិខ្ពង់ខ្ពស់ មានឧត្តុង្គឧត្តមក្នុងស្រុកឡុកអៀង លើកកងទ័ពមកធ្វើសង្គ្រាមនឹងយើង ហេតុម្ដេចទើបស្ងៀមនៅតែក្នុងបន្ទាយឲ្យយូរម្ល៉េះ មិនឃើញច្បាំងឲ្យដឹងកម្លាំងថ្វីដៃគ្នាហើយដឹងតម្រិះប្រាជ្ញា ធម្មតាជាជាតិទាហាន ហើយមិនបានចេញមុខពីក្នុងបន្ទាយដូច្នេះ ឧបមាបីដូចសំពត់ទ្រស្បែកជើងនៅក្នុងស្បែកជើងរបស់ស្ត្រីដូចន័យសំពត់កំណាត់ដែលយើងឲ្យមកនេះ ដែលយើងធ្វើរបស់នេះមក គឺប្រាថ្នានឹងចង់ឲ្យ**សុម៉ាអ៊ី**អាប់យសចំពោះមុខកូនទាហានទាំងពួង បើជាមនុស្សស្រឡាញ់មុខក្រសួងគង់ចេញច្បាំងនឹងយើង។

**សុម៉ាអ៊ី**ឃើញដូច្នោះ ក៏ឲ្យនឹកខឹងក្នុងចិត្ត តែប្រើអាការៈយ៉ាងស្និទ្ធ ធ្វើជាអស់សំណើចហើយសរសើរ**ខុងបេង**ថាមានសតិបញ្ញា ទើបឲ្យជប់លៀងអាហារបម្រើនោះតាមសមគួរ ហើយចាត់សំពត់សាច់ឧត្តមជាបំណាច់ថែមទៀត **សុម៉ាអ៊ី**ក៏នៅផ្ទៀតសួរអ្នកកាន់សំបុត្រនោះថា សព្វថ្ងៃនេះ **ខុងបេង**លើកមកធ្វើសឹកសង្គ្រាមនៅដេកស៊ីជាប្រក្រតីទេឬ? ម្យ៉ាងទៀតបានឲ្យកំជាប់កំជាត្រួតត្រាសេនាទាហានព្រមព្រៀងទេឬប្រការម្ដេច? បម្រើនោះឆ្លើយថា តាំងពីមហាឧបរាជលើកកងទ័ពមកនេះ នឹងពិសាអាហារចំណីក៏បានដោយតិច នឹងសម្រាន្តក៏មិនដូចប្រក្រតីធម្មតា ព្រោះរវល់តែត្រួតត្រាសេនាទាហានឲ្យរក្សាបន្ទាយជាការធំ **សុម៉ាអ៊ី**តបថា ដែល**ខុងបេង**គិតធ្វើការសង្គ្រាមដូច្នេះ ឃើញថាមានសេចក្ដីនឿយព្រួយលំបាកពេកណាស់ ធម្មតាមនុស្សដែលហត់នឿយដូច្នេះរមែងមានអាយុនោះខ្លី ដូច**ខុងបេង**សព្វថ្ងៃមុខជាឆាប់ស្លាប់ប្រាកដ យើងគិតទៅគួរឲ្យកំណាត់ចិត្តព្រួយដែរ ព្រោះឃើញថាបើអត់ពី**ខុងបេង**ទៅ ការដែលនឹងនៅធ្វើសង្គ្រាមនឹងអ្នកឯទៀត ក៏មិនសូវប្រឹតប្រៀនឲ្យសប្បាយបាន។

បម្រើនោះបានស្ដាប់ព័ត៌មានគ្រប់ប្រការ ក៏លា**សុម៉ាអ៊ី**ត្រឡប់មកវិញ ទើបចូលទៅជម្រាប**ខុងបេង**ថា **សុម៉ាអ៊ី**មើលសំបុត្រហើយសើចមិនបានជាខឹងសម្បារណាទេ ហើយក៏ពណ៌នាសេចក្ដីតាមសម្ដី**សុម៉ាអ៊ី**ថានោះ ឲ្យ**ខុងបេង**ស្ដាប់គ្រប់ប្រការ។ **ខុងបេង**ឮហើយឆ្លើយថា **សុម៉ាអ៊ី**មានសតិបញ្ញាកន្លង ដឹងសុខទុក្ខរបស់យើងទាំងអស់។ **អៀវហ៊្វ**និយាយនឹង**ខុងបេង**ថា ប្រសាសន៍គិតធ្វើការទាំងម្ល៉េះ ឃើញថាបានសេចក្ដីហត់នឿយព្រួយលំបាកពេកណាស់ ព្រោះយកញើសតាងទឹកអត់ដំណេកស្រេកបង្ហុយទាល់តែស្គមថមថយកម្លាំងយ៉ាងនេះ ខ្ញុំបាទយល់ឃើញថាគង់ត្រូវដូចពាក្យ**សុម៉ាអ៊ី**ថាមិនខុស។

**ខុងបេង**ឮដូច្នោះក៏យំស្រក់ទឹកភ្នែកហើយតបថា សព្វថ្ងៃនេះយើងមិនមែនមិនដឹងទេ ដែលយើងធ្វើនេះ ព្រោះគិតឃើញដល់គុណព្រះចៅ**ឡៅពី** បើនឹងលះបង់សោះក៏នឹងរកនរណាជាជំនួសទុកចិត្តមិនបាន បានជាយើងខំឧស្សាហ៍មកធ្វើការសង្គ្រាមនេះ ប្រាថ្នានឹងប្រាបប្រាមសត្រូវផែនដីឲ្យរាបទាប ដើម្បីនឹងបានទំនុកបម្រុងព្រះចៅ**ឡៅសៀន**ឲ្យបានគង់នៅជាសុខ។ ទាហានទាំងពួងឮដូច្នោះក៏ទប់ទឹកភ្នែកមិនបាន នាំគ្នាយំសោកអាណិត**ខុងេង**គ្រប់ៗគ្នា វេលានេះមុខមាត់**ខុងបេង**ក៏សៅហ្មងស្លក់ស្លាំងមិនសប្បាយសោះ ចេះតែឈឺចុកពោះក្នុងឱរាដូចបន្លាមុតជាប់ជានិច្ច ភ្លេចទាំងគិតការសង្គ្រាមដែលតតាំងច្បាំងនឹង**សុម៉ាអ៊ី**ជាយូរថ្ងៃ។

ឯនាយទាហានធំតូចក្នុងកងទ័ព**សុម៉ាអ៊ី**ដឹងថា **ខុងបេង**ឲ្យសំបុត្រមកជាខ្ទេគោះគំរោះមើលងាយដូច្នោះ ក៏នាំគ្នានិយាយនឹង**សុម៉ាអ៊ី**ថា ប្រសាសន៍ជានាហ្មឺនមានស័ក្តិយសខ្ពស់ធំក្នុងស្រុកហ្លួង ហេតុម្ដេចមកជើងឆ្ងល់នៅស្ងៀម ទុកឲ្យទាហានស្រុកសែឈួន ដែលតូចទាបមើលងាយប្រមាថដូច្នេះមិនគួរសោះ។ យើងខ្ញុំទាំងអស់នឹងសុំអាសាចេញទៅច្បាំងយកជ័យជម្នះ**ខុងបេង**ឲ្យបាន។ **សុម៉ាអ៊ី**តបថា ដែលយើងស្ងៀមនៅដូច្នេះ មិនមែននឹងខ្លាច**ខុងបេង**នោះទេ ព្រោះតែមានតម្រាស់ព្រះចៅ**ចូយ៉យ**ហាមឃាត់ បានជាយើងទ្រាំអត់មិនទាន់ចេញច្បាំង បើអ្នកទាំងឡាយនឹងចង់ចេញតតាំងច្បាំងយកអាសាធ្វើការសង្គ្រាមណាស់ ក៏ត្រូវតែរង់កុំរូតរះពេកឡើយ ចាំយើងនេះហើយនឹងបកសំបុត្រចូលទៅក្រាបទូលសុំអនុញ្ញាតសិន បើទ្រង់ប្រោស

ដោយប្រការយ៉ាងណា សឹមទទួលចាត់ការតាម ហើយ**សុម៉ាអ៊ី**ក៏តែងសំបុត្រចាត់បម្រើសេះឲ្យកាន់ចូលទៅក្រាបបង្គំទូលថ្វាយព្រះចៅ**ចូយ៉យ** ដែលគង់នៅឯស្រុកហាប់ប៉ា។

ព្រះចៅ**ចូយ៉យ**ទទួលសំបុត្រនោះហើយ ក៏បើកទតព្រះនេត្រឃើញសេចក្តីថា ទូលព្រះបង្គំជាខ្ញុំ**សុម៉ាអ៊ី** បានធ្វើការរណរង្គសង្គ្រាមនឹង**ខុងបេង**តាមរឿងហូរហែពីដើមមក ទូលព្រះបង្គំជាខ្ញុំបានយកចិត្តទុកដាក់ចាត់ការតាមព្រះតម្រាស់ ឥឡូវនេះ **ខុងបេង**ឲ្យសំបុត្រមកចំអកឡកទ្រគោះគម្រោះមើលងាយណាស់ ទូលព្រះបង្គំជាខ្ញុំនឹងនាយទាហានក្មេងចាស់ ក៏បានសេចក្តីអប្បយសខ្មាសមុខពួកអ្នកស្រុកសែឈ្លួនពន់ប្រមាណ បានពិគ្រោះប្រឹក្សាគ្នានឹងអាសាចេញតស៊ូនឹង**ខុងបេង**ឲ្យបាន ទើបទ្រង់អនុញ្ញាតប្រោសប្រាណនឹងបានទទួលធ្វើតាម។ ព្រះចៅ**ចូយ៉យ**បានទ្រង់ជ្រាបតាមសេចក្តីសំបុត្រហើយ ក៏ប្រឹក្សានឹងអស់នាហ្មឺនមុខមន្ត្រីថា សំបុត្រ**សុម៉ាអ៊ី**ដែលប្តឹងមកដូច្នេះយល់ឃើញដូចម្តេច? **ឈិនយុន**ទូលថា ដ្បិត**សុម៉ាអ៊ី**និងអស់ទាហានក្នុងកងទ័ពបានសេចក្តីអប្បយសណាស់ ព្រោះ**ខុងបេង**ឲ្យសំបុត្រទៅឡកចំអកបញ្ឈឺចិត្តដែល**សុម៉ាអ៊ី**នៅគិតពុំបានចេញច្បាំងនោះ ព្រោះនៅខ្លាចព្រះតម្រាស់ព្រះចៅ**ចូយ៉យ**ដែលឃាត់ហាម តែអស់ពួកទាហានដែលពុំឃើញបម្រាមចេះតែខឹងក្តៅ ប្រុងតែនឹងចេញច្បាំងតស៊ូនឹង**ខុងបេង**ពេកណាស់ បានជា**សុម៉ាអ៊ី**ធ្វើសំបុត្រពិតទូលចង់ច្បាស់ព្រះទ័យា ប្រាថ្នានឹងឲ្យមានព្រះតម្រាស់តបទៅវិញ តើយ៉ាងម្តេច? ព្រះចៅ**ចូយ៉យ**យល់ឃើញត្រូវ ទើបឲ្យ**ឈិនយុន**កាន់ព្រះតម្រាស់ទៅឲ្យ**សុម៉ាអ៊ី**ថា កុំឲ្យចេញច្បាំង ត្រូវបង្អង់តាំងរក្សាតែបន្ទាយឲ្យមាំសិនចុះ។ **សុម៉ាអ៊ី**ឃើញព្រះតម្រាស់ដូច្នោះ ក៏នាំចេញប្រកាសប្រាប់នាយកងនាយទ័ពថា នេះព្រះតម្រាស់ឲ្យហាមឃាត់ទៀត នោះអស់នាយកងនាយទ័ពក៏ទាល់ស្មៀតនឹងតវ៉ា នាំគ្នាប្រយ័ត្នរក្សាតែបន្ទាយតមក។

**ខុងបេង**ដឹងកិត្តិស័ព្ទថា ព្រះចៅ**ចូយ៉យ**ឲ្យសំបុត្រមកឃាត់ហាម**សុម៉ាអ៊ី**ដូច្នោះ ក៏និយាយនឹងនាយទាហានទាំងពួងថា **សុម៉ាអ៊ី**គិតញញើតខ្លាចយើងណាស់ បានជាយកព្រះតម្រាស់មករារាំងមិនចេញច្បាំងនឹងយើង។ **កៀងអ៊ុយ**សួរ**ខុងបេង**ថា ហេតុម្តេចបានជាប្រសាសន៍ជ្រាបច្បាស់រឿងដូច្នេះ? **ខុងបេង**តបថា យើង

ឃើញដោយហេតុ**ស៊ុម៉ាអ៊ី**មិនចេញច្បាំងនឹងយើងយូរមកណាស់ ច្បាស់ជាគិតខ្លាចយើងក្រែងទាហានទាំងពួងប្រែបែរចិត្តគិតដកឃ្លា បានជាទូលព្រះចៅ**ចូយ៉យ**សូមអនុញ្ញាតចេញច្បាំង ព្រះចៅ**ចូយ៉យ**ត្រឡប់ជាឃាត់ដើម្បីនឹងយកចិត្តទាហានប៉ុណ្ណោះទេ។

ខណៈនោះ **ប៊ីហ៊ុយ**មកពីស្រុកសែឈ្ងួននាំព័ត៌មានមកប្រាប់**ខុងបេង**ថា ព្រះចៅ**ចូយ៉យ**លើកទ័ពជាបីផ្លូវទៅវាយស្រុកកាំងតាំងតាមរឿងនោះឲ្យ**ខុងបេង**ស្តាប់ គ្រប់ប្រការ ហើយឥឡូវកងទ័ពស្រុកកាំងតាំងចាញ់ប្រៀបស្តេច**ចូយ៉យ** ហើយលើកទ័ពត្រឡប់ទៅស្រុកកាំងតាំងវិញអស់ហើយ។ **ខុងបេង**បានដឹងដូច្នោះក៏ស្តុតរន្ធត់ចិត្តស្រែកភ្ញាត់សំឡេងយ៉ាងខ្លាំងហើយដកដង្ហើមធំ ទទួលខ្យល់ដង្ហើមប្រទះគ្នាក៏ចុកស្ទះដួលដុះសន្លប់បាត់ស្មារតី នោះនាហ្មឺនទាហានទាំងពួងក៏ភ័យជ្រួលច្របល់រាល់គ្នាស្ទុះទៅត្រកងគ្រាហ៍លើកឡើងបានដឹងស្មារតី។ **ខុងបេង**ក៏ស្រដីថា រោគយើងបណ្តាលកម្រើកពីរោគចាស់ យើងឃើញច្បាស់ថា អាយុយើងមិនស្ថិតនៅយូរទេ។

លុះវេលាយប់ **ខុងបេង**ឧស្សាហ៍ដើរចេញទៅមើលអាកាស ឃើញផ្កាយសម្រាប់ខ្លួនសៅហ្មងរស្មីខុសនឹងធម្មតា ក៏រឹតតែខ្លោចផ្សាជាទុក្ខខ្លាំងណាស់ ទើបនាំ**កៀងអ៊ុយ**ចូលទៅកាន់ទីដំណេកខាងក្នុងហើយថា នែ៎! អ្នក**កៀងអ៊ុយ** អាយុរបស់យើងនឹងអស់ក្នុងពេលព្រឹកស្អែកនេះហើយ។ **កៀងអ៊ុយ**ឮហើយក៏ភ្ញាក់ស្លុតអស់វិញ្ញាណត្រឡប់សួរភ្លាមទៅវិញថា ហេតុម្តេចបានជាមហាឧបរាជមានប្រសាសន៍ដូច្នេះ? **ខុងបេង**ឆ្លើយថា យើងបានពិគ្រោះមើលមណ្ឌលអាកាស ឃើញផ្កាយសម្រាប់ខ្លួនរបស់យើងវិប្បរិត ទើបមកគិតឃើញថា អាយុយើងនឹងអស់ហើយ។

**កៀងអ៊ុយ**ថា បើដូច្នោះប្រសាសន៍ចូរតែងពលីការបូជាទេវតារំដោះគ្រោះចេញចុះ មុខជាតអាយុទៅមុខបានខ្លះ។ **ខុងបេង**តបថា ធ្វើការពលីការនោះយើងក៏ដឹងខ្លះដែរ តែជាបោរាណកម្មដល់អាយុយើង ហើយយើងក៏ត្រូវតាក់តែងគ្រឿងបូជាសុំកម្លាំងទេវតាឲ្យជួយតាមផលបុណ្យទៅខ្លះ ហើយបង្គាប់**កៀងអ៊ុយ**ថា អ្នកឯងត្រូវចាត់ចែងរើសទាហាន៤៩នាក់ ឲ្យពាក់អាវសពាក់មួកសកាន់ទង់សព័ទ្ធជុំវិញខ្លួនយើង ហើយហាមកុំឲ្យនរណាចេញចូលឲ្យដឹងឃើញជាដាច់ខាត យើងនឹងស្នឹង

ស្នាធន៍ ធ្វើការបរិកម្មនៅក្នុងវាំងននពីពេលកណ្តាលយប់គម្រប់ប្រាំពីររាត្រី បើឃើញគោមយើងសម្រាប់ខ្លួននៅឆេះឆ្អុះមានរស្មីភ្លឺថ្លា យើងក៏នៅមានជន្មាតទៅទៀតបានពីរឆ្នាំ បើឃើញគោមភ្លើងនោះរលត់ យើងក៏អស់ជីវិតផុតជាប្រាកដហើយ។ **កៀងអ៊ុយ**ក៏ចេញទៅចាត់ចែងធ្វើការតាម**ខុងបេង**បង្គាប់គ្រប់ប្រការ។

លុះវេលាយប់ **ខុងបេង**ក៏អុជគោមទុកក្រៅវាំងនន៤៩ដួង អុជក្នុងវាំងននព័ទ្ធជុំខ្លួន៧ដួង ឯគោមធំប្រចាំខ្លួននោះអុជដាក់កណ្តាល ទើបតាំងលាជភ្ញីផ្កា អុជធូបទៀនជុំវិញបូជាតាមតម្រា ហើយ**ខុងបេង**ក៏សូត្រអារាធនាទេវតាថា “បពិត្រទេវតាជាធំ រីខ្លួនខ្ញុំឈ្មោះ**ជូកឺលៀង** គឺ**ខុងបេង** បានតាំងយកកំណើតក្នុងរវាងផែនដីកើតចលាចល ព្រះចៅ**ឡៅពី**មានព្រះទ័យឧស្សាហ៍យាងយាត្រាទៅរកខ្ញុំម្ចាស់បីគ្រា ខ្ញុំអម្ចាស់ក៏មានចិត្តស្នេហាលះបង់ភរិយាបុត្រគេហដ្ឋាន បានចូលមកជួយធ្វើការទំនុកបម្រុងផែនដី ព្រះចៅ**ឡៅពី**មានព្រះទ័យទន់ត្រជាក់ គួរជាទីពឹងពំនាក់អាស្រ័យប្រជាជន ព្រះអង្គក៏ទ្រង់មានព្រះគុណជប់លៀងឲ្យខ្ញុំ លៀងខ្ញុំអម្ចាស់ដល់ខ្នាត កាលព្រះអង្គទ្រង់ទៀបទ្រង់ព្រះសុវណ្ណគត ក៏បានទ្រង់មត់ព្រះវាចាត្រាស់បរិពារ ផ្តាំទុកឲ្យខ្ញុំអម្ចាស់ជួយឧបត្ថម្ភគាំពារការផែនដី ខ្ញុំអម្ចាស់ក៏បានតាំងចិត្តគិតរាជកិច្ច ដើម្បីធ្វើរណរង្គសង្គ្រាមតាមប្រហារបច្ចាមិត្តឥតស្រាក ឥឡូវផលវិបាកកម្មពុំសម្រេចតាមប្រាថ្នា ឃើញដួងតារាជាសម្រាប់រូបខ្ញុំអម្ចាស់នោះសៅហ្មង ឃើញថាជីវិតខ្ញុំអម្ចាស់នឹងលោតឆ្លងមិនរហូតហើយស្រេចនូវទេវតា តែចិត្តខ្ញុំអម្ចាស់មិនអស់សេចក្តីប្រាថ្នា ចង់នៅធ្វើការថ្វាយព្រះមហាក្សត្រតទៅទៀត ហេតុទេវតាឯណាដែលជាញាតិមិត្ត អនុគ្រោះជួយគិតបំពេញកម្លាំង អាយុជីវិតឲ្យខ្ញុំអម្ចាស់ទុកឲ្យទាន់សិនចុះ ខ្ញុំម្ចាស់នឹងបានបណ្តុះបណ្តាលនូវសេចក្តីត្រជាក់ជួយជាទីពឹងពំនាក់ នៃបណ្តារាស្ត្រឲ្យបានសេចក្តីសុខតទៅ” **ខុងបេង**តាំងប្រកាសហើយក៏អង្គុយបរិកម្មអាគមគាថាទាល់តែភ្លឺស្វាង។

លុះព្រឹកឡើង **ខុងបេង**ក៏ចេញនិយាយរាជការ ត្រួតត្រាកំជាប់ទាហានឲ្យរក្សាបន្ទាយ ទទួលពេលនោះ**ខុងបេង**ក្អកធ្លាក់ឈាមស្រស់ៗជាច្រើនគ្រា អស់បណ្តារាជការទាំងពួងក៏ជួយគ្នាកែខៃបានសេចក្តីសុខស្រួល ដល់ពេលយប់**ខុងបេង**ក៏ចូល

ពិធីធ្វើការតាមតម្រា តែដល់ថ្ងៃកាលណា ក៏ចេញនិយាយតាមការប្រក្រតី មិនដែលដាច់ ធ្វើការដូច្នេះបាន៦រាត្រី។

ខណៈនោះ **សុម៉ាអ៊ី**មិនបានឃើញទាហាន**ខុងបេង**ចេញទៅច្បាំងសោះ ជាយូរថ្ងៃណាស់**សុម៉ាអ៊ី**សង្ស័យ។ លុះដល់ពេលកណ្ដាលយប់ជាគម្រប់៧ថ្ងៃនោះ **សុម៉ាអ៊ី**ក៏ចេញទៅមើលមណ្ឌលអាកាសឃើញផ្កាយវិបរិត ក៏មានចិត្តត្រេកអរណាស់ ទើបនិយាយនឹង**ហែហ៊ូប៉ា**ថា ឃើញផ្កាយមហាឧបរាជស្រុកសៃឈ្វនមានរស្មីសៅហ្មង ឃើញថាអាយុ**ខុងបេង**នឹងដល់កំណត់ស្លាប់ឆាប់ហើយ ត្រូវអ្នកឯងនាំទាហានមួយពាន់ទៅប្លន់បន្ទាយ**ខុងបេង**ក្នុងពេលយប់នេះចុះ ហើយឃើញថាបន្ទាយនោះស្ងប់ស្ងាត់ឥតទាហានទេ ឬមានដែរ តែសម្ងំស្ងៀមស្ងាត់ មុខជា**ខុងបេង**ឈឺប្រាកដហើយ ត្រូវអ្នកឯងស្រែកចំអកឲ្យពួកទាហាន**ខុងបេង**ចេញមកច្បាំង លុះយើងដឹងថា**ខុងបេង**ជាប្រការម្ដេចសឹមគិតការតទៅទៀត។ **ហែហ៊ូប៉ា**បញ្ជាទាហានទៅលបមើលពីក្រោយតាមសម្ដី**សុម៉ាអ៊ី**បង្គាប់។

កាល**ខុងបេង**ធ្វើការពលីកម្មគម្រប់៦រាត្រី ឃើញមានរស្មីភ្លើងគោមធំដែលអុជទុកសម្រាប់តអាយុ**ខុងបេង**នោះភ្លឺរុងរឿងស្វាងថៃស ក៏ត្រេកអរណាស់ទាំងអស់គ្នាគិតថា មុខជានឹងតអាយុ**ខុងបេង**នៅបាន ខណៈនោះ**កៀងអ៊ុយ**ក៏នៅត្រួតត្រាទាហានដែលព័ទ្ធវង់៤៩នាក់ ឲ្យចាំមើលមនុស្សកុំឲ្យចេញចូលបាន ហើយ**កៀងអ៊ុយ**ចូលទៅវែកវាំងននមើល ឃើញ**ខុងបេង**សំយាកសក់កាន់គ្របីអង្គុយអានមន្តអាគមគាថា ស្រាប់តែសំឡេង**សុម៉ាអ៊ី**ស្រែកមកថាជាពាក្យទ្រគោះមើលងាយផ្សេងៗ ទើប**កៀងអ៊ុយ**ចេញមកពីខាងក្នុង បង្គាប់ទាហានឲ្យទៅស៊ើបស្ដាប់ការ។

ឯ**អ៊ុយអៀន**បានឮសំឡេងទាហាន**សុម៉ាអ៊ី**ស្រែកឌឺដងឲ្យដូច្នោះ ក៏នឹកខឹងខ្លាំងណាស់ មិនបានដឹងថា **ខុងបេង**តាំងពិធីនៅទីណា ទើបម្នីម្នាបំពានដើរចូលទៅខាងក្នុង ដើម្បីនឹងជម្រាប**ខុងបេង**ឲ្យដឹងការ ទទួលរង្គើគោមសម្រាប់តអាយុ**ខុងបេង**នោះ ភ្លើងក៏រលត់ទៅ **ខុងបេង**ឃើញដូច្នោះក៏ស្លុតវិញ្ញាណចោលគ្របីចេញពីដៃ ស្រែកឡើងដោយសំឡេងខ្លាំងថា សេចក្ដីស្លាប់រូបយើងជាបុរាណកម្មនាំមក

ទាន់ហើយ ទោះបីនឹងចេះរិះគិតប្រការម្ដេចក៏មិនផុតហួសទៅបាន ខ្លួនយើងគ្រានេះមុខជានឹងដល់នូវសេចក្ដីស្លាប់ប្រាកដហើយ។

**កៀងអ៊ុយ**ត្រឡប់ចូលទៅវិញ ឃើញអន្តរាយពិធីដូច្នោះក៏ខឹងណាស់ ហូតគ្រប៉ីចេញយ៉ាងរហ័សនឹងសម្លាប់**អ៊ុយអៀន**។ **ខុងបេង**ស្ទុះពានចេញទៅចាប់ដៃជាប់ហើយឃាត់ថា ដែលអ្នកនឹងសម្លាប់**អ៊ុយអៀន**នោះមិនគួរ ហេតុទាំងនោះពីព្រោះផលកម្មរបស់យើងប្រុងនឹងស្លាប់ ហើយនឹងចៀសមិនផុតទេ ថាហើយ**ខុងបេង**ក៏ក្អួតឈាមទាល់តែសន្លប់នៅទីនោះ។ **កៀងអ៊ុយ, អ៊ុយអៀន**ក៏ជួយគ្រាត្រកង**ខុងបេង**ដឹងស្មារតី។ **ខុងបេង**ក៏និយាយនឹង**អ៊ុយអៀន**ថា **សុម៉ាអ៊ី**ស្មានក្នុងចិត្តថាយើងឈឺចាប់ហើយ បានជាឲ្យទាហានឃ្លាំមើលប្រាថ្នានឹងឲ្យឃើញជាក់ច្បាស់ ហេតុនេះឲ្យអ្នកឯងលើកពលចេញទៅច្បាំងនឹងទាហាន**សុម៉ាអ៊ី** នោះ**អ៊ុយអៀន**ក៏ឡើងសេះនាំទាហានចេញទៅដល់មុខបន្ទាយ។

**ហែហ៊្សឺប៉ា**ឃើញ**អ៊ុយអៀន**បរសេះចេញទៅ ក៏នាំទាហានថយត្រឡប់ទៅបន្ទាយវិញ **អ៊ុយអៀន**ដេញដិតប្រកិតតាមទៅចម្ងាយផ្លូវប្រមាណពីររយសិន លុះមិនទាន់ក៏ត្រឡប់វិលមកវិញ ចូលទៅជម្រាប**ខុងបេង**តាមការ។ **ខុងបេង**ឲ្យ**អ៊ុយអៀន**ទៅនៅរក្សាទីតាមដើម ហើយ**ខុងបេង**ក៏នាំ**កៀងអ៊ុយ**ចូលទៅល្វែងខាងក្នុង ហើយថា ខ្លួនយើងតាំងចិត្តនឹងទំនុកបម្រុងព្រះមហាក្សត្រ តែមិនសមប្រកបតាមសេចក្ដីប្រាថ្នា ព្រោះជីវិតអាត្មានៃយើងនឹងដល់នូវសេចក្ដីស្លាប់ហើយ តែថាយើងនៅមានវិជ្ជានិងតម្រិះចេះដឹងតាមក្បួនតម្រាដែលបានរៀនមក គិតជាតួរអក្សរ ១០ម៉ឺន៤ពាន់១១២តួ គិតជាសេចក្ដី ២៤៥ តម្រេះខាងពិជ័យសង្គ្រាម និងតម្រាមើលឫក្សខាងលើខាងក្រោមសឹងតែនៅក្នុងក្បួនទាំងអស់ យើងពិគ្រោះមើល មិនឃើញមានអ្នកឯណាដែលនឹងមានសេចក្ដីឧស្សាហ៍រៀនតម្រាទាំងនេះបាន ឃើញតែខ្លួនអ្នកមួយដែលមានសតិបញ្ញានឹងរៀនឲ្យចំណានបាន ព្រោះអ្នកមានចិត្តសត្យទៀងត្រង់ទាំងប្រកបដោយសេចក្ដីព្យាយាមជាច្រើន គួរអ្នកនឹងរក្សាតម្រានេះទុករៀនឲ្យបានចំណានចុះ។ **កៀងអ៊ុយ**បានឮដូច្នោះ ក៏ទទួលតម្រានោះទុកហើយអង្គុយយំ។

ទើប**ខុងបេង**យកតម្រានោះមកណែនាំពន្យល់ឲ្យ**កៀងអ៊ុយ**មើល ហើយថា តម្រាក្របឈើនេះរបស់យើងគិតខ្លួនឯង តែនៅមិនទាន់ធ្វើល្បងមើល បើអ្នកយកទៅហើយត្រូវធ្វើមើលឲ្យដឹងចុះ បាញ់ម្តងបានព្រួញដប់។ **កៀងអ៊ុយ**គំនាប់ហើយទទួលទុក។ **ខុងបេង**ថា អ្នកចូរទំនុកបម្រុងផែនដីតាមតម្រានេះចុះ ឯស្រុកសែឈ្នួននោះគ្មានសត្រូវកន្លងចូលទៅធ្វើអន្តរាយបានទេ ព្រោះគយផ្លូវនេះជាច្រកប្រហបភ្នំដាច់ស្រយាលឆ្ងាយណាស់ អ្នកចូររវាំងតែតំបន់អ៊ឹមបេងនោះមួយ ព្រោះទីនោះមានសត្រូវប៉ងនឹងកន្លងចូលទៅធ្វើអន្តរាយតែផ្លូវនោះឯង ហើយ**ខុងបេង**ឲ្យហៅ**ម៉ាតាយ**ចូលទៅខ្សឹបប្រាប់ថា បើយើងស្លាប់ហើយ **អ៊ុយអៀន**នឹងប្រែចិត្តជាក្បត់នឹងព្រះចៅ**ឡៅសៀន**ចូរអ្នកឯងទៅនៅនឹង**អ៊ុយអៀន**ក្នុងបន្ទាយ ហើយរិះគិតកម្ចាត់ចេញឲ្យបាន។ **ម៉ាតាយ**ទទួលបណ្តាំហើយក៏លាចេញទៅនៅនឹង**អ៊ុយអៀន**។

**ខុងបេង**ឲ្យហៅខ្លួន**អៀវងី**ចូលទៅទៀត ហើយប្រាប់ថា ខ្លួនយើងនឹងដល់នូវសេចក្តីស្លាប់ក្នុងគ្រានេះហើយ ឯ**អ៊ុយអៀន**នឹងប្រែក្បត់នឹងព្រះចៅ**ឡៅសៀន** អ្នកឯងចូរយកសំបុត្រនេះទុក ហើយមានការក្រលំបាកវេលាណា ត្រូវឲ្យហែកស្រោមសំបុត្រនេះមើល ហើយត្រូវធ្វើតាមគ្រប់ប្រការ ឯអ្នកដែលនឹងសម្លាប់**អ៊ុយអៀន**មានខ្លួនបម្រុងហើយ **អៀវងី**យំហើយក៏ទទួលសំបុត្រលាចេញទៅ។ **ខុងបេង**បង្គាប់ការស្រេចហើយក៏សន្លប់បាត់ស្មារតីទៅយូរណាស់។ លុះដល់ពេលព្រលប់ទើប**ខុងបេង**ភ្ញាក់ដឹងស្មារតីឡើងវិញ ហើយតែងសំបុត្រសម្តែងពីអាការជំងឺធ្ងន់ ចាត់បម្រើសេះឲ្យចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន**។

ព្រះចៅ**ឡៅសៀន**ជ្រាបសេចក្តីក៏មានព្រះទ័យតក់ស្លុតមហិមា ទ្រង់ចាត់**លីហុក**ជាព្រះរាជបម្រើឲ្យទៅសួរអាការជំងឺ បើ**ខុងបេង**នឹងមានបណ្តាំជាយ៉ាងម្តេចក៏ត្រូវឲ្យចាំពាក្យពេចន៍នោះទៅក្រាបទូលតាមការ **លីហុក**ក៏ថ្វាយបង្គំលាទៅដល់បន្ទាយភ្នំគីសាន់ ហើយចូលទៅសួរ**ខុងបេង**ជម្រាបថា ព្រះចៅ**ឡៅសៀន**ជ្រាបថា ប្រសាសន៍ឈឺធ្ងន់ ព្រះអង្គក៏ទ្រង់មិនសប្បាយព្រះទ័យសោះ ទើបទ្រង់ត្រាស់ប្រើខ្ញុំបាទឲ្យមកសួរ។ **ខុងបេង**ក៏ឆ្លើយថា ខ្លួនយើងនេះតាំងចិត្តគិតថា នឹងនៅធ្វើរាជការតបស្នងឆ្លងព្រះតេជគុណ ឥឡូវឥតបុណ្យវាសនាបានជាធ្វើតាមមិនសម្រេច

មានអកុសលកម្មមកផ្តាច់ឲ្យអស់អាយុក្នុងពេលព្រឹកស្អែកនេះហើយ ខ្លួនអ្នកនៅក្រោយ ក៏ចូរតាំងចិត្តសុចរិតដល់ព្រះមហាក្សត្រ គឺព្រះចៅ**ឡៅសៀន**ជាម្ចាស់ចុះ ឲ្យដូចជាខ្លួនយើង ទោះអ្នកនឹងប្រើមនុស្សធ្វើការអ្វីៗ គប្បីប្រមាណឲ្យស្គាល់ការធ្ងន់ស្រាល ហើយឲ្យស្គាល់តម្រិះប្រាជ្ញាមនុស្សដែលនឹងប្រើទៅធ្វើ ធ្វើការអ្វីគប្បីឲ្យត្រូវនឹងការដែលធ្វើបានសឹមប្រើ ឯការខាងទាហាននិងតម្រាពិជ័យសង្គ្រាមនោះ យើងក៏បានទុកដាក់មុខងារនោះឲ្យ**កៀងអ៊ុយ**ជាស្រេចអស់ហើយ អ្នកឯងចូរវិលត្រឡប់ទៅក្រាបទូលព្រះចៅ**ឡៅសៀន**វិញចុះ ថាយើងមានបុណ្យវាសនាតិចណាស់ វេលានេះនឹងសូមក្រាបថ្វាយបង្គំលាស្លាប់ហើយ ៗយើងនឹងតែងសំបុត្រទៅក្រាបថ្វាយជាក្រោយ **លីហុក**ក៏ត្រឡប់ទៅវិញ។

ក្រោយពីនោះមក **ខុងបេង**ឲ្យទាហានគ្រាប់លើកឡើងរទេះបរចេញទៅមើលត្រួតត្រាការខាងមុខបន្ទាយ ពេលនោះជាទេសកាលរងាណាស់ **ខុងបេង**ក៏កម្រើករោគខ្លាំងឡើង ភ្នាក់ងារក៏ម្នីម្នានាំចូលបន្ទាយ **ខុងបេង**ដកដង្ហើមធំហើយថា ខ្លួនយើងមានចិត្តសត្យទៀងត្រង់នឹងផែនដីណាស់ មិនគួរដល់នូវសេចក្តីស្លាប់សោះ ហេតុព្រោះទេវតាមិនជួយឡើយ ហើយឲ្យហៅ**អៀវងី**ទៅផ្តាំថា ខ្លួនយើងអស់បុណ្យវាសនាហើយ អ្នកឯងហើយត្រូវធំក្នុងកងទ័ព ត្រូវតែគិតកំជាប់ចងចិត្តសេនាទាហានកុំឲ្យបែកចិត្ត ឯ**អងប៉េង, ម៉ាតាយ, លៀវហ្វ៊, ទៀវអេក, ទៀវងី** ទាំង៥នាក់នេះ សុទ្ធតែជាមនុស្សសុចរិតទៀងត្រង់ អ្នកចូរជួយទំនុកបម្រុងឲ្យដូចខ្លួនយើង មួយទៀត បើអ្នកនឹងលើកទ័ពត្រឡប់ទៅវិញ កុំឲ្យបែកការណ៍ជាចលាចល ត្រូវប្រើកលទៅជាប្រក្រតី ទោះបីបើសត្រូវវាដឹងនឹងតាមទៅ ក៏ត្រូវជួយគ្នាវាច្បាំងរាំងកុំឲ្យមានអន្តរាយដល់កងទ័ព ឯ**កៀងអ៊ុយ**សោត គេក៏មានតម្រិះប្រាជ្ញានិងថ្វីដៃខ្លាំងពូកែមែន យើងក៏បានបង្គាប់ការទាំងពួងទុកដាក់ជាស្រេច បើអ្នកធ្វើអ្វី ឲ្យគប្បីប្រឹក្សាពិគ្រោះនឹង**កៀងអ៊ុយ**។ **ទៀវងី**ទទួលបណ្តាំហើយក៏អង្គុយយំដំឱរា។

**ខុងបេង**ឧស្សាហ៍សរសេរសំបុត្រថ្វាយព្រះចៅ**ឡៅសៀន** មានសេចក្តីថា ទូលព្រះបង្គំជាខ្ញុំ**ខុងបេង**សូមក្រាបថ្វាយបង្គំលាព្រះអង្គ សូមទ្រង់ជ្រាប ព្រោះតាំងចិត្តឧស្សាហ៍ធ្វើរាជការថ្វាយតាមសតិបញ្ញារៀងមកពេញកម្លាំង ព្រោះតាំងចិត្តគិត

ឃើញថា ព្រះវររាជបិតារបស់ព្រះអង្គទ្រង់មានព្រះករុណាចិញ្ចឹមរក្សាឱ្យទូលព្រះបង្គំជាខ្ញុំ បានធ្វើធំដល់ត្រឹមនេះ ព្រះករុណាទិគុណាមិនមានទីបំផុត ចិត្តទូលព្រះបង្គំជាខ្ញុំក៏មានវិតក្កនៅ ព្រោះសត្រូវខាងជើងខាងត្បូងក៏ពុំទាន់រាបទាប តែឥឡូវជាកម្មនាំអត្តភាពមកដល់នូវសេចក្ដីស្លាប់ ចិត្តក៏នៅឈឺចាប់គ្រប់វារៈខ្យល់ដង្ហើមចេញចូលនៅឡើយ បើទូលព្រះបង្គំស្លាប់ហើយ សូមព្រះអង្គទ្រង់រក្សានូវសេចក្ដីសត្យពិតធម៌ បម្រុងរក្សាសេនាទាហាននូវអស់អាណាប្រជានុរាស្ត្រ ឱ្យនៅជាសុខក្សេមក្សាន្តតាមបុរាណរាជប្រវេណី សូមកុំឱ្យទ្រង់បង់ទីអំណាត់គិតតែស្ដាប់ពាក្យមនុស្សពាលបណ្ដាលកាចនោះឡើយ បើព្រះអង្គផ្ទង់ព្រះទ័យបានហើយទើបប្រទេសស្រុកនឹងបានសុខប្រក្រតីទៅ ឯក្នុងទីឋានលំនៅនៃទូលព្រះបង្គំជាខ្ញុំនោះមានដើមមនសម្រាប់ចិញ្ចឹមនាងនៅដល់៨០០ដើម ដីស្រែ៥០រ៉ៃ ឯទីស្រែនិងចម្ការមនប៉ុណ្ណោះក៏ល្មមសមគួរដល់ភរិយាបុត្ររបស់ទូលព្រះបង្គំជាខ្ញុំចិញ្ចឹមជីវិតបានហើយ ឯទ្រព្យរបស់ក្រៅពីនោះដែលមាននៅក្នុងផ្ទះទូលព្រះបង្គំទាំងអស់ សូមព្រះអង្គទ្រង់មានព្រះបង្គាប់ឱ្យជញ្ជូនចូលទៅទុកដាក់ក្នុងព្រះឃ្លាំងមហាសម្បត្តិ ជាព្រះរាជទ្រព្យសម្រាប់ចែកចាយឱ្យខ្ញុំរាជការ គឺសេនាទាហានជាដើម។ លុះសរសេរចប់ ក៏ច្រកដាក់ក្នុងស្រោមប្រគល់ទុកឱ្យមនុស្សទំនុកទុកចិត្តបម្រុងនាំទៅថ្វាយ។

ទើប**ខុងបេងផ្ដាំអៀវងី**ថា បើយើងស្លាប់ហើយកាលណា កុំឱ្យបង្គាប់ទាហានមានទុក្ខសោកយំស្រណោះអាឡោះអាល័យកាន់ទុក្ខអ្វីឡើយ ចូរធ្វើកិរិយាព្រងើយកន្តើយដោយប្រក្រតីធម្មតាដូចយើងនៅរស់ កុំឱ្យកិត្តិស័ព្ទនេះខ្ចាយខ្ចរឮទៅដល់ពួកសត្រូវខ្មាំងថាយើងស្លាប់ ឱ្យអ្នកចាត់ការធ្វើមឈូសសម្រាប់ដាក់សពយើងឱ្យអង្គុយ ហើយឱ្យយកអង្ករ៧គ្រាប់សម្រាប់ដាក់ក្នុងមាត់ ហើយឱ្យតាំងគោមភ្លើងមួយអុជតម្កល់ទុកពីក្រោមសពយើង ប្រាថ្នានឹងរក្សាផ្កាយសម្រាប់រក្សាអាយុយើងកុំឱ្យបាត់ទៅ បើភ្លើងគោមនោះរលត់ទៅកាលណា ផ្កាយសម្រាប់អាយុយើងសូន្យបាត់ទៅកាលនោះ បើ**សុម៉ាអ៊ី**មើលផ្កាយយើងមិនឃើញហើយ ក៏អាចដឹងថាយើងស្លាប់ប្រាកដ គង់នឹងលើកទ័ពជាប់តាមទៅធ្វើអន្តរាយដល់កងទ័ពយើងមិនខាន បើ**សុម៉ាអ៊ី**ឃើញផ្កាយយើងនៅលើអាកាសទេ គង់តែមិនអាចលើកទ័ពមកញាំញី អ្នក

ចូរលើកទ័ពត្រឡប់ទៅ បើឃើញ**សុម៉ាអ៊ី**លើកទ័ពជាប់ជិតដោយតាម ចូរអ្នកលើកទាហានវាយញែកជាប៉ែកទប់ខាំងទប់ឲ្យមាំ ហើយយករូបយន្តខ្លួនយើងដាក់ឲ្យអង្គុយលើរទេះបរទៅជាកណ្ដាលពួកទាហាន បើ**សុម៉ាអ៊ី**ឃើញគង់តែនឹងភិតភ័យខ្លាចថយទៅឯង។ **អៀវងី**ក៏ទទួលធ្វើតាមបង្គាប់គ្រប់ប្រការ។

លុះវេលាយប់ **ខុងបេង**ឲ្យទាហានលើកគ្រាប់ចេញទៅទីខាងមុខ ចង្អុលឲ្យទាហានមើលផ្កាយ ហើយថា ផ្កាយដែលនៅជិតទិសពាយ័ព្យនោះឯង គឺជាផ្កាយសម្រាប់អាយុរបស់យើង។ ទាហានទាំងពួងមើលទៅឃើញផ្កាយសម្រាប់អាយុ**ខុងបេង**អន់ស្រអាប់រស្មី មើលទៅបីដូចជានឹងធ្លាក់ចុះមកពីលើអាកាសវេហាស៍ **ខុងបេង**ក៏ឲ្យទាហានលើកគ្រាប់ចូលទៅខាងក្នុង វេលានោះ**ខុងបេង**ក៏ភ្លឹកស្មារតីនិយាយមិនរួច អស់ចៅភ្នាក់ងារនិងបណ្ដានាយទ័ពនាយកងទាំងពួងឃើញដូច្នោះ ក៏ភ័យជ្រួលច្របល់វាល់គ្នា ទទួល**លីហុក**ជារាជបម្រើមកដល់ពីស្រុកសែឈ្វន ចូលទៅឃើញ**ខុងបេង**និយាយមិនចេញសោះ ក៏នាំគ្នាយំសោកស្រណោះអាល័យ **លីហុក**ថា ខ្លួនខ្ញុំគ្មាននិស្ស័យបានជាមកមិនទាន់ ឃើញថាវេលានេះអស់បានឮពាក្យសំខាន់ក្នុងបណ្ដាំនាំទៅក្រាបបង្គំទូលព្រះចៅ**ឡៅសៀន**ហើយ ទេវតាអើយ! សូមឲ្យលោកមកជួយមហាឧបរាជផងចុះ។ ខណៈនោះ **ខុងបេង**ក៏បានភ្ញាក់ស្មារតីដឹងខ្លួនប្រាណបានប្រែខ្លួនបើកភ្នែកឡើងឃើញ**លីហុក** ក៏និយាយថា យើងដឹងថាអ្នកត្រឡប់ទៅមុននោះ មុខជាព្រះចៅ**ឡៅសៀន**ត្រាស់ប្រើឲ្យវិលមកទៀត។

**លីហុក**ឆ្លើយតបថា សេចក្ដីទាំងពួងដែលលោកមានបណ្ដាំហើយនោះ ខ្ញុំបាទក៏បានក្រាបទូលអស់ហើយ ឥឡូវនៅឡើយចេះតែទ្រង់ព្រះវិតក្កព្រួយព្រះទ័យដោយសេចក្ដីមួយខថា បើអត់ពីប្រសាសន៍ទៅហើយ គួរនឹងតាំងនរណាឲ្យធ្វើមហាឧបរាជជំនួសប្រសាសន៍បាន? **ខុងបេង**តបថា បើយើងអនិច្ចកម្មទៅត្រូវតាំងឲ្យ**ជៀវអ្អួន**ធ្វើឧបរាជជំនួសយើងចុះ។ **លីហុក**សួរថា បើអត់អំពី**ជៀវអ្អួន**ទៅ ប្រសាសន៍យល់ថាគួរតាំងនរណាជាមហាឧបរាជជំនួសវិញ? **ខុងបេង**ឆ្លើយថា ត្រូវតាំងឲ្យ**ប៊ីហ៊ុយ**ជាជំនួស**ជៀវអ្អួន**។ **លីហុក**សួរថា ចុះបើអត់ពី**ប៊ីហ៊ុយ**ទៅទៀត តើនឹងតាំងនរណាទៅជំនួស? ទទួល**ខុងបេង**ដាច់ខ្យល់ផុតជីវិតក្នុងខណៈនោះតែម្ដង។ កាល**ខុងបេង**

ទទួលអនិច្ចកម្មនៅថ្ងៃ៨រោចខែភទ្របទ កំណត់អាយុបាន៥៤ឆ្នាំ ព្រះចៅ**ឡៅសៀន**សោយរាជបាន១២ឆ្នាំ (ព.ស ៧៧៧)។

ក្នុងខណៈនោះ កងទ័ព**ខុងបេង**ឲ្យបង្កើតសេចក្តីវិប្បយោគស្ងួតស្ងប់ទូទៅទាំងបន្ទាយ ព្រះពាយក៏បណ្តាលបោកបក់ធ្លាក់ចុះមក មេឃអាកាសងេរងាស ពពកអួរអាប់ងងឹតសព្វទិសា បណ្តានាយទ័ពនាយកងនិងទាហាននានា ដែលបានដឹងសេចក្តីច្បាស់ហើយ ឲ្យតក់ស្លុតរន្ធត់វិញ្ញាណ មនុស្សម្នាទាំងប៉ុន្មានក៏នាំគ្នាទួញយំដំឱរា រួចក៏ហាមឃាត់គ្នាឲ្យស្ងៀមស្ងាត់បាត់យំសោកាទៅវិញ។ **កៀងអ៊ុយ** និង **អៀវងី**ក៏ចាត់ការរៀបសពតាមទម្លាប់ទំនៀម និងធ្វើតាមបណ្តាំដែល**ខុងបេង**ផ្តាំទុកនោះគ្រប់ប្រការ ហើយក៏ត្រួតត្រារៀបចំពលទាហាននឹងលើកកងទ័ពត្រឡប់ទៅក្រុងសែឈួនវិញ រៀបឲ្យកងក្រោយបណ្តោយទៅជាកងមុខ។

ឯ**សុម៉ាអ៊ី**នោះ លុះដល់ពេលកណ្តាលអាធ្រាត្រយប់ស្ងាត់ដែល**ខុងបេង**ស្លាប់នោះ ក៏ចេញទៅមើលផ្កាយឃើញផ្កាយសម្រាប់**ខុងបេង**មហាឧបរាជស្រុកសែឈួនក្រហមជាពណ៌ឈាមធ្លាក់ចុះមកកណ្តាលបន្ទាយ**ខុងបេង**ដល់បីដង ហើយត្រឡប់ឡើងទៅតាំងនៅទីដដែលវិញ តែរស្មីស្រអាប់មិនដូចប្រក្រតី **សុម៉ាអ៊ី**ក៏គិតថា **ខុងបេង**ស្លាប់ហើយ ទើបមានសេចក្តីសោមនស្សត្រេកអរ គិតនឹងលើកទ័ពទៅវាយបន្ទាយ**ខុងបេង**ក្នុងខណៈនោះ ទើបមករំពឹងគិតថយក្រោយវិញថា ហេតុដែលឃើញនោះនឹងជឿយកជាការពិតពុំទាន់បាន ខ្លាចក្រែង**ខុងបេង**ឃើញថាយើងមិនបានលើកទ័ពចេញច្បាំងជាយូរថ្ងៃមកហើយ ទើបក្លែងធ្វើឧបាយយកទាហានចេញទៅពួនបង្កប់ទុកក្រៅបន្ទាយទេដឹង បានជាឲ្យដុតផ្កាភ្លើងចោល ទម្លាក់ពីលើកំពូលភ្នំគីសាន់ ដើម្បីនឹងឲ្យយើងសម្គាល់ឃើញថា**ខុងបេង**ស្លាប់ទៅហើយ យើងមុខជាមានចិត្តកម្រើកលើកកងទ័ពទៅចោមវាយ ទាហាន**ខុងបេង**នឹងចេញស្កាត់ខ្ទប់ប្រសព្វជាប់ពីក្រោយឲ្យយើងធ្លោះការ។ **សុម៉ាអ៊ី**គិតតាមប្រាជ្ញាឃើញដូច្នោះក៏រង់មិនលើកទ័ពចេញទៅ ហើយតម្រូវឲ្យ**ហែហ៊្វូប៉ា**នាំទាហានប្រមាណ៥០នាក់ ចេញទៅស៊ើបស្តាប់ឲ្យដឹងថា **ខុងបេង**ស្លាប់ហើយឬនៅ? **ហែហ៊្វូប៉ា**នាំទាហានចេញទៅតាម**សុម៉ាអ៊ី**បង្គាប់។

និយាយពី**អ៊ុយអៀន** កាលក្នុងពេលយប់ដែល**ខុងបេង**ស្លាប់នោះ ក៏ដេកមិនឲ្យលក់សោះ យូរបន្តិចក៏លក់ភាំងមួយស្របក់ ស្រាប់តែយល់សប្តិឃើញថាកំបុតក្បាល មានភ្នំសង្កត់ដើមទ្រូងពាប់មកទាំងឆ្វេងស្តាំ **អ៊ុយអៀន**ភ្ញាក់ឡើងក៏គិតសង្ស័យ ទើបស្រាយយល់សប្តិឲ្យ**ទៀវទិត**នាយទាហានស្តាប់។ **ទៀវទិត**ពិគ្រោះមើលឃើញថា យល់សប្តិនេះកាចណាស់ ទើបក្លែងទំនាយថា លោកយល់សប្តិនេះល្អណាស់ ដែលមានភ្នំនោះឧបមាដូចប្លែងខ្លួនបាន ព្រោះជាតិមករនោះក៏មានភ្នំមានឫទ្ធិមានកម្លាំងជាច្រើន ក្នុងរឿងនិមិត្តលោកនេះក៏បីដូចជាមកសម្តែងឫទ្ធិ។ **អ៊ុយអៀន**បានឮដូច្នោះ ក៏មានសេចក្តីត្រេកអរណាស់ថា បើសមប្រកបដូចសេចក្តីទំនាយរបស់អ្នកទាយនេះ យើងនឹងតបគុណឲ្យដល់ខ្នាត។ **ទៀវទិត**ធ្វើជាទទួលពាក្យ ហើយក៏ចេញទៅចាត់ទាហានលើកចេញពីបន្ទាយ ប្រទះគ្នានឹង**ប៊ីហ៊ុយ** ៗក៏ដណ្តឹងសួរថា អ្នកឯងទើបលើកពលចេញមកពីបន្ទាយទេឬ? **ទៀវទិត**ឆ្លើយថា ទើបលើកចេញមកទេ ខ្ញុំមកផៀងចូលទៅក្នុងបន្ទាយ**អ៊ុយអៀន** ៗនិយាយពីយល់សប្តិឲ្យស្តាប់ ហើយ**ទៀវទិត**ក៏ពណ៌នារឿងយល់សប្តិ**អ៊ុយអៀន** និងក្លែងទំនាយនោះឲ្យ**ប៊ីហ៊ុយ**ស្តាប់គ្រប់ប្រការ។ **ប៊ីហ៊ុយ**សួរថា ហេតុម្តេចបានជាអ្នកឯងដឹងថាយល់សប្តិនោះកាច? **ទៀវទិត**ឆ្លើយថា ខ្ញុំឃើញកាចព្រោះអក្សរភ្នំនោះប្រកបត្រូតគ្នាពីរតួ ទើបហៅថាភ្នំ បើនឹងញែកចេញថាមួយតួម្តង មើលថា មិត្តភ្នំធ្វើប្រទូសរ៉ាយ បានជាខ្ញុំក្លែងទំនាយយក-មករ មកប្រៀប ប្រាថ្នានឹងឲ្យ**អ៊ុយអៀន**មានចិត្តកំរើប។

**ប៊ីហ៊ុយ**ក៏រំឮកហាមថា បើដូច្នោះអ្នកឯងមិនត្រូវនិយាយឲ្យនរណាដឹងទេ ហើយ**ប៊ីហ៊ុយ**ក៏វិលទៅបន្ទាយវិញ ចូលទៅរក**អ៊ុយអៀន** ហើយបណ្តេញមនុស្សឲ្យដើរចេញ **ប៊ីហ៊ុយ**និយាយប្រាប់**អ៊ុយអៀន**ថា កាល**ខុងបេង**ទៀបស្លាប់បានបង្គាប់ទុកថា ឲ្យលើកកងទ័ពត្រឡប់ចូលទៅក្រុងវិញ ហើយថា ឲ្យអ្នកលើកទាហានរាំងពីក្រោយ ឥឡូវនាយទ័ពនាយកងទាំងពួងនឹងលើកទៅតាមលំដាប់ អ្នកជានាយក្រោយនឹងឲ្យគេលើកទៅមុន រួចសឹមលើកពលទៅតាមក្រោយគេឬម្តេច?

**អ៊ុយអៀន**សួរថា **ខុងបេង**តាំងនរណាឲ្យធ្វើមេទ័ពធំ? **ប៊ីហ៊ុយ**ប្រាប់ថា **ខុងបេង**តាំងទុកឲ្យ**កៀងអ៊ុយ**និយាយរាជការខាងទាហាន សម្រាប់កេណ្ឌចេញច្បាំង

តាំង**អៀវងី**ឱ្យកាន់អាជ្ញាសិទ្ធិបង្គាប់បញ្ជានាយទាហាន និងទាហានទាំងអស់។ **អ៊ុយអៀន**ថា **អៀវងី**គ្រាន់តែជាមន្ត្រីតូចសោះ ដែលនឹងឱ្យឡើងសក្តិយសកាន់អាជ្ញាសិទ្ធិបង្គាប់បញ្ជាលើនាយទាហាននោះមិនគួរសោះ គួរណាស់ត្រឹមតែឱ្យនាំសព**ខុងបេង**ត្រឡប់ទៅស្រុកប៉ុណ្ណោះ។ ឯខ្លួនយើងនឹងនាំពលទាហានចេញទៅធ្វើការសង្គ្រាមយកសេចក្តីគាប់ប្រសើរទើបគួរប្រពៃ ឯ**ខុងបេង**តែម្នាក់ស្លាប់យ៉ាងនេះ នឹងលះលើកការផែនដីវិលវែរទៅស្រុកនោះមិនត្រូវទេ។ **ប៊ីហ៊ុយ**ថា ពីដើម**ខុងបេង**បានបង្គាប់ទុកថា បើ**ខុងបេង**ស្លាប់ហើយឱ្យលើកទ័ពត្រឡប់ទៅស្រុកសិន ដែលអ្នកនឹងនៅធ្វើការសឹកតទៅនោះ នឹងមិនធ្វើខុសពាក្យបណ្តាំ**ខុងបេង**ទេឬ?

**អ៊ុយអៀន**តបថា ការសឹកគ្រានេះ បើកុំតែបងមិនស្តាប់ពាក្យយើង ៗនឹងធ្វើការជាកលឧបាយផ្សេងៗ មុខជាវាយយកបានស្រុកឡុកអៀងជាស្រេចទៅហើយ ឯខ្លួនយើងក៏ជានាហ្មឺនធំដែរ គឺបានជាមេកងទ័ពមុខ ឥឡូវអត់អំពី**ខុងបេង**ទៅហើយ ដែលនឹងឱ្យយើងធ្វើជាកូនសំពាយនៅចាំការពារពីក្រោយ**អៀវងី**ដូច្នេះ យើងមិនសុខចិត្តធ្វើទេ។ **ប៊ីហ៊ុយ**ថា អ្នកប៉ានការពារណាស់ ខ្ញុំនឹងទៅប្រាប់**អៀវងី**ឱ្យយកត្រាសម្រាប់មុខងារមេកងធំ មកប្រគល់ឱ្យអ្នកវិញទើបសមគួរ ថាហើយក៏លាទៅរក**អៀវងី**ក្នុងបន្ទាយធំ ហើយអធិប្បាយសេចក្តីឱ្យស្តាប់គ្រប់ប្រការ។

**អៀវងី**ឮហើយក៏អស់សំណើចថា **អ៊ុយអៀន**នោះ មហាឧបរាជបានទំនាយទុកថា បើលោកនោះអស់បុណ្យវាសនាទៅកាលណា **អ៊ុយអៀន**ក៏នឹងកម្រើកចិត្តឡើងកាលណោះ ឥឡូវឃើញសមប្រកបដូចមហាឧបរាជថាមិនខុស វេលានេះបើ**អ៊ុយអៀន**នឹងធ្វើប្រការយ៉ាងណាក៏ដោយ តាមតែគំនិតប្រាជ្ញាវាចុះ ទើបឱ្យ**កៀងអ៊ុយ**នាំទាហានលើកចេញទៅជាកងក្រោយប្រយោជន៍នឹងបានការពារខ្មាំងសត្រូវ ហើយអញ្ជើញសព**ខុងបេង**ឡើងកាន់រថ និងលើករូបយន្តឡើងកាន់រទេះ ឱ្យលើកទ័ពដើរជាប្រក្រតីទៅតាមបណ្តាំ**ខុងបេង**។

ឯ**អ៊ុយអៀន**នៅរង់ចាំ**ប៊ីហ៊ុយ**យូរណាស់ ទើបប្រើ**ម៉ាតាយ**ឱ្យឃុំនាំទាហាន ១៥នាក់ជិះសេះទៅស៊ើបស្តាប់ការឱ្យដឹងថា នាយកងណាខ្លះដែលលើកទៅនោះ **ម៉ាតាយ**ត្រឡប់មកប្រាប់**អ៊ុយអៀន**ថា កងទ័ពទាំងអស់នោះបានលើកទៅខ្លះហើយ

**អៀវងី**ឲ្យ**កៀងអ៊ុយ**នាំទាហានលើកទៅជាក្រោយ **អ៊ុយអៀន**បានឮដូច្នោះក៏ខឹងណាស់ថា ដែល**អៀវងី**ឲ្យ**កៀងអ៊ុយ**លើកទៅជាកងក្រោយនោះគឺជាវាបង្អាចមើលងាយ ហើយនិយាយនឹង**ម៉ាតាយ**ថា ដែល**អៀវងី**ធ្វើដូច្នោះ តើអ្នកឯងនឹងជួយយើងឬទេ? **ម៉ាតាយ**ថា ខ្ញុំបាទក៏មានសេចក្ដីខឹងណាស់ដែរ ព្រោះ**អៀវងី**ធ្វើដូច្នេះ ខ្ញុំបាទមិនចូលចិត្តតាំងពីដើមមក វេលានេះខ្ញុំបាទសុំចូលខាងលោក ដើម្បីនឹងបានជួយគ្នានឹងសម្លាប់**អៀវងី**ចេញឲ្យបាន។ **អ៊ុយអៀន**ឮដូច្នោះក៏មានចិត្តត្រេកអរ មិនបានដឹងកល**ម៉ាតាយ** ទើបចាត់ទាហានព្រមគ្នា ហើយក៏លើកច្រូតកាត់តម្រង់ទៅចាំស្ទាក់នៅដើមផ្លូវ បំណងនឹងចាំធ្វើអន្តរាយ**អៀវងី**។

ឯ**ហៃហ៊្វប៉ា**កាលចូលទៅលបស្ដាប់ឃើញដូច្នោះ ក៏ស្រូតទៅប្រាប់**សុម៉ាអ៊ី**ថា ឥឡូវកងទ័ពស្រុកសែឈួនលើកត្រឡប់វិលទៅវិញហើយ **សុម៉ាអ៊ី**ឮដូច្នោះក៏ស្ទុតទន្ទ្រាំជើងហើយថា ឯ**ខុងបេង**នោះមុខស្លាប់ពិតប្រាកដហើយ **សុម៉ាអ៊ី**ក៏ចាត់ទាហានហើយឡើងសេះនាំបុត្រទាំងពីរស្រូតទៅដល់បន្ទាយ**ខុងបេង** ក៏មិនបានឃើញទាហាន**ខុងបេង**ដើរទៅខាងមុខជាច្រើន ស្រាប់តែឮស្នូរផាវនិងស្នូរទាហានស្រែកហ៊ោលើចង្កេះភ្នំរាំងសងខាងផ្លូវ ឯទាហាន**ខុងបេង**ដែលលើកទៅក៏ប្រពាក់ប្រពូននាំគ្នាសាមកក្រោយ **សុម៉ាអ៊ី**ឃើញ**ខុងបេង**កាន់ផ្លិតរោមសត្វបក់នៅលើរទេះឃើញទង់ជ័យចារឹកអក្សរថា “**ខុងបេង**ទ័ព” **សុម៉ាអ៊ី**ភ័យស្លុតចិត្ត ឈប់បង្អង់នៅទីនោះគិតថា **ខុងបេង**មិនមែនដល់នូវសេចក្ដីស្លាប់ទេ ខ្លួនអញនេះមកត្រូវកល**ខុងបេង**ទៀតហើយ ទើបឲ្យថយទ័ពនឹងត្រឡប់មកវិញ។

**កៀងអ៊ុយ**ក៏បរសេះចុះមកពីលើភ្នំហើយស្រែកថា **សុម៉ាអ៊ី**ត្រូវកលមហាឧបរាជហើយនឹងរត់ទៅណាបាន ទាហាន**សុម៉ាអ៊ី**ស្ដាប់ជាក់ក៏ភ័យធ្លាក់ថ្លើមទាំងអស់គ្នា ក៏នាំគ្នាទម្លាក់គ្រឿងសាស្ត្រាវុធពីដៃ ស្ទុះរត់វៃទៅត្រសុករុកពានលើគ្នាជាន់គ្នាស្លាប់ពិការជាច្រើន **សុម៉ាអ៊ី**ក៏បរសេះពុះទម្លាយរត់ត្រឡប់ទៅវិញ ទទួលឮសំឡេង**ហៃហ៊្វប៉ា, ហៃហ៊្វហ៊ុយ** បរសេះមករាំងបីមុខសេះ**សុម៉ាអ៊ី** ហើយថាឈប់នៅសិន **សុម៉ាអ៊ី**ឮដូច្នោះរឹតតែភ័យមួយសាទៀត ទើបគិតថា សត្រូវតាមទៅកាត់យកក្បាលខ្លួនបាន ទើបយកដៃស្ទាបក្បាលមើលក៏មិនដឹងថាខ្លួននៅទេ រឹតតែបង្ខំ

បរសេះរត់ទៅ **ហែហ្វ៊ូប៉ា, ហែហ្វ៊ូហ៊ុយ**ស្រែកថា លោកកុំភ័យខ្លាចអ្វី ទ័ពស្រុកសែឈ្វូនវិលទៅវិញហើយ **សុម៉ាអ៊ី**ស្ដាប់ម្ដងទៀតទើបច្បាស់ស្រឡះស្មារតីជាគ្នាឯងក៏ឈប់នៅ ប្រមូលបានទាហានខ្លះហើយក៏នាំគ្នាចូលទៅក្នុងបន្ទាយវិញ។

លុះកន្លងមកពីរថ្ងៃ មានពួកអ្នកស្រុកនៅទីនោះចូលទៅប្រាប់**សុម៉ាអ៊ី**ថា កងទ័ពស្រុកសែឈ្វូនកាលលើកត្រឡប់ទៅនោះ ខ្ញុំបាទបានឮសំឡេងទ្ហូញយំអឹងកង ឯរទេះដែលដោតទង់សាលាចេញមក មិនមែន**ខុងបេង**ទេ គឺជារូបយន្តទេតើ! គេធ្វើបន្លំប្រាជ្ញានឹងឲ្យលោកខ្លាច ឯ**ខុងបេង**នេះស្លាប់យូរហើយ។ **សុម៉ាអ៊ី**បានឮដំណឹងច្បាស់ដូច្នោះ ក៏ដូចគេភ្ញាក់ខ្លួនទាំងមានអំណរជាទីបំផុតទើបថា យើងបានប្រមាណការមិនខុស ព្រោះយើងបានឃើញថា**ខុងបេង**ស្លាប់ហើយជាប្រាកដ តែនៅមិនទាន់ច្បាស់លាស់ពីថ្ងៃណា ឥឡូវទើបបានដឹងពិត យើងនឹងគិតលើកទ័ពទៅតាមឲ្យទាន់។ ទើប**សុម៉ាអ៊ី**ប្រុងប្រៀបរៀបជាក្បួនទ័ពគ្រប់ៗកង ហើយក៏លើកឆ្លងតាមទៅដល់តំបន់ជ:ង៉ាន់ផោ ឃើញថាមិនទាន់ហើយក៏លើកវិលត្រឡប់មកវិញ ហើយនិយាយនឹងអស់នាយទាហានថា ដែល**ខុងបេង**ស្លាប់ទៅហើយក្នុងវេលានេះ អស់គេយើងទាំងឡាយក៏បានអង្គុយជាសុខ នឹងបានដេកក៏លក់យ៉ាងស្និទ្ធបិទភ្នែកជិត លុះត្រឡប់ទៅដល់ទីបន្ទាយ**ខុងបេង** ក៏ដើរមើលបែបភាពបន្ទាយតូចធំដែល**ខុងបេង**បានតាំងទុកនោះ ឃើញត្រូវតាមរបៀបក្បួនពិជ័យសង្គ្រាម ហើយជាធម្មតាសតិបញ្ញាមនុស្សក្នុងលោកនេះ នឹងរកអ្នកឯណាឲ្យចេះដឹងប្រហែលនឹង**ខុងបេង**នេះគ្មានសោះឡើយ។ ថាហើយ**សុម៉ាអ៊ី**ក៏កំជាប់ទាហាន ឲ្យត្រួតត្រាគ្រប់ទីគយដានច្រើនតំបន់ជាមាំមួនណាស់ ហើយក៏លើកទ័ពត្រឡប់ទៅស្រុកឡុកអៀង។

និយាយពី**អៀវងី, កៀងអ៊ុយ** លុះលើកទ័ពអមសព**ខុងបេង**ទៅដល់តំបន់ចៀងគោជាមាត់ផ្លូវនឹងចូលទៅស្រុកសែឈ្វូន ក៏បញ្ឈប់កងទ័ពហើយប្រាប់រេហ៍ពលទាំងអស់ថា **ខុងបេង**ទទួលមរណភាពហើយ ត្រូវតែយើងទាំងអស់គ្នាស្លៀកពាក់សកាន់ទុក្ខតាមទំនៀម នោះពួកទាហានទាំងអស់ឮដូច្នោះក៏តក់ស្លុតរន្ធត់ស្មារតីដោយសេចក្ដីអាឡោះអាល័យ**ខុងបេង**ណាស់ ក៏នាំគ្នាប្រះប្រាណយំសោកា ខ្លះក៏យកក្បាលបោកខ្ទប់នឹងថ្មសិលាបែកចេញឈាមទៅខ្លះ ខ្លះក៏ដួលសន្លប់សុបសៅនៅទី

នោះច្រើនណាស់ វេលានោះ ស្រាប់តែឮសូសំឡេងទាហានស្រែកហ៊ោគឹកកងឃើញមានពន្លឺភ្លើងឆេះឡើងពីមុខច្រកភ្នំ **អៀវងី**ក៏ចាត់នាយកងធំៗឲ្យស្រួតរូតទៅមើល ហើយមកប្រាប់ថា **អ៊ុយអៀន**លើកទាហានមកចាំស្កាត់ពីមុខច្រើនណាស់។

**អៀវងី**ឮដូច្នោះភ័យណាស់ ហើយនិយាយថា មហាឧបរាជកាលមុននឹងអនិច្ចកម្មបានផ្ដាំទំនាយទុកថា **អ៊ុយអៀន**នឹងចេញជាក្បត់ ឥឡូវក៏ឃើញមែនប្រាកដតាមប្រសាសន៍មហាឧបរាជថា ដែល**អ៊ុយអៀន**មកតាំងទ័ពឈប់ស្កាត់ទ័ពយើងពីមុខដូច្នេះ អស់អ្នករាល់គ្នានឹងយល់ឃើញប្រការម្ដេច? **ប៊ីហ៊ុយ**ឆ្លើយថា ដែលនឹងតតាំងល្បងថ្វីដៃនឹង**អ៊ុយអៀន**នោះ យើងក៏មិនមានត្រូវការកោតញញើតខ្លាចឡើយ តែថាការនោះ យើងត្រូវតែបកសំបុត្រចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន**ឲ្យជ្រាបមុនសិន ដើម្បីនឹងបានការប្រុងប្រយ័ត្នកុំឲ្យធ្លោះការ។ **អៀវងី**ថា ផ្លូវចៅសាននោះកាត់តម្រង់ទៅស្រុកសៃឈ្នួនបាន ហើយក៏តែងសំបុត្របកចាត់បម្រើសេះឲ្យនាំចូលទៅក្រាបទូលថ្វាយ សូមជ្រាបគ្រប់ប្រការ។

ឯព្រះចៅ**ឡៅសៀន** តាំងពីបានជ្រាបដំណឹងថា **ខុងបេង**មានជំងឺឈឺវេលាណា ព្រះអង្គក៏រឹងទ្រង់ព្រះវិតក្កមិនសប្បាយសោះ។ កាល**ខុងបេង**អនិច្ចកម្មនោះ ព្រះចៅ**ឡៅសៀន**ទ្រង់យាងចូលក្រឡាបន្ទំផ្ទុំលក់ស្កល់ ក៏ទ្រង់ព្រះសុបិននិមិត្តឃើញថា ភ្នំកិមពិនលាននោះបណ្ដាលទម្លាយចុះ លុះវេលាព្រឹកឡើងស្ដេចតើនចាកព្រះបន្ទំយាងចេញគង់ក្នុងទីព្រះរាជរោងរម្យ ជួបជុំនាហ្មឺនមុខមន្ត្រី ក៏ទ្រង់ស្រាយព្រះសុបិននិមិត្តឲ្យមន្ត្រីទាំងពួងស្ដាប់ **ចៀវជុយ**ក្រាបទូលថា កាលពីយប់មិញទូលព្រះបង្គំជាខ្ញុំបានឃើញផ្កាយសម្រាប់មហាឧបរាជធ្លាក់ចុះខាងទិសពាយ័ព្យ ទូលព្រះបង្គំជាខ្ញុំឃើញថា នឹងមានភ័យដល់មហាឧបរាជ ដែលព្រះអង្គទ្រង់ព្រះសុបិននិមិត្តនោះក៏ប្រកបសេចក្ដីគ្នាណាស់។ ព្រះចៅ**ឡៅសៀន**បានទ្រង់ជ្រាបដូច្នោះ ក៏រឹងរឹតតែត្រង់ព្រះវិតក្កខ្លាំងណាស់អស់មានសេចក្ដីសប្បាយ។

លុះកន្លងមកប្រាំថ្ងៃ **លីហុក**ចូលទៅក្រាបទូលតាមបណ្ដាំ**ខុងបេង** ដែលបានផ្ដាំទុកគ្រប់ប្រការ ហើយទូលថា ឥឡូវមហាឧបរាជទទួលអនិច្ចកម្មទៅហើយ។ ព្រះចៅ**ឡៅសៀន**ទ្រង់ព្រះសណ្ដាប់ច្បាស់ក៏ភ័យណាស់ត្រាស់ថា ដែល**ខុងបេង**

ទទួលអនិច្ចកម្មនោះ ដូចហាក់ទេវតាតាមប្រហារជីវិតយើងឯង ក៏ទ្រង់ព្រះកន្សែងសោកាត្រាតែដួលសន្លប់ចុះ នោះពួកខន្ទីទាំងពួងក៏នាំគ្នាចូលទៅក្រាប់ត្រកងកែឲ្យដឹងព្រះស្មារតីឡើង ហើយអញ្ជើញព្រះអង្គចូលទៅល្វែងខាងក្នុង ព្រះចៅ**ឡៅសៀន**ក៏មិនបានចេញទ្រង់និយាយរាជការជាច្រើនថ្ងៃ ឯអស់មុខមន្ត្រីទាំងប៉ុន្មាននិងអាណាប្រជានុរាស្ត្របណ្ដាដែលមានក្នុងស្រុកសៃឈួន ក៏សឹងតែមានសេចក្ដីសោកយំស្រណោះអាឡោះអាល័យ**ខុងបេង**ពេញទាំងទីក្រុង។

ឯ**លីងៀម**តាំងពីត្រូវទោសដកហូតងារចេញចាកតំណែងវេលាណា ក៏ដឹងថាខ្លួនប្រព្រឹត្តខុសពិត គិតនឹងតាំងខ្លួនឲ្យល្អឡើងវិញ ដើម្បីនឹងឲ្យ**ខុងបេង**ប្រើប្រាស់តទៅ លុះដឹងថា**ខុងបេង**ទទួលអនិច្ចកម្មហើយ ក៏ឲ្យមានសេចក្ដីស្រណោះអាឡោះអាល័យយំសោកជាទុក្ខណាស់ គិតឃើញច្បាស់ថា បើជាមានមហាឧបរាជទៀតនឹងរើសរកចិត្ត ឬគំនិតមារយាទឲ្យដូច**ខុងបេង**គ្មានឡើង **លីងៀម**គិតហើយក៏រឹតតែកើតទុក្ខទ្រមក្រំគ្រាទៅជាឈឺចាប់ ក៏ធ្វើកាលកិរិយាទៅ។

ខណៈនោះ មានបម្រើសេះនាំសំបុត្រ**អ៊ុយអៀន**ចូលមកក្រាបទូលព្រះចៅ**ឡៅសៀន**មានសេចក្ដីថា **អៀវងី**ចេញជាក្បត់នឹងរាជការដណ្ដើមយកសពមហាឧបរាជទុក ហើយគប់គិតនឹងពួកខ្មាំងសត្រូវ នឹងលើកទ័ពចូលមកធ្វើសេចក្ដីអន្តរាយដល់ស្រុកសៃឈួន ទូលព្រះបង្គំជាខ្ញុំបាននាំទាហានមកស្កាត់នៅមាត់ផ្លូវចៀងតោ។

ព្រះចៅ**ឡៅសៀន**បានជ្រាបដូច្នោះ ក៏ត្រាស់ប្រឹក្សានឹងបណ្ដាមុខមន្ត្រីទាំងពួងថា បើប្រសិនណា**អៀវងី**ជាក្បត់មែន នោះ**អ៊ុយអៀន**ក៏មានថ្វីដៃល្មមតស៊ូគ្នានឹង**អៀវងី**បានណាស់ ហេតុម្ដេចក៏ច្រឡាស់លើកទាហានស្រូតមកស្កាត់ផ្លូវពីមុខវិញដូច្នេះ ម្យ៉ាងទៀតពីដើមនោះ យើងក៏បានឮព្រះក្រសែព្រះវររាជបិតាត្រាស់ថា**ខុងបេង**ទំនាយទុកថា អំណើះតទៅមុខ**អ៊ុយអៀន**នឹងប្រែជាក្បត់ ព្រោះមានលក្ខណៈជាមនុស្សអាក្រក់ប្រាកដណាស់ គិតនឹងឲ្យសម្លាប់ចេញតែរឿយៗ តែហាក់ដោយមានអ្នកឯទៀតឃាត់ឃាំងរាំងរា ព្រោះឃើញថា**អ៊ុយអៀន**មានថ្វីដៃ បានជាអធ្យាស្រ័យទុកប្រើការ ឧបមាដូចជាគឿនកូនទាហានប៉ុណ្ណោះ ដែល**អ៊ុយអៀន**

ពោលទោស**អៀវងី**មកនោះ លុះយើងនឹងជឿធ្វើតាមទៅក្រែង**អៀវងី**នៅជាល្អទេ ក៏នឹងប្រែចិត្តឲ្យគិតត្រឡប់ជាខូចអាក្រក់ទៅវិញ ត្រូវតែយើងនៅគិតគ្នាន់គ្នេរចាំមើលចាំស្តាប់សព្ទដំណឹងឲ្យដឹងពិតសិនចុះ អស់មុខមន្ត្រីក៏យល់ឃើញតាម។

ខណៈនោះ ទទួលមានបម្រើសេះកាន់សំបុត្រ**អៀវងី**ចូលមកថ្វាយព្រះចៅ**ឡៅសៀន** មានសេចក្តីថា កាលមហាឧបរាជនៅមិនទាន់មរណភាពនៅឡើយ បានផ្តាំទុកដរាបថាឲ្យ**អ៊ុយអៀន**លើកទាហានទៅជាកងក្រោយ ក្នុងវេលាដែលនឹងបណ្តោយទ័ពធំវិលមកស្រុកសែឈ្លួនវិញ លុះមហាឧបរាជទទួលអនិច្ចកម្មទៅ**អ៊ុយអៀន**នៅមិនធ្វើតាមសោះ។ វេលាដែលថយទ័ពធំមកនោះ **អ៊ុយអៀន**ត្រឡប់ជាក្បត់នាំទាហានស្រូតទៅស្ទាក់ពីមុខនៅត្រង់ផ្លូវចៀងតោ ប្រាថ្នានឹងដណ្តើមយកសពមហាឧបរាជទៅឲ្យសត្រូវ។ ព្រះចៅ**ឡៅសៀន**ជ្រាបដូច្នោះ ក៏យកសំបុត្រទាំងពីរច្បាប់នោះទៅប្រឹក្សានឹងនាហ្មឺនទាំងពួងថា នរណានឹងឃើញយ៉ាងម្តេច?

**ជៀវអ៊្លួន**ក្រាបទូលថា ឯចិត្ត**អ៊ុយអៀន**នោះជាមនុស្សឫស្យាគ្មានសត្យានុស័ត្យសោះ គិតតែលើកកម្ពស់តាំងខ្លួនជាធំ លុះឃើញ**អៀវងី**បានតាំងជាមេទ័ពក៏មានចិត្តមានះមិនចំណុះចុះចូល បានជាត្រឡប់ប្រែចិត្តគិតក្បត់ ប្តឹងពោលទោសពី**អៀវងី**វិញ ឯ**អៀវងី**នោះពេញជាមនុស្សមានចិត្តស័ត្យទៀងត្រង់ណាស់ បានជាមហាឧបរាជរាប់អានប្រើប្រាស់មកយូរហើយ មិនមានទាស់អធ្យាស្រ័យអ្វីសោះ។ ទូលព្រះបង្គំជាខ្ញុំទទួលធានាខ្លួន**អៀវងី**ថាជាមនុស្សល្អប្រាកដ បើប្រសិនណាជា**អៀវងី**ត្រឡប់ជាក្បត់វិញ សូមឲ្យព្រះករុណាយកខ្លួនទូលព្រះបង្គំជាខ្ញុំព្រមទាំងបុត្រភរិយាទៅប្រហារជីវិតចុះ។

ព្រះចៅ**ឡៅសៀន**សួរថា ដែល**អ៊ុយអៀន**ថាក្បត់ឥឡូវនេះ តើយើងនឹងគិតកម្ចាត់ចេញប្រការម្តេច? **ជៀវអួន**ទូលថា ព្រះអង្គកុំទ្រង់ព្រះវិតក្កឡើយ ជាងារទូលព្រះបង្គំហើយហ្នឹង ព្រោះទូលព្រះបង្គំជាខ្ញុំឃើញថា មហាឧបរាជបានប្រាប់កលឧបាយទុកនឹង**អៀវងី** ឲ្យរិះគិតកម្ចាត់**អ៊ុយអៀន**ចេញជាពិតណាស់។ វេលានោះស្រាប់តែ**ប៊ីហ៊ុយ**ចូលទៅគាល់ព្រះចៅ**ឡៅសៀន** ហើយទូលពីរឿង**អ៊ុយអៀន**ប្រែចិត្តក្បត់នោះថ្វាយទ្រង់ព្រះសណ្តាប់គ្រប់ប្រការ ព្រះចៅ**ឡៅសៀន**ទ្រង់ជ្រាបដូច្នោះ

ក៏ប្រឹក្សានឹងបណ្ដានាហ្មឺនមុខមន្ត្រីទាំងពួង ហើយឲ្យ**តាំងអ៊ុន**ទៅនិយាយបញ្ចុះបញ្ចូលយកចិត្ត**អ៊ុយអៀន**ទុក នោះ**តាំងអ៊ុន**ក៏ថ្វាយបង្គំលាចេញទៅ។

ឯ**អ៊ុយអៀន**នោះ លុះលើកទ័ពទៅតាំងនៅផ្លូវចៀងតោហើយ ក៏លើករំកិលចូលទៅតាំងខ្ជាប់ខ្ជួននៅមាត់ផ្លូវចាំកុក ក៏មានចិត្តគិតត្រេកអរថា គ្រានេះមុខជាសមប្រកបនឹងគំនិតគិតរបស់ខ្លួនជាប្រាកដហើយ។ ខណៈនោះ**អៀវងី**និង**កៀងអ៊ុយ**ក៏ចាត់ប្រើ**ហោប៉េង**ឲ្យនាំទាហានបីរយនាក់នៅប្រចាំការខាងក្រោយ ហើយក៏បង្ខំលើកទ័ពធំនាំសព**ខុងបេង**ច្រូតកាត់ផ្លូវនឹងទៅស្រុកហាន់តុង។ **ហោប៉េង**ក៏នាំទាហាននៅប្រចាំការពីក្រោយទៅ លុះឃើញ**អៀវងី** និង**កៀងអ៊ុយ**លើកទៅផុតតំបន់ចាំកុក ហើយ ក៏ឲ្យទាហានស្រែកហ៊ោឡើងជាទីឡូកបញ្ឈឺចិត្ត**អ៊ុយអៀន** បម្រើល្បាត**អ៊ុយអៀន**ក៏ចូលទៅប្រាប់**អ៊ុយអៀន**ថា **អៀវងី** និង**កៀងអ៊ុយ**នាំសព**ខុងបេង**រត់កាត់ផ្លូវតម្រង់ទៅស្រុកហាន់តុងវិញទៅហើយ **ហោប៉េង**នាំទាហាននៅចាំការពារពីក្រោយ ហើយបង្គាប់ឲ្យទាហានស្រែកហ៊ោកញ្ជ្រៀវចំអកឡកឲ្យថែមទៀត។

**អ៊ុយអៀន**ឮដូច្នោះក៏ខឹងខ្លាំងណាស់ ទើបពាក់ក្រឹសកាន់លំពែងឡើងសេះនាំទាហានស្រូតតាមទៅ **ហោប៉េង**ឃើញ**អ៊ុយអៀន**តាមមកជិតក៏ឈប់ទ័ព ហើយយកស៊ែសេះចង្អុលមុខ**អ៊ុយអៀន**ហើយស្រែកជេរថា មហាឧបរាជទើបអនិច្ចកម្មនៅមិនទាន់ត្រជាក់ខ្លួនប្រាណផង ហេតុម្ដេចឯងមកប្រែចិត្តគិតក្បត់ដូច្នេះ ហើយស្រែកប្រកាសប្រាប់អស់ទាហានដែលមកជាមួយនឹង**អ៊ុយអៀន**នោះថា បណ្ដាពួកអស់អ្នករាល់គ្នានេះ កាលមហាឧបរាជនៅរស់នៅឡើយ លោកក៏មិនដែលធ្វើអ្វីឲ្យទាស់ចិត្តខ្លួនរាល់គ្នា ហេតុអ្វីអ្នករាល់គ្នាមករួមដៃជាមួយនឹងអាក្បត់ដូច្នេះ? ខ្លួនមិនគិតដល់បុត្រភរិយាទេឬ? ចូរអ្នកទាំងអស់គ្នានាំគ្នាចូលទៅទទួលយកបៀវត្សងស្រុកសែឈ្លួនវិញប្រសើរជាងនៅជាមួយនឹងអាក្បត់ ដើម្បីនឹងបានទំនុកបម្រុងបុត្រភរិយាតទៅ។ ទាហានទាំងពួងបានឮដូច្នោះក៏យល់ឃើញត្រូវណាស់ នាំគ្នាក្រឡាស់រត់ចេញពី**អ៊ុយអៀន**អស់ប្រហែលពាក់កណ្ដាល។

**អ៊ុយអៀន**ឮ**ហោប៉េង**ថាដូច្នោះ ថែមទាំងឃើញពួកទាហានរបស់ខ្លួនរត់អស់ទៅច្រើនក៏ឲ្យខឹងក្ដៅណាស់ ទើបបរសេះវាំលំពែងចូលទៅប្រយុទ្ធនឹង**ហោប៉េង**បាន

ដប់ភ្លែង **ហោប៉េង**ទល់កម្លាំងនឹង**អ៊ុយអៀន**មិនបានក៏ញាក់សេះរត់ទៅ។ **អ៊ុយអៀន**បានចំណាប់ក៏បំផាយសេះតាមទៅតែម្នាក់ឯង ទាហាន**ហោប៉េង**ឃើញក៏ព្រួតគ្នាបាញ់ធ្នូចម្រុះមកលើខ្លួនសន្ធឹកណាស់ ក៏ញាក់សេះរត់ថយទៅវិញ ឃើញទាហានរបស់ខ្លួននៅស្ដើងស្ដួចតិចណាស់ក៏រឹតតែខឹង តែប្រឹងធ្វើកម្លាដេញកាប់ទាហានរបស់ខ្លួនស្លាប់អស់ប្រហែលប្រាំបួនដប់នាក់ ទាហានទាំងនោះភ័យខ្លាចក៏ពុំអាចរត់ចេញ **អ៊ុយអៀន**ឃើញ**ម៉ាតាយ**នាំទាហាននៅជាប្រក្រតីក៏ស្រដីថា ខ្លួនអ្នកជាមនុស្សមានចិត្តសត្យត្រង់នឹងយើង បើយើងធ្វើការនេះបានសមប្រកបតាមគំនិតដែលយើងគិតទុកហើយ នឹងឲ្យបំណាច់រង្វាន់អ្នកឲ្យដល់ខ្នាត ហើយក៏នាំ**ម៉ាតាយ**និងទាហានទាំងពួងទៅតាម**ហោប៉េង**ទៅ ចម្ងាយផ្លូវប្រហែលពីររយសិន (៨ គ.ម) លុះមិនទាន់ហើយក៏ឈប់នៅទីនោះ ទើបប្រឹក្សានឹង**ម៉ាតាយ**ថា យើងត្រូវនាំគ្នាទៅចូលនៅធ្វើរាជការខាង**ចូយ៉យ**វិញឬប្រការម្ដេច?

**ម៉ាតាយ**ក្លែងឆ្លើយថា លោកមានប្រសាសន៍នេះមិនគួរទេ ធម្មតាជាជាតិទាហានហើយបើគិតការអ្វីត្រូវគិតឲ្យសម្រេច ទើបនឹងប្រាកដកេរ្តិ៍ឈ្មោះទៅខាងមុខវែងឆ្ងាយ ដូចខ្លួនលោកវេលានេះ ក៏មានថ្វីដៃខ្លាំងពូកែ ទាំងប្រកបដោយសតិបញ្ញាគិតការជ្រៅទូលាយ ក្នុងស្រុកសែឈ្នួនក្ដី ស្រុកហាន់តុងក្ដី នឹងរកនរណាតថ្វីដៃនឹងលោកគ្មាន ខ្ញុំបាទសុំអាសាវាយយកស្រុកសែឈ្នួនឲ្យបានទៀត លោកក៏នឹងបានជាធំ។ **អ៊ុយអៀន**មិនបានដឹងឧបាយសោះ ក៏រឹតតែមានសេចក្ដីរីករាយត្រេកអរទើបនាំគ្នាស្រូតលើកទៅតាំងនៅជិតកំពែងស្រុកហាន់តុង។

ឯ**កៀងអ៊ុយ**ឡើងទៅនៅលើសើនកំពែង ឃើញ**អ៊ុយអៀន**តាំងបន្ទាយនៅជិតជើងកំពែងស្រុកក៏ភ័យណាស់ ទើបប្រឹក្សានឹង**អៀវងី**ថា **អ៊ុយអៀន**មានទាហានតិចទេ តែកម្លាំងថ្វីដៃខ្លាំងពូកែណាស់ ហើយបានទាំង**ម៉ាតាយ**ទុកជាកម្លាំងផង បើដូច្នេះ តើយើងនឹងគិតកម្ចាត់ប្រការម្ដេចទើបបាន? **អៀវងី**ឆ្លើយតបថា មហាឧបរាជបានឲ្យសំបុត្រទុក ហើយផ្ដាំពាក្យជ្រៅទុកទៀតថា ឯ**អ៊ុយអៀន**នឹងប្រែក្បត់ បើវាលើកតាមមកដល់ជើងកំពែងស្រុកហើយ ត្រូវឲ្យយកសំបុត្រនោះមកលាមើលប្រការមួយទៀត លោកបានផ្ដាំប្ដេជ្ញាទុកលើ**ម៉ាតាយ** ៗក៏ទៅនៅជាមួយនឹង**អ៊ុយអៀន**

បំណងនឹងចាំធ្វើការបំផ្លាញវាហើយ ៗ**អៀវងី**ក៏ហែកសំបុត្រនោះមើលឃើញសេចក្តីថា បើឡើងសេះទៅច្បាំងនឹង**អ៊ុយអៀន** សឹមឲ្យបើកស្រោមសំបុត្រជាន់ក្នុងមើលទៀត។

**កៀងអ៊ុយ**ឃើញដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ទើបនិយាយនឹង**អៀវងី**ថា លោកចូរយកសំបុត្រនោះទុកទៅចុះ ខ្លួនខ្ញុំនឹងចេញទៅតស៊ូនឹង**អ៊ុយអៀន**ជាមុន លោកចូរនាំទាហានជូនទៅតាមក្រោយ។ **អៀវងី**យល់ឃើញតាម **កៀងអ៊ុយ**ក៏ឡើងសេះនាំទាហានចេញទៅស្រែកជេរ**អ៊ុយអៀន**ថា កាលមហាឧបរាជនៅរស់នៅឡើយ លោកក៏មិនដែលធ្វើអ្វីឲ្យខ្លួនទាស់តូចចិត្ត ហេតុម្តេចខ្លួនបានជាត្រឡប់ប្រែចិត្តក្បត់ដូច្នេះ? **អ៊ុយអៀន**តបថា មិនមែនជាការងាររបស់ឯងទេ ឯងចូរស្រូតរូតត្រឡប់ទៅប្រាប់**អៀវងី** ឲ្យចេញមកច្បាំងតខ្លួននឹងអញទើបត្រូវ។

*លោកអ្នកអានអាចរកមើលសៀវភៅផ្សេងទៀតតាមរយៈគេហទំព័រ*

www.khmerliterature.wordpress.com

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៧៩

**ចារឹកឡើងទញ្ញដោយ ៖ ឈុល ជាវ៉**

*(តាំងពីព្រះចៅ**ចូសង** តាំង**សុម៉ាអ៊ី**ឲ្យជាទីមហាឧបរាជ **ហែហ៊ួប៉ា**មិនព្រមចំណុះ**សុម៉ាអ៊ី** ក៏កេណ្ឌពលទាហានបានបីពាន់ គិតលើកទៅវាយស្រុកឡុកអៀង **ហែហ៊ួប៉ា**អស់ដៃរត់ទៅចូលព្រះចៅ**ឡៅសៀន**។ **កៀងអ៊ុយ** និង**ហែហ៊ួប៉ា**លើកទ័ពទៅវាយស្រុកអេកជីវ ខូចខាតរេហ៍ពលច្រើនវិលទៅស្រុកហាន់តុងវិញ។ ព្រះចៅ**ចូសង**សោយរាជ្យបានបីឆ្នាំ (ព.ស ៧៩៤) **សុម៉ាអ៊ី**ស្លាប់ ក្រោយពីនោះមួយឆ្នាំ ព្រះចៅ**ស៊ុនគួន**សុគត **ស៊ុនលៀង**រាជឱរសឡើងសោយរាជ្យ ចាត់**ជូកាត់កេក**ជាមេទ័ព លើកទៅវាយស្រុកវុយកុក **ជូកាត់កេក**ជាក្បត់ ព្រះចៅ**ស៊ុនលៀង**ឲ្យសម្លាប់។ **កៀងអ៊ុយ, ហែហ៊ួប៉ា**ច្បាំងនឹងទ័ព**សុម៉ាស៊ូ**)។*

**បន្ទាប់ពីព្រះចៅចូយ៉យ**សុគតទៅ ព្រះចៅ**ចូសង**ជាបុត្រក៏ឡើងសោយរាជ្យសម្បត្តិ។ ព្រះចៅ**ចូសង**ក៏តាំង**សុម៉ាអ៊ី**ជាទីមហាឧបរាជ មានគ្រឿងយសប្រាំបួនយ៉ាងតាមបណ្ដាសក្តិ **សុម៉ាអ៊ី**នៅមិនព្រមទទួលងារ។ ព្រះចៅ**ចូសង**ក៏ប្រគល់ឲ្យទៀតដល់ពីរគ្រា ទើប**សុម៉ាអ៊ី**ព្រមទទួលងារជាមហាឧបរាជ ទើបព្រះចៅ**ចូសង**បង្គាប់**សុម៉ាអ៊ី**និងបុត្រឲ្យនិយាយរាជការក្នុងស្រុក វេលានោះ**សុម៉ាអ៊ី**ក៏ឲ្យស៊ើបរកបក្សពួក**ចូសង**ក្នុងស្រុកនោះឃើញថាអស់ហើយ នៅសល់តែ**ហែហ៊ួប៉ា** ដែលជាសែស្រឡាយនៃ**ចូសង** ៗតាំងឲ្យធ្វើជាចៅហ្វាយស្រុកហងជីវ បានត្រួតត្រានិយាយរាជការលើអាណាខេត្តទាំងពួងដែលត្រូវឡើងខេត្តហងជីវ **សុម៉ាអ៊ី**គិតថា បើប្រសិនណាជា**ហែហ៊ួប៉ា**ដឹងថា**ចូសង**ជាអន្តរាយហើយ វាមិនលែងឡើយនឹងសងសឹកវិញមុខជារេហ៍ពលទាំងពួងនឹងបានសេចក្ដីលំបាក គិតដូច្នោះហើយក៏ចាត់ប្រើ**តាន់ថាយ**ឲ្យកាន់ត្រាព្រះតម្រាស់ចេញទៅយកខ្លួន**ហែហ៊ួប៉ា**។

ឯ**ហែហ៊ួប៉ា**ដឹងខ្លួនថា **ចូសង**មុខជាអន្តរាយហើយ ក៏ឲ្យគិតវិតក្កដល់ខ្លួនឯងណាស់ តែនៅគិតនឹងធ្វើការសងសឹកកែខ្លួន ទើបប្រមូលទាហានបានបីពាន់នាក់ ហើយចាត់ចែងនាយទ័ពនាយកងត្រៀមការ ដែលនឹងលើកទៅវាយស្រុកឡុកអៀង នោះ**គួយហ៊ួយ**ជាចៅហ្វាយស្រុកចាស់ដឹងការ ក៏នាំទាហានស្ម័គ្របក្សពួករបស់ខ្លួនលើកទៅកម្ចាត់**ហែហ៊ួប៉ា**។ **គួយហ៊ួយ**កាន់លំពែងជិះសេះបំផាយចូលទៅស្រែកជេរ**ហែហ៊ួប៉ា**ថា ឯងនេះជាពូជព្រះរាជវង្ស គួរឬមកគិតក្បត់ផែនដី? **ហែហ៊ួប៉ា**ក៏ស្រែកជេរថា ឯងបានពឹងបុណ្យជីដូនជីតារបស់អញ ក៏បាននៅជាសុខដរាបមក អា**សុម៉ាអ៊ី**វាគិតកម្ចាត់**សែចូ**ចេញទាំងអស់ ម៉េចឯងនៅឃើញថាល្អទៀត? ឯងនេះមិនមែនជាបក្សពួកអាក្បត់ទេឬ? **គួយហ៊ួយ**បានឮដូច្នោះក៏ខឹងខ្លាំងណាស់ឡើងជិះសេះវាំលំពែងចូលទៅ **ហែហ៊ួប៉ា**វាំដាវចូលស៊ូគ្នាបានប្រមាណដប់ភ្លែង **គួយហ៊ួយ**ថយកម្លាំងក៏បំផាយសេះរត់ **ហែហ៊ួប៉ា**បានចំណាប់ក៏ដេញជិតតាមទៅ។

ឯ**តាន់ថាយ** ដែល**សុម៉ាអ៊ី**ប្រើឲ្យនាំទាហានកាន់សំបុត្រទៅហៅខ្លួន**ហែហ៊ួប៉ា**ទទួលលើកពលទៅប្រទះក៏ដឹងថា **ហែហ៊ួប៉ា**និង**គួយហ៊ួយ**កំពុងតឫទ្ធិតបះគ្នា ក៏លើកពលយោធាវាយប្រសព្វចូលទៅព្រួតថែមទៀត **ហែហ៊ួប៉ា**ឃើញថានឹងតទល់ពុំឈ្នះ ព្រោះ**តាន់ថាយ**វាយខ្ទប់ពីម្ខាងចូលមកសម្លាប់ពួកពលច្រើនណាស់ ក៏ប្រះត្រឡប់នាំទាហានដែលសល់ពីស្លាប់នោះរត់ចូលទៅស្រុកហាន់តុង ស្វាមីភក្តិចូលធ្វើជាខ្ញុំព្រះចៅ**ឡៅសៀន** ពួកនាយគយក៏ឲ្យល្បាតចូលទៅប្តឹង**កៀងអ៊ុយ**ដែលឈររក្សាស្រុកហាន់តុង។ **កៀងអ៊ុយ**សង្ស័យណាស់ ទើបប្រើទាហានឲ្យចេញទៅដេញដោលយកសេចក្តីពិត លុះបានសេចក្តីពិតហើយក៏នាំ**ហែហ៊ួប៉ា**ចូលទៅជួបនឹង**កៀងអ៊ុយ** ធ្វើសេចក្តីគំនាប់គ្នាហើយ **ហែហ៊ួប៉ា**ក៏យំ ហើយក៏ពណ៌នាហេតុរឿងដែលក្តៅក្រហាយ មិនសប្បាយចិត្តនឹង**សុម៉ាអ៊ី**សម្លាប់**ចូសង**នោះគ្រប់ប្រការ។ **កៀងអ៊ុយ**ស្តាប់ហើយឆ្លើយថា អ្នកមកដោយផ្លូវឆ្ងាយណាស់ ដែលតាំងចិត្តជាស្វាមីភក្តិជាខ្ញុំព្រះចៅ**ឡៅសៀន**គ្រានេះឃើញថាមិនបង់ប្រយោជន៍ទេ ព្រោះព្រះចៅ**ឡៅសៀន**ពេញជាពូជព្រះរាជវង្សក្សត្រ និយាយហើយក៏ហៅ**ហែហ៊ួប៉ា**បរិភោគអាហារតុជាមួយគ្នា ហើយសួរថា **អាសុម៉ាអ៊ី**អាពុកនិងកូនវានិយាយរាជការស្រុក

ទេសនោះ តើអ្នកបានឮវាវិះគិតនឹងធ្វើការជាចម្រូងចម្រាសដល់ស្រុកសែឈ្លូនដែរឬទេ?

**ហែហ្វ៊ីប៉ា**ឆ្លើយថា អាកញ្ញោស់សត្រូវផែនដីនោះ ឥឡូវខ្ញុំឃើញវានៅគិតតែនឹងចេញក្បត់ព្រះចៅ**ចូសង**ដរាប តែនៅមិនទាន់សម្រេចគំនិតរបស់វានោះ ឃើញថាវានឹងគិតការដល់ស្រុកទេសផងមិនទាន់បាន ខ្ញុំសម្លឹងទៅឃើញមនុស្សល្អៗ មានសតិបញ្ញានាំបានពលរេហ៍ច្រើនមានពីរនាក់ បើ**សុម៉ាអ៊ី**ប្រើទៅធ្វើការសង្គ្រាមស្រុកកាំងតាំងនិងស្រុកសែឈ្លូន ក៏គង់នឹងអន្តរាយដោយថ្វីដៃមនុស្សនោះ។ **កៀងអ៊ុយ**សួរថា ទាំងពីរនាក់នោះឈ្មោះអ្វីដែរ?

**ហែហ្វ៊ីប៉ា**ឆ្លើយថា ម្នាក់ឈ្មោះ**ចុងហោយ** ជាបុត្រ**ចុងហ៊ីវ**ពួកស្រុកអេងជីវកាលអាយុបាន៧ខួប បិតានាំទៅគាល់ព្រះចៅ**ចូភី** ។ឲ្យលេងភ្លេងថ្វាយទ្រង់ព្រះសណ្តាប់ **ចុងហោយ**ឆ្លៀវឆ្លាតណាស់ ថាថ្វាយខ្លួនក្នុងមួយរំពេច ព្រះចៅ**ចូភី**ក៏ទ្រង់ប្រោសប្រាណណាស់ លុះធំឡើងបិតាក៏ប្រដៅឲ្យដឹងតម្រាពិជ័យសង្គ្រាម ហើយបានសិក្សាចំណានក្នុងសិល្បសាស្ត្រសម្រាប់ទាហាន កាលព្រះចៅ**ចូភី**ទិវង្គតទៅក៏បានឡើងជាទីពីស្ស៊ូលួងចៅក្រុមអាល័ក្ស រហូតមកដល់ផែនដីព្រះចៅ**ចូយ៉យ** **សុម៉ាអ៊ី** និង**ចៀវចេ**ក៏កោតក្រែងរអែងខ្លាច**ចុងហោយ**ណាស់ នៅមានម្នាក់ទៀតឈ្មោះ**តេងង៉ាយ**ជាបុត្រពួកស្រុកងីអៀង បិតាស្លាប់ចោលពីតូច ចិត្តទាហានហានក្លា ចូលចិត្តចង់ធ្វើមេទ័ពមេកងស្វែងរកវិជ្ជាការពិជ័យសង្គ្រាមស្ទាញស្ទាត់ណាស់ **សុម៉ាអ៊ី**ក៏រាប់អានហើយតាំងឲ្យជាទី**ខាំចាន់កុងជី** ស្រដីត្រួតត្រាលើទាហានទាំងពួងឈ្មោះទាំងពីរនាក់នេះប្រាកដជាមនុស្សស្រស់ស្រួចពិតណាស់។ **កៀងអ៊ុយ**បានឮដូច្នោះក៏អស់សំណើចហើយថា ខ្ញុំពិគ្រោះមើលទៅឃើញថា អាក្មេងទាំងពីរនាក់នោះ ថ្វីដៃវានឹងមកតស៊ូនឹងខ្ញុំមិនបានទេ ថាហើយក៏នាំ**ហែហ្វ៊ីប៉ា**ចូលទៅគាល់ព្រះចៅ**ឡៅសៀន**ក្នុងស្រុកសែឈ្លូន ថ្វាយបង្គំហើយទូលថា **សុម៉ាអ៊ី**វាវិះគិតកម្ចាត់**ចូសង**ចេញ ហើយវានឹងមកធ្វើអន្តរាយដល់**ហែហ្វ៊ីប៉ា** ៗក៏រត់ចូលមកស្វាមីភក្តិថ្វាយខ្លួនជាខ្ញុំព្រះអង្គ ឯព្រះចៅ**ចូសង**ក៏នៅខ្ចីសេចក្តីណាស់ ទូលព្រះបង្គំជាខ្ញុំឃើញ**សុម៉ាអ៊ី**អាពុកនិងកូនវាធ្វើយ៉ាងនេះ នឹងដណ្តើមយករាជសម្បត្តិជាប្រាកដ ទូល

ព្រះបង្គំជាខ្ញុំពិគ្រោះមើលឃើញថា ស្រុកវុយកុកវេលានេះ មុខជានឹងរៀវរោយថយទៅហើយ ទូលព្រះបង្គំជាខ្ញុំរក្សាស្រុកហាន់តុងមកក៏យូរណាស់ហើយ ស្រូវអង្ករស្បៀងអាហារក៏ចម្រើនបរិបូរ ទាំងរេហ៍ពលសេនាទាហានក៏មានកម្លាំងច្រើនណាស់ហើយ ទូលព្រះបង្គំជាខ្ញុំនឹងសុំអាសាចេញទៅវាយយកស្រុកវុយកុកថ្វាយជាព្រះរាជាណាចក្រកខេត្តនៃព្រះអង្គ នឹងតាំងឱ្យ**ហែហ៊ូប៉ា**ជានាយទ័ពមុខចេញទៅធ្វើការ មុខជានឹងសម្រេចតាមប្រាថ្នាជាប្រាកដ។

**ហ៊ុយវុយ**សេនាបតីធំឆ្លើយ **ទៀវអ៊ួន** និង**តាំងអ៊ុន**មានសតិបញ្ញា មានថ្វីដៃច្បាំងខ្លាំងពូកែជាទាហានឯករបស់យើងក៏ស្លាប់អស់ទៅហើយ ក្នុងស្រុកយើងសព្វថ្ងៃនេះអស់មានមនុស្សល្អសោះ នឹងលើកទ័ពទៅក្នុងឥឡូវនេះ ឃើញថាមុខជាមិនសម្រេចការ ហេតុនេះគួរពិចារណាកុំអាលស្រាលរហ័ស ត្រូវតែគិតឱ្យឃើញផ្លូវប្រយោជន៍ច្បាស់ហើយសឹមលើកទៅធ្វើការ។ **កៀងអ៊ុយ**ឆ្លើយថា លោកមានប្រសាសន៍នោះ ខ្ញុំបាទមិនយល់ឃើញផងសោះ ថ្ងៃ យប់ ខែនិងឆ្នាំចេះតែកន្លងលឿនទៅមិននៅបង្អង់ឈប់ឱ្យយើងទេ នឹងរង់រេចាំឱ្យបានការក៏នឹងខូចវេលាទទេទៅ លោកចាំវេលាណាទើបបានការនឹងលើកទៅនោះសោត? **ហ៊ុយវុយ**តបថា បុរាណលោកពោលទុកមកថា មេទ័ពមេកងដែលនឹងគិតធ្វើការសង្គ្រាមនោះ គប្បីឱ្យពិគ្រោះមើលកម្លាំង និងសេចក្ដីត្រិះរិះការ ហើយថ្វីដៃសេនាទាហាន នូវគ្រឿងសាស្ត្រាវុធរបស់ខ្លួន និងសត្រូវ បើមើលទៅឃើញថាមានជ័យជម្នះហើយទើបធ្វើការ បើមិនទាន់ស្គាល់ការស្រាលធ្ងន់ទេ មិនគួរទៅ យ៉ាងដូចអ្នកគិតទៅធ្វើការគ្រានេះ ទោះបីកាលមហាឧបរាជដែលលោកជាមនុស្សមានសតិបញ្ញាស្រួច មានជីវិតរស់នៅឡើយ ក៏លោកមិនទាន់អាចធ្វើទេ។

**កៀងអ៊ុយ**ថា ខ្ញុំបាទនៅក្នុងស្រុកហាន់តុងនោះ ក៏បានពិគ្រោះពួកស្រុកលើក្នុងស្រុកកៀងឃើញថា ឃើញថា មុខជាវានឹងមកចំណុះចុះចូលខ្ញុំបាទទាំងអស់ បើខ្ញុំបាទនឹងលើកទ័ពចេញធ្វើការគ្រានេះ នឹងចេញសំបុត្រឱ្យទៅបញ្ចុះបញ្ចូលពួកស្រុកកៀង គង់នឹងមកចូលពុំខាន ខ្ញុំបាទនឹងដាក់ពួកនោះឱ្យជាទាហានជូន បើនៅមិនទាន់បានស្រុកវុយកុកទេ ក៏គង់នឹងធ្វើអាណាខេត្តទាំងពួងដែលឡើងស្រុកវុយកុក

នោះ ឲ្យនៅក្នុងកណ្ដាប់ដៃខ្ញុំបាទឲ្យបាន។ ព្រះចៅ**ឡៅសៀន**ត្រាស់ថា បើអ្នកនឹងយកអាសាយើងទៅវាយស្រុកវុយកុកគ្រានេះ អ្នកចូរត្រិះរិះឲ្យល្អិតសិន ដើម្បីរៀបបម្រុងជើងការឲ្យសេនាទាហានធ្វើការឲ្យពេញដៃយកជ័យជម្នះឲ្យបាន ទើបនឹងមិនបង់ប្រៀបនឹងសត្រូវ។

**កៀងអ៊ុយ**ក៏ក្រាបបង្គំលានាំ**ហែហ៊្វួប៉ា**ត្រឡប់ទៅស្រុកហាន់តុងវិញ លុះទៅដល់ហើយក៏ចាត់បម្រើឲ្យនាំសំបុត្រចេញទៅបញ្ចុះបញ្ចូលស្រុកកៀង ហើយទើបប្រឹក្សាគ្នាថា យើងនឹងឲ្យ**កុអាន់** និង**លីហ៊ុម** ទាំងពីរនាក់នេះនាំទាហានដប់ប្រាំពាន់លើកទៅវាយ**គួយហ៊្វួយ**ចៅហ្វាយស្រុកអេងជីវ ឲ្យទៅតាំងបន្ទាយនៅភ្នំកុកសាន់ជាពីរបន្ទាយធ្វើការបណ្ដោះអាសន្ន ហើយសឹមយើងលើកទ័ពតាមទៅជាក្រោយ លុះព្រឹក្សាគ្នាហើយទើបចាត់ចែងរៀបចំសេះ និងគ្រឿងសាស្ត្រាវុធស្រូវអង្ករស្បៀងអាហារ ហើយចាត់ការ**កុអាន់** និង**លីហ៊ុម**លើកទ័ពទៅ។ លុះទៅដល់ភ្នំកុកសាន់ក៏ញែកទាហានចេញជាពីរកង ក្នុងមួយកងប្រាំពីរពាន់ប្រាំរយនាក់ តាំងបន្ទាយព័ទ្ធភ្នំកុកសាន់។ **កុអាន់**តាំងនៅទិសខាងកើត **លីហ៊ុម**តាំងនៅទិសខាងលិច។

ទាហានកងក្រវែលក៏ចាត់បម្រើសេះ ឲ្យចូលទៅប្ដឹងដល់**គួយហ៊្វួយ**ថា **កៀងអ៊ុយ**ស្រុកហាន់តុងឲ្យលើកកងទ័ពមកតាំងព័ទ្ធភ្នំកុកសាន់ តាំងបន្ទាយពីរ។ **គួនហ៊្វួយ**ដឹងដូច្នោះ ទើបចាត់បម្រើសេះឲ្យនាំសំបុត្រចូលទៅប្ដឹងជាផ្លូវរាជការដល់ស្រុកឡុកអៀង ឯ**តាន់ថាយ**ដែលកាន់សំបុត្រចេញទៅហៅខ្លួន**ហែហ៊្វួប៉ា** ក៏នៅមិនទាន់ត្រឡប់វិលចូលទៅក្រុងវិញ **គួយហ៊្វួយ**ឲ្យ**តាន់ថាយ**នាំទាហានប្រាំម៉ឺនលើកពលទៅតទល់ ក៏លើកចេញពីបន្ទាយ ឯ**តាន់ថាយ**ក៏ឲ្យទាហានតាំងបន្ទាយព័ទ្ធទុកទាំងពីរបន្ទាយ ហើយបំបែកកងទ័ពឲ្យទៅស្កាត់ដើមផ្លូវកាត់ប្រចាំជូន ឯ**កុអាន់** និង**លីហ៊ុម**នៅបន្ទាយដាច់អស់ស្រូវអង្ករស្បៀងអាហារ។

**គួយហ៊្វួយ**លើកកងទ័ពចេញទៅ ឃើញ**តាន់ថាយ**ព័ទ្ធសត្រូវទុកបានដូច្នោះ ក៏ត្រេកអរណាស់ ទើបចូលទៅក្នុងបន្ទាយហើយនិយាយនឹង**តាន់ថាយ**ថា ពួកសត្រូវនេះដាច់បាយទឹកអស់ហើយ បានអាស្រ័យតែទឹកជ្រោះអូរដែលហូរចុះពីលើភ្នំ បើយើងរិះគិតបិទទប់អូរជ្រោះអស់ហើយ ទឹកក៏ហូរចុះទៅគ្មាន សត្រូវអត់ទឹកហើយ

គង់នឹងថយកម្លាំងចុះ យើងនឹងចូលកាច់យកបន្ទាយក៏សឹងបានដោយងាយ។ **តាន់ថាយ**យល់ឃើញថាត្រូវណាស់ ក៏ប្រមូលទាហានឲ្យទៅបិទមាត់អូរនោះអស់។

**លីហ៊ុម**ឃើញទាហានអត់ទឹកដាច់អស់ ក៏នាំទាហានចេញពីបន្ទាយនឹងទៅដងទឹក ពួកទាហាន**តាន់ថាយ**ក៏លើកគ្នាស្កាត់ផ្លូវ **លីហ៊ុម**ឃើញលើសកម្លាំងនាំទាហានចូលទៅក្នុងបន្ទាយ នោះ**កុអាន់**ឃើញទាហានស្រេកទឹកណាស់ ក៏លើកចេញទៅហើយនាំទាំង**លីហ៊ុម**ឲ្យលើកទៅជាពីរកង បំណងនឹងទៅដងទឹក នោះទាហាន**តាន់ថាយ**វាយស្កាត់ទុកនឹងចេញទៅមិនបាន ក៏នាំគ្នាត្រឡប់មកបន្ទាយវិញ ឯ**លីហ៊ុម**ក៏ប្រឹក្សាថា បើនឹងស្ងៀមនៅដូច្នេះក៏ពុំស្រួល ត្រូវតែនាំគ្នារត់ចេញទៅ។ **កុអាន់**មិនព្រមចេញឆ្លើយថា ដែលនឹងលើកទ័ពត្រឡប់ទៅនោះហើយ បើនឹងនៅដូច្នេះដូចជានាំគ្នាមកស្លាប់អសារឥតការទាំងអស់ បើអ្នកមិនទៅក៏វាហើចុះ យើងត្រូវតែទៅ ថាហើយក៏បបួលទាហានទៅប្រមាណសែសិបនាក់។ លុះវេលាកណ្ដាលយប់ក៏វាយទម្លាយចេញទៅ ទាហាន**តាន់ថាយ**ក៏ចេញស្កាត់ទុក ហើយសម្លាប់ពួកនោះស្លាប់ទាំងអស់។

ឯខ្លួន**លីហ៊ុម**ត្រូវអារុធរបួសពិការជាច្រើនអន្លើរត់ចេញទៅបាន ជិះសេះទៅតាមជើងភ្នំសេសាន វេលាកណ្ដាលយប់ងងឹតខ្លាំងណាស់ មិនដឹងកន្លែងណាមានទឹកផឹកសោះ ព្រោះស្រេកទឹកណាស់ មានលិឍតែជាតិទឹកសន្សើមដែលជាប់នឹងស្លឹកឈើ ស្មៅ អត់អាហារអស់រវាងពីរយប់ពីរថ្ងៃ ទើបទៅប្រទះនឹងកងទ័ព**កៀងអ៊ុយ** ចុះពីលើសេះហើយក៏ចូលទៅរក**កៀងអ៊ុយ** ហើយពណ៌នារឿងរ៉ាវទាំងពួងឲ្យស្ដាប់។ **កៀងអ៊ុយ**ថា មិនមែនថាខ្ញុំនឹងព្រងើយកន្តើយទេ គឺរៀបកងទ័ពហើយស្រូតមក ដែលយូរយ៉ាងនេះព្រោះចាំកងទ័ពស្រុកកៀងមិនឃើញមកឡើយ ថាហើយក៏ឲ្យទាហាននាំខ្លួន**លីហ៊ុម**ទៅរក្សារបួសឯស្រុកសែឈួន។ **កៀងអ៊ុយ**និយាយនឹង**ហែហ៊្វូប៉ា**ថា យើងកំពុងចាំកងទ័ពស្រុកកៀងយូរណាស់ ហើយក៏មិនឃើញមកឡើយ ឥឡូវកងទ័ពដែលឲ្យលើកទៅតាំងនៅទីភ្នំកុកសាន់នោះ មុខជាអន្តរាយនឹងសត្រូវអស់ហើយ យើងនឹងរិះគិតប្រការម្ដេច ទើបនឹងកែយកជ័យជម្នះសឹកសត្រូវបាន?

**ហែហ្វ៊ប៉ា**ថា ខ្ញុំបាទយល់ឃើញថាកងទ័ពស្រុកអេងជីវ លើកចេញទៅព័ទ្ធ**លីហ៊ឹម, កុអាន់**ជាប់ហើយ បើយើងលើកទៅចូលតាមផ្លូវភ្នំងីវថោសាន់ ក្រោយស្រុកអេងជីវវាយចូលទៅ នោះ**គួយហ្វ៊យ, តាន់ថាយ**ក៏នឹងលើកទ័ពត្រឡប់មកតនឹងយើង កងទ័ព**កុអាន់**ក៏មិនបានអន្តរាយ។ **កៀងអ៊ុយ**បានឮដូច្នោះក៏មានសេចក្ដីត្រេកអរពន់ប្រមាណណាស់ថា ដែលអ្នកគិតឧបាយយ៉ាងនេះ ឃើញថានឹងមានជ័យជម្នះជាប្រាកដណាស់ ចូរអ្នកស្រួតរូតគិតលើកកងទ័ពចេញទៅឲ្យទាន់ការចុះ។

ខណៈនោះ **តាន់ថាយ**ប្រឹក្សានឹង**គួយហ្វ៊យ**ថា **លីហ៊ឹម**លួចរត់ចេញខ្លួនទៅបានហើយ មុខជាប្រាប់**កៀងអ៊ុយ** ៗគង់នឹងដឹងដំណឹងថា យើងលើកកងទ័ពមកព័ទ្ធនៅទីនេះ មុខជាលើកទ័ពវាយចូលមកតាមផ្លូវភ្នំងីវថោសាន់ សូមឲ្យអ្នកលើកទ័ពទៅចាំស្កាត់នៅតំបន់ទៀវស៊ីយជាដើម កុំឲ្យប្រចាំជួនបាន ខ្ញុំបាទនឹងលើកទ័ពទៅវាយ**កៀងអ៊ុយ**ដែលវាយសង្គុញចូលមកដល់ភ្នំងីវថោសាន់ បើ**កៀងអ៊ុយ**ដឹងថាយើងស្កាត់កាត់ផ្លូវប្រចាំជួនបានហើយ គង់នឹងមានព្រួយភ័យបែកទៅជាប្រាកដ។ **គួយហ្វ៊យ**យល់ឃើញត្រូវ ក៏លើកទ័ពចេញទៅតាមដែលគិតគ្នា។

វេលានោះ ពួកកងល្បាតចាត់បម្រើសេះឲ្យទៅប្រាប់**កៀងអ៊ុយ**ថា កងទ័ពស្រុកអេងជីវលើកចេញមកច្រើនណាស់ **កៀងអ៊ុយ**ក៏ឡើងសេះកាន់លំពែងស្រួតនាំទាហានចេញទៅតទល់ **តាន់ថាយ**ក្រឡេកឃើញ**កៀងអ៊ុយ**ក៏ស្រែកថា អញដឹងហើយថា ឯងនឹងលើកទ័ពវាងចូលទៅផ្លូវនេះបានជាអញលើកមកចាំទទួល ថាហើយក៏បរសេះរាំដាវចូលប្រយុទ្ធគ្នា **កៀងអ៊ុយ**រាំលំពែងចូលច្បាំងនឹង**តាន់ថាយ**បានបីភ្លែង **តាន់ថាយ**ក៏ប្រះរត់នាំទាហានឡើងទៅលើភ្នំងីវថោសាន់ **កៀងអ៊ុយ**មិនតាមឡើងទៅ តាំងបន្ទាយនៅជើងភ្នំនោះ ហើយទាហានទៅស្រែកជេរបញ្ឈឺចិត្ត**តាន់ថាយ**ឲ្យចុះមកតស៊ូគ្នា **តាន់ថាយ**ក៏លើកទាហានចុះមកតនឹង**កៀងអ៊ុយ**ជាច្រើនវេលាមិនចាញ់មិនឈ្នះ។

**ហែហ្វ៊ប៉ា**និយាយនឹង**កៀងអ៊ុយ**ថា យើងច្បាំងគ្នាក៏ច្រើនវេលាណាស់ ហើយមិនទាន់ចាញ់ឈ្នះគ្នា នឹងនៅយូរណាស់ក៏មិនបាន ក្រែងសត្រូវនឹងគិតកលឧបាយ

ប្រទូសរ៉ាយយើង សុំឲ្យលោកលាទ័ពថយទៅសិនចុះ ដើម្បីយើងនឹងគិតកលឧបាយដទៃយកជ័យជម្នះវិញឲ្យបាន។

មានពួកល្បាតមកប្រាប់ថា **គួយហ៊្វយ**លើកកងទ័ពទៅស្កាត់នៅដើមផ្លូវហើយ មុខជាយើងនឹងបញ្ជូនពួកប្រចាំជូនមិនស្រួលទេ **កៀងអ៊ុយ**ព្រួយចិត្តណាស់ ក៏ឲ្យ**ហែហ៊្វប៉ាំ**រំសាយទ័ពទៅសិន **កៀងអ៊ុយ**ក៏លើកចេញទៅជាក្រោយ។ ឯខ្លួន**តាន់ថាយ**ដឹងថា **កៀងអ៊ុយ**រំសាយទ័ពទៅហើយ ក៏ចាត់មេទ័ពមេកងចេញជាប្រាំកង ឲ្យដេញវាយខ្ទប់ពីក្រោយបណ្តោយទៅម្ខាងមួយកង ឯខ្លួន**តាន់ថាយ**ក៏លើកតាមទៅជាក្រោយ។

ខណៈនោះ **កៀងអ៊ុយ**ក៏នៅរាំងចុងទ័ពពីក្រោយ **តាន់ថាយ**ក៏ពារទម្លាយចូលទៅមិនបានត្រឡប់នាំទាហានរត់ចេញ **គួយហ៊្វយ**ក៏លើកទាហានស្កាត់ ឯ**កៀងអ៊ុយ**ក៏ព្រួតចោមវាយទម្លាយចេញបាន តែទាហាន**កៀងអ៊ុយ**ស្លាប់ច្រើនណាស់ ដែលសល់នៅនោះតិចជាងស្លាប់ទៅទៀត។ **កៀងអ៊ុយ**នាំទាហានទៅប្រទះនឹងកងទ័ព**សុម៉ាស៊្វ** ជាបុត្រ**សុម៉ាអ៊ី**។

កាលដំបូង **កៀងអ៊ុយ**លើកទ័ពទៅវាយស្រុកអេងជីវ ទើប**គួយហ៊្វយ**ឲ្យមានសំបុត្រទៅសុំកងទ័ព **សុម៉ាអ៊ី**ក៏ចាត់**សុម៉ាស៊្វ**ជាបុត្រលើកទ័ពមកជាពលប្រាំម៉ឺន **សុម៉ាស៊្វ**ដឹងថា **កៀងអ៊ុយ**ច្បាំងនឹង**គួយហ៊្វយ**ហើយ ក៏លើកទ័ពទៅស្កាត់នៅដើមផ្លូវ។ **សុម៉ាស៊្វ**នេះទ្រង់ទ្រាយមុខមូល បបូរមាត់ក្រាស់ ស្លឹកត្រចៀកយារធំ ភ្នែកខាងស្តាំមានពកធំទំហំប៉ុនផ្លែប៉ែន មានរោមសែឬហាសិបសសៃ លុះក្រឡេកទៅឃើញកងទ័ព**កៀងអ៊ុយ**លើកមក ក៏ឡើងសេះរាំងារចេញទៅ។

**កៀងអ៊ុយ**ក្រឡេកឃើញខឹងណាស់ស្រែកថា អាក្មេងច្រមក់ប៉ុណ្ណោះ គួរឬអង់អាចមកតនឹងអញ ថាហើយក៏បំផាយសេះចូលទៅប្រយុទ្ធគ្នានឹង**សុម៉ាស៊្វ**បានបីភ្លែង ឃើញលើសកម្លាំងក៏នាំទាហានថយរត់ទៅ **កៀងអ៊ុយ**ក៏នាំទាហានទៅដល់ទីគយហែប៉ែនគួន ដែលជាគយស្រុកសែឈួន ទាហានបើកទ្វារទទួល**កៀងអ៊ុយ**ចូលទៅ ហើយក៏បិទខ្ទាប់ទៅវិញ **សុម៉ាស៊្វ**ត្រឡប់តាមទៅក៏ឲ្យទាហានទម្លាយទ្វារ។ កាល**ខុងបេង**ជិតនឹងស្លាប់នោះ បានប្រដៅទាហានឲ្យរៀនបាញ់ធ្នូសំដៅឈើក្រាស់

មនុស្សម្នាក់បាញ់ម្ដងបានដប់ព្រួញ នោះទាហានដែលនៅលើសេនកំពែងក៏បាញ់ធ្នូចម្រុះបីដូចគ្រាប់ភ្លៀង ត្រូវទាហាន**សុម៉ាស៊ូ**ស្លាប់ច្រើនណាស់ **សុម៉ាស៊ូ**ខូចខាតពលច្រើនណាស់ ក៏លើកថយទ័ពត្រឡប់ទៅវិញ។

ឯ**កុអាន់**ដែលរក្សាបន្ទាយនៅក្បែរភ្នំកុកសាន់ លុះ**លីហ៊ឹម**រត់ទៅហើយ ក៏រង់ចាំមើលកងទ័ពជួនមិនឃើញ ពួកទាហានដាច់ទឹកខ្លាំងណាស់ លុះនឹងហែកទម្លាយចេញក៏មិនរួច ទើបបើកទ្វារបន្ទាយនាំទាហានចេញគំនាប់ចុះចូលនឹង**គួយហ៊្វយ**។ ឯ**កៀងអ៊ុយ**នាំទាហានទៅធ្វើការគ្រានោះ ខូចខាតទាហានច្រើនណាស់ លុះត្រឡប់ទៅស្រុកហាន់តុងក៏ឲ្យសមសែមជួយជុលកំពែង និងសេនបន្ទាយដែលបាក់បែកឲ្យមាំមួនឡើងវិញ។ **សុម៉ាស៊ូ**ក៏លើកទ័ពត្រឡប់ទៅស្រុកឡុកអៀង ហើយចូលទៅប្ដឹងការរាជការដល់បិតា។

គ្រានោះព្រះចៅ**ចូសង**សោយរាជ្យសម្បត្តិបាន១៣ឆ្នាំ (ព.ស៧៩៤) ទទួលដល់ខែភទ្របទ**សុម៉ាអ៊ី**មានជំងឺឈឺធ្ងន់ណាស់ ឃើញថាមិនរស់ហើយ ក៏ឲ្យរកខ្លួន**សុម៉ាស៊ូ**និង**សុម៉ាចៀវ**ជាបុត្រទាំងពីរឲ្យចូលដល់ទីគ្រែដំណេក ក៏និយាយថា បិតាបានជាទីមហាឧបរាជនិយាយរាជការទាំងផែនដី ដោយសត្យ ដោយធម៌ មិនបានគិតវៀចនឹងផែនដី តែមនុស្សខ្លះក្លែងថាបិតាជាក្បត់នឹងផែនដី យើងអាស្រ័យសត្យសុចរិតរក្សាខ្លួនមិនឲ្យអន្តរាយ វេលានេះបិតានឹងស្លាប់ហើយ ត្រូវចៅនៅជាខ្ញុំរាជការតទៅ ចូរតាំងចិត្តសត្យត្រង់ស្វាមីភក្តិនឹងអម្ចាស់ផែនដីឲ្យត្រាតែអស់ជីវិត បើនឹងធ្វើការកុំគប្បីធ្វើចិត្តនោះស្រួលរហ័ស ត្រូវតែរិះគិតឲ្យល្អិតល្អរួចសឹមធ្វើ។ លុះនិយាយផុតពាក្យ **សុម៉ាអ៊ី**ក៏ដាច់ខ្យល់ស្លាប់។ **សុម៉ាស៊ូ, សុម៉ាចៀវ** ក៏នាំសេចក្ដីចូលក្រាបបង្គំទូលព្រះចៅ**ចូសង**ថា **សុម៉ាអ៊ី**ជាបិតាអនិច្ចកម្ម នោះព្រះចៅ**ចូសង**ក៏ត្រាស់បង្គាប់ឲ្យចៅភ្នាក់ងារ រៀបតែងការសពតាមទម្លាប់ទំនៀមមហាឧបរាជ ហើយឲ្យហែសពនោះទៅបញ្ចុះទុកក្នុងស្រុកឡុកអៀង មានចារឹកជាអក្សរទុកតាមប្រពៃណី ហើយតាំង**សុម៉ាស៊ូ**ជាទីសេនាបតីធំ តាំង**សុម៉ាចៀវ**ជាទីទៀវគីសៀងចុងគុន ឲ្យស្ដីរាជការត្រួតត្រាលើនាយទាហានទាំងពួង។

នោះកាលថ្ងៃ១កើត ខែផល្គុនរំលងមួយឆ្នាំទៅទៀត បង្កើតតែហេតុព្យុះធំរលកក្នុងមហាសមុទ្រក៏កម្រើកឡើង ទឹកក៏ជោរជន់ឡើងលិចអស់ស្រុកកាំងតាំងក្នុងស្រុកនោះជម្រៅទឹកប្រហែល៨ហត្ថ ព្យុះក៏បក់ដកយកដើមឈើធំ ដែលដុះនៅក្នុងមុខផ្លូវស៊ិនសិកអណ្តែតឡើងទៅលើអាកាស ហើយដើមនោះក៏ធ្លាក់ចុះមកជិតក្បែរទ្វារស្រុកកាំងតាំង ចុងមុតចុះជាប់ទៅក្នុងដី។ ព្រះចៅ**ស៊ុនគួន**ឃើញប្លែកណាស់ក៏ឲ្យពិភាល់ ព្រោះមិនដឹងជាល្អ ឬអាក្រក់ ព្រះអង្គក៏ជាទុក្ខក្នុងព្រះទ័យត្រាស់ឲ្យហៅ**ជូកាត់កេក** និង**លីតាយ**ជានាហ្មឺនធំទាំងពីរនាក់ឲ្យចូលទៅដល់ទីបន្ទំហើយទ្រង់ក៏ផ្តាំផ្ញើស្រុកទេស និងបុត្រភរិយា ប្រជារាស្ត្រ ហើយក៏សោយទិវង្គតកាលជិតនឹងរលត់ព្រះជន្មនោះ នៅក្នុងខែពិសាខ (ព.ស ៧៩៥) ព្រះជន្ម៧១ឆ្នាំសោយរាជ្យបាន២៤ឆ្នាំ។

**ជូកាត់កេក** និងបណ្តាមុខមន្ត្រីធំតូចទាំងពួង ក៏លើក**ស៊ុនលៀង**ឲ្យសោយរាជ្យសម្បត្តិជំនួសបិតា ព្រះចៅ**ស៊ុនលៀង**ក៏ឲ្យតែងការព្រះសព ហើយហែទៅបញ្ចុះទុកនៅទីតំបន់ទៀវឡេងតាមប្រវេណី ហើយឲ្យចារឹកជាអក្សរថាទីនេះបញ្ចុះព្រះសពព្រះចៅតៃហងតេ។

ខណៈនោះ មានបម្រើស៊ើបការនាំព័ត៌មានទៅប្តឹងដល់**សុម៉ាស៊ូ**ក្នុងស្រុកឡកអៀងថា ព្រះចៅ**ស៊ុនគួន**សុគតហើយ **សុម៉ាស៊ូ**ដឹងដូច្នោះ ទើបប្រឹក្សានឹងអស់នាហ្មឺនមុខមន្ត្រីធំតូចទាំងពួងថា យើងនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំង តើអស់អ្នករាល់គ្នានឹងយល់ឃើញប្រការម្តេច? **ហៅឡូន**ទីប្រឹក្សាថា ដ្បិតវេលានេះមិនទាន់មានឱកាសឲ្យស្រួលសោះ ដែលនឹងលើកទ័ពទៅធ្វើការនោះ ព្រោះស្រុកកាំងតាំងមានទន្លេសមុទ្របាំងនៅទីរបាំង បើនឹងលើកទ័ពទៅធ្វើការសង្គ្រាមក៏វាយពុំបាន បើដូច្នេះហើយបានជាខ្ញុំបាទយល់ឃើញថា បើលើកទ័ពទៅធ្វើការវេលានេះក៏មិនបានទេ ព្រោះស្រុកទេសរបស់នរណាៗក៏ដោយ ត្រូវតែត្រួតត្រារក្សារៀងខ្លួនប្រសើរជាង បើមានចន្លោះស្រួលវេលាណា សឹមលើកទ័ពទៅវាយយកជ័យជម្នះតែម្តង។ **សុម៉ាស៊ូ**ថា ដែលនឹងបង្អង់រង់ចាំឲ្យមានចន្លោះឱកាសនោះដឹងជាយ៉ាងណាអាយុសង្ខាររបស់យើងនឹងឃឺននៅបានប៉ុន្មានរយឆ្នាំ ទើបនឹងមានចន្លោះឱកាស?

**សុម៉ាចៀវ**ជាប្អូន**សុម៉ាស៊ូ**ថា **ស៊ុនគួន**ស្លាប់ហើយឬ បានជា**ស៊ុនលៀង**សោយរាជសម្បត្តិជួសបិតា អាយុក៏នៅក្មេង ខ្លីទាំងសេចក្តីគិត បើយើងនឹងលើកទ័ពទៅធ្វើការសង្គ្រាមឃើញនឹងបានតែម្តង។ **សុម៉ាស៊ូ**យល់ត្រូវផង ទើបប្រើឲ្យ**អងសង**ជានាយទាហានធំនាំទាហានដប់ម៉ឺន ឲ្យ**ប៊ូឃីវខៀម**នាំទាហានដប់ម៉ឺន ឲ្យ**សុម៉ាចៀវ**ជាប្អូនជាមេកងធំ លើកទៅវាយស្រុកកាំងតាំង។ កាលលើកទ័ពទៅគ្រានេះក្នុងខែកត្តិក លុះលើកទៅដល់ដែនស្រុកកាំងតាំងហើយ **សុម៉ាចៀវ**ក៏ឲ្យប្រមូលនាយទ័ពនាយកងទាំងពួងចូលទៅប្រឹក្សាថា អាណាខេត្តស្រុកកាំងតាំងទាំងពួងមាំមួនណាស់ ពីត្រឹមស្រុកតាំងហ៊ិន ព្រោះមុខស្រុកនោះមានប៉មកំពែងធំ ជាទីប្រដាប់ខ្ទប់ទាំងសងខាងឆ្វេងស្តាំ ដែលនឹងកាច់ចូលទៅនោះកម្រណាស់ យើងត្រូវតែរៀបចំចាត់ចែងឲ្យស្រួលបួល ថាហើយក៏បង្គាប់ឲ្យ**អងសង**និង**ប៊ូឃីវខៀម**ទាំងពីរនាយ ឲ្យនាំទាហានម្នាក់បីម៉ឺនជាប៉ែកឆ្វេងស្តាំ ហើយផ្តាំថា កុំអាលឲ្យលើកវាយ ត្រូវឲ្យចាំកងទ័ពហ្លួងទ័ពមុខ និងទ័ពឆ្វេងស្តាំលើកទៅព្រមហើយ សឹមឲ្យជួយគ្នាវាយប្រសព្វតែម្តង ហើយឲ្យ**អាវជុន**ជានាយនាំពលប្រាំម៉ឺន ហើយបង្គាប់ថា អ្នកលើកទៅដល់មាត់កំពង់ហើយឲ្យសាងស្ពានផែឆ្លងទន្លេទៅបាន ហើយក៏ញែកទាហានចេញជាពីរកងស្រួតវាយយកប៉មឆ្វេងស្តាំ បើវាយបានហើយនឹងបានសេចក្តីគាប់ប្រសើរណាស់ នោះ**អាវជុន**ក៏លើកទៅ។

ឯ**ជូកាត់កេក**ស្រុកកាំងតាំងដឹងថា **សុម៉ាចៀវ**ស្រុកវុយកុកលើកទ័ពទៅ ក៏ឲ្យប្រជុំនាហ្មឺនមុខមន្ត្រីធំតូចនិងទីប្រឹក្សាទាំងពួងចូលទៅព្រមគ្នា ហើយនិយាយថា **សុម៉ាចៀវ**លើកទ័ពមកគ្រានេះ នឹងបាននរណាចេញទៅតទល់? **តេងហង**នាយទាហានធំឆ្លើយថា ស្រុកតាំងហ៊ិននោះជាកម្លាំងស្រុកកាំងតាំង ទាំងស្រូវអង្ករស្បៀងអាហារក៏បរិបូរ ហើយមានប៉មបន្ទាយមាំមួនជាទីស្រួលណាស់ បើស្រុកតាំងហ៊ិនខូចហើយ ឃើញថាប៊ូអៀងក៏ជាអន្តរាយ គួរយើងនឹងរក្សាស្រុកតាំងហ៊ិនទុកឲ្យមាំមួនចុះ។

**ជូកាត់កេក**ឆ្លើយថា អ្នកនិយាយនោះត្រូវណាស់ អ្នកចូរធ្វើមេទ័ពទឹកនាំពលបីពាន់លើកចេញទៅ។ **លីគី, តងជូ, ឡៅបៅ** នាយទាហានទាំងបីនាក់នេះ នាំ

ទាហានម្នាក់មួយម៉ឺន ជាមេទ័ពគោក លើកទៅជាបីកង ឯខ្លួនយើងនិងទ័ពហ្លួងជាជំនួយលើកតាមទៅ កាលនឹងលើកចូលវាយនោះ នឹងមានផាវអុជជាសញ្ញា បើបានឮស្នូរផាវជាសញ្ញា ក៏ឲ្យមេទ័ពស្រួតលើកចូលវាយឲ្យព្រមគ្នា ទាំងគោក ទាំងទឹក។ **តេងហាង**ក៏លើកទ័ពទឹកមានទូកចម្បាំង៣៥នាំពលបីពាន់ លើកទៅស្រុកតាំងហ៊ិន។ ឯ**លីគី, តងជូ, ឡៅបៅ** នាំពលម្នាក់មួយម៉ឺន ជាទ័ពគោកលើកចេញទៅស្រុកតាំងហ៊ិនតាមផ្លូវគោក **ជូកាត់កេក**ក៏លើកទ័ពហ្លួងទៅជាលំដាប់គ្នា។

ខណៈនោះ **អាវជុន**ជាមេទ័ពមុខ**សុម៉ាចៀវ** ធ្វើស្ពានឆ្លងទន្លេនាំកងទ័ពទៅដល់ត្រើយម្ខាងហើយក៏ប្រើ**ហ៊ួនកែ, ហ៊ួនចុង** នាំទាហានចូលវាយប៉មឆ្វេងស្ដាំ នោះនាយទាហានរក្សាប៉មស្ដាំឈ្មោះ**ឡៅលៀក** ប៉មឆ្វេងឈ្មោះ**ជួនតេក** ប៉មទាំងពីរនាក់នេះខ្ពស់មាំមួនណាស់ **ហ៊ួនកែ** និង**ហ៊ួនចុង**នឹងទម្លាយចូលទៅក៏ពុំបាន ទើបរាថយចេញទៅតាំងបន្ទាយ។ **ឡៅលៀក** និង**ជួនតេក**ឃើញទាហានសត្រូវចូលមកច្រើនណាស់ នឹងបើកទ្វារប៉មចេញដេញវាយមិនបាន ក៏រង់នៅតែក្នុងប៉ម។ គ្រានោះជាទេសកាលរងាណាស់ **អាវជុន**ក៏នាំនាយទ័ពនាយកងទាំងពួងទៅសេពសុរានៅក្នុងបន្ទាយ កងប្រចាំការទើបឲ្យបម្រើសេះទៅប្រាប់ថា កងទ័ពស្រុកកាំងតាំងលើកមកជាទ័ពទូក៣០ នោះ**អាវុជន**ក៏ចេញទៅក្រៅបន្ទាយ ក្រឡេកទៅឃើញកងទ័ពពីចម្ងាយ ប្រមាណមើលក៏ឃើញថាទូកមួយ និងបន្ទុកទាហានបានតែមួយរយ ទើបត្រឡប់ចូលទៅក្នុងបន្ទាយវិញ ហើយបង្គាប់នាយទ័ពនាយកងទាំងពួងថា ទូក៣០ នឹងបន្ទុកទាហានបានប្រមាណបីពាន់ យើងក៏មិនល្មមនឹងញញើតខ្លាចសោះ ថាហើយបង្គាប់ឲ្យទាហានរក្សាបន្ទាយ ឯខ្លួនក៏ត្រឡប់ទៅផឹកស្រាវនឹងនាយកងទៀតក៏ស្រវឹងទាំងនាយទាំងបាវ។

ឯ**តេងហាង**នាយទ័ពក៏ឲ្យរាទូកចូលអែបមាត់ច្រាំង ក្រឡេកទៅឃើញពលក្នុងរសាប់រសាយមិនបានរក្សាបន្ទាយឲ្យមាំមួន ឃើញបានចំណាប់ហើយក៏ប្រកាសដល់ទាហានទាំងពួងថា យើងជាជាតិទាហានត្រូវតែតាំងចិត្តគិតរកសេចក្ដីគាប់ប្រសើរដាក់ខ្លួនឲ្យបានក្នុងថ្ងៃនេះ ថាហើយក៏បង្គាប់ទាហានទាំងពួងឲ្យដោះមួកនិងគ្រឹសចេញគ្រប់គ្នា ហាមកុំឲ្យកាន់អាវុធវែង ឲ្យកាន់គ្រប៊ីនិងដាវ នោះទាហាន

ក្នុងបន្ទាយក្រឡេកឃើញដូច្នោះក៏សើចលេង មិនបានរវាំងខ្លួនប្រាណ **តេងហង**ក៏ផុតផាវឡើងជាសញ្ញាបីដង ហើយកាន់ដាវដៃពីរលោតឡើងពីលើទូករត់តម្រង់ទៅក្នុងបន្ទាយ ទាហានទាំងពួងក៏រត់តាមនាំគ្នាហែកទម្លាយបន្ទាយចូលទៅបាន **ហាន់ចុង**ក៏កាន់លំពែងរត់ចេញទៅចាក់**តេងហង** ៗទាត់បានក៏កាប់នឹងដាវត្រូវពោះ**ហាន់ចុង**ដួលចុះ **តេងហង**ស្ទុះទៅកាត់យកក្បាលបាន ឯ**ហ៊្សួនកែ**ក្រឡេកឃើញ**ហាន់ចុង**ស្លាប់ក៏ខឹងណាស់ កាន់ដាវវែងរត់ចូលទៅចាក់**តេងហង**ភ្លាត់ច្រលួសទៅចន្លោះចង្កេះ **តេងហង**តាមយកដាវវែងបាន **ហ៊្សួនកែ**គេចរត់ត្រឡប់ថយ **តេងហង**គ្រវែងកាប់នឹងដាវត្រូវជើង**ហ៊្សួនកែ**ដួលចុះ **តេងហង**ក៏ស្ទុះទៅចាក់នឹងលំពែងត្រូវ**ហ៊្សួនកែ**ស្លាប់ ទាហាន**តេងហង**បីពាន់ក៏ដេញកាប់សម្លាប់ទាហាន**អាវជុន** ៗក៏ឡើងសេះនាំទាហានហែកទម្លាយបន្ទាយរត់ចេញទៅ លុះទៅដល់ស្ពានផែ ពួកពលទាំងនោះខ្លាចស្លាប់ក៏រត់ដណ្ដើមជ្រែកជ្រៀតគ្នាឆ្លងទៅ មនុស្សចុះទៅច្រើនណាស់លើសទម្ងន់ ស្ពាននោះក៏បែករយះផែក៏លិចទៅ ទាហានក៏លង់ទឹកស្លាប់ច្រើនណាស់ **អាវជុន**ខូចខាតទាហានស្លាប់ក្នុងបន្ទាយ និងស្លាប់ក្នុងទឹកប្រហែលពីរភាគនៅសល់មួយភាគ ខូចខាតសេះនិងគ្រឿងសាស្ត្រាវុធ គ្រឿងឧបភោគបរិភោគច្រើនណាស់ ក៏នាំទាហានដែលសល់នោះរត់ទៅរក**សុម៉ាចៀវ** ៗបានដឹងសេចក្ដីហើយ ត្រួតមើលការឃើញថានឹងធ្វើការតទៅនោះជាលំបាកណាស់ ក៏លើកទ័ពត្រឡប់ចូលស្រុក។

ឯ**ជូកាត់កេក**ជាមេទ័ព និងនាយទ័ពនាយកងទាំងពួង ក៏លើកទ័ពត្រឡប់ចូលទៅស្រុកតាំងហ៊ិន លុះឃើញ**តេងហង**ធ្វើការមានជ័យជម្នះ ក៏ឲ្យចែករង្វាន់បំណាច់ដល់នាយទ័ពនាយកង និងទាហានទាំងពួងតាមគុណានុរូប ហើយទើបប្រឹក្សានឹងភ្នាក់ងារទាំងពួងថា **សុម៉ាចៀវ**លើកទ័ពមកធ្វើការនឹងយើងគ្រានេះ ចាញ់ប្រៀបយើងថយទ័ពត្រឡប់ទៅវិញ យើងបានចំណាប់ហើយ ត្រូវលើកតាមទៅតាំងបន្ទាយភ្ជាប់ពីម្ខាងខាងទិសឯជើង មុខជាបានស្រុកឡុកអៀងដោយស្រួល បើបានហើយនឹងបែងផែនដីចែកគ្នាពាក់កណ្ដាលម្នាក់ ថាហើយក៏ស្រូតកេណ្ឌទាហានឲ្យបាន២០ម៉ឺន ក៏លើកទៅវាយស្រុកវុយកុក។ លុះទៅដល់កណ្ដាលផ្លូវក៏បង្កើតផ្សែងផុសឡើងអំពីផែនដីឲ្យងងឹតណាស់ សូម្បីអង្គុយនៅជិតគ្នាក៏មើលមិនឃើញ **ចៀវអៀន**ទី

ប្រឹក្សាម្នាក់និយាយថា ការប្លែកបង្កើតឡើងដូច្នេះ អាក្រក់ល្អនឹងអន្តរាយមេទ័ព សុំឱ្យលោករំសាយកងទ័ពត្រឡប់ទៅស្រុកកាំងតាំងសិនចុះ កុំអាលទៅវាយស្រុកវុយកុកឡើយ។

**ជូកាត់កេក**បានឮដូច្នោះក៏ខឹងណាស់ យើងនឹងធ្វើការធំឱ្យមានជ័យជម្នះ អ្នកឯងនិយាយជាពាក្យអប្រិយឱ្យយើងដូច្នេះ នឹងឱ្យនាយទ័ពនាយកងនូវទាហានទាំងពួងខូចចិត្តគំនិតឬ? ថាហើយក៏បង្គាប់ឱ្យយកខ្លួន**ចៀវអៀន**ទៅសម្លាប់ចេញ នោះនាយទ័ពនាយកងទាំងពួងនាំគ្នាអង្វរសុំទោស**ជូកាត់កេក** ឱ្យរួចពីសេចក្ដីស្លាប់ ឱ្យ**ចៀវអៀន**ចេញពីរាជការទៅជារាស្ត្រ ហើយក៏ស្រូតលើកទ័ពចេញទៅ ឯ**តេងហង**និយាយនឹង**ជូកាត់កេក**ថា ខ្ញុំបានពិគ្រោះមើលឃើញថា គយស៊ិនសៀនេះជាទីមាំមួនណាស់ ពេញជាទីសំខាន់របស់ស្រុកវុយកុក បើយើងវាយបានទីនោះហើយ មុខជា**សុម៉ាស៊ូ**នឹងមានភ័យជាខ្លាំង ហើយយើងនឹងវាយចូលទៅក៏មុខជានឹងបានដោយងាយ។ **ជូកាត់កេក**យល់ឃើញត្រូវ ក៏ឱ្យលើកទ័ពទៅតាមផ្លូវគយស៊ិនសៀ។

ពួកគយល្បាតនាំយកសេចក្ដីទៅប្ដឹងដល់**ទៀតតេក**ជាមេគយធំថា កងទ័ពស្រុកកាំងតាំងលើកទ័ពមកច្រើនណាស់។ **ទៀតតេក**ឃើញលើសកម្លាំងនឹងចេញតពុំបាន ក៏ឱ្យទ្វារគយរក្សាខ្ជាប់ខ្ជួនពីក្នុងបន្ទាយ **ជូកាត់កេក**ក៏តាំងបន្ទាយទ័ពខ្ជាប់ ហើយឱ្យបម្រើសេះកាន់សំបុត្រទៅដល់**កៀងអ៊ុយ**ដូចគិតទុកមកនេះ ឯ**ទៀតតេក**ក៏ឱ្យបម្រើសេះកាន់សំបុត្រទៅប្ដឹងតាមខរាជការដល់ក្រុងឡកអៀង។ **ងីសុង**ទីប្រឹក្សាម្នាក់និយាយនឹង**សុម៉ាស៊ូ**ថា គ្រានេះ**ជូកាត់កេក**លើកមកព័ទ្ធគយស៊ិនសៀហើយ តែថាគយនោះមាំមួនណាស់ ព្រោះមានមនុស្សនៅត្រួតត្រារក្សាសុទ្ធតែខ្លាំងពូកែ ទោះបីយ៉ាងណាក៏មិនជាអន្តរាយទេ ត្រូវតែយើងស្ងៀមនៅសិនចុះ កុំអាលលើកកងទ័ពចេញទៅជួយឡើយ ព្រោះ**ជូកាត់កេក**លើកទ័ពមកចម្ងាយឆ្ងាយណាស់ ទោះបីនឹងបានស្បៀងអាហារអ្វីច្រើនតិចក៏មិនយូរគង់នឹងអស់ បើកាលណាអស់ហើយ គង់រំសាយទ័ពទៅឯង បើថយទ័ពរត់ទៅ សឹមយើងលើកទ័ពដេញតាមវាយពីក្រោយ មុខជាបានជ័យជម្នះតែម្ដង ខមួយទៀតខ្ញុំបាទខ្លាចក្រែងតែពីខាងជើង ព្រោះ**កៀងអ៊ុយ**

នឹងលើកទ័ពចុះមកជាទ័ពខ្នប់ប្រសព្វវាយព្រួតគ្នា សុំឲ្យចាត់កងទៅប្រចាំការពារ។ **សុម៉ាស៊ូ**យល់ឃើញត្រូវក៏ចាត់ឲ្យ**សុម៉ាចៀវ**នាំពលទៅជួយ**គួយហ៊ួយ** ដើម្បីរក្សាការពារស្រុកអេងជីវ ហើយប្រើ**ប៊ូឃីវខៀម** និង**អាវជុន**ឲ្យនាំទាហានលើកទៅជួយគយសុិនសៀ ហើយកំជាប់ថា ឲ្យអ្នកឯងរាល់គ្នាចាំមើល បើកងទ័ព**ជូកាត់កេក**រត់ទៅហើយ ត្រូវស្រូតលើកទាហានដេញតាមវាយពីក្រោយ កុំឲ្យញញើតដៃឡើយ។

ឯ**ជូកាត់កេក**ក៏បង្គាប់ថា ត្រូវឲ្យខំស្រុះគ្នាលើកវាយទម្លាយបន្ទាយឲ្យបាន ហើយឲ្យពារទម្លាយកំពែងទាំងកណ្តាលយប់កណ្តាលថ្ងៃ បើនរណាគេចវេះដោះដៃមិនស្រុះចិត្តគ្នាធ្វើការនេះឲ្យបានតាមបង្គាប់ទេ នឹងកាត់ក្បាលចេញ នោះអស់ពួកទាហានក៏ខំស្រុះគ្នាពារទម្លាយកំពែងទាំងកណ្តាលយប់កណ្តាលថ្ងៃ ឯកំពែងគយខាងជើងនោះឃើញថាមុខជាទម្លាយចូលទៅបាន។ **ទៀតតេក**ឃើញដូច្នោះ ទើបគិតកលឧបាយធ្វើសំបុត្រឲ្យបម្រើកាន់ទៅដល់**ជូកាត់កេក**ថា ទំនៀមស្រុករុយកុកបើសត្រូវវាយមក ហើយអ្នករក្សាស្រុកខំការពាររក្សាទុកបានដល់មួយរយថ្ងៃ ហើយមិនមានកងទ័ពស្រុកហ្លួងមកជួយទេ អ្នករក្សាស្រុកនេះឃើញលើសកម្លាំងនឹងតទល់ពុំបាន មុខជានឹងនាំទាហានចេញមកសុំចំណុះចុះចូលសត្រូវតែម្តង ឯបងប្អូនដែលនៅក្នុងស្រុកនោះក៏មិនជាទោសខុសទាំងអស់គ្នា។ ឥឡូវខ្លួនខ្ញុំឧស្សាហ៍រក្សាបន្ទាយមកបានប្រមាណ៨៥ថ្ងៃហើយ ក៏មិនឃើញកងទ័ពលើកមកជួយ សុំឲ្យលោកបង្អង់ឲ្យខ្ញុំប្រហែល១៥ថ្ងៃសិន ឲ្យលួមខ្ញុំនឹងរិះគិតចាត់ចែងការដែលនឹងនាំយោធាចេញមកចំណុះចុះចូលលោកតែម្តង នោះ**ជូកាត់កេក**ក៏ជឿស្តាប់ចិត្ត មិនបានបង្ខំគិតឲ្យទាហានពានទម្លាយកំពែង។

ឯ**ទៀវតេក**នោះ លុះបញ្ឆោត**ជូកាត់កេក**ដូច្នោះហើយ ក៏បង្ខំឲ្យរៀបចំកំពែងបន្ទាយពីខាងជើងដែលខ្ទេចខ្ទីទៅនោះឲ្យស្រួលបួលមាំឡើង ហើយឲ្យទាហានកាន់អាវុធទៅត្រៀមប្រចាំការព្រមនៅលើសើនបន្ទាយ ហើយ**ទៀវតេក**ក៏ស្រែកថា ស្បៀងអាហាររបស់ពួកអញក៏នៅបរិបូរ បើនឹងចិញ្ចឹមពលទាហានបានមួយឆ្នាំទៀត អញក៏មិនខ្លាចទេ អញត្រូវការអ្វីនឹងចេញទៅចំណុះឯង ព្រោះឯងជាជាតិឆ្កែស្រុកកាំងតាំង។ **ជូកាត់កេក**បានឮដូច្នោះក៏ខឹងណាស់ ទើបបង្គាប់ទាហានឲ្យពារ

ទម្លាយកំពែង នោះទាហាន**ទៀវតេក**ក៏នាំគ្នាបាញ់ធ្នូចម្រុះចុះមក ព្រួញត្រូវមុខ**ជូកាត់កេក**ធ្លាក់ពីលើសេះ ពួកទាហានក៏នាំចូលទៅក្នុងបន្ទាយ **ជូកាត់កេក**ក៏មានសេចក្ដីខឹងក្ដៅណាស់ ក៏បង្គាប់ទាហានឲ្យបង្ខំពារទម្លាយកំពែង។

នោះពួកនាយទ័ពនាយកងនិយាយថា វេលានេះអស់ពលទាហានមកធ្វើការយូរណាស់ហើយ បរិភោគបាយទឹកខុសទម្លាប់ធម្មតា បង្កើតជាជំងឺតម្កាត់ច្រើនណាស់ ដែលលោកនឹងឲ្យចូលទៅពារទម្លាយបន្ទាយមិនងាយបានទេ **ជូកាត់កេក**ខឹងខ្លាំងណាស់ថា បើនរណាមិនសុខចិត្តគិតធ្វើរាជការទេ ហើយមកប្រាប់ថាឈឺត្រូវឲ្យយកខ្លួនទៅសម្លាប់ចេញ នោះអស់ពួកទាហានឮហើយ ក៏ខ្លាចសេចក្ដីស្លាប់នាំគ្នារត់អស់ជាច្រើន **ឈូលិម**នាយទាហានធំ ក៏នាំទាហានជាស្ម័គ្របក្សពួករបស់ខ្លួនរត់ទៅចូលស្រុកវុយកុក នោះមានទាហានចូលទៅប្រាប់**ជូកាត់កេក**ថា ទាហានរត់អស់នៅស្ដើងស្ដួចណាស់ហើយ **ឈូលិម**នាយទាហានធំនាំទាហានរត់ទៅចូលសត្រូវហើយ **ជូកាត់កេក**ឮដូច្នោះក៏មានសេចក្ដីភ័យណាស់ ខំជិះសេះត្រួតមើលទាហានឃើញនៅស្ដួចស្ដើងណាស់ បើនឹងរង់នៅទីនោះ ក៏រឹតតែបណ្ដោយរបួសទៅមុខទើបបង្គាប់ឲ្យរំសាយទ័ពត្រឡប់ទៅស្រុកកាំងតាំង។

ឯកងល្បាតដឹងដូច្នោះ ក៏ចាត់បម្រើសេះទៅប្ដឹងដល់**ប៊ូយីវខៀម** ៗក៏បង្ខំលើកទ័ពទៅសង្កត់សង្កិនសម្លាប់ទាហាន**ជូកាត់កេក**ស្លាប់ច្រើនណាស់ **ជូកាត់កេក**ខូចខាតទាហានគ្រានោះមានសេចក្ដីអប្បយសណាស់ ព្រោះកាច់គេតាមអំពើចិត្តតែម្នាក់ឯងហើយថ្លោះការ **ជូកាត់កេក**ទ្រមខ្លួនមកឈឺនៅផ្ទះ ក៏នាំនាហ្មឺនធំតូចទៅសួរអាការ។

**ជូកាត់កេក**មានសេចក្ដីខ្មាសណាស់ ទើបនិយាយនឹងនាហ្មឺនទាំងពួងថា ខ្លួនខ្ញុំទៅធ្វើការគ្រប់គ្រាគ្រប់កាលមានតែជ័យជម្នះ គ្រានេះមានគ្រោះឲ្យថ្លោះការទាំងរូបអាត្មារៀបស្លាប់ ហើយថែមទាំងខូចខាតទាហានជាច្រើន បានសេចក្ដីអប្បយសណាស់ ព្រោះនាយទ័ពនាយកងទាំងពួងមិនបានជាចិត្តមួយនឹងគ្នាបានថ្លោះធ្លោយដល់សត្រូវ បើនរណាតិះដៀលនិន្ទាថាយើងចាញ់ទ័ព យើងនឹងចាប់ខ្លួនអ្នកនោះទៅសម្លាប់ចេញ។ អស់មុខមន្ត្រីទាំងពួងក៏ឈឺចិត្តណាស់ លុះនឹងឆ្លើយតបទៅ**ជូកាត់**

**កេក**ថាម្តេចពុំហ៊ាន ព្រោះញញើតខ្លាចដោយសក្តិយសជាធំ ព្រះចៅ**ស៊ុនលៀង**ក៏យាងត្រឡប់ទៅវិញ។ **ជូកាត់កេក**ក៏ដកហូតងារ**ស៊ុនជុន**ដែលបាននាំទាហានរក្សាព្រះអង្គនោះចាកតំណែង ហើយតាំង**ទៀវអៀត** និង**ជូអ៊ិន**ឲ្យជានាយទាហានរក្សាព្រះអង្គ ឯ**ស៊ុនជុន**នោះជាពូជព្រះរាជវង្សជាបុត្រ**ស៊ុនយង់** ជាក្មួយ**ស៊ុនចេង** ៗនោះជាប្អូន**ស៊ុនគៀត**បិតាព្រះចៅ**ស៊ុនគួន** លុះ**ជូកាត់កេក**ហូតងារចេញក៏មានសេចក្តីខឹងណាស់ តែថាមិនដឹងធ្វើប្រការម្តេចក៏នៅស្ងៀមទៅ។

**តេងអ៊ិន**ជានាហ្មឺនធំម្នាក់ មានចិត្តឈឺក្តៅនឹង**ជូកាត់កេក**តាំងពីដើមរៀងមក លុះដឹងថាធ្វើរំលោភដូច្នោះ **តេងអ៊ិន**ក៏ទៅរក**ស៊ុនជុន**ហើយនិយាយថា **ជូកាត់កេក**បានធ្វើធំហើយរំលោភកំហែងនាហ្មឺនទាំងពួងណាស់ធ្វើការសព្វថ្ងៃនេះ ខ្ញុំពិគ្រោះមើលឃើញដូចជាវាប្រុងនឹងក្បត់ផែនដី លោកជាពូជព្រះរាជវង្ស ហេតុម្តេចមកនៅស្ងៀមមិនរិះគិតនឹងកម្ចាត់សត្រូវរាជសម្បត្តិចេញ។ **ស៊ុនជុន**ថា ការនេះខ្ញុំបាទគិតយូរមកហើយ តែថាវាទាល់ច្រកល្ហកសោះមិនមានទីប្រឹក្សា បើបានលោកមកជាភឿនគិតត្រូវនឹងគំនិតគ្នាហើយ មុខជានឹងសម្រេចការ ខ្ញុំគិតថា នឹងនាំលោកចូលទៅទូលព្រះចៅ**ស៊ុនលៀង**សូមទ្រង់ជ្រាបតាមការដែលខ្ញុំគិតគ្រប់ប្រការនេះ រួចហើយនឹងគិតចាប់ខ្លួន**ជូកាត់កេក** តើលោកនឹងយល់ឃើញប្រការម្តេច? **តេងអ៊ិន**យល់ឃើញត្រូវ ក៏នាំគ្នាចូលទៅគាល់ហើយ ខ្សឹបទូលកិច្ចការទាំងពួង។

ព្រះចៅ**ស៊ុនលៀង**ត្រាស់ថា ការនេះយើងបានគិតឃើញយូរមកហើយ តែថាទាល់គំនិតណាស់ មិនត្រូវបង្អង់ឲ្យយូរឡើយ ត្រូវតែអ្នកទាំងពីរស្វាមីភក្តិដល់យើងឃើញដល់ការផែនដីដូច្នោះហើយ មិនត្រូវបង្អស់ឲ្យយូរឡើយ ត្រូវតែស្រូតរិះគិតកម្ចាត់សត្រូវផែនដីនេះចេញឲ្យបាន។ **តេងអ៊ិន**ទើបទូលថ្កានថា សូមព្រះអង្គឲ្យទាហានដែលមានថ្វីដៃខ្លាំងពូកែកាន់អាវុធបង្កប់នៅក្នុងឆាក ហើយទ្រង់ណាត់ថា បើឮស្នូរចោលពែងស្រាវេលាណា ឲ្យទាហានព្រមគ្នាចេញមកសម្លាប់**ជូកាត់កេក**វេលានោះ។ លុះត្រៀមការព្រមស្រេចហើយ ព្រះចៅ**ស៊ុនលៀង**ក៏ឲ្យទៅអញ្ជើញ**ជូកាត់កេក**មកបរិភោគអាហារលៀងតុ។ ឯ**ជូកាត់កេក**ដេកឈឺនៅក្នុងផ្ទះ ឲ្យចេះតែក្តៅក្នុងប្រាណ រំខានចិត្តណាស់ ក៏ចេញមកនិយាយរាជការ ក្រឡេកទៅឃើញ

មនុស្សម្នាក់ស្លៀកពាក់សដើរចូលមកចំពីមុខក៏ខឹងណាស់ បង្គាប់ទាហានឲ្យចាប់មនុស្សនោះយកទៅវាយសួរពិចារណា មនុស្សក៏ឆ្លើយឲ្យការថា បិតាខ្ញុំបាទស្លាប់នឹងទៅនិមន្តល្បួងជីមកធ្វើបុណ្យ ខ្ញុំបាទមិនដឹងមិនស្គាល់បានជាដើរមកប្រទះលើលោកម្ចាស់ ដោយស្មានថាទីនេះជាទីវត្ត ខ្ញុំបាទខុសណាស់ហើយ ស្រេចតែលោកម្ចាស់នឹងមេត្តាប្រោស។ **ជូកាត់កេក**ខឹងណាស់ ឲ្យហៅទាហានរក្សាទ្វារមកសួរថា ហេតុម្តេចបានជាឯងបណ្តោយឲ្យអាមនុស្សនេះចូលមកក្នុងភូមិអញ? អ្នករក្សាទ្វារប្រហែល៥០នាក់ឲ្យការថា ខ្ញុំបាទកាន់អាវុធគ្រប់ដៃរក្សាមាត់ទ្វារព្រមដោយមុខ ក៏មិនបានឃើញនរណាដើរចូលមកទេ។ **ជូកាត់កេក**ក៏បង្គាប់ឲ្យយកពួកទាហានរក្សាទ្វារទាំងអស់នោះ ហើយនិងមនុស្សដែលចូលទៅនោះទៅសម្លាប់ទាំងអស់។ លុះវេលាកណ្តាលយប់ក៏ឲ្យរំខានក្នុងចិត្តណាស់ ដេកមិនលក់ ស្រាប់តែឮសូរដូចរន្ទះបាញ់ លុះស្ទុះចេញមកក្រឡេកឃើញដងទង់ដែលដោតលើសើនបន្ទាយនោះដាច់ចេញជាពីរកំណាត់ ក៏រឹតតែភ័យណាស់ ត្រឡប់ចូលទៅដេកវិញក៏មិនលក់ មានបិសាចចូលទៅលងបន្លាចធ្វើជាខ្យល់បក់ទៅត្រូវខ្លួន**ជូកាត់កេក** ៗក្រឡេកឃើញពួកមនុស្សដែលយកទៅស្លាប់នោះគ្មានក្បាលទាំងអស់ ឃើញដៃវាយួរក្បាលម្នាក់មួយដើរចូលទៅតាមគ្នា ហើយស្រែកថា លោកយកជីវិតមកឲ្យយើងវិញ។

**ជូកាត់កេក**ឃើញដូច្នោះក៏រឹតតែខ្នាញ់ណាស់ ក៏ស្ទុះច្រឡោតទាល់តែធ្លាក់ពីលើគ្រែបាត់មាត់មួយស្របក់ អ្នករក្សាជំងឺកែខៃដឹងឡើងវិញ លុះវេលាព្រឹក**ជូកាត់កេក**ចេញទៅលុបមុខ ធំក្លិនឆ្អាបទឹកក្នុងភាជនៈដែលលុបមុខនោះបីដូចឈាមស្រស់ៗ ក៏ខឹងខ្លាំងណាស់ ទើបឲ្យមនុស្សបម្រើទៅដងទឹកថ្មីយកមកឲ្យជាច្រើនគ្រាក៏នៅឆ្អាបជាក្លិនលោហិតដដែល រឹតតែសង្ស័យណាស់ ទទួលមានរាជបម្រើត្រាស់ឲ្យហៅ**ជូកាត់កេក** សេចក្តីថា ព្រះចៅ**ស៊ុនលៀង**ឲ្យអញ្ជើញលោកទៅពិសាតុលៀងអាហារ **ជូកាត់កេក**ក៏រៀបខ្លួនឡើងសេះ មានទាហានហែមុខក្រោយចូលទៅគាល់ មានឆ្កែលឿងមួយដែល**ជូកាត់កេក**ចិញ្ចឹមទុកក្នុងផ្ទះនោះ ក៏ស្ទុះទៅខាំជាយអាវ**ជូកាត់កេក**ទាញទុក ហើយវាស្រែកលូបីដូចជាសំលេងស្រែកយំ **ជូកាត់កេក**នឹកប្លែកក្នុងចិត្តណាស់ ប្រឹងស្រែកគំហកដេញឆ្កែឲ្យចេញទៅបន្តិច ស្រាប់តែក្រឡេក

ទៅឃើញផ្សែងភ្លើងផុសឡើងពីផែនដី ជាប្រផ្នូលប្លែកដូចកាលទៅទ័ព ក៏រឹតតែប្លែកចិត្តទៀត **ទៀវអៀត**ទាហានស្និទ្ធម្នាក់ក៏រំឭកថា ដែលមានព្រះតម្រាស់ឲ្យព្រះតេជព្រះគុណអញ្ជើញទៅពិសាលៀងគ្រានេះ ដូចជាមិនដឹងច្បាស់ការធ្ងន់ស្រាលអ្វីឡើយ ហេតុនេះហើយសូមឲ្យព្រះតេជព្រះគុណត្រិះរិះគិតឲ្យល្អិតល្អមែនទែនកុំស្រាល។ **ជូកាត់កេក**បានឮដូច្នោះក៏ឲ្យត្រឡប់បរទេះទៅផ្ទះវិញ។ **តេងអ៊ិន**និង**ស៊ុនជុន**ដឹងថា **ជូកាត់កេក**ត្រឡប់ទៅវិញ ក៏បរសេះស្រូតទៅទាន់រទេះហើយថា ព្រះចៅ**ស៊ុនលៀង**រឭកដល់លោកមហាឧបរាជណាស់ ទើបឲ្យតាមអញ្ជើញទៅពិសាលៀងកុំខាន ហេតុម្តេចបានជាលោកអញ្ជើញទៅវិញ? **ជូកាត់កេក**ថា ខ្ញុំមកដល់ទីនេះហើយ តែមិនស្រួលក្នុងពោះ ឃើញថានឹងទ្រាំទៅគាល់មិនបាន បានជាត្រឡប់ទៅវិញ។

**តេងអ៊ិន**ថា តាំងពីមហាឧបរាជអញ្ជើញទៅទ័ព ទាល់តែត្រឡប់មកវិញនៅមិនទាន់បានចូលគាល់សោះ ព្រះចៅ**ស៊ុនលៀង**យកព្រទ័យទុកដាក់ នឹករឭកត្រាស់សួរជារឿយៗជ្រាបថាលោកធូរស្រាលអាការៈជំងឺហើយ បានជាតាមអញ្ជើញទៅពិសាលៀង ហើយនឹងបានប្រឹក្សាពីការរាជការផែនដីផង លោកអញ្ជើញមកហើយត្រូវតែខំកាត់ចិត្តចូលទៅគាល់ម្តងចុះ ដើម្បីបំពេញព្រះទ័យព្រះចៅ**ស៊ុនលៀង**ដែលទ្រង់ស្នេះសរាប់អាន។ **ជូកាត់កេក**បានឮដូច្នោះក៏មិនមានសេចក្តីសង្ស័យអ្វីសោះ ក៏ត្រឡប់ចូលទៅគាល់ **ទៀវអេក**ទាហានជំនិតក៏តាមទៅផង។

ព្រះចៅ**ស៊ុនលៀង** ទ្រង់ធ្វើបដិសណ្ឋារៈគួរសមនឹង**ជូកាត់កេក** ហើយអញ្ជើញឲ្យអង្គុយកៅអី ហើយអញ្ជើញឲ្យសេពសុរា **ជូកាត់កេក**រវាំងខ្លួនណាស់ទូលថា ទូលព្រះបង្គំជាខ្ញុំនៅឈឺនឹងទទួលព្រះរាជទានសុរាពុំបាន។ **ស៊ុនជុន**ថា ខ្ញុំបាទឃើញមហាឧបរាជពិសាស្រាថ្នាំលាយសុរានៅផ្ទះជាដរាប កុំឲ្យទទឹងព្រះអធ្យាស្រ័យឡើយ គួរប្រើមនុស្សឲ្យទៅយកស្រាថ្នាំមកពិសាឲ្យល្មមតាមព្រះរាជហឫទ័យ។ **ជូកាត់កេក**ក៏ប្រើបម្រើឲ្យទៅយកស្រាថ្នាំមកផឹក ព្រះចៅ**ស៊ុនលៀង**ឃើញ**ជូកាត់កេក**ផឹកស្រាថ្នាំស្រវឹងក្នុងខ្លួនហើយ ទើបត្រឡប់យកសេចក្តីដែលព្រះបិតាបានផ្តាំផ្ញើមស្រុកទេសនឹងខ្លួនរបស់ព្រះអង្គនោះ មកប្រាប់ឮឲ្យ**ជូកាត់កេក**ទុកចិត្ត។

**ស៊ុនជុន**ក៏ចូលទៅឆាកដោះអាវចេញ ហើយតែងខ្លួនជាមាំមួនបែបយ៉ាងចូលធ្វើសង្គ្រាម ហើយកាន់គ្រប៊ីចេញទៅស្រែកថា មានព្រះតម្រាស់ឲ្យយើងសម្លាប់មារសត្រូវរាជសម្បត្តិ គឺរូប**អាជូកាត់កេក**នេះឲ្យអស់ជីវិត។ **ជូកាត់កេក**ភ័យណាស់ ដៃចាប់គ្រប៊ីងាកខ្លួននឹងក្រោកឡើង ស្រាប់តែ**ស៊ុនជុន**ស្ទុះទៅកាប់**ជូកាត់កេក**ដាច់ក្បាលធ្លាក់ចុះ **ទៀវអៀត**ក៏វាំដាវចូលទៅចាក់ត្រូវដៃ**ស៊ុនជុន**ធ្លាក់គ្រប៊ីពីដៃ ទាហានដែលកាន់អាវុធត្រៀមក្នុងឆាក ក៏ស្ទុះស្រចេញមកព័ទ្ធជុំខ្លួន**ទៀវអៀត** ហើយចាក់**ទៀវអៀត**ដួលស្លាប់ **ស៊ុនជុន**ក៏បង្គាប់ទាហានឲ្យទៅចាប់ភរិយាបុត្រ**ជូកាត់កេក** និង**ទៀវអៀត** ហើយឲ្យយករបស់ទ្រព្យសព្វវត្ថុដាក់ជាព្រះរាជទ្រព្យហ្លួងទាំងអស់ លុះបង្គាប់ហើយ ក៏ឲ្យយកអាវរុំសព**ជូកាត់កេក**និង**ទៀវអៀត**ទៅចោលក្រៅកំពែងក្រុងខាងទិសឯត្បូង។

ឯភរិយាបុត្រ**ជូកាត់កេក** វេលានោះ បណ្ដាលជាទុក្ខក្ដៅក្រហាយក្នុងទ្រូងខ្លាំងណាស់ ក្រឡេកទៅឃើញស្រីម្នាក់ដែលជាមនុស្សបម្រើក្នុងផ្ទះនោះ បិសាច**ជូកាត់កេក**ទៅចូលវា ៗក៏មានក្លិននោះឆ្អាបណាស់ ហើយវាដើរចូលទៅក្នុងផ្ទះ ភរិយាក៏សួរថា ខ្លួនឯងត្រូវនឹងអ្វីបានជាធុំក្លិនឆ្អាបឈាមណាស់ម្ល៉េះ? ស្រីនោះខមភ្នែកលៀនអណ្ដាតហើយលោតឡើងទៅលើដំបូលផ្ទះ ហើយចុះមកអង្គុយ**លីហឹង**ស្រែកថា អញនេះគឺ**ជូកាត់កេក**។ ទទួលទាហានទៅដល់ចោមព័ទ្ធផ្ទះទុក ហើយដេញចាប់ភរិយាបុត្រ**ជូកាត់កេក** និងមនុស្សក្នុងផ្ទះបានទាំងអស់ ហើយក៏រឹបយករបស់ទ្រព្យមាសប្រាក់ ហើយនាំយកមនុស្សទាំងអស់ទៅប្រហារជីវិតកណ្ដាលផ្សារ ឯរបស់ទ្រព្យក៏នាំទៅដាក់ជាព្រះរាជទ្រព្យហ្លួងទាំងអស់។ គ្រានោះជាខែកត្តិក ក្នុងរវាងព្រះចៅ**ស៊ុនលៀង**សោយរាជបានពីរឆ្នាំ (ព.ស ៧៩៦) កាល**ស៊ុនជុន**សម្លាប់**ជូកាត់កេក**វេលានោះ ព្រះចៅ**ស៊ុនលៀង**ក៏តាំង**ស៊ុនជុន**ជាមហាឧបរាជនិយាយរាជការទូទាំងផែនដី។

ឯ**កៀងអ៊ុយ**មេទ័ពស្រុកសែឈួន លុះដឹងតាមសំបុត្រ**ជូកាត់កេក**ឲ្យទៅដល់ក៏ពេញអំណាចណាស់ ទើបនាំសេចក្ដីនោះទៅទូលព្រះចៅ**ឡៅសៀន** ហើយទូលលានឹងលើកកងទ័ពទៅវាយស្រុកវុយកុក ព្រះចៅ**ឡៅសៀន**ក៏យល់ព្រមផង **កៀងអ៊ុយ**

កេណ្ឌទាហានបានម្ភៃម៉ឺន ឲ្យ**លៀវហ្វ៊ូ**ជាប៉ែកឆ្វេង **ទៀវអេក**ជាប៉ែកស្តាំ ឲ្យលើកទៅមុន ឲ្យ**ហែហ្វ៊ូប៉ា**ជាទីប្រឹក្សាក្នុងទ័ពហ្លួង ឲ្យ**ទៀវងី**ជាកងទ័ពក្រោយប្រចាំចួន លុះរៀបស្រេចក៏ឲ្យលើកកងទ័ពចេញទៅតាមផ្លូវហែបេងគួន លើកទ័ពទៅគ្រានោះ ព្រះចៅ**ឡៅសៀន**សោយរាជ្យបាន១៦ឆ្នាំ (ព.ស៦៩៦) **កៀងអ៊ុយ**ប្រឹក្សានឹង**ហែហ្វ៊ូប៉ា**ថា យើងលើកកងទ័ពទៅគ្រាមុនថ្លោះការនឹងសត្រូវ គ្រានេះទាហានយើងក៏ច្រើន គ្រឿងសាស្ត្រាវុធក៏ច្រើនគ្រប់សព្វ យើងត្រូវរិះគិតធ្វើការហ្មត់ចត់ តើអ្នកគិតយល់ឃើញប្រការម្តេច ទើបនឹងបានជ័យជម្នះសត្រូវខ្លាំងឲ្យបាន?

**ហែហ្វ៊ូប៉ា**ថា អាណាខេត្តឡើងវុយកុកប៉ែកខាងជើងឃើញតែស្រុកអាន់ណាំនោះមានស្រូវអង្ករស្បៀងអាហារបរិបូរ បើយើងវាយយកបាននឹងបានជាកម្លាំងចិញ្ចឹមអាហារដោយស្រួល កាលយើងលើកទៅគ្រាមុនថ្លោះការនឹងពួកសត្រូវ ព្រោះកងទ័ពស្រុកកៀងមិនបានមកដល់ព្រម គឺមកមិនទាន់វេលា គ្រានេះសុំឲ្យអ្នកមានសំបុត្របង្គាប់ទៅឲ្យលើកកងទ័ពមកតាមផ្លូវសេកអេង ឲ្យមកបញ្ចូលគ្នានឹងទ័ពយើងនៅស្រុកតងតេងព្រមគ្នា ហើយយើងនឹងលើកទៅវាយស្រុកអាន់ណាំ។ **កៀងអ៊ុយ**បានឮដូច្នោះក៏មានសេចក្តីត្រេកអរណាស់ ទើបឲ្យចាត់ចែងនាំយកពេជ្រនិងប្រាក់មាសព្រៃសាច់យ៉ាងល្អជាគ្រឿងរាជបណ្ណាការទៅដល់**ប៊ីតង** ចៅហ្វាយស្រុកកៀងឲ្យលើកទ័ពមកជួយ។ **ប៊ីតង**ចៅហ្វាយស្រុកកៀងខេត្តក្រៅ បានបណ្ណាការក៏ពេញអំណរណាស់ ទើបកេណ្ឌពលបានប្រាំម៉ឺន ចាត់**ហោងោ** និង**សៀវកួ**ទាំងពីរនាក់នេះជាមេទ័ពមុខ ខ្លួន**ប៊ីតង**ជាមេទ័ពហ្លួងលើកទៅស្រុកតងតេង។

ឯ**គួយហ្វ៊ូយ**ចៅហ្វាយស្រុកអេងជីវ ដឹងថា **កៀងអ៊ុយ**លើកទ័ពមក ក៏ឲ្យបម្រើសេះកាន់សំបុត្រចូលទៅប្តឹងតាមខរាជការដល់ក្រុងឡុកអៀង **សុម៉ាស៊ូ**ទើបប្រឹក្សានឹងនាហ្មឺនទាំងពួងថា កងទ័ព**កៀងអ៊ុយ**លើកមកគ្រានេះ នរណានឹងអាសាចេញទៅតទល់បាន? **ឈីជិត**នាហ្មឺនធំម្នាក់ក៏និយាយថា ខ្ញុំបាទនឹងសុំអាសាចេញទៅ **សុម៉ាស៊ូ**ដឹងមកពីដើមថា **ឈីជិត**នោះជាមនុស្សមានសតិបញ្ញាទាំងកម្លាំងក៏ច្រើន ឃើញទាហានហានក្លាក្នុងការសង្គ្រាម លុះបានឮ**ឈីជិត**ទទួលអាសាដូច្នោះក៏ពេញចិត្តណាស់ ទើបឲ្យ**ឈីជិត**ជាមេទ័ពមុខ **សុម៉ាចៀវ**ជាមេទ័ពហ្លួង នាំទាហានលើក

ទៅដល់តំបន់តងតេង **ឈីជិត**កាន់ពូថៅជិះសេះនាំទាហានចេញទៅ **កៀងអ៊ុយ**ចាត់ប្រើ**លៀវហ្វ៊ូ**នាំទាហានចេញច្បាំង។ **លៀវហ្វ៊ូ**កាន់លំពែងជិះសេះនាំទាហានចេញទៅតស៊ូគ្នានឹង**ឈីជិត**បានបីភ្លេង ពេលនោះលំពែងភ្លាត់ធ្លាក់ពីដៃដោយចាញ់ប្រៀបក៏ទាញសេះរត់ទៅ **កៀងអ៊ុយ**ប្រើឲ្យ**ទៀវអេក**ចេញទៅជួយ **ទៀវអេក**កាន់លំពែងជិះសេះចេញច្បាំងនឹង**ឈីជិត**បានប្រមាណប្រាំភ្លេង លើសកម្លាំងក៏ថយរត់ចេញ **ឈីជិត**បានចំណាប់ ក៏នាំទាហានដេញទន្ទ្រានពានពារសម្លាប់ទាហាន**កៀងអ៊ុយ**ស្លាប់ជាច្រើន **កៀងអ៊ុយ**ឃើញទាហានរសាប់រសាយណាស់ នឹងតទល់មិនបានក៏រំសាយទ័ពថយទៅប្រមាណបីរយសិន (១២ គ.ម) ក៏តាំងបន្ទាយខ្ជាប់នៅទីនោះឯ**សុម៉ាចៀវ**ហាមមិនឲ្យទាហានដេញតាម ក៏បង្គាប់ទាហានឲ្យតាំងបន្ទាយនៅប្របគ្នា។

**កៀងអ៊ុយ**ក៏ប្រឹក្សានឹង**ហែហ្វ៊ូប៉ា**ថា **ឈីជិត**នោះជាមនុស្សមានកម្លាំងថ្វីដៃខ្លាំងណាស់ យើងត្រូវគិតប្រការម្ដេចទើបនឹងសម្លាប់ចេញបាន? **ហែហ្វ៊ូប៉ា**ថា ចាំព្រឹកស្អែកយើងនឹងបង្កប់ទាហានទុកសងខាងផ្លូវ ហើយឲ្យខ្លះចេញទៅច្បាំងតដៃនឹង**ឈីជិត** ហើយឲ្យធ្វើជាចាញ់រត់ថយមក បើ**ឈីជិត**ដេញតាម យើងត្រូវឲ្យទាហានដែលពួនបង្កប់នោះចេញវាយស្ទាក់ពីសងខាង គង់នឹងព្រួតចាប់**ឈីជិត**បានជាប្រាកដ។

**កៀងអ៊ុយ**ថា **សុម៉ាចៀវ**នោះជាបុត្រ**សុម៉ាអ៊ី** គេក៏ចំណានក្នុងកលសឹកណាស់ ដែលនឹងបញ្ឆោតដូច្នោះ ក្រែងមិនសម្រេចដូចគំនិតគិត ព្រោះទីផ្លូវស្នាមចម្បាំងនោះទំនងស្រួលណាស់ មុខជាគេនឹងមិនដេញតាមទេដឹង ពិគ្រោះមើលឃើញថា កងទ័ពស្រុកវុយកុកមកធ្វើការនឹងយើងពីមុនមក រមែងប្រើទាហានទៅចាំស្កាត់ផ្លូវប្រចាំជូន ដែលយើងចាំសម្លាប់**ឈីជិត**ក្នុងទីចម្បាំងដូច្នេះ ដូចជាមិនបាន ព្រោះកម្លាំងពលទាហានគេក៏ច្រើន ត្រូវតែយើងតាំងទ័ពនៅក្នុងបន្ទាយឲ្យមាំមួនចុះ មុខជា**សុម៉ាចៀវ**នឹងប្រើ**ឈីជិត**ឲ្យចាំវាយកាត់ទ័ពប្រចាំជូន យើងត្រូវគិតបញ្ឆោត**ឈីជិត**ឲ្យចាញ់កលយើង នៅវេលាដែលវាយកាត់ទ័ពប្រចាំជូននោះឲ្យបាន ព្រោះទីនោះជាច្រកចង្អៀត។ **ហែហ្វ៊ូប៉ា**ក៏យល់ឃើញត្រូវ។

**កៀងអ៊ុយ**ក៏ឲ្យហៅ**លៀវហ្វ៊ូ** និង**ទៀវអេក**មកពន្យល់ឲ្យធ្វើកលឧបាយ ដែលខ្លួនធ្លាប់ធ្វើការជាមួយនឹង**ខុងបេង** អ្នកទាំងពីរក៏ទៅធ្វើដូចគំនិតគិតទុក តាម**កៀងអ៊ុយ**បង្គាប់ពន្យល់នោះ ឯ**កៀងអ៊ុយ**នៅរក្សាបន្ទាយឲ្យទាហានធ្វើកង្វារក្រចាប់ដែករាយពេញបន្ទាយ ហើយឲ្យកាត់ឈើធ្វើចម្រូងដោតរាយប្រជុំក្នុងបន្ទាយក្រៅបន្ទាយជាច្រើន ឯ**ឈីជិត**នាំទាហានចេញទៅមុខបន្ទាយ**កៀងអ៊ុយ** ហើយស្រែកចំអកឡកបញ្ឈឺចិត្តរាល់ថ្ងៃឲ្យ**កៀងអ៊ុយ**ចេញច្បាំង **កៀងអ៊ុយ**ក៏មិនព្រមចេញច្បាំងសោះ លុះនឹងចូលហែកទម្លាយបន្ទាយក៏ពុំបាន។

កងល្បាតទើបប្រើបម្រើសេះទៅប្រាប់**សុម៉ាចៀវ**ថា ទាហាន**កៀងអ៊ុយ**នាំពួកប្រចាំជូនមកដល់ក្រោយភ្នំចៀតឡុងសាន់ហើយ **សុម៉ាចៀវ**ទើបប្រឹក្សានឹង**ឈីជិត**ថា **កៀងអ៊ុយ**មិនបានចេញច្បាំងនឹងយើងតាំងខ្ជាប់ខ្ជួនមួនមាំក្នុងបន្ទាយប្រហែលជាចាំទ័ពជូនហើយ បើដូច្នោះត្រូវយើងឲ្យទៅកាត់ពួកប្រចាំជូនឲ្យបាន បើ**កៀងអ៊ុយ**ខ្វះផុតពួកប្រចាំជូនកាលណា មុខជានឹងរត់ចាញ់យើងជាប្រាកដ អ្នកចូរនាំទាហានចេញទៅធ្វើការនេះឲ្យបានសម្រេចចុះ។ **ឈីជិត**នាំទាហានប្រាំពាន់លើកចេញទៅពីពេលព្រលប់ ទៅដល់ភ្នំចៀតឡុងសាន់ហើយ ពួកកងល្បាតមកប្រាប់ថាទាហាន**កៀងអ៊ុយ**ប្រហែលពីររយប្លាយនាំប្រចាំជូន បន្ទុកគោយន្តប្រហែលមួយរយប្លាយមក នោះ**ឈីជិត**ក៏ឲ្យទាហានទៅបង្កប់នៅសងខាងផ្លូវ ឯខ្លួន**ឈីជិត**ក៏ទៅតាំងស្កាត់នៅដើមផ្លូវ នោះពួកកងល្បាតខាង**កៀងអ៊ុយ**ក៏ចាត់បម្រើសេះឲ្យទៅប្រាប់**កៀងអ៊ុយ**ថា **ឈីជិត**លើកទ័ពតម្រង់ទៅចាំកាត់ពួកប្រចាំជូនហើយ នោះ**កៀងអ៊ុយ**ក៏លើកទ័ពទៅ លុះកងប្រចាំជូនទៅដល់ **ឈីជិត**ក៏ឲ្យទាហានស្រែកហ៊ោវាយប្រសព្វចូលទៅ នោះពួកទាហានប្រចាំជូនឃើញហើយ ក៏នាំគ្នារត់ទៅតាមផ្លូវត្រង់លើ**លៀវហ្វ៊ូ** និង**ទៀវអេក**ធ្វើកលនោះ **ឈីជិត**ក៏ឲ្យទាហានពីរពាន់ប្រាំរយនាំរបស់ប្រចាំជូនយកទៅ ឯខ្លួនក៏នាំទាហានពីរពាន់ប្រាំរយដេញតាមទៅ លុះដេញទៅបានប្រហែលមួយរយសិន (៤ គ.ម) ដល់ផ្លូវប្រហាប ក៏ទទួលប្រទះនឹងរទេះកល់ជាច្រើនដែល**លៀវហ្វ៊ូ** និង**ទៀវអេក**ធ្វើជាកល់ទុកតាមផ្លូវនោះ **ឈីជិត**ក៏ឲ្យទាហានចុះពីលើសេះជួយគ្នារុញរទេះនោះឲ្យអែបទៅខាងផ្លូវ ទាហានក៏ចូលទៅព័ទ្ធរុំជុំគ្នា

រុញរទេះនោះ ឯទាហានដែលតាមទៅនោះក៏ប្រជ្រៀតបៀតគ្នាជាច្រើនណាស់ រទេះនោះក៏លឿនគ្រឿនចាកទី ស្រាប់តែឆេះឡើងជាភ្លើងគ្រប់រទេះ អណ្តាតសន្ធោសន្ធៅផ្ទុះទៅត្រូវទាហានពួកនោះរបួសពិការស្លាប់ជាច្រើន **ឈីជិត**គិតថា គេធ្វើកលទទឹងពីមុខទុកហើយ លុះនឹងត្រឡប់ទៅតាមផ្លូវដែលមក ក្រែងគេបង្កប់ទាហានស្ទាក់កាត់ទុក ទើបនាំទាហានរត់ទៅមុខតាមផ្លូវតូចក្បែរជើងភ្នំមួយ លុះទៅដល់ជិតមាត់ផ្លូវក៏ប្រទះនឹងរទេះកល់អែបនៅសងខាងផ្លូវជាច្រើន រឹតតែភ័យណាស់ ក៏បង្ខំទាហានស្រូតទៅឲ្យផុត រទេះគោនោះក៏ឆេះឡើងជាភ្លើង បកអណ្តាតប្រសព្វគ្នាពីសងខាងផ្លូវ ត្រូវលើពួកទាហាននោះរបួសពិការស្លាប់ជាច្រើនណាស់ **ឈីជិត**ក៏នាំទាហានដែលសល់ពីស្លាប់រត់ផុតទៅហើយបានឮស្នូរផាវជាសញ្ញា ក្រឡេកទៅឃើញ**លៀវហ៊្វ**ចេញមកពីខាងឆ្វេង **ទៀវអេក**ចេញមកពីខាងស្តាំ នាំទាហានស្រែកហ៊ោព័ទ្ធចូលមកទាំងសងខាង សម្លាប់ពួកទាហាន**ឈីជិត**ស្លាប់ទាំងអស់ ឯ**ឈីជិត**បំផាយសេះរត់ទៅប្រទះនឹង**កៀងអ៊ុយ**ចេញមកស្ទាក់ពីមុខ **ឈីជិត**ភ័យណាស់ នឹងត្រឡប់អាវុធចូលតស៊ូមិនទាន់ **កៀងអ៊ុយ**ចាក់ត្រូវ**ឈីជិត**ធ្លាក់ពីលើសេះ អស់ពួកទាហានក៏ស្ទុះចូលទៅព័ទ្ធជុំវិញ ព្រួតគ្នាចាក់កាប់**ឈីជិត**ទាល់តែដាច់ខ្យល់ស្លាប់។

ឯទាហាន**ឈីជិត**ពាក់កណ្តាលដែលនាំរបស់ប្រចាំជូនទៅនោះ ទៅប្រទះនឹង**ហែហ៊្វប៉ា** ៗក៏ឲ្យទាហានឡោមព័ទ្ធឃាត់ឃុំទុក ពួកទាហាន**ឈីជិត**ទប់ពុំឈ្នះក៏ព្រមស្ម័គ្រចូលទៅជាពួក**ហែហ៊្វប៉ា**ទាំងអស់ ហើយនាំគ្នាកាន់ទង់ជ័យ**ឈីជិត**ជាមុខ នាំកងទ័ពនិងស្បៀងតម្រង់ទៅបន្ទាយ**សុម៉ាចៀវ** ៗឃើញជាពួកទាហាន**ឈីជិត**វាយយកស្បៀងប្រចាំជូនបានមក ក៏បើកទ្វារទទួលឲ្យចូលទៅ **ហែហ៊្វប៉ា**ក៏នាំទាហានចូលទៅក្នុងបន្ទាយ**សុម៉ាចៀវ** ក៏នាំទាហានរត់ទម្លាយចេញទៅបាន។ **លៀវហ៊្វ**និង**ទៀវអេក**ក៏បង្ខំស្រូតទៅប្រទះនឹង**សុម៉ាចៀវ** ហើយព្រួតគ្នាវាយប្រសព្វ**សុម៉ាចៀវ**ទ្រាំមិនបានក៏ប្រេះរត់ទៅតាមផ្លូវមួយ ប្រទះគ្នានឹងកងទ័ព**កៀងអ៊ុយ** ៗក៏បរពលចូលចោមវាយ**សុម៉ាចៀវ** ៗទាល់ច្រកគេចសោះ ក៏ដោះរត់ឡើងទៅលើភ្នំចៀតឡុងសាន់ ភ្នំនោះមានផ្លូវចំពោះឡើងទៅតែមួយ មានអន្លង់ទឹកតូចមួយ ល្មមផឹកបាន ចំនួនមនុស្សមួយរយនាក់ ទាហានដែលឡើងទៅជាមួយនឹង**សុម៉ាចៀវ**នោះ

ប្រមាណប្រាំមួយពាន់ នាំគ្នាផឹកទឹកនោះរីងអស់។ **កៀងអ៊ុយ**នឹងប្រឹងឡើងទៅពុំបាន ក៏ឲ្យទាហានព័ទ្ធភ្នំនោះទុក។ **សុម៉ាចៀវ**ឃើញសេះ និងទាហានឃ្លានស្រេកទឹកណាស់ ក៏ងើបមុខឡើងមើលអាកាស ហើយទន្ទ្រាំដើងថា យើ! ទេពតាមិនអាណិតយើងទេឬ? នឹងឲ្យអត់ទឹកស្លាប់ទាំងអស់គ្នាហើយ។

**អងថា** សមុហបញ្ជីឆ្លើយថា ពីគ្រាមុនឈ្មោះ**គ្រេងកះយុង**ម្នាក់ លើកកងទ័ពទៅច្បាំងនឹងសត្រូវ ហើយដាច់ទឹកផឹកសោះ បានប្រទះអន្លង់មួយចូលទៅរកទឹកគ្មានក៏ក្រាបចុះបន់ស្រន់ទេពតាទើបានទឹកផឹកបរិបូរ។ លោកដាច់ទឹកវេលានេះ សុំឲ្យបន់ស្រន់ទេពតាទៅមើលចុះ។ **សុម៉ាចៀវ**យល់ឃើញត្រូវ ក៏ដើរឡើងទៅដល់អន្លង់ទឹកនោះ ហើយក៏ក្រាបចុះបីដងបន់ស្រន់ថា ខ្ញុំអម្ចាស់ឈ្មោះ**សុម៉ាចៀវ** បានយកអាសាអម្ចាស់ផែនដីចេញមកប្រាបប្រាមខ្មាំងសត្រូវ បើខ្ញុំអម្ចាស់នឹងអស់ជីវិតហើយ សុំកុំឲ្យមានទឹកមកឡើយ ខ្ញុំម្ចាស់នឹងបានអារ-កឲ្យស្លាប់ ទាហានទាំងពួងនឹងនាំគ្នាចូលទៅចំណុះសត្រូវតែម្តង បើខ្ញុំម្ចាស់នៅមានជីវិតធ្វើការរាជការថ្វាយអម្ចាស់ផែនដីតទៅ សូមឲ្យទេពតាបណ្តាលឲ្យមានទឹកមកពេញអន្លង់នេះចុះ។ លុះបន់ស្រន់ល្មមតែផុតពាក្យសច្ចាធិដ្ឋាន ក៏មានទឹកហូរចេញមកពេញអន្លង់នោះ អស់រេហ៍ពល និងសេះក៏បានបរិភោគឆ្អែតស្កប់ស្កល់រាល់គ្នា មិនបានស្រុតស្រេកឡើយ។

**កៀងអ៊ុយ**និយាយនឹងទាហានទាំងពួងថា មហាឧបរាជព័ទ្ធ**សុម៉ាអ៊ី**ទុកបានម្តង តែចាប់ខ្លួនមិនបាន យើងក៏មានសេចក្តីខឹងក្តៅណាស់ គ្រានេះយើងឃើញថា **សុម៉ាចៀវ**មុខជាមិនផុតពីដៃយើងទេ យើងមុខជាចាប់បានខ្លួនជាប្រាកដហើយ។

ឯ**គួយហ្ស៊ួយ**នៅស្រុកអេងជីវបានដឹងថា **កៀងអ៊ុយ**ព័ទ្ធ**សុម៉ាចៀវ**ទុកលើភ្នំចៀតឡុងសាន់ហើយ ទើបប្រឹក្សានឹង**តាន់ថាយ**ថា នឹងលើកកងទ័ពទៅជួយឬ? **តាន់ថាយ**ឆ្លើយថា ដែលនឹងលើកទៅជួយនោះ ខ្ញុំនៅមានបារម្ភណាស់ ព្រោះ **កៀងអ៊ុយ**លើកទ័ពមកគ្រានេះ មានកងទ័ពស្រុកកៀងលើកមកផង លើកមកដល់ដែនស្រុកអាន់ណាំហើយ លុះដឹងថា លោកលើកទៅជួយ**សុម៉ាចៀវ**វេលាណា គង់ **កៀងអ៊ុយ**នឹងលើកត្រឡប់ទៅវាយយកស្រុកអេងជីវវិញ យើងនឹងមិនថ្លោះការទេឬ? ខ្ញុំបាទគិតថានឹងទម្លាយកងទ័ពស្រុកកៀងចេញមុន និងឲ្យជីករំលុងធំវែងស្នាក់

ពីមុខស្រុកទុក ហើយខ្ញុំបាទនឹងទៅបញ្ឆោត**ប៊ីតង**ចៅហ្វាយស្រុកកៀងឲ្យលើកមកវាយស្រុកយើង ហើយយើងនឹងកម្ចាត់**ប៊ីតង**ចេញ បើបានហើយសឹមលើកទៅជួយ**សុម៉ាចៀវ** នឹងមិនបាច់រវាំងក្រោយឡើយ។

**គួយហ៊្វីយ**យល់ឃើញត្រូវផង ក៏ប្រើ**តាន់ថាយ**នាំទាហានប្រាំពាន់ទៅបញ្ឆោត**ប៊ីតង**។ **តាន់ថាយ**ក៏លើកចេញទៅ លុះដល់ទៅជិតស្រុកកៀងហើយ ទើបប្រើទាហានឲ្យចងគ្រឿងសាស្ត្រាវុធរែកចូលទៅឲ្យ**ប៊ីតង**។ **តាន់ថាយ**ទៅដល់**ប៊ីតង**ហើយ ក៏ក្រាបចុះហើយយំ ៗហើយថា ខ្ញុំបាទធ្វើរាជការនឹង**គួយហ៊្វីយ**មានសេចក្ដីគាប់ប្រសើរណាស់ **គួយហ៊្វីយ**មិនបានលើកសេចក្ដីគាប់ប្រសើរនោះឲ្យខ្ញុំបាទពេញចិត្តសោះឡើយ តាំងខ្លួនជាធំហើយ គិតកម្ចាត់ខ្ញុំបាទចេញទៀត ខ្ញុំបាទមានសេចក្ដីតូចចិត្តណាស់ បានជាស្ម័គ្រចិត្តចូលមកនៅជាមួយលោក ព្រោះខ្ញុំបាទដឹងពីដើមថាលោកមានសតិបញ្ញាចេះចិញ្ចឹមរក្សាមនុស្សល្អៗ បានជាខ្ញុំបាទចូលមកនៅនឹងលោក ឯដែលនឹងវាយយកស្រុកអេងជីវនោះ ជាភ្នាក់ងារលើខ្ញុំបាទម្នាក់ឯងចុះ សុំកុំឲ្យលំបាកឡើយ សុំឲ្យលោកលើកកងទ័ពទៅក្នុងពេលយប់នេះចុះ ខ្ញុំបាទនឹងសុំទៅសងសឹកវិញឲ្យបាន។ **ប៊ីតង**ក៏ជឿស្ដាប់ចិត្តទើបបង្គាប់ឲ្យ**ងោហោ** និង**សៀវគួ**លើកទ័ពទៅជាមួយនឹង**តាន់ថាយ**។

ឯ**ងោហោ** និង**សៀវគួ**ក៏ឲ្យទាហាន**តាន់ថាយ**នៅរវាំងពីក្រោយ យកតែខ្លួន**តាន់ថាយ**ទៅមុនជាមួយផង។ លុះដល់ពេលយាមពីរយប់ ក៏លើកទៅដល់ស្រុកអេងជីវ ក្រឡេកទៅឃើញទ្វាកំពែងបើកចំហ **តាន់ថាយ**ក៏បំផាយសេះទៅប្រាប់**គួយហ៊្វីយ** ដែលត្រៀមកងទ័ពទុកនោះនាំគ្នាចេញមកវាយត្រឡប់ពីក្រោយ ទាហាន**តាន់ថាយ**ដែលតាមមកពីនាយនោះ ក៏ដេញកាប់សម្លាប់ពីក្រោយចូលទៅ ទាហាន**ងោហោ** និង**សៀវគួ**ក៏ធ្លាក់ចុះក្នុងរំលុងទាំងសេះ និងមនុស្សជាន់សង្កត់លើគ្នារបួសពិការស្លាប់ជាច្រើនណាស់ ទាហានដែលសល់ពីស្លាប់នោះ ក៏សុំចំណុះចុះចូលនៅនឹង**តាន់ថាយ**។

ឯ**ងោហោ** និង**សៀវគួ** ក៏យកដាវអារ-កស្លាប់ទាំងពីរនាក់ លុះព្រឹកឡើង**គួយហ៊្វីយ**និង**តាន់ថាយ**ក៏លើកចូលទៅវាយ**ប៊ីតង**ចៅហ្វាយស្រុកកៀង ដែលតាំងនៅ

ដែនស្រុកអាន់ណាំនោះ **ប៊ឹតង**ឃើញកងទ័ព**តាន់ថាយ**និង**គួយហ៊ួយ**ក៏មានសេចក្ដីខឹងក្ដៅណាស់ ឡើងសេះនាំទាហានចេញមកក្រៅបន្ទាយ។ ឯទាហាន**គួយហ៊ួយ**និង**តាន់ថាយ**ឃើញទាហាន**ប៊ឹតង**តិចណាស់ ក៏ចូលឃ្មុំរុំព័ទ្ធចាប់ខ្លួន**ប៊ឹតង**បាន ចងយកទៅឱ្យ**គួយហ៊ួយ** ៗក្រឡេកឃើញធ្វើជាភ័យភ្ញាក់ចុះពីលើសេះប្រញាប់ប្រញាល់ទៅស្រាយចំណងពីខ្លួន**ប៊ឹតង**ចេញអស់ ហើយនិយាយថា ព្រះចៅ**ចូហង**ទ្រង់ព្រះមេត្តាលោកណាស់ថា លោកជាមនុស្សទៀងត្រង់តាំងព្រះទ័យប្រុងតែនឹងទំនុកបម្រុងលោក ហេតុម្ដេចក៏លោកប្រែចិត្តទៅចូលខាង**កៀងអ៊ុយ**ដែលជាមនុស្សអាក្រក់នោះវិញ? **ប៊ឹតង**ក៏អង្វរករសុំអាយុជីវិតហើយថា ខ្ញុំបាទសុំធ្វើជាខ្ញុំព្រះចៅ**ចូហង**ទៅ។ **គួយហ៊ួយ**ថា បើដូច្នោះលោកចូរធ្វើជាមេទ័ពមុខ លើកទៅវាយ**កៀងអ៊ុយ**ដែលព័ទ្ធ**សុម៉ាចៀវ**ទុកនោះ បើសម្រេចរាជការហើយ យើងនឹងពិតទូលយកសេចក្ដីគាប់ប្រសើរឱ្យ **ប៊ឹតង**ក៏ទទួលអាសា។ លុះវេលាព្រលប់ក៏នាំពលលើកចេញទៅជាទ័ពមុខ លុះពេលយាមបីទៅដល់ជិតបន្ទាយ**កៀងអ៊ុយ** ហើយក៏ប្រើទាហានឱ្យចូលទៅប្រាប់**កៀងអ៊ុយ**ថា ទ័ព**ប៊ឹតង**លើកមកដល់ហើយ។ **កៀងអ៊ុយ**មានអំណរណាស់ក៏បង្គាប់ថា ឱ្យអញ្ជើញ**ប៊ឹតង**ចូលមកចុះ។ **ប៊ឹតង**នាំទាហានរបស់ខ្លួន និងទាហានរបស់**គួយហ៊ួយ**ចូលទៅជាមួយផងជាច្រើន **កៀងអ៊ុយ**ឃើញចម្លែកណាស់ទើបឃាត់ថា ឱ្យទាហានតាំងបន្ទាយនៅខាងក្រៅសិនចុះ ត្រូវអញ្ជើញតែខ្លួនអ្នក និងទាហានដែលតាមខាងក្រោយឱ្យចូលមកចុះ **ប៊ឹតង**ក៏នាំទាហាន**គួយហ៊ួយ** និងទាហានរបស់ខ្លួនដែលមានថ្វីដៃប្រហែលមួយរយនាក់ចូលទៅក្នុងបន្ទាយ **ប៊ឹតង**នៅមិនទាន់បង្គាប់ឱ្យធ្វើការអ្វី ស្រាប់តែពួកទាហានទាំងនោះឃើញបានចំណាប់ហើយក៏លើកគ្នាដេញកាប់សម្លាប់ពួកទាហានក្នុងបន្ទាយជាជ្រួលច្របល់ឡើង ទាហានខាងក្រៅក៏ពារទម្លាយចូលទៅក្នុងបន្ទាយបានព្រួតជួយគ្នា។

**កៀងអ៊ុយ**តក់ស្លុតស្មារតីណាស់ មិនទាន់នឹងកន្ត្រាក់ចាប់យកអាវុធ ក៏លោតឡើងលើសេះបររត់ទៅ ទាហានទាំងពួងក៏នាំគ្នារត់ចេញពីក្នុងបន្ទាយខ្ចាត់ខ្ចាយចេញទៅ **កៀងអ៊ុយ**មិនមានអាវុធកាន់សោះ ស្រវាចាប់បានតែដងធ្នូទទេ នៅជាប់ក្នុងចង្កេះ គ្មានព្រួញសោះធ្លាក់អស់ពីដៃ។ **គួយហ៊ួយ**ឃើញ**កៀងអ៊ុយ**ក៏បំផាយសេះ

ដេញ **កៀងអ៊ុយ**ក៏យឹតធ្នូតែបន្ដោះទទេ **គួយហ៊្វួយ**បានឮតែសំឡេងខ្សែបន្ដោះធ្នូមិនមានព្រួញសោះ **គួយហ៊្វួយ**ក៏យកស្រោមដាវធ្វើជាព្រួញបាញ់ទៅ **កៀងអ៊ុយ**ស្ទាក់ចាប់បានក៏បង្អង់នៅឲ្យ**គួយហ៊្វួយ**ស្ទុះចូលទៅជិត គ្នេរប្រមាណបានចំណាប់ហើយក៏បាញ់ត្រូវ**គួយហ៊្វួយ**ធ្លាក់ពីលើសេះ **កៀងអ៊ុយ**ក៏ត្រឡប់ទៅដណ្ដើមបានលំពែងសម្រាប់ដៃ**គួយហ៊្វួយ**លើកឡើងនឹងចាក់ ទទួលទាហាន**គួយហ៊្វួយ**ក៏ស្ទុះចូលទៅដល់ទាន់ **កៀងអ៊ុយ**ក៏រត់ទៅ។ ទាហានក៏នាំ**គួយហ៊្វួយ**វិលទៅបន្ទាយ តែល្មមកន្ត្រាក់ដកយកស្រោមដាវដែលមុតនោះបាន លោហិតក៏ហូរចេញមកច្រើនណាស់ **គួយហ៊្វួយ**ក៏ដាច់ខ្យល់ស្លាប់ **សុម៉ាចៀវ**ក៏នាំទាហានចុះពីលើភ្នំទៅជួយគ្នាដេញសត្រូវទៅ។

ឯ**ហែហ៊្វូប៉ា**រត់ទៅប្រទះនឹង**កៀងអ៊ុយ** ក៏នាំគ្នាត្រឡប់ទៅស្រុកហាន់តុងទើបប្រឹក្សាគ្នាថា យើងទៅទ័ពគ្រានេះ ខូចខាតទាហានច្រើនណាស់ តែថាបានប្រៀបដោយវំលាងនាយទាហានឯកដែលមានថ្វីដៃបានពីរនាក់ កូនទាហានក៏បានច្រើនដែលស្លាប់វិនាសនោះ សេចក្ដីខុសយើងក៏មាន សេចក្ដីគាប់យើងក៏បាន ទោះនឹងចូលទៅគាល់ក៏មិនទាន់ជាអ្វីទេ ថាហើយក៏នាំគ្នាចូលទៅគាល់ព្រះចៅ**ឡៅសៀន**ឯក្រុងសែឈួន។

និយាយអំពី**សុម៉ាចៀវ** ក៏បានឲ្យបំណាច់រង្វាន់ដល់**ប៊ឹតង** និងទាហានទាំងពួងតាមសមគួរ ហើយទើបបង្គាប់ថា អ្នកចូរវិលត្រឡប់ទៅស្រុកវិញចុះ ខ្ញុំចូលទៅគាល់នឹងទូលសេចក្ដីគាប់ឲ្យ **ប៊ឹតង**ក៏លាទាហានត្រឡប់ទៅស្រុកកៀង **សុម៉ាចៀវ**ក៏លើកទ័ពត្រឡប់ទៅក្រុងឡុកអៀង។

នោះ**សុម៉ាស៊ូ** និង**សុម៉ាចៀវ**បាននិយាយរាជការក្នុងស្រុកវុយកុក បណ្ដានាហ្មឺនមុខមន្ត្រីធំតូច ក៏សឹងនៅក្រោមបង្គាប់បញ្ជាទាំងអស់ បើនឹងខុសនិងត្រូវប្រការម្ដេចក៏រកនរណាទទឹងទាស់គ្មាន។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៨០

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**សុម៉ាស៊ូ**ឡើងអំណាច ព្រះចៅ**ចូហង**និងមន្ត្រីធំបីនាក់គិតការស្ងាត់នឹងកម្ចាត់**សុម៉ាស៊ូ** ៗដឹងសម្លាប់មន្ត្រីបីនាក់ និងព្រះអគ្គមហេសីស្តេច ដករាជសម្បត្តិ**ចូហង** តាំង**ចូម៉**ឲ្យឡើងសោយរាជសម្បត្តិ **សុម៉ាស៊ូ**ឡើងជាមហាឧបរាជ។ **សុម៉ាស៊ូ**ស្លាប់ **សុម៉ាចៀវ**ឡើងជាមហាឧបរាជជំនួសបង **កៀងអ៊ុយ**លើកទ័ពទៅច្បាំងនឹងស្រុកវុយកុក)។*

**ឯព្រះចៅចូហង**ចេញនិយាយរាជការវេលាណា បើបានឃើញមុខ**សុម៉ាស៊ូ**ចូលគាល់ក៏ឲ្យមានសេចក្តីខ្លាចក្រែងពេកណាស់ ថ្ងៃមួយនោះឃើញ**សុម៉ាស៊ូ**កាន់គ្រប៊ីដើរចូលទៅក្នុងទីគាល់ ស្តេចក៏ស្លុតព្រះទ័យលឿនព្រះអង្គរំពុកចុះពីព្រះទីនាំងកៅអី ស្តេចចេញទៅទទួលគំនាប់**សុម៉ាស៊ូ** ៗអស់សំណើចហើយថា មានទំនៀមពីណានឹងឲ្យអម្ចាស់ចេញទៅទទួលខ្ញុំឯងនោះ? អញ្ជើញឡើងទៅគង់លើព្រះទីនាំងវិញចុះទើបនឹងសមគួរ។

ឯអស់នាហ្មឺនមុខមន្ត្រីកំពុងតែប្រឹក្សាការរាជការ លុះឃើញ**សុម៉ាស៊ូ**ចូលទៅហើយក៏ស្ងៀមទាំងអស់គ្នា ព្រះចៅ**ចូហង**ក៏ទ្រង់ស្ងៀមមួយស្របក់ហើយក៏ត្រឡប់យាងចូលទៅក្នុង។ **សុម៉ាស៊ូ**ក៏ចេញចាកទីគាល់មិនមានសេចក្តីកោតក្រែងរអែងខ្លាចព្រះចៅ**ចូហង**សោះ ឡើងជិះលើរទេះមានទាហានប្រហែលមួយពាន់នាក់ ដៃកាន់សាស្ត្រាវុធហែហមអមព្រះអង្គចេញមកពីក្នុងវាំងត្រឡប់ទៅផ្ទះ ព្រះចៅ**ចូហង**ក្រឡេកទតឆ្វេងស្តាំឃើញមន្ត្រីធំជាទីប្រឹក្សានៅគាល់នៅទីនោះបីនាក់ ឈ្មោះ**ហែហៅហៀន១, លីហង១, ទៀវអ៊ិម**ជាបិតានាង**ទៀវហង**មហេសីស្តេច១ ព្រះចៅ**ចូហង**ទ្រង់បណ្តេញមនុស្សទាំងពួងឲ្យចេញអស់ហើយ ទើបទ្រង់ហៅមន្ត្រីទាំងបីនាក់ឲ្យចូលមកជិតព្រះអង្គ ៗចាប់ដៃ**ទៀវអ៊ិម**ហើយក៏ទ្រង់ព្រះកន្សែងសោកា

ហើយត្រាស់ថា សព្វថ្ងៃនេះ**សុម៉ាស៊ូ**មើលងាយយើងដូចកូនក្មេង មើលងាយនាហ្មឺនមុខមន្ត្រីទាំងពួងដូចស្មៅជើងក្រាស យើងមើលទៅឃើញមិនយូរទេរាជសម្បត្តិនេះក៏នឹងជារបស់**សុម៉ាស៊ូ**។

**លីហាង**ទូលថា ទូលព្រះបង្គំជាខ្ញុំនេះ មិនមានសតិបញ្ញាដែលនឹងជួយព្រះអង្គបាន តែទូលព្រះបង្គំជាខ្ញុំគិតថា នឹងសុំត្រាព្រះតម្រាស់របស់ព្រះអង្គចេញទៅបញ្ចុះបញ្ចូលអាណាខេត្តទាំងពួងនឹងបានរកមនុស្សល្អមានសតិបញ្ញា មានថ្វីដៃខ្លាំងពូកែ និងទាហានទាំងពួងបានច្រើន ហើយនឹងចូលមកកម្ចាត់អាសត្រូវផែនដីចេញឲ្យបាន។ **ហែហៅហៀន**ក្រាបទូលថា **ហែហ្វ៊ីប៉ា**ជាបងទូលព្រះបង្គំជាខ្ញុំ រត់ចូលទៅនៅនឹងព្រះចៅ**ឡៅសៀន** ព្រោះពួក**សុម៉ាស៊ូ**ប្រុងនឹងធ្វើអន្តរាយ។ បើបងទូលព្រះបង្គំជាខ្ញុំដឹងថាព្រះអង្គនឹងកម្ចាត់**សុម៉ាស៊ូ** ក៏នឹងត្រឡប់មកជួយ ទូលព្រះបង្គំជាខ្ញុំជាពូជព្រះរាជវង្ស កើតហេតុដូច្នេះហើយនឹងស្ងៀមនៅបានឬ? នឹងសុំទៅបញ្ចុះបញ្ចូលជាមួយនឹង**លីហាង**។

ព្រះចៅ**ចូហាង**ទ្រង់ត្រាស់ថា យើងញញើតណាស់ ក្រែងធ្វើទៅមិនសម្រេច មន្ត្រីទាំងពីរនាក់យំហើយទូលថា ទូលព្រះបង្គំជាខ្ញុំតាំងសត្យស្បថស្បាន់ព្រមនឹងគ្នានឹងរិះគិតកម្ចាត់អាសត្រូវផែនដីឲ្យបាន។ ព្រះចៅ**ចូហាង**ទើបផ្តាស់ស្នងព្រះអង្គពីខាង ជាន់ក្នុងមកកាត់ជាប្រហោង ហើយកាត់ម្រាមព្រះហស្តយកព្រះលោហិតសរសេរជាព្រះតម្រាស់ ដាក់ក្នុងព្រះស្រទាប់ឆ្លងព្រះអង្គនោះ ហើយប្រគល់ឲ្យ**ទៀវអ៊ិម**រួចត្រាស់ថា កាលគ្រាព្រះចៅ**ចូឆូ**ជាព្រះអយ្យកោទួតនៃយើងសម្លាប់ពួក**តាំងស៊ិន**ចេញអស់នោះ ព្រោះធ្វើការមិនជិត ឥឡូវអ្នកទាំងបីនាក់នឹងធ្វើគ្រានេះ បើនាំឲ្យបែកធ្លាយហើយក៏មិនជាការល្អ។ **លីហាង**ទូលថា នៅមិនទាន់បានជាការអ្វី ព្រះអង្គមកមានព្រះវាចាជាប្រផ្នូលដូច្នេះមិនគួរទេ។ ទូលព្រះបង្គំជាខ្ញុំមិនមែនល្ងង់ភ្លើដូច**តាំងស៊ិន**នោះទេ។ **សុម៉ាស៊ូ**វានឹងស្រួចយ៉ាងណាទៅ! វាមិនមែនដូចជាព្រះចៅ**ចូឆូ**ទេ ព្រះអង្គកុំទ្រង់ព្រួយព្រះទ័យឡើយ។ ទូលហើយក៏ថ្វាយបង្គំចេញមក។

ខណៈនោះមានមនុស្សនាំយកសេចក្តីកំបាំងនេះទៅប្រាប់**សុម៉ាស៊ូ** ៗខឹងណាស់ កាន់គ្រប៊ីនាំទាហានប្រាំរយសុទ្ធតែកាន់អាវុធគ្រប់ដៃចូលទៅដល់ទ្វារព្រះ

រាជវាំង ទទួលជួបប្រទះនឹង**ហែហៅហៀន**, **លីបង** និង**ទៀវអ៊ិម** ៗខ្លាចក៏ចៀសទៅបំបាំងនឹងពួកទ្វារព្រះរាជវាំង **សុម៉ាស៊ូ**សួរដណ្ដឹងថា អស់នាហ្មឺនមុខមន្ត្រីទាំងពួងគេចេញពីទីគាល់ព្រមគ្នាហើយ អ្នកឯងទាំងបីនាក់នៅយូរទើបចេញមកក្រោយគេនោះតើខ្លួនមានគិតការអ្វី? ទាំងបីនាក់ឆ្លើយថា ដ្បិតទ្រង់ចង់សណ្ដាប់ព្រះរាជពង្សាវតារ ឱ្យខ្ញុំបាទមើលថ្វាយ។ **សុម៉ាស៊ូ**សួរថា ឱ្យមើលរឿងអ្វី? **លីហង**ថា មើលរឿង**អ៊ីអ៊ិន** គឺ**ជីវថង**ជាមហាឧបរាជ លុះមើលដល់ឈ្មោះនេះ ទ្រង់សួរថា **អ៊ីអ៊ិន** និង**ជីវថង**បានបម្រុងផែនដីដល់ពីររាជ្យនោះ តើគឺធ្វើយ៉ាងម្ដេច? ខ្ញុំបាទទាំងបីនាក់ទូលថា បម្រុងដូចព្រះតេជគុណរក្សាផែនដីដូចសព្វថ្ងៃនេះ។ **សុម៉ាស៊ូ**ក្លែងធ្វើអស់សំណើចហើយថា អ្នកឯងទាំងបីនាក់ស្ទួយរូបយើងយកទៅប្រៀបផ្ទឹមនឹងរូប**អ៊ីអ៊ិន** ហើយនិង**ជីវថង**ម្ល៉ឹងឬ? យើងអាចដឹងដល់ទឹកចិត្តអ្នកឯងទាំងអស់ហើយ គឺអ្នកឯងយកយើងទៅប្រៀបដូចជា**អងម៉ាំង** និង**តាំងតុះ** ដែលជាសត្រូវនឹងរាជសម្បត្តិនោះទេតើ! ទាំងបីនាក់ឆ្លើយថា យើងខ្ញុំក៏ជាខ្ញុំព្រះតេជគុណប្រាកដ ដែលនឹងគិតថាទៅដូច្នោះនោះមិនគួរទេ។

**សុម៉ាស៊ូ**ខឹងណាស់ថា អាបីនាក់ អាឯងញុះញង់ទូលសេចក្ដីស្ងាត់កំបាំងហើយយំដោយហេតុអ្វី? ទាំងបីនាក់ក៏បដិសេធថាមិនមែនទេ។ **សុម៉ាស៊ូ**ក៏ស្រែកគំហកហើយថា ឯងយំនៅភ្នែកមិនទាន់បាត់ក្រហមទេ តើគួរឬមកបដិសេធដូច្នេះវិញ? **ហែហៅហៀន**ឃើញការដែលធ្វើនោះបែកធ្លាយហើយក៏ឆ្លើយថា អញយំនោះ ព្រោះអាឯងរិះគិតជាក្បត់នឹងដណ្ដើមយករាជសម្បត្តិ។ **សុម៉ាស៊ូ**ក៏បង្គាប់ឱ្យទាហានព្រួតចាប់ខ្លួនអ្នកទាំងបីនាក់ **ហែហៅហៀន**តែដៃទទេ ក៏តាំងឃុំដៃចូលទៅដាល់តប់**សុម៉ាស៊ូ** នោះទាហានក៏ស្ទុះទៅព្រួតចាប់ខ្លួនបាន **សុម៉ាស៊ូ**ក៏ឱ្យស្រាវជ្រាវរើរកនូវខ្លួន ក៏ឃើញឡាយព្រះហស្តដែលស្ដេចលិខិតត្រាស់បង្គាប់លាក់ក្នុងស្រទាប់អាវ**ទៀវអ៊ិម** ហើយយកមកមើលឃើញសេចក្ដីថា “**សុម៉ាស៊ូ** និងស្ម័គ្របក្សពួកវារិះគិតជាក្បត់នឹងដណ្ដើមយករាជសម្បត្តិ បើមុខមន្ត្រីណាមានចិត្តស្វាមីភក្តិដល់យើង ចូរស្រូតរិះគិតជាប្រញាប់ដើម្បីនឹងកម្ចាត់សត្រូវផែនដីនេះឱ្យបាន យើងនឹងឱ្យលឿនទីយសសក្តិ និងបំណាច់រង្វាន់ឱ្យធួនដល់ចិត្ត”។ **សុម៉ាស៊ូ**ឃើញដូច្នោះ

ក៏ខឹងខ្លាំងណាស់ថា យើ! អាពួកអស់នេះ វាគិតធ្វើអន្តរាយអញទេតើ! ទោសវាជាទម្ងន់ណាស់ នឹងលើកលែងក៏មិនបាន ទើបបង្គាប់ឲ្យយកនាហ្មឺនទាំងបីនាក់ទៅប្រហារជីវិតកណ្តាលផ្លាផ្សារអស់ទាំងគោត្រ។ ទាំងបីនាក់នោះក៏ស្រែកជេរ**សុម៉ាស៊ូ**ដោយពាក្យទ្រគោះតាមអំពើក្តៅ ពួកទាហានក៏យកកាំបិតពូថៅវាយមាត់បំបាក់ធ្មេញទាំងបីនាក់អស់ អ្នកទាំងបីនាក់នោះក៏មិនឈប់ស្ងៀម រឹតតែគំរាមស្រែកជេរទាល់ស្លាប់។ **សុម៉ាស៊ូ**ក៏ចូលទៅក្នុងវាំង។

ខណៈនោះ ព្រះចៅ**ចូហង**កំពុងប្រឹក្សាការជាមួយនឹងនាង**ទៀវហងហៅ** ក៏ទូលថា ក្នុងវាំងនេះមានមនុស្សច្រើនណាស់ បើសេចក្តីនេះបែកផ្សាយទៅ ខ្ញុំម្ចាស់ក៏នឹងក្ស័យស្លាប់អសារ។ និយាយមិនទាន់ផុតមាត់ ស្រាប់តែក្រឡេកទៅឃើញ**សុម៉ាស៊ូ**កាន់គ្រប៊ីដើរចូលទៅ។ លុះចូលទៅដល់ហើយ **សុម៉ាស៊ូ**និយាយថា បិតាទូលព្រះបង្គំជាខ្ញុំបានលើកតម្កើងព្រះអង្គឲ្យបានសោយរាជសម្បត្តិ ទោះបី**ជីវថង**មហាឧបរាជពីបុរាណដែលមានអំណាចណាស់ ក៏យកមកផ្ទឹមប៉ះនឹងបិតាទូលព្រះបង្គំជាខ្ញុំពុំបាន ទូលព្រះបង្គំជាខ្ញុំបានទំនុកបម្រុងព្រះអង្គដរាបមក ទោះបី**អ៊ីអ៊ិន**ពីដើមដែលជាមហាឧបរាជនោះ ក៏មិនបានធ្វើឲ្យដូចទូលព្រះបង្គំជាខ្ញុំទេ គុណដែលមានមកពីដើមទាំងប៉ុន្មានក៏សូន្យទៅអស់ហើយ ព្រោះព្រះអង្គមកស្តាប់ពាក្យញុះញង់ ហើយទ្រង់ត្រឡប់គិតប្រទូសរ៉ាយទូលព្រះបង្គំជាខ្ញុំវិញ។ ព្រះចៅ**ចូហង**ឆ្លើយតបថា យើងមិនមែនគិតធ្វើដូច្នោះទេ។

**សុម៉ាស៊ូ**ក៏ហូតយកអាវឆ្លងព្រះអង្គចោលចំពោះមុខព្រះភក្ត្រ លើកដៃចង្អុលហើយថា នេះរបស់នរណា ៗធ្វើនេះ? ព្រះចៅ**ចូហង**ភ្ញាក់ស្លុតព្រះទ័យមិនមានព្រះស្មារតីសោះ មានព្រះអង្គញ័រចំប្រប់ តែប្រឹងទប់ឆ្លើយថា យើងធ្វើការដូច្នោះ ពីព្រោះមានគេបង្គាប់ឲ្យធ្វើ ខ្លួនយើងមិនបានគិតធ្វើលោកទេ។ **សុម៉ាស៊ូ**ថា ធ្វើខ្លួនឯងត្រឡប់ឆ្លើយដាក់គេដទៃវិញ ទោសព្រះអង្គខុសធ្ងន់យ៉ាងនេះហើយ តើនឹងរិះគិតដូចម្តេចទៅវិញ? ព្រះចៅ**ចូហង**ស្លុតព្រះទ័យណាស់ ក៏ក្រោកលុតជង្គង់ដាក់ព្រះអង្គចុះហើយថា ទោសខ្ញុំខុសណាស់ហើយ សុំឲ្យលោកអត់ទោសខ្ញុំចុះ។ **សុម៉ាស៊ូ**ថា ព្រះអង្គជាបង្គោលផែនដី ទូលព្រះបង្គំមិនធ្វើអន្តរាយដល់ព្រះអង្គទេ អញ្ជើញស្តេចឡើង

គង់លើព្រះទីនាំងតាមសមគួរចុះ ថាហើយក៏ចង្អុលមុខនាង**ទៀវហងហៅ**នឹងគ្របឺថា នាងនេះជាបុត្រ**ទៀវអ៊ិម** ត្រូវតែប្រហារជីវិតឲ្យស្លាប់តាមបិតា។ ព្រះចៅ**ចូហង**ក៏ទ្រង់ព្រះកន្សែងអង្វរសុំជីវិតនាង**ទៀវហងហៅ**។ **សុម៉ាស៊ូ**ក៏មិនស្តាប់ បង្គាប់ទាហានឲ្យចាប់ដឹកកន្ត្រាក់យកខ្លួនទៅ ពួកទាហាននាំនាងទៅដល់មាត់ទ្វារទិសខាងកើត ក៏ឲ្យនាងយកព្រៃរុំក ទាហានក៏ចាប់ទាញព្រៃម្ខាងម្នាក់រឹតទាល់តែបែកបំពង់កស្លាប់។

លុះពេលព្រឹកឡើង **សុម៉ាស៊ូ**ឲ្យហៅអស់នាហ្មឺនមន្ត្រីតូចធំទាំងអស់ មកប្រជុំព្រមគ្នានៅទីសាលាជំនុំរាជការ ទើបប្រឹក្សាគ្នាថា ព្រះចៅ**ចូហង**មិនយកព្រះទ័យទុកដាក់ក្នុងរាជកិច្ចទាំងពួង រមែងជឿស្តាប់តាមពាក្យមនុស្សអាក្រក់វាញុះញង់ នឹងឲ្យស្រុកទេសជាចលាចល ឥឡូវខ្ញុំគិតយល់ថា នឹងឲ្យស្តេចនេះនៅក្នុងរាជសម្បត្តិពុំបាន ត្រូវតែលើកយកចេញផុត ហើយយើងនឹងរើសរកព្រះរាជបុត្រនតោឯណាដែលមានសតិបញ្ញាឆ្លៀវឆ្លាត គួរនឹងទទួលរាជសម្បត្តិបាន ៗឱហាតត្រួតត្រាផែនដីតទៅ។ តើអស់អ្នកទាំងឡាយនឹងយល់ឃើញប្រការម្តេច?

អស់នាហ្មឺនមុខមន្ត្រីទាំងពួងឆ្លើយថា លោកជាមហាឧបរាជសម្រេចរាជការមានសតិបញ្ញាជ្រៅទូលាយណាស់ លោកបានត្រិះរិះយល់សមគួរយ៉ាងណា ហើយមកប្រឹក្សាតើនរណានឹងអាចទទឹងអធ្យាស្រ័យលោកបាន? ព្រោះលោកមានប្រសាសន៍នេះគួរនឹងការរាជការផែនដី។ **សុម៉ាស៊ូ**ក៏នាំនាហ្មឺនមុខមន្ត្រីទាំងនោះ ចូលទៅគាល់ព្រះនាង**គួយថាយហៅ** ទូលស្នើតាមសេចក្តីដែលយល់ឃើញថ្វាយព្រះសណ្តាប់គ្រប់ប្រការ។ ព្រះនាង**គួយថាយហៅ**ក៏សួរថា បើដូច្នោះអស់អ្នកនឹងលើកយកនរណាឡើងជាម្ចាស់ផែនដីវិញ? **សុម៉ាស៊ូ**ទូលថា ទូលព្រះបង្គំជាខ្ញុំពិគ្រោះមើលឃើញថា **ចូគី**ជាពូជព្រះរាជវង្ស សព្វថ្ងៃនៅធ្វើជាចៅហ្វាយស្រុកផែសៀ ឈ្មោះជាមនុស្សមានសតិបញ្ញាឆ្លៀវឆ្លាតមុតមាំណាស់ ឃើញត្រូវនឹងធ្វើអម្ចាស់ផែនដីបាន។

ព្រះនាង**គួយថាយហៅ**ឆ្លើយថា មិនគួរទេ។ យើងពិគ្រោះមើលទៅឃើញថា នឹងយកមាមកសោយរាជ្យជំនួសក្មួយនោះ មិនត្រូវនឹងទំនៀមទម្លាប់សណ្តាប់ប្រវេណី **ចូម៉**ក្មួយព្រះចៅ**ចូភី**ជាចៅហ្វាយស្រុកង្វូនសៀ ឆ្លាតឆ្លៀវមានសតិបញ្ញា

ល្មមនឹងរក្សាផែនដីបាន សុំឲ្យអ្នកទាំងពួងប្រឹក្សាគ្នាមើលចុះ។ **សុម៉ាស៊ូ**ទូលតបថា ដែលទ្រង់មានព្រះសុវនីយ៍នោះប្រពៃណាស់ ដែលនឹងលើករាជសម្បត្តិឲ្យ**ចូម៉**នោះឃើញសមគួរហើយ។ អស់នាហ្មឺនមុខមន្ត្រីក៏យល់ឃើញព្រមផង **សុម៉ាស៊ូ**ក៏ឲ្យបម្រើកាន់សំបុត្រទៅអញ្ជើញ**ចូម៉**មក ហើយទូលព្រះនាង**គួយថាយហៅ**ថា សុំអញ្ជើញព្រះអង្គយាងឡើងទៅលើសាលានិយាយរាជការ នឹងបានប្រឹក្សាទោសព្រះចៅ**ចូហង**។

ព្រះនាង**គួយថាយហៅ** ក៏ចូលទៅអញ្ជើញព្រះចៅ**ចូហង**ចេញមកគង់លើសាលានិយាយរាជការ ហើយព្រះនាងត្រាស់ថា ចៅបានសោយរាជសម្បត្តិ ប្រព្រឹត្តមិនត្រូវតាមគន្លងធម៌ និងទំនៀមទម្លាប់ក្សត្រអំពីបុរាណ ប្រព្រឹត្តខ្លួនប្រាណជាមនុស្សអន្ធពាលស្រើបស្រាលដោយល្បែងស្រាល្បែងស្រី មានប្រក្រតីស្រវឹងជានិរន្តរ៍ មិនសមគួរជាម្ចាស់ផែនដី គឺគ្មានយកហឫទ័យទុកដាក់នឹងសេចក្តីសុខទុក្ខអាណាប្រជានុរាស្ត្រសោះ ដែលធ្វើដូច្នោះនឹងតាំងនៅជាម្ចាស់ផែនដីតទៅទៀតពុំសមគួរ។ វេលានេះអស់នាហ្មឺនមុខមន្ត្រីធំតូចរាល់គ្នា គេបានប្រឹក្សាជំនុំយល់ព្រមឃើញថា ខ្លួនចៅនឹងនៅជាម្ចាស់ផែនដីតទៅទៀតពុំបានទេ ត្រូវតែចៅនាំយកព្រះសែងគ្រប៊ី និងត្រាសម្រាប់រាជមកប្រគល់ឲ្យនាហ្មឺនគេចុះ គេនឹងបានលើកយករូបមនុស្សដទៃ ដែលមានសតិបញ្ញាឲ្យឡើងសោយរាជសម្បត្តិជាម្ចាស់តទៅ ឯខ្លួនចៅត្រូវវិលទៅទទួលនាទីរាជការ ជាទីចើអងតាមលំអានព្រះបិតាតាំងទុកពីដើមនោះចុះ បើមិនមានព្រះតម្រាស់ឲ្យហៅទេ មិនត្រូវចូលគាល់ឡើយ។ **ចូហង**ក៏យកព្រះសែងគ្រប៊ី និងត្រាសម្រាប់រាជ្យមកប្រគល់ ហើយក៏ក្រាបបង្គំលាព្រះនាង**គួយថាយហៅ**យំហើយដើរចេញទៅ មាននាហ្មឺនប្អូនប្រាំនាក់នឹករឭកដល់គុណ**ចូហង**ទប់ទឹកភ្នែកពុំបានក៏នាំគ្នាយំហើយតាមជូនទៅ **ចូហង**ក៏នាំគ្រប់គ្រួចេញទៅនៅទីដំណាក់ដើមនៃខ្លួន។

ឯ**ចូម៉**ចូលមកដល់ទិសខាងជើង **សុម៉ាស៊ូ**ក៏ចាត់អស់នាហ្មឺនមុខមន្ត្រីធំតូចឲ្យចេញទៅទទួល អស់នាហ្មឺនទៅដល់ក៏ធ្វើគំនាប់ **ចូម៉**ចុះពីលើរទេះសេះហើយ ក៏ធ្វើគំនាប់អស់នាហ្មឺនទាំងពួង។ **អងសុក**ជានាហ្មឺនធំម្នាក់និយាយថា ព្រះអង្គកុំធ្វើ

គំនាប់អស់យើងខ្ញុំម្ចាស់ឡើយ។ **ចូម៉**តបថា ខ្លួនខ្ញុំនេះក៏ជាខ្ញុំផែនដីនឹងមិនគំនាប់អស់លោកក៏មិនគួរ នោះអស់នាហ្មឺនក៏នាំគ្នាពច**ចូម៉**ដាក់លើរទេះបរចូលទៅក្នុងព្រះរាជវាំង។ **ចូម៉**នៅកោតក្រែងមិនព្រមជិះរទេះ នោះមានព្រះតម្រាស់ព្រះនាង**គួយថាយហៅ**ឲ្យ**ចូម៉**ចូលគាល់។ **ចូម៉**ក៏ក្រាបចុះ **សុម៉ាស៊ូ**ទាញដៃ**ចូម៉**ឲ្យក្រោកឡើងហើយទើបប្រស្រ័យថា លោកបានសេចក្ដីសុខសប្បាយទេឬ? ថាហើយក៏នាំចូលទៅគាល់ព្រះនាង**គួយថាយហៅ** ៗត្រាស់ថា កាលនៅពីតូច យើងបានពិគ្រោះមើលឃើញប្លែក ទាំងកិរិយាមារយាទនិងលក្ខណៈរាសីល្អណាស់ ប្លែកខុសពីក្មេងទាំងពួងយើងក៏នឹកតែក្នុងចិត្តថា ចៅគង់នឹងបានជាម្ចាស់ផែនដីប្រាកដ ឥឡូវឃើញពិតដូចគំនិតនឹកទុក វេលានេះ អស់នាហ្មឺនមុខមន្ត្រីជំនុំយល់ព្រមគ្នា ត្រូវឲ្យចៅសោយរាជសម្បត្តិតពូជព្រះរាជវង្ស បើចៅបានជាម្ចាស់ផែនដីហើយ ចូរតាំងនៅក្នុងសត្យសុចរិតឧស្សាហ៍យកចិត្តទុកដាក់ក្នុងកិច្ចរាជការទាំងពួង បើនឹងធ្វើការអ្វីគប្បីឲ្យពិគ្រោះឲ្យហ្មត់ចត់ល្អ ឲ្យដឹងច្បាស់ក្នុងខខុសត្រូវទោសគុណធ្ងន់ស្រាល កុំស្រវឹងរោលរាលទៅដោយការលេងល្បែងពាលមានស្រា និងស្រីជាដើម។ ចូរប្រព្រឹត្តខ្លួនតាមទំនៀមទម្លាប់ច្បាប់បុរាណរាជប្រវេណី ដែលជាទីវង្សក្សត្រសោយរាជសម្បត្តិតៗមកពីដើម។

**ចូម៉**ទូលថា ទូលព្រះបង្គំជាខ្ញុំមានសតិបញ្ញាតិចណាស់ មិនគួរនឹងស្វែងស្វះទទួលនូវរាជសម្បត្តិបានទេ។ ព្រះនាង**គួយថាយហៅ** នូវអស់មុខមន្ត្រីក៏មិនស្ដាប់ចេះតែលួងលោមអញ្ជើញដល់បីគ្រា ទើប**ចូម៉**ទទួល។ **សុម៉ាស៊ូ** និងអស់នាហ្មឺនមុខមន្ត្រីទាំងពួង ក៏ព្រមគ្នាអញ្ជើញ**ចូម៉**ទៅកាន់ព្រះទីនាំងចុងព្រះរាជរោងរម្យ ទើបលើកថ្វាយនូវព្រះសែងគ្រប៊ី និងត្រាសម្រាប់រាជ្យឲ្យ**ចូម៉** ៗក៏បានតាំងនៅក្នុងសម្បត្តិក្សត្រតាំងពីថ្ងៃនោះមក ទើបថ្វាយព្រះនាមថា ព្រះចៅ**ចេងង្ងួន** (ព.ស ៧៩៧) ព្រះចៅ**ចូម៉**ក៏ទ្រង់បើកលែងមនុស្សទោសទាំងអស់ ហើយលើកលែងយកពន្ធសួយសារអាករទាំងពួងតាមបុរាណរាជប្រវេណីក្សត្រ ដែលសោយរាជសម្បត្តិរៀងមកនោះ ហើយតាំង**សុម៉ាស៊ូ**ជាមហាឧបរាជ កាលបើចូលគាល់ ឲ្យមានមនុស្សកាន់គ្រឿងសាស្ត្រាវុធហែចូលទៅ លុះដល់ជិតទីស្ដេច ហើយហាមមិនឲ្យថ្វាយបង្គំ

គ្រាន់តែធ្វើគំនាប់ហើយអង្គុយចុះ លុះនឹងពិតទូលពីការអ្វីក៏ហាមមិនឲ្យចេញនាមខ្លួនដូចមន្ត្រីទាំងពួង ហើយឲ្យនាហ្មឺនទាំងពួងធំតូចលឿនទីតាមគុណបំណាច់។

ព្រះចៅ**ចូម៉**សោយរាជ្យបានពីរឆ្នាំ។ លុះដល់ខែមេឃ **ប៊ូយីវខៀម**ពួកស្រុកកោឡាំទៅឈរធ្វើចៅហ្វាយស្រុកកេងជីវ បានស្រដីត្រួតលើខេត្តហ្លួយឡាំ ខេត្តឈីនឈុនផង លុះដឹងថា**សុម៉ាស៊ូ**អហង្ការនិរទេសម្ចាស់ផែនដីចេញហើយ យកអ្នកឯងទៀតមកតាំងឡើងតាមអំពើចិត្តឯង ក៏មានសេចក្ដីខឹងខ្លាំងណាស់ នោះ**ប៊ូយីវទៀន**ជាបុត្រនិយាយនឹងបិតាថា លោកអាពុកបានជាចៅហ្វាយស្រុក មានយសស័ក្តិអាជ្ញាសិទ្ធិនៅក្នុងដៃ ដែល**សុម៉ាស៊ូ**ធ្វើដូច្នេះ យើងនឹងស្ងៀមមិនគួរទេ។ **ប៊ូយីវខៀម**ថា ដែលចៅនិយាយដូច្នេះប្រពៃណាស់។ ទើបឲ្យអញ្ជើញ**ប៊ុនឃឹម**ដែលជាបក្សពួករបស់**ចូសង** មកខាងក្រោយផ្ទះជាទីស្ងាត់ ធ្វើគំនាប់គ្នាហើយក៏អង្គុយនៅមិនទាន់នឹងចរចាគ្នាក៏យំសោកាល័យ។ **ប៊ុនឃឹម**សួរថា ហេតុអ្វីបានជាយំ **ប៊ូយីវខៀម**ក៏ប្រាប់រឿងទាំងពួងឲ្យស្ដាប់ហើយថា ហេតុដូច្នេះបានជាខ្ញុំមានសេចក្ដីឈឺចិត្តណាស់។ **ប៊ុនឃឹម**ថា លោកគិតធ្វើការបម្រុងផែនដីដូច្នេះគួរណាស់ហើយ ខ្ញុំបាទនឹងជួយឲ្យអស់ពីចិត្ត បុត្ររបស់ខ្ញុំបាទម្នាក់ឈ្មោះ**ប៊ុនសេក**មានកម្លាំងច្រើនណាស់ អាចសត្វូនឹងមនុស្សមួយម៉ឺននាក់បាន វាក៏ខឹងក្ដៅណាស់ដែរ គិតតែនឹងកម្ចាត់**សុម៉ាស៊ូ**ចេញ ដើម្បីសងសឹកជួស**ចូសង** បើយើងនឹងលើកទ័ពទៅ ត្រូវតាំងវាជាមេទ័ពមុខ មុខជានឹងបានជ័យជម្នះសត្រូវជាប្រាកដ។ **ប៊ូយីវខៀម**ឮដូច្នោះក៏មានអំណរណាស់ ទើបចាក់សុរាដាក់ពែង ហើយលើកឡើងតាំងសត្យាធិដ្ឋានស្បថស្បាន់តគ្នា ហើយឲ្យទៅបញ្ចុះបញ្ចូលនាយទាហានស្រុកហ្លួយឡាំថា នាង**គួយថាយហៅ**មានព្រះតម្រាស់បង្គាប់ឲ្យទាហានទាំងពួង ទៅឲ្យព្រមគ្នាដល់ស្រុកឈីវឈុន លុះទាហានទាំងអស់ចូលទៅព្រមគ្នាហើយ ក៏ឲ្យតាំងរោងពិធីខាងទិសបស្ចិមឲ្យសម្ដាប់សេះសមួយ យកឈាមមកកូរលាយទឹកវិភ័ទ្ទសច្ចាឲ្យទាហានទាំងពួងផឹក ហើយថា **សុម៉ាស៊ូ**វាក្បត់នឹងផែនដី នាង**គួយថាយហៅ**មានព្រះតម្រាស់បង្គាប់មកឲ្យយើងលើកទ័ពទៅកម្ចាត់**សុម៉ាស៊ូ**ចេញ អស់ពលទាហានបានឮដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ ព្រមចិត្តគ្នាដែលនឹងកម្ចាត់**សុម៉ាស៊ូ**។ **ប៊ូយីវខៀម**ក៏នាំទាហានប្រាំម៉ឺន

លើកទៅតាំងនៅស្រុកហាងសៀ **ប៊ុនឃីម**នាំទាហានពីរម៉ឺនជាទ័ពឈ្លួន **ប៊ូឃីវខៀម**មានសំបុត្រទៅដល់អាណាខេត្តឡើងឲ្យលើកទាហានមកជួយ។

ឯ**សុម៉ាស៊ូ**ឈឺភ្នែកជាខ្លាំង ឲ្យពេទ្យទៅកាត់ហើយដាក់ថ្នាំរក្សាជាយូរថ្ងៃ ទទួលបម្រើសេះទៅប្រាប់ថា កងទ័ពស្រុកហ៊្វយឡាំលើកមក នោះ**សុម៉ាស៊ូ**ក៏ឲ្យអញ្ជើញ**អងសុក**ជានាហ្មឺនធំចូលទៅប្រឹក្សាថា ដ្បិតកងទ័ព**ប៊ូឃីវខៀម**លើកមក តើយើងនឹងរិះគិតប្រការម្ដេច? **អងសុក**ថា កាលគ្រា**គួនអ៊ូ**ជាទាហានឯក មានថ្វីដៃខ្លាំងពូកែប្រាកដទូទាំងផែនដី **លីបង**រិះគិតបញ្ចុះបញ្ចូលគ្រប់គ្រួទាហាន ដែលនៅក្នុងស្រុកកេងជីវបាន ហើយក៏មានជ័យជម្នះដល់**គួនអ៊ូ** គ្រានេះខ្ញុំគិតថានឹងឲ្យទៅបញ្ចុះបញ្ចូលគ្រប់គ្រួទាហានស្រុកហ៊្វយឡាំ ដែលនៅក្នុងដែនស្រុកវុយកុក បើបានហើយយើងនឹងលើកកងទ័ពទៅតាំងស្កាត់ទុកនៅផ្លូវ **ប៊ូឃីវខៀម**នឹងត្រឡប់ទៅឯងយើងគង់មានជ័យជម្នះជាប្រាកដ។

**សុម៉ាស៊ូ**ថា អ្នកនិយាយនេះត្រូវណាស់ តែថាខ្ញុំនៅឈឺនឹងទៅឯងមិនបាន ដែលនឹងឲ្យមនុស្សដទៃទៅជំនួស ខ្ញុំក៏មិនទុកចិត្តជាបានការក្រែងធ្វើឲ្យខូចការទៅ **ចុងហោយ**នាយទាហានធំឆ្លើយថា ទាហានស្រុកហ៊្វយឡាំខ្លាំងពូកែណាស់ ដែលនឹងឲ្យអ្នកដទៃទៅជំនួសក្រែងនឹងតទល់មិនឈប់ ការគ្រានេះជាការធំ បើខុសភ្លាត់ហើយនឹងខូចរាជការទៅ។ **សុម៉ាស៊ូ**ក៏មានៈក្នុងចិត្តក្រោកឡើងឈរហើយថា ខ្ញុំឈឺប៉ុណ្ណោះមិនទាន់ជាអ្វីប៉ុន្មានទេ ត្រូវតែទៅខ្លួនឯងទើបបានការ។ ថាហើយក៏ឲ្យ**សុម៉ាចៀវ**នៅរក្សាស្រុក ទើបឲ្យ**ជូកាត់ទុន**នាយទាហានជាមេទ័ពស្រុកអ៊ីជីវលើកទៅវាយស្រុកឈីវឈុន ឲ្យ**អាវជុន**នាយទាហានជាមេទ័ពស្រុកសេងជីវ លើកទៅស្កាត់នៅតំបន់ចៀវសងជាផ្លូវសត្រូវនឹងត្រឡប់ទៅ ឲ្យ**អងទី**នាយទាហានទៅវាយតំបន់ទិនឡាំ ឯខ្លួន**សុម៉ាស៊ូ**ជាមេទ័ពហ្លួង ជិះរថលើកទ័ពទៅតាំងនៅស្រុកសុងយ៉ុង។ នាហ្មឺន និងទាហានទាំងពួងអង្គុយព្រមគ្នារិះគិតការដែលនឹងឲ្យមានជ័យជម្នះដល់សត្រូវ។

**តេងប៉ោ**ទីប្រឹក្សា**ប៊ូឃីវខៀម**នោះ មានសតិបញ្ញាចេះរិះគិតណាស់ តែថានឹងរិះគិតការអ្វីក៏មិនរហូតទៅបាន ឯ**ប៊ុនឃីម**មានកម្លាំងច្រើន តែថាគ្មានប្រាជ្ញានិង

គំនិតសោះ ឯទាហានស្រុកហ្ស៊ួយឡាំមានថ្វីដៃខ្លាំងពូកែក្លាហានណាស់ យើងនឹងធ្វើភ្លីភ្លើមើលងាយនោះមិនបានទេ។ សុំឲ្យរក្សាបន្ទាយគូទុកឲ្យមាំមួន បើយើងឃើញកម្លាំងសត្រូវថមថយហើយ សឹមរិះគិតវាយឲ្យខ្ទេចខ្ទី កុំឲ្យដឹងខ្លួនទាន់ឡើយ។

**អងគី**ថា កងទ័ពក្បត់លើកមកគ្រានេះ មិនមែនទាហានទាំងពួងមានចិត្តរិះគិតមកឯងទេ ជាហេតុព្រោះ**ប៉ូឃីវខៀម**រិះគិត ទាហានទាំងពួងទទឹងមិនបានក៏ចាំចិត្តគិតតែមក បើយើងលើកទ័ពធំទៅវាយ ក៏ឃើញថាទាហានទាំងពួងនឹងភ្លយរត់ខ្ចាត់ខ្ចាយទៅ **សុម៉ាស៊ូ**ថា អ្នកនិយាយនេះត្រូវណាស់ ក៏លើកកងទ័ពហ្លួងរំកិលចូលទៅបោះនៅទីនោះសិន បើបង្អង់ឲ្យយូរទៅ សត្រូវមកតាំងមាំជាមុនហើយ យើងនឹងពារទម្លាយយកដោយកម្រ **សុម៉ាស៊ូ**យល់ឃើញត្រូវផង ក៏ឲ្យ**អងគី**នាយទ័ពមុខលើកទៅតាំងបន្ទាយនៅជើងកំពែងស្រុងឡាំតេង។

**ប៉ូឃីវខៀម**តាំងទ័ពនៅស្រុកអងសៀដឹងថា **សុម៉ាស៊ូ**លើកទ័ពមកទើបប្រឹក្សានឹងទាហានទាំងពួង នោះ**កាន់យ៉ុង**នាយទាហានកងមុខថា ឯទីស្រុកឡាំតេងនោះមានភ្នំ និងទន្លេខ្ទប់ជុំជាទីមាំមួនណាស់ បើពួក**សុម៉ាស៊ូ**តាំងនៅមុនហើយ មុខជាយើងធ្វើការបានដោយកម្រណាស់ សុំឲ្យលោកបង្ខំលើកកងទ័ពទៅតាំងនៅទីនោះឲ្យបានជាមុនទើបស្រួល។

**ប៉ូឃីវខៀម**ក៏ឲ្យលើកកងទ័ពនឹងទៅស្រុកឡាំតេង ទៅមួយស្របក់មានបម្រើសេះមកប្រាប់ថា ស្រុកឡាំតេងនោះ ទាហាន**សុម៉ាស៊ូ**ទៅតាំងនៅទីនោះហើយ **ប៉ូឃីវខៀម**មិនទាន់ជឿ ក៏លើកកងទ័ពទៅជិតដល់ឃើញមានបន្ទាយមាំមួនណាស់ មានទង់ជ័យដោតរាយជុំវិញ **ប៉ូឃីវខៀម**ឃើញដូច្នោះក៏ថយទ័ពត្រឡប់ទៅតាំងបន្ទាយនៅកណ្តាលផ្លូវ បម្រើសេះមកប្រាប់ថា ទ័ព**ស៊ុនជុន**ស្រុកកាំងតាំង លើកឆ្លងទន្លេមកនឹងវាយស្រុកឈីវឈុន **ប៉ូឃីវខៀម**ភ័យណាស់ ថាបើស្រុកឈីវឈុនជាអន្តរាយហើយ តើយើងនឹងត្រឡប់ទៅនៅទីឯណា? ថាហើយក៏រំសាយទ័ពទៅក្នុងពេលកណ្តាលយប់នោះ លើកទៅតាំងនៅស្រុកហាងសៀ។

**សុម៉ាស៊ូ**ដឹងថា **ប៉ូឃីវខៀម**រំសាយទ័ពថយផុតទៅហើយ ក៏ឲ្យហៅនាហ្មឺនមុខមន្ត្រីចូលទៅប្រឹក្សា **ប៉ៅតាន**ដឹងថា **ប៉ូឃីវខៀម**រំសាយទ័ពទៅគ្រានេះ ព្រោះខ្លាច

កងទ័ពស្រុកកាំងតាំងនឹងលើកឆ្មក់មកពីក្រោយទៅវាយស្រុកឈីវឈុន ឃើញទំនងនឹងរំសាយទ័ពទៅនៅស្រុកហាងសៀ ហើយនឹងបែងរំលែកទាហានឱ្យទៅរក្សាស្រុកឈីវឈុន សុំឱ្យលោកចាត់ទាហានលើកទៅជាបីកងទៅវាយស្រុកងាក់កែសៀ ស្រុកហាងសៀ ខ្ញុំបាទឃើញថាទាហានស្រុកហ៊្វយឡាំក៏នឹងថយទ័ពទៅឯង។ លោកចូរធ្វើសំបុត្រទៅដល់**តេងងាយ**ចៅហ្វាយស្រុកកុនជីវ ជាមនុស្សមានសតិបញ្ញាចេះរិះគិត ឱ្យលើកទៅជួយវាយស្រុកងាក់កែសៀ បើបានហើយឃើញថានឹងប្រាបដោយងាយ។ **សុម៉ាស៊ូ**យល់ឃើញត្រូវ ក៏ឱ្យសំបុត្រទៅដល់**តេងងាយ**ថា ឱ្យលើកកងទ័ពទៅវាយស្រុកងាក់កែសៀ យើងនឹងលើកតាមទៅផង។

ឯ**ប៊ូឃីវខៀម**តាំងទ័ពនៅស្រុកហាងសៀ ខ្លាចកងទ័ព**សុម៉ាស៊ូ**នឹងលើកទៅវាយ ក៏ឱ្យបម្រើសេះទៅស៊ើបល្បាតស្តាប់ដំណឹងរឿយៗ ហើយឱ្យអញ្ជើញ**ប៊ុនឃីម**មកក្នុងបន្ទាយហើយប្រឹក្សាថា ខ្ញុំក្រែង**សុម៉ាស៊ូ**នឹងលើកទៅវាយយកស្រុកងាក់កែសៀ។ **ប៊ុនឃីម**ថា ខ្ញុំបាទនិង**ប៊ុនអេង**សុំទាហានប្រាំពាន់ នឹងលើកទៅរក្សាស្រុកងាក់កែសៀទុកឱ្យបាន លោកកុំព្រួយឡើយ។ **ប៊ូឃីវខៀម**មានអំណរណាស់ ទើបចាត់ប្រើ**ប៊ុនអេង**អាពុក និងកូននាំទាហានប្រាំពាន់ចេញទៅ លុះទៅដល់ជិតមានបម្រើសេះមកប្រាប់ថា កងទ័ពស្រុកវុយកុកលើកមកមានទាហានប្រហែលមួយម៉ឺនប្លាយ មកតាំងនៅទិសឯលិច មានទង់សដោតជាសម្គាល់ និងទង់ជ័យទាំងពួងនោះ ឃើញថាមិនមែនកងទ័ព នាយទាហាន ឃើញថាជាកងទ័ពស្តេចលើកមក តែថាទង់សម្គាល់ជាឈ្មោះ**សុម៉ាស៊ូ** ឥឡូវតាំងបន្ទាយនៅឡើយមិនទាន់ស្រេច បើយើងលើកទ័ពទៅជាពីរកងវាយប្រសព្វខ្ទប់មុខជានឹងបែកបានដោយងាយ។ បិតាទើបសួរថា យើងនឹងលើកទ័ពទៅពេលណាល្អ? **ប៊ុនអេង**ថា លើកទៅពេលយប់នេះនឹងបានចំណាប់ល្អ។ បិតានាំពលពាក់កណ្តាលលើកទៅទិសខាងត្បូង ខ្ញុំបាទនិងពលពាក់កណ្តាលទៅវាយទិសឯជើង បើដល់ពេលកណ្តាលអាធ្រាត្រឱ្យលើកចូលវាយឱ្យព្រមគ្នា។ លុះវេលាយប់ក៏លើកទ័ពញែកទៅតាមដែលគិតគ្នានោះ ឯ**ប៊ុនអេង**នោះអាយុបាន១៨ឆ្នាំ កម្ពស់៦ហត្ថ ពាក់ក្រិសសៀតដំបងដែក ជិះសេះយន្តចូលទៅជិតបន្ទាយ**សុម៉ាស៊ូ**។

ឯ**សុម៉ាស៊ូ**តាំងទ័ពនៅចាំក្នុងទ័ព**តេងងាយ** នៅតែមិនទាន់ឃើញមក ភ្នែកនោះក៏រឹតតែឈឺចាប់ជាខ្លាំងណាស់ ចេះតែដេកសំងំនៅលើគ្រែ ប្រើទាហានប្រហែលបីរយនាក់ឲ្យព័ទ្ធរង់រក្សាខ្លួន លុះពេលកណ្ដាលអាធ្រាត្របានឮសំឡេងទាហានក្នុងបន្ទាយ ផ្អើលជ្រួលច្រាល់ច្របល់គ្នាទាំងសេះនិងមនុស្ស ទើបឲ្យបម្រើចេញទៅពិនិត្យមើលក៏បានសេចក្ដីថា មានទាហានម្នាក់មានកម្លាំងខ្លាំងពូកែណាស់មិនមាននរណាទប់ទល់បាន ៗដេញវាយបុករុកទម្លាយបន្ទាយចូលមកពីទិសឯជើង **សុម៉ាស៊ូ**បានឮដូច្នោះក៏ភ័យខ្លាំងណាស់ ឲ្យក្ដៅរោលរាលក្នុងដើមទ្រូងបីដូចជាភ្លើងឆេះ ព្រោះទោសៈបណ្ដាលឡើង ឯរោគក្នុងភ្នែកក៏រឹតតែកំរើបខ្លាំង កែវភ្នែកនោះក៏ផ្ទុះចេញមក តែគិតក្រែងទាហានទាំងពួងដឹងនឹងប្រែចិត្ត **សុម៉ាស៊ូ**ក៏យកសំពត់ភួយទៅរុំព័ទ្ធហើយដេកខាំទាល់តែសំពត់នោះដាច់ជាពីរកំណាត់។

វេលានោះ **ប៊ុនអេង**នាំទាហានហែកបន្ទាយចូលទៅបាន ក៏ដេញកាប់សម្លាប់ទាហាន**សុម៉ាស៊ូ**ស្លាប់ច្រើនណាស់ **ប៊ុនអេង**បែរមុខទៅខាងណា ក៏វិនាសខាងនោះអស់គ្មាននរណាតទល់បាន។ **ប៊ុនអេង**ប្រហារតែខាងទិសឧត្តរមួយប៉ែក ដើម្បីចាំមើលបិតានឹងលើកមកវាយប្រសព្វពីម្ខាងក៏មិនឃើញ លុះនឹងវាយតចូលទៅទៀតឲ្យដល់ទ័ពហ្លួង មានទាហាន**សុម៉ាស៊ូ**ព្រួតគ្នាបាញ់ធ្នូស្នាក់ពីមុខបីដូចគ្រាប់ភ្លៀង ចេះតែពារទន្ទ្រានទៅវិញទៅមកទាល់តែភ្លឺស្វាងក៏ហែកចូលទៅមិនបាន លុះព្រឹកឡើងទើបបានឮសំឡេងត្រែ សំឡេងស្គរសម្រាប់កងទ័ពក៏ប្លែកចិត្តគិតថា ហេតុម្ដេចបានជាបិតាទើបនឹងលើកមកពីទិសឯត្បូង ក៏លើកមកពីទិឯងជើងវិញ ទើបបំផាយសេះទៅមើល ក៏ឃើញឯកងទ័ព**តេងងាយ** ៗកាន់ដាវជិះសេះនាំមុខស្រែកថា អាក្បត់ផែនដី ឯងកុំតនឹងអញចូរស្រូតមកលេងគ្នា។ **ប៊ុនអេង**ឮដូច្នោះក៏វាំលំពែងចូលទៅប្រយុទ្ធគ្នាបានប្រហែលហាសិបភ្លេង មិនទាន់ចាញ់ឈ្នះ។ កាលកំពុងតស៊ូគ្នានោះ ទាហាន**សុម៉ាស៊ូ**លើកជំនួយមកជួយវាយប្រសព្វពីម្ខាងមុខនិងក្រោយ ឯទាហាន**ប៊ុនអេង**ក៏គេចដោះយកតែរួចខ្លួន នៅតែ**ប៊ុនអេង**ម្នាក់ឯង ក៏ជែងវែកទម្លាយទាហាន**សុម៉ាស៊ូ**ចេញមបានទៅទិសឯត្បូង។ ទាហានសេះ**សុម៉ាស៊ូ**ប្រហែលមួយរយសុទ្ធតែមានថ្វីដៃ ក៏បំផាយសេះដេញតាមទៅដល់ស្ពានស្រុកងាក់កែសៀ **ប៊ុនអេង**

ឃើញទាហានដេញខ្លាន់ពីក្រោយទៅជិតនឹងទាន់ ក៏ញាក់សេះត្រឡប់ស្រែកគំហកស្ទុះសង្កុញមកវិញ ទាហានទាំងពួងក៏នាំគ្នាថយ។ **ប៊ុនអេង**ក៏ត្រឡប់សេះបរតិចៗទៅមុខទៅ។ ទាហាន**សុម៉ាស៊ូ**នាំគ្នាទៅប្រជុំហើយប្រឹក្សាគ្នាថា ទាហានម្នាក់នេះហានក្លាណាស់ យើងព្រមចិត្តគ្នាដេញចាប់ខ្លួនឲ្យត្រាតែបាន គិតហើយក៏បំផាយសេះដេញតាមទៅ **ប៊ុនអេង**ត្រឡប់មុខសេះវិលមកតស៊ូ ហើយស្រែកគំហកថា អាពួកទាហានជ្រូកឯងមិនខ្លាចសេចក្ដីស្លាប់ទេឬ? ថាហើយក៏ចាប់ដំបងដែកដេញចូលទៅវាយស្លាប់ច្រើនណាស់ ត្រឹមតែពួកទាហាន**សុម៉ាស៊ូ**បែកហើយត្រឡប់លើកដេញហើយបែកត្រឡប់ក្រោយដល់បួនប្រាំគ្រា **ប៊ុនអេង**វាយស្លាប់គ្រប់គ្រា។ ទាហាន**សុម៉ាស៊ូ**ក៏ត្រឡប់ទៅវិញ។

ឯ**ប៊ុនឃឹម**ជាបិតា**ប៊ុនអេង**លើកទាហានចេញមកក្នុងពេលយប់នោះ វាងទៅខាងភ្នំវីរក់វង្វេងផ្លូវនឹងរកច្រកចេញមិនរួច ទាល់តែភ្លឺស្រាង។ លុះព្រឹកឡើងទើបក្រឡេកឃើញច្បាស់ជាមិនមែនផ្លូវ មិនឃើញទ័ព**ប៊ុនអេង** ឃើញតែកងទ័ព**សុម៉ាស៊ូ**មានជ័យជម្នះរុករានទន្ទ្រានដេញមកច្រើនណាស់ លើសកម្លាំងក៏ថយទ័ពរត់ទៅផ្លូវស្រុកឈីវឈុន។

មានទាហាន**សុម៉ាស៊ូ**ម្នាក់ឈ្មោះ**អ៊ិនតាយបុក** ពីដើមជាមនុស្សស្និទ្ធទំនុកចិត្ត**ចូហាង** លុះ**សុម៉ាស៊ូ**សម្លាប់**ចូសង**ទៅហើយ **អ៊ិនតាយបុក**ក៏ទៅនៅធ្វើការនឹង**សុម៉ាស៊ូ** គិតតែចង់សម្លាប់**សុម៉ាស៊ូ**សងសឹកតបគុណ**ចូហាង** កាលពីដើម**ប៊ុនឃឹម**និងឈ្មោះនេះស្រឡាញ់រាប់អានគ្នាណាស់ លុះ**សុម៉ាស៊ូ**ឈឺភ្នែកហើយ នៅរិះគិតរកទំនងមិនទាន់បានការក៏ចូលទៅនិយាយថា ខ្ញុំបាទឃើញថា**ប៊ុនឃឹម**នោះជាមនុស្សសត្យពិតត្រង់ ដែលនឹងគិតការជាក្បត់ផែនដីនោះមិនមែនទេ ដែលមកធ្វើការទាំងនេះ ក៏ព្រោះនឹងរឹងទទឹង**ប៊ូឃើវខៀម**មិនបាន បើដូច្នោះ ខ្ញុំបាទសុំទៅនិយាយបញ្ចុះបញ្ចូល**ប៊ុនឃឹម**ឲ្យស្ម័គ្រមកចូលខាងលោកមុខជាបាន។ **សុម៉ាស៊ូ**យល់ឃើញត្រូវក៏បើកឲ្យទៅ។

**អ៊ិនតាយបុក**ពាក់ក្រិសឡើងជិះសេះ តាមទៅជិត**ប៊ុនឃឹម**ហើយស្រែកដង្ហោយហៅ**ប៊ុនឃឹម**ថា អ្នកឃើញយើងច្បាស់ឬទេ? យើងឈ្មោះ**អ៊ិនតាយបុក**។

**ប៊ុនឃីម**ក្រឡេកមក **អ៊ុនតាយបុក**ក៏បើកម្លុកបង្ហាញមុខពីលើខ្នងសេះ យកស៊ែចង្អុលមុខហើយស្រែកថា **ប៊ុនឃីម**ហេតុម្ដេចបានជាលើកទ័ពរត់ដូច្នេះ ត្រូវបង្អង់នៅបន្តិចសិននឹងបានការ **អ៊ុនតាយបុក**ថាដូច្នោះ ព្រោះឃើញថា**សុម៉ាស៊ូ**ឈឺធ្ងន់នឹងជិតស្លាប់ហើយ ទើបចង**ប៊ុនឃីម**ទុក។

ឯ**ប៊ុនឃីម**មិនដឹងចិត្ត**អ៊ុនតាយបុក** ក៏ស្រែកបង្អកដេរហើយលើកធ្នូឡើងបាញ់ **អ៊ុនតាយបុក**ឃើញដូច្នោះតូចចិត្តណាស់ ក៏យំហើយញាក់សេះត្រឡប់មកវិញ **ប៊ុនឃីម**ក៏នាំទាហានរត់ទៅតាមផ្លូវស្រុកឈើវឈុន លុះដឹងថា **ជូកាត់អៀន**ទាហាន **សុម៉ាស៊ូ**បានស្រុកនោះហើយ ក៏ងាកមុខតម្រង់ទៅស្រុកហាងសៀ លុះឃើញទ័ព **អាវជុន**និង**អងគី**, **តេងងាយ**លើកមកស្ទាក់ពីមុខជាបីផ្លូវ **ប៊ុនឃីម**យល់ថានឹងពារទម្លាយទៅមិនបាន ក៏លើកត្រឡប់ទៅស្រុកកាំងតាំង ស្ម័គ្រចូលទៅជាខ្ញុំ**ស៊ុនជុន**ដែលជាមហាឧបរាជ។

ឯ**ប៊ូឃីវខៀម** តាំងនៅស្រុកហាងសៀ ដឹងថាស្រុកឈើវឈុនខូចហើយ ទ័ព**ប៊ុនឃីម**ក៏បែកទៀត កងទ័ព**សុម៉ាស៊ូ**ក៏លើកមកជាបីផ្លូវ តាំងនៅជិតស្រុកក៏លើកទាហានចេញច្បាំង ក្រឡេកឃើញ**តេងងាយ**លើកចេញមក ក៏ឲ្យ**កាន់យ៉ុង**ចេញតមិនទាន់បានមួយភ្លែង **តេងងាយ**កាប់នឹងដាវត្រូវ**កាន់យ៉ុង**ស្លាប់ ហើយក៏ពារទន្ទ្រានដេញចូលទៅ **អាវជុន**, **អងគី** ក៏លើកទាហានចូលចោមវាយទាំងបួនទិស **ប៊ូឃីវខៀម**ឃើញថានឹងតស៊ូមិនបាន ក៏នាំទាហានស្និទ្ធិប្រហែលដប់នាក់រត់ទៅដល់ស្រុកស៊ិមក្អួន។ **សងប៉េក**ចៅហ្វាយស្រុកក៏បើកទ្វារទទួលចូលទៅ ហើយតែងតុលៀង**ប៊ូឃីវខៀម**ស្រវឹងស្រាមិនដឹងខ្លួន **សងប៉េក**ក៏សម្លាប់កាត់យកក្បាលនាំទៅឲ្យ**សុម៉ាស៊ូ**។

លុះ**សុម៉ាស៊ូ**ប្រាបប្រាមសត្រូវរាបទាបហើយ ក៏តាំង**ជូកាត់អៀន**ជានាយទាហានធំ បាននិយាយរាជការស្រុកអេងជីវ ស្រុកហ៊្វយឡាំទាំងពួងនោះ ហើយក៏លើកត្រឡប់ទៅស្រុកហ៊្វូតោ។ **សុម៉ាស៊ូ**ឈឺភ្នែកធ្ងន់ណាស់ រឹតតែចាប់ពើតជាខ្លាំង វេលាកណ្ដាលអាធ្រាត្រដេកក៏មិនលក់ គ្រាន់តែរលីវបន្តិចទៅ ក៏ក្រឡេកឃើញ**លីហង**និង**ទៀវអ៊ិម** ហើយនិង**ហែហៅហៀន**ទាំងបីនាក់ មកឈរនៅប្របគ្រែ

ដំណោកក៏ដឹងថា ខ្លួនមុខជាមិនរស់រួចហើយ ទើបប្រើមនុស្សឲ្យចូលទៅក្រុងឡុកអៀងរក**សុម៉ាចៀវ**ឲ្យទៅជួប **សុម៉ាចៀវ**ក៏ចូលទៅដល់ទីដំណោកឃើញថាមុខជាមិនរស់ ក៏តាំងតែយំសោកអាលោះអាល័យ **សុម៉ាស៊ូ**ក៏ផ្តាំថា បងបានធ្វើរាជការរៀងមក ក៏បានសេចក្តីចម្រើនសក្តិយសពេញជាទីមហាឧបរាជ បងក៏អាចចេះរក្សាខ្លួនមិនមានសេចក្តីអន្តរាយ ចៅត្រូវទទួលការធ្វើជំនួសបងតទៅ ត្រូវតែរវាំងរក្សាខ្លួនឲ្យបានល្អ បើមានកិច្ចរាជការជាខធំ កុំត្រូវទុកចិត្តអ្នកដទៃឲ្យខូចផ្លូវការរាជការការដែលខុសទាស់ហើយ ក៏នឹងវិនាសអស់ដល់ទាំងគោត្រ លុះផ្តាំសព្វគ្រប់ហើយក៏ប្រគល់ត្រាសម្រាប់ងារឲ្យ**សុម៉ាចៀវ**ជាប្អូន។

ឯ**សុម៉ាចៀវ**នៅចង់ឲ្យបងផ្តាំប្រដៅឲ្យបានសេចក្តីតទៅទៀត តែឃើញថាបងមានសេចក្តីទុក្ខវេទនា ក្នុងភ្នែកកម្រើកធ្ងន់ណាស់ **សុម៉ាស៊ូ**ស្រែកឡើងដោយសំឡេងខ្លាំងហើយដាច់ខ្យល់ស្លាប់។ កាល**សុម៉ាស៊ូ**ស្លាប់នោះក្នុងខែផល្គុន ព្រះចៅ**ចូម៉**សោយរាជបានពីរឆ្នាំប្លាយ **សុម៉ាចៀវ**ក៏តែងការសពបងតាមប្រវេណី ហើយនាំសេចក្តីនោះទៅក្រាបទូលព្រះចៅ**ចូម៉** ៗក៏មានត្រាស់ព្រះរាជតម្រាស់តាំងឲ្យ**សុម៉ាចៀវ**ស្តីរាជការក្នុងស្រុកហ៊ូតោ ដើម្បីការពារទ័ពខ្មាំងខាងស្រុកកាំងតាំង **សុម៉ាចៀវ**ក៏មិនពេញចិត្តនៅជាអល់អែក តែថាមិនប្រកែក គ្រាន់តែនៅស្ងៀម។

**ចុងហោយ**និយាយនឹង**សុម៉ាចៀវ**ថា លោកមហាឧបរាជបងទើបតែនឹងអនិច្ចកម្ម ចិត្តខ្ញុំរាជការទាំងពួងក៏នៅមិនទាន់រៀបរយ ដែលលោកនឹងតាំងនៅក្នុងស្រុកហ៊ូតោនោះ បើមានមនុស្សអាក្រក់វាគិតប្រទូសរ៉ាយឲ្យវឹកវរឡើងក្នុងវាំង ដែលនឹងទៅកម្ចាត់ចេញនោះឃើញថាមិនទាន់ការ ឯ**សុម៉ាចៀវ**ក៏យល់ឃើញត្រូវ ទើបលើកទាហានទៅឈប់នៅតំបន់ឡុកស៊ុយ ព្រះចៅ**ចូម៉**ជ្រាបការដូច្នោះ ក៏មានព្រះទ័យភ័យណាស់ណា។ មានទាហានធំម្នាក់ឈ្មោះ**អងសុក**ទូលស្តេចថា សូមឲ្យព្រះអង្គតាំង**សុម៉ាចៀវ**ជាទីឧបរាជ និយាយរាជការជំនួសបងឲ្យមានទឹកចិត្តសប្បាយ ព្រះចៅ**ចូម៉**ក៏យល់ត្រូវផង ទើបប្រើ**អងសុក**ឲ្យកាន់ព្រះតម្រាស់ទៅដល់**សុម៉ាចៀវ**ឲ្យចូលទៅគាល់នឹងបានតាំងជាមហាឧបរាជ។ **សុម៉ាចៀវ**ក៏ចូលទៅគាល់ព្រះចៅ**ចូម៉** ធ្វើគំនាប់ទទួលទីនិយាយរាជការទូទាំងផែនដី។

ខណៈនោះ ពួកល្បាតរាជការខាងស្រុកសៃឈួន លុះដឹងដំណឹងថា **សុម៉ាស៊្វ** ស្លាប់ហើយ ក៏នាំសេចក្ដីនោះទៅប្ដឹងដល់**កៀងអ៊ុយ** ៗក៏នាំព័ត៌មាននោះចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន**ហើយថា **សុម៉ាស៊្វ**ទើបស្លាប់ **សុម៉ាចៀវ**បានតាំងជាមហាឧបរាជជំនួសបង មុខជានឹងចោលស្រុកឡុកអៀងមិនខាន ព្រោះទើបនឹងតាំងទីនិយាយរាជការថ្មី ស្រុកទេសដែលជារាជអាណាខេត្តទាំងអស់នៅមិនទាន់រាបទាប ទូលព្រះបង្គំជាខ្ញុំសុំអាសាលើកទៅវាយស្រុកវុយកុកមុខជានឹងបាន។ ព្រះចៅ**ឡៅសៀន**ក៏មិនដឹងនឹងទទឹងទាស់ ទ្រង់ព្រមបើកឲ្យ**កៀងអ៊ុយ**ទៅ **កៀងអ៊ុយ**ក៏ថ្វាយបង្គំលាចេញទៅស្រុកហាន់តុង រៀបចាត់ចែងលើកទ័ពចេញទៅ។

ខណៈនោះ **ទៀវអេក**ជានាយទាហានធំហាមឃាត់ថា ខបខណ្ឌសីមាដែលត្រូវឡើងស្រុកសៃឈួនក៏តិច ស្បៀងអាហារក៏ស្ដួចស្ដើង ដែលនឹងលើកទ័ពទៅផ្លូវក៏ឆ្ងាយ ឃើញថាកម្រណាស់ សុំឲ្យតែងកងទ័ពចេញទៅរក្សាអាណាខេត្តរបស់យើងទុក ឲ្យបណ្ដារាស្ត្របាននៅជាសុខ ខ្ញុំបាទគិតយ៉ាងនេះ ឃើញនឹងមានសេចក្ដីចម្រើនដល់ស្រុកទេសរបស់យើង។ **កៀងអ៊ុយ**ថា អ្នកនិយាយនេះខ្ញុំមិនយល់ឃើញផងសោះ ព្រោះកាលពីគ្រាមុនមហាឧបរាជនៅមិនទាន់ចូលមកធ្វើខ្ញុំរាជការនៅឡើយបានកំណត់ទុកថា ផែនដីក្នុងមហាប្រទេសចិនទាំងឡាយនឹងបែកទៅជាបីប៉ែក លុះចូលមកធ្វើរាជការហើយក៏លើកទ័ពទៅវាយស្រុកវុយកុក ទៅតាំងបន្ទាយនៅទីភ្នំគីសាន់ដល់ប្រាំមួយលើក ហើយរាជការក៏មិនសម្រេចរលត់សូន្យពាក់កណ្ដាលផ្លូវ កាលនឹងរលត់សូន្យនោះលោកក៏បានផ្ដាំទុកនឹងយើងឲ្យធ្វើការតទៅ គ្រានេះយើងបានចំណាប់ហើយត្រូវតែតាំងចិត្តគិតយកអាសាអម្ចាស់ផែនដី ទៅធ្វើការតបស្នងព្រះតេជព្រះគុណ តាមប្រវេណីជាតិទាហាន ទោះនឹងបាត់ខ្លួនប្រាណក៏ពុំត្រូវសោកស្ដាយអាល័យជីវិត។ ឯស្រុកវុយកុកសោត ក៏ជាសត្រូវនឹងយើងមកពីដើម ត្រូវតែលើកទៅវាយឲ្យបានក្នុងពេលនេះ។

**ហែហ៊្វប៉ា**ឆ្លើយថា លោកមានប្រសាសន៍នេះត្រូវណាស់ សុំឲ្យលើកកងទ័ពទៅតាមផ្លូវប៉ៅស៊ីវ យើងនឹងវាយយកស្រុកថៅសេ និងស្រុកឡាំអាន់ ដែលជាស្រុកសំខាន់បានហើយ ក៏នឹងបានខេត្តទាំងពួងដោយស្រួល។ **ទៀវអេក**ឆ្លើយថា លោក

លើកទៅធ្វើការគ្រានេះ ដើរទ័ពយូរណាស់ ទើបនឹងបានជ័យជម្នះលើកត្រឡប់មកវិញ ឯក្នុងតម្រាពិជ័យសង្គ្រាមមាននិយាយទុកថា មេទ័ព មេកង អ្នកដែលចេញទៅធ្វើការរណរង្គសង្គ្រាម នឹងលើកទៅវាយគេ ត្រូវកុំឱ្យគេដឹងខ្លួនទាន់ ទើបនឹងមានជ័យជម្នះ បើគេដឹងខ្លួនហើយ គេគង់ត្រៀមការយុទ្ធនាសង្គ្រាមទុកព្រម នរណាមានឫទ្ធិខ្លាំងពូកែយ៉ាងណា ក៏គង់ធ្វើការមិនសមគួរ ហេតុនេះសូមឱ្យលោកខំស្រូតលើកទៅជាប្រញាប់កុំឱ្យសត្រូវដឹងខ្លួនទាន់ឡើយ មុខជានឹងបានជ័យជម្នះតែម្តង។ **កៀងអ៊ុយ**យល់ឃើញត្រូវ ក៏ឱ្យកេណ្ឌប្រមូលទាហានទាល់តែអស់ បានចំនួនមនុស្សហុកសិបម៉ឺន។ ហើយលើកទៅតាមផ្លូវប៉ៅស៊ីវ។

លុះទៅដល់តំបន់ទន្លេថៅស៊ុយ កងល្បាតទៅប្រាប់**កៀងអ៊ុយ**ថា **តេងអង**ថៅហ្វាយស្រុកយង់ជីវ និង**តាន់ថាយ**នាយទាហានរងនាំពលប្រាំពីរម៉ឺនលើកតម្រង់មក **កៀងអ៊ុយ**ទើបរិះគិតបទឧបាយឱ្យទាហានធំលើកទៅជាពីរកង ឱ្យទៅវាយត្រឡប់ពីក្រោយ **ទៀវអេក**និង**ហែហ៊ូប៉ា**ក៏លើកចេញទៅ **កៀងអ៊ុយ**ក៏លើកកងទ័ពឆ្លងទន្លេថៅស៊ុយទៅតាំងនៅឆ្នេរច្រាំងត្រើយខាងលិច ឯ**តេងអង**ក៏នាំពលចូលទៅនឹងប្រយុទ្ធគ្នា លុះលើកកងទ័ពទៅដល់ជិតហើយក៏ស្រែកសួរថា ស្រុកវុយកុក ស្រុកកាំងតាំង ស្រុកសៃឈ្មូន ទាំងបីប្រទេសនេះតាំងនៅស្រួល បើទាំងអស់គ្នានៅឱ្យស្ងៀមក៏មានតែសេចក្តីសុខ ហេតុអ្វីបានជាអ្នកឯងលើកកងទ័ពមកវាយស្រុកយើង?

**កៀងអ៊ុយ**ស្រែកថា ព្រះចៅ**ចូហាង**ខុសត្រូវប្រការម្តេច បានជា**សុម៉ាស៊ូ**លើកយកស្តេចឱ្យចេញពីរាជសម្បត្តិ ហើយយកអ្នកដទៃមកលើកឱ្យធ្វើជាស្តេចវិញ? អស់នាហ្មឺនមុខមន្ត្រីទាំងពួងខ្លាចអំណាចហើយក៏យល់ព្រមតាមទៅ យើងនៅផ្សេងប្រទេសទេ តែឃើញថាថៅហ្វាយនាយឯងធ្វើខុសប្រវេណីអំពីបុរាណពេកណាស់ បានជាលើកទ័ពមកធ្វើទោស ប្រាថ្នានឹងមិនឱ្យខ្ញុំផែនដីយកយឿងយ៉ាងតទៅខាងមុខ។ **តេងអង**បានឮដូច្នោះក៏ទញ់ទាល់វាចា មិនដឹងឆ្លើយថាប្រការម្តេចក៏ក្រឡេកមើលមុខនាយទាហានទាំងបួននាក់ ឈ្មោះ**ចោប៉េង១, ហ៊្វូយអេង១, ឡៅតាត់១, ជួហាង១** ហើយថា កងទ័ពស្រុកសៃឈ្មូនឆ្លងមកតាំងបន្ទាយនៅត្រើយខាងនេះ បើ

ចាញ់ពួកយើងមុខជាទាហាននឹងស្លាប់ជាច្រើនណាស់។ **កៀងអ៊ុយ**នោះមានថ្វីដៃខ្លាំងពូកែច្រើន តែយើងមើលមិនឃើញមុខនរណានឹងចេញទៅតទល់បាន យើងឃើញតែពួកអ្នកឯងទាំងបួននាក់ ចូរជួយគ្នាតើល្មមនឹងរងរាំប់បានទេ? បើគេចាញ់ប្រៀបថយនឹងយើងទៅហើយ ត្រូវអស់អ្នកនាំទាហានដេញទន្ទ្រានឲ្យមួនមាំ ថាហើយក៏ដេញទាហាននោះចូលតស៊ូ។ **កៀងអ៊ុយ**ក៏បានចេញតទល់បានមួយស្របក់ក៏ញាក់សេះនាំទាហានចូលបន្ទាយ។ **តេងអង**បង្ខំស្រូតឲ្យទាហានដេញតាម**កៀងអ៊ុយ**ថយទៅជិតក្បែរមាត់ទឹក ហើយក៏នាំទាហានគេចឆ្លងទៅត្រើយទិសខាងលិច ហើយស្រែកប្រកាសដល់ទាហានទាំងពួងថា សត្រូវដេញមកជិតណាស់ហើយ ពួកយើងសុទ្ធតែជាជាតិទាហានដៃជា ៗពូកែចំណា បានធ្លាប់ធ្វើការសង្គ្រាមមកពីដើម ហេតុម្តេចបានជាគ្រានេះមកនាំគ្នាញញើតខ្លាចដូច្នេះ ទាហាន**តេងអង**នៅខាងទិសឯកើត។

**ទៀវអេក** និង**ហែហ៊ូប៉ា** ដែលលើកពលទៅពួនបង្កប់ លុះដឹងថាទ័ពទាំងសងខាងកំពុងច្បាំងគ្នា ក៏វាយត្រឡប់ពីក្រោយចូលទៅមួយកង វាយប្រសព្វចូលពីខាងមុខមួយកង **កៀងអ៊ុយ**ក៏តាំងសម្តែងឫកពារធ្វើមាំមួន បរពលចូលទន្ទ្រានត្រឡប់ចូលទៅវិញព្រមគ្នាទាំងបីកង ព័ទ្ធទាហាន**តេងអង**ចុះទៅមាត់ទន្លេ ឯទាហាន**តេងអង**ដែលចុះទៅមុន ទាល់នឹងទឹកខ្លាចពុំអាចចុះទៅចេះតែវារង់នៅ ប៉ែកដែលរត់ចុះទៅខាងក្រោយ ទាំងមនុស្ស និងសេះក៏ជាន់គ្នារបួសពិការស្លាប់ប្រហែលពីរភាគ ប៉ែកដែលរត់ចុះទឹកក៏ស្លាប់ជាច្រើន ទាហាន**កៀងអ៊ុយ**ក៏កាត់យកក្បាលបានមួយម៉ឺនប្លាយ។

**តេងអង**នាំពលមួយរយប្លាយវាយទម្លាយគេចចេញទៅបាន ហើយរត់ទៅតាមផ្លូវតេកតោសៀ ចូលទៅដល់កំពែងស្រុកហើយបិទទ្វារខ្ជាប់ខ្ជួនឲ្យមានទាហានរក្សាត្រួតត្រា។ **កៀងអ៊ុយ**មានជ័យជម្នះហើយ ក៏រៀបបាយទឹកជប់លៀងទាហាន និងឲ្យបំណាច់រង្វាន់ ហើយប្រឹក្សាថា យើងនឹងលើកតាមទៅវាយយកស្រុកតេកតោសៀទៀត តើអស់អ្នករាល់គ្នានឹងយល់ឃើញប្រការម្តេច? **ទៀវអេក**ឆ្លើយហាមឃាត់ថា លោកធ្វើការគ្រានេះមានជ័យប្រាកដកិត្តិយសណាស់ហើយ សុំឲ្យបង្អង់តែ

ត្រឹមនេះចុះ បើនឹងធ្វើការតទៅទៀតក្រែងភ្លាំងនឹងមិនខូចការទេឬ? ដូចគេវាយពស់ហើយ ហើយវាយជើងផង គឺឲ្យឃើញជើងពស់។

**កៀងអ៊ុយ**តបថា អ្នកនិយាយនេះមិនត្រូវទេ ពីដើមយើងលើកទ័ពមកធ្វើការថ្លោះការផងគេជាច្រើនគ្រា ៗនេះយើងឧស្សាហ៍មកធ្វើការទៀតក៏បានជ័យជម្នះ ទាហានស្រុករុយកុកបែកគ្រានេះ ខ្មោចខ្មីច្រើនណាស់ មើលទៅឃើញរួញរារអាខ្លាំងហើយ បើយើងលើកទៅវាយថែមទៀត ពលយើងក៏មានទឹកចិត្តខិតខំមុខជានឹងបានស្រុកតេកតោសៀដោយងាយប្រហែលមួយជំទាស់ដៃ ថៅកុំបីកោតញញើតក្នុងចិត្តឡើយ។ **ទៀវអេក**ឃាត់ហាមដល់បីសា **កៀងអ៊ុយ**មិនស្តាប់ ក៏លើកទ័ពទៅស្រុកតេកតោសៀ។

ឯ**តាន់ថាយ**ខូចកងទ័ពនឹង**កៀងអ៊ុយ**ហើយ ក៏ទៅបញ្ចុះបញ្ចូលប្រមូលពលទាហាននឹងមកជួយ**តេងអង** លុះឃើញ**តេងងាយ**ថៅហ្វាយស្រុកកុនជីវនាំទាហានជូនមក មានសេចក្តីត្រេកអរណាស់ ចេញទៅទទួលចូលមក **តេងងាយ**និយាយថា លោកមហាឧបរាជឲ្យលើកកងទ័ពមកជួយ។ **តាន់ថាយ**ឆ្លើយតបថា លោកនឹងរិះគិតប្រការម្តេចទើបនឹងឲ្យមានជ័យជម្នះ?

**តេងងាយ**ថា **កៀងអ៊ុយ**មានជ័យជម្នះដល់យើងនៅទីឆ្នេរមាត់ទន្លេថៅស៊ុយហើយ បើតាំងបញ្ចុះបញ្ចូលទាហានបួនអាណាខេត្តក្នុងវែនក្វែននេះបានហើយធ្វើការតចូលមក ខ្ញុំបាទឃើញថាខាងយើងនឹងលំបាកជាប្រាកដនេះ**កៀងអ៊ុយ**មិនទាន់គិតធ្វើដូច្នេះសោះ ក៏លើកកងទ័ពត្រង់ចូលមកព័ទ្ធស្រុកតេកតោសៀតែម្តងដូច្នេះយើងនឹងខ្លាចអ្វី ដោយស្រុកតេកតោសៀនេះមាំមួនណាស់ទោះបីនឹងវាយយ៉ាងណាក៏មិនបែក បើយើងនឹងលើកកងទ័ពទៅបង្កប់នៅភ្នំហាងនៀ ចាំមើលបើឃើញកងទ័ព**កៀងអ៊ុយ**លើកមក ត្រូវបញ្ឆោតដោយកលឧបាយគង់នឹងចាញ់រត់ទៅជាប្រាកដមុខជាមិនបង្អង់ឈប់ច្បាំងទេ។

**តាន់ថាយ**យល់ឃើញត្រូវ ក៏ឲ្យកេណ្ឌប្រមូលទាហានជាម្ភៃកង ក្នុងមួយកងហាសិបនាក់ ហើយឲ្យត្រៀមកំភ្លោះនិងផាវចោលទៅ ហើយឲ្យស្រែកហ៊ោឲ្យគឹកកងរំពង។ ឯ**កៀងអ៊ុយ**ឲ្យតាំងបន្ទាយប្រាំបីអន្លើ ព័ទ្ធស្រុកតេកតោសៀ ឲ្យទាហាន

ពារកំពែងទម្លាយប៉មដល់ប្រាំបួនថ្ងៃដប់ថ្ងៃ ហើយក៏ហែកចូលទៅមិនបាន ទាល់គំនិតណាស់មិនដឹងនឹងគិតយ៉ាងម្តេច ក៏ឲ្យរំខានក្នុងចិត្តពេកណាស់ លុះវេលាយប់ពួកកងល្បាតឲ្យបម្រើសេះមកប្រាប់ថា កងទ័ពលើកមកជាពីរកង ទង់ជ័យមួយមានអក្សរសម្គាល់ថា "**តាន់ថាយ ចៀងអាយ ចុងគុន**" ទង់ជ័យមួយមានអក្សរសម្គាល់ "**តេងងាយ** ចៅហ្វាយស្រុកកុនជីវ" **កៀងអ៊ុយ**ភ័យណាស់ឲ្យប្រមូលមុខមន្ត្រីចូលមកប្រឹក្សា។

**ហែហ្សប៉ា**ឆ្លើយថា **តេងងាយ**នេះ មានថ្វីដៃច្បាំងខ្លាំងពូកែណាស់ ទាំងសតិបញ្ញាក៏ឆ្លៀវឆ្លាតក្នុងការរណរង្គសង្គ្រាម។ **កៀងអ៊ុយ**ថា កងទ័ពគេលើកមកពីចម្ងាយទាហានរេហ៍ពលរសាំរសាយទេ យើងត្រូវបង្ខំស្រូតរូតលើកចូលទៅវាយឃើញថានឹងបានដោយងាយ កុំឲ្យតែដឹងខ្លួនតាំងបន្ទាយទាន់ ថាហើយក៏ចាត់**ទៀវអេក**ឲ្យនាំពលចូលទៅទម្លាយវាយស្រុក ចាត់**ហែហ្សប៉ា**ឲ្យទៅវាយចុងគយ ឯ**កៀងអ៊ុយ**ក៏លើកទៅវាយទ័ព**តេងងាយ** លុះលើកទៅបានប្រមាណហាសិបសិនស្រាប់តែឮស្គរកំភ្លោះផាវ និងសំឡេងមនុស្សស្រែកហ៊ោសំឡេងស្គរទ័ពសន្ធាប់សន្ធឹកខ្លាំងណាស់ ក្រឡេកទៅឃើញទង់ជ័យដោតរាយជុំវិញដេរដាសក៏ភ័យណាស់គិតថាមុខជាត្រូវកលរបស់**តេងងាយ**ជាប្រាកដ នឹងថ្លោះការរបស់គេហើយក៏ថយទ័ព ទើបឲ្យបម្រើសេះទៅតាមកងទ័ព**ទៀវអេក** ឲ្យលើកថយត្រឡប់ទៅស្រុកហាន់តុង ឯ**កៀងអ៊ុយ**នៅរាំងពីក្រោយ លុះថយទៅដល់គយកៀមកុកទើបដឹងថាកងទ័ពដែលព័ទ្ធខ្លួននោះជាច្រើនស្រទាប់ណាស់ គឺជាកលសឹករបស់**តេងងាយ**ធ្វើបញ្ឆោតឲ្យថ្លោះការ ក៏នាំនាយទ័ពនាយកងទាំងពួងចូលទៅគាល់ព្រះចៅ**ឡៅសៀន**ឯក្រុងសែឈួន ហើយទូលរឿងរ៉ាវដែលទៅបានធ្វើការនោះសព្វគ្រប់ប្រការ។

ព្រះចៅ**ឡៅសៀន**ឃើញ**កៀងអ៊ុយ**មានជ័យជម្នះ បានសេចក្តីគាប់ប្រសើរមកក៏ទ្រង់តាំងឲ្យឡើនទីជាតៃចុងគុន **កៀងអ៊ុយ**ក៏ថ្វាយបង្គំលាទៅដល់ស្រុកហើយ ក៏មានចិត្តខឹងនឹង**តេងងាយ**ពេកណាស់ ឲ្យទាហានត្រៀមគ្រឿងសាស្ត្រាវុធ និងសេះជំនិះនូវអស់គ្រឿងសព្វយុទ្ធន៍ព្រមហើយ ឲ្យមានសំបុត្រចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន**ថា នឹងសុំលាលើកកងទ័ពទៅវាយស្រុកវុយកុកមួយលើកទៀត។

ឯ**តេងអង**ដឹងថា **កៀងអ៊ីុយ**រំសាយទ័ពលើករត់ទៅហើយ ដោយសារ**តេងងាយ**មកជួយ ទើបឲ្យទៅអញ្ជើញ**តេងងាយ**មកបរិភោគអាហារក្នុងស្រុក ហើយក៏ឲ្យតែងសំបុត្រ បកសេចក្តីគាប់ប្រសើររបស់**តេងងាយ**ទៅទូលព្រះចៅ**ចូម៉**ៗក៏ត្រាស់ឲ្យតាំង**តេងងាយ**ជា **អាន់សៃចុងកុន** នាំទាហាននៅរក្សាស្រុក**អេងជីវ**ជាមួយនឹង**តាន់ថាយ**។ **តេងងាយ**ចេញទៅទទួលគំនាប់ត្រាតាំងតាមទម្លាប់ទំនៀម **តាន់ថាយ**ក៏ឲ្យអញ្ជើញ**តេងងាយ**ទៅបរិភោគអាហារតុលៀង ហើយនិយាយថា ទាហានស្រុកសៃឈ្នួនចាញ់គំនិតរិះគិតរបស់លោកគ្រានេះ ឃើញថាមុខជាមិនលើកមកទៀតឡើយ។ **តេងងាយ**ថា ខ្ញុំឃើញថា ទាហានស្រុកសៃឈ្នួននឹងលើកមកទៀត ដោយហេតុដល់ប្រាំប្រការ។ **តាន់ថាយ**សួរថា ហេតុប្រាំប្រការនោះគឺអ្វីខ្លះ? សុំលោកអធិប្បាយឲ្យស្តាប់មើល។ **តេងងាយ**ថា ហេតុជាបឋមនោះ គឺទាហានស្រុកសៃឈ្នួនរត់ទៅក៏មែន តែថាមិនចាញ់ដោយកម្លាំងរេហ៍ពលនឹងមានជ័យជម្នះទុកមុន បានសេះនិងសាស្ត្រាវុធរបស់យើងទៅជាច្រើន ឯខាងយើងមានជ័យឲ្យគេរត់ទៅក៏មែន តែថាយើងក៏ខូចរេហ៍ពលច្រើនណាស់ ហេតុជាគម្រប់ពីរនោះ គឺទាហានស្រុកសៃឈ្នួនបានបែបយ៉ាងពី**ខុងបេង**បង្ហាត់បង្រៀនទុកស្ទាញស្ទាត់ ព្រមព្រៀងគម្រប់បីនោះ គឺទាហានស្រុកសៃឈ្នួនលើកមកខាងផ្លូវគោក ផ្លូវទឹកបន្ទុកស្បៀងប្រចាំជូន មិនលំបាកដោយកម្លាំងទាហានសោះ ទាហានខាងយើងលើកមកបានតែផ្លូវគោកម្យ៉ាង លំបាកដោយស្បៀងអាហារណាស់ ហេតុជាគម្រប់បួននោះគឺទីក្រុងតេកតោសៀ និងស្រុកឡុងសេនេះ ហើយនិងស្រុកឡាំអាន់ភ្នំគីសាន់ទាំងអម្បាលនេះធំទូលាយណាស់ ទាហានស្រុកសៃឈ្នួនបានមករឿយៗដឹងស្គាល់គ្រប់អន្លើតំបន់ញែករំសាយរាយគ្នាមកគ្រប់ផ្លូវ ទាហានយើងត្រួតត្រារក្សាបានដោយកម្រ ហេតុជាគម្រប់ប្រាំនោះ គឺទាហានស្រុកសៃឈ្នួននឹងលើកមកធ្វើការគ្រាណា រមែងមកអាស្រ័យស្បៀងអាហារក្នុងស្រុកកៀងជាកម្លាំងគ្រប់គ្រា។ ខ្ញុំឃើញហេតុប្រាំប្រការដូច្នេះទើបថា កងទ័ពស្រុកសៃឈ្នួននឹងលើកមកទៀតជាប្រាកដ។ **តាន់ថាយ**ស្តាប់ហើយក៏សរសើរតម្រិះប្រាជ្ញា**តេងងាយ**ថា លោកមានសតិបញ្ញាឆ្លុះភ្លឺយល់ន័យកន្លងដឹងសេចក្តីដូច្នេះ នឹងខ្លាចអ្វីដល់ពួកសត្រូវទាំងនោះ។ ថាហើយ**តាន់ថាយ**

និង**តេងងាយ**ក៏តាំងស័ត្យស្បថស្បាន់ជាបងប្អូននឹងគ្នាដរាបទាល់អស់ជីវិត ហើយក៏ឲ្យទាហានទាំងពួងហាត់រៀបគុនអាវុធយុទ្ធសង្គ្រាម ឲ្យជំនាញស្ទាញស្ទាត់គ្រប់ប្រការ ហើយឲ្យទាហានទៅតាំងបន្ទាយរាយរក្សាគយច្រកល្ហក ដែលជាទីខបខណ្ឌពន្ធសីមាឲ្យមាំមួនគ្រប់តំបន់។

ឯ**កៀងអ៊ុយ**នោះ លុះប្រមូលរេហ៍ពលបានច្រើនហើយ ក៏តាំងជប់លៀងអាហារហើយប្រឹក្សាថា យើងនឹងលើកកងទ័ពទៅច្បាំងនឹងស្រុកវុយកុកគ្រានេះ តើអស់អ្នកនឹងយល់ឃើញឃើញជាប្រការម្ដេច? មានហោរាម្នាក់ឈ្មោះ**ហ្លួនកៀន**ឆ្លើយថា លោកលើកទ័ពទៅគ្រាមុន បានជ័យជម្នះមានកិត្តិយសទុកជាប្រាកដហើយ ទាហានស្រុកវុយកុកកោតក្រែងរអែងខ្លាច បានជាតបះតេជះដល់ស្រុកសៃឈ្មួន ហើយលោកនឹងលើកទ័ពទៅទៀតគ្រានេះ បើថ្លោះធ្លោយភ្លាំងភ្លាត់ ក៏នឹងភ្លយឲ្យខូចកិត្តិយសពីគ្រាមុននោះអសារទៅឥតប្រយោជន៍។ **កៀងអ៊ុយ**ថា អ្នកនិយាយនេះព្រោះឃើញថាដែនស្រុកវុយកុកនោះធំទូលាយ ហើយមានពលទាហានច្រើន បានជានាំឲ្យញញើតខ្លាច ឯខ្ញុំឃើញថាកងទ័ពយើងបានប្រៀបជាងស្រុកវុយកុកច្រើនណាស់ ដោយហេតុប្រាំប្រការ ទើបមិនឲ្យក្រែងខ្លាច។

បណ្ដាអស់នាយទាហានទើបសួរតបថា ប្រសាសន៍ថាហេតុប្រាំប្រការនោះគឺម្ដេចខ្លះ? **កៀងអ៊ុយ**ឆ្លើយតបថា ហេតុទាំងប្រាំប្រការនោះយើងនឹងពណ៌នាឲ្យស្ដាប់ ហើយក៏និយាយត្រូវដូចពាក្យ**តេងងាយ**ដែលអធិប្បាយប្រាប់**តាន់ថាយ** ដែលយើងប្រារព្ធហើយខាងលើនេះគ្រប់ប្រការ។ ហើយ**កៀងអ៊ុយ**ថា យើងឃើញបានប្រៀបយ៉ាងនេះឯង ទើបពេញចិត្តដែលនឹងគិតទៅវាយស្រុកវុយកុក បើដូច្នេះហើយមិនទៅទេ តើនឹងទៅកាលណាវិញឲ្យជាជាងកាលនេះ? **ហែហ្លប៉ា**ថា **តេងងាយ**នោះនៅក្មេងសេចក្ដីក៏ពិតមែន តែគេមានសតិបញ្ញាស្រួចស្រស់ណាស់ ហើយគ្រានេះក៏បានជាទី “**អាន់សៃចុងគុន**” ផង មុខជានឹងចាត់ចែងពលទាហានឲ្យរក្សាស្រុក និងគយច្រកល្ហកតាមទីខេត្តខណ្ឌមាំមួនជាងពីដើម យើងកុំអាលមើលងាយក្រែងថ្លោះការ។

**កៀងអ៊ុយ**ឮដូច្នោះក៏ខឹងណាស់ ស្រែកគំហកថា នឹងធ្វើការធំហើយមកនាំនិយាយយ៉ាងនេះឲ្យពលទាហានមានចិត្តរួញរា នរណាក៏ដោយកុំហាមឃាត់យើង

ទៀត យើងមិនស្តាប់ទេ។ ថាហើយក៏បង្គាប់ថា ឲ្យលើកកងទ័ពចេញទៅ ឯខ្លួន**កៀងអ៊ុយ**ក៏នាំទាហានជាកងមុខលើកទៅ។ អស់ទាំងវេហ៍ពលក៏លើកតាមទៅដល់តំបន់ភ្នំគីសាន់ នោះមានកងល្បាតចាត់បម្រើសេះមកប្រាប់ថា ទ័ពស្រុកវុយកុកលើកមកតាំងបន្ទាយស្កាត់ផ្លូវ មានបន្ទាយប្រាំបួនអន្លើ **កៀងអ៊ុយ**ក៏មិនជឿស្តាប់ ទើបជិះសេះនាំទាហានឡើងទៅលើភ្នំ ក្រឡេកទៅឃើញបន្ទាយវាយហែគ្នាទៅជាមាំមួនណាស់ មើលដូចអសិរពិសមានក្បាល និងកន្ទុយពេនព័ទ្ធវ័ណ្ឌរុំគ្នា **កៀងអ៊ុយ**និយាយនឹង**ហែហ្សូប៉ា**ថា អ្នកនិយាយមកនេះត្រូវណាស់ **តេងងាយ**នោះមានតម្រិះរិះគិតមុតមាំមែន ពិគ្រោះមើលទៅឃើញរបៀបការប្រហែលនឹងលោកមហាឧបរាជអាចារ្យនៃយើង ដែលយើងហែកពារទម្លាយចូលទៅឃើញជាមិនបាន ក្រែងមានថ្លោះការ ប្រហែល**តេងងាយ**នៅក្នុងបន្ទាយនោះទេដឹងឬ? ថាហើយក៏នាំទាហានត្រឡប់មកវិញ ហើយឲ្យតាំងបន្ទាយនៅក្បែរមាត់ផ្លូវជាមាំមួន ហើយបង្គាប់ទាហានឲ្យចេញទៅយាមល្បាតលាតក្រវែលជាប្រាំពួក ក្នុងមួយពួកប្រាំរយ ឲ្យតែងខ្លួនប្លែកៗពីគ្នា កាន់ទង់ប្រាំយ៉ាងពណ៌លឿង ខៀវ ស ក្រហម ខ្មៅ មិនឲ្យដូចគ្នា ហើយតាំង**ប៉ៅនៅ**នាយទាហានឲ្យនៅរក្សាបន្ទាយ ទើបកំជាប់ថា អ្នកឯងរក្សាបន្ទាយឲ្យល្អ ដ្បិតខ្លួនយើងនឹងលើកទ័ពទៅវាយស្រុកឡាំអាន់។

ឯ**តេងងាយ**ដឹងថា កងទ័ពស្រុកសៃឈួនលើកមកតាំងបន្ទាយនៅមាត់ផ្លូវប្រហប ច្រើនថ្ងៃហើយមិនបានលើកមកវាយ មានតែទាហានមកដើរយាមល្បាតមើលផ្លូវមួយរយ ឬមួយរយហាហើយត្រឡប់ទៅ ផ្លាស់ប្តូរគ្នាមួយថ្ងៃប្រាំពួក តែងខ្លួនប្លែកៗពីគ្នា កាន់ទង់ក៏ពណ៌ផ្សេងៗគ្នា ទើប**តេងងាយ**ជិះសេះនាំទាហានឡើងទៅមើលលើកំពូលភ្នំ ក្រឡេកឃើញបន្ទាយហើយត្រឡប់ចុះទៅប្រាប់**តាន់ថាយ**ថា ខ្ញុំគួរយល់ថា**កៀងអ៊ុយ**មិននៅក្នុងបន្ទាយនេះទេ ប្រហែលនឹងលើកទៅវាយស្រុកឡាំអាន់ជាប្រាកដ ឯទាហានដែលលើកមកយាមល្បាតនោះឃើញស្លួចស្តើងទេ សូមឲ្យលោកលើកទៅវាយយកបន្ទាយនោះឲ្យបាន ហើយតាំងស្កាត់នៅដើមផ្លូវ ខ្ញុំនឹងលើកទៅជួយស្រុកឡាំអាន់ បើ**កៀងអ៊ុយ**ថយហើយ ខ្ញុំនឹងស្រូតទៅតាំងនៅភ្នំបូសៀងសាន់ ហើយនឹងបង្កប់ទាហានទុកសងខាងផ្លូវដែលជាទីប្រហប បើ

**កៀងអ៊ុយ**លើកមកទីនោះ នឹងលើកវាយខ្ទប់ឲ្យបាន មុខជានឹងថ្លោះការផងយើងមិនខាន។

**តាន់ថាយ**ថា ខ្ញុំមកនៅខេត្រឡុកសេនេះយូរប្រមាណម្ភៃសាមសិបឆ្នាំហើយ មិនទាន់ដឹងច្បាស់ផែនទីស្រុកនេះសោះ លោកនៅស្រុកឯទៀតទេ ហេតុម្តេចបានជាដឹងច្បាស់គ្រប់ច្រកល្ហកគ្រប់តំបន់ដូចទេវតា? ដែលលោកថានេះត្រូវណាស់ ចូរស្រូតរូតលើកទៅចុះ ខ្ញុំនឹងចូលកាច់យកបន្ទាយនេះឲ្យបាន។ **តេងងាយ**លើកទ័ពទៅតាមផ្លូវកាត់ ខំស្រូតរូតទៅដល់ភ្នំបូសៀងសាន់មុន**កៀងអ៊ុយ**ទៅដល់ ក៏តាំងបន្ទាយយ៉ាងមួនមាំនៅលើភ្នំនោះ **តេងងាយ**ចាត់ប្រើ**តេងអង**ជាកូន និង**សុមៅ**នាយទាហានឲ្យនាំទាហានម្នាក់ប្រាំពាន់ បង្គាប់ឲ្យលើកទៅតាំងនៅទីច្រកតំបន់ទួនកោះ នាយទាហានទាំងពីរនាក់ក៏លើកទៅពួនបង្កប់ ឯក្នុងបន្ទាយ**តេងងាយ**នោះ ហាមប្រាមមិនឲ្យនិយាយគ្នាឲ្យឮមាត់ករសោះ ធ្វើហាក់ដូចជាគ្មានមនុស្សនៅ ទង់ក៏មិនដោតសោះ។

**កៀងអ៊ុយ**លើកទៅដល់ទីនោះ ចូលទៅខាងមុខភ្នំបូសៀងសាន់ ផ្លូវនឹងចូលទៅស្រុកឡាំអាន់ ក៏នឹងនិយាយ**ហែហួប៉ា**ថា ភ្នំនេះជាទីស្រួលបួលមាំមួនណាស់ បើយើងចូលទៅតាំងបន្ទាយនៅបាន នឹងបានស្រុកឡាំអាន់ដោយងាយ តែខ្ញុំឃើញថា**តេងងាយ**មានគំនិតរិះគិត ប្រហែលនឹងលើកទ័ពមកតាំងចាំស្កាត់ជាមុនទេដឹង? និយាយគ្រាន់តែផុតពាក្យ ស្រាប់តែឮសូរស្គរស្រែកហ៊ោចុះមកពីលើភ្នំ ក្រឡេកទៅឃើញទង់មានចារឹកអក្សរសម្គាល់ថា "**តេងងាយ**" កងមុខភ័យណាស់ **កៀងអ៊ុយ**ក៏លើកទ័ពជំនួនជួនឡើងទៅ ទាហាន**តេងងាយ**ក៏ថយត្រឡប់ទៅ **កៀងអ៊ុយ**ក៏ដេញជិតតាមទៅដល់មុខបន្ទាយឲ្យទាហានស្រែកជេរជាពាក្យទ្រគោះ ដើម្បីឲ្យ**តេងងាយ**ចេញមកច្បាំង **តេងងាយ**ក៏តាំងនៅមិនចេញសោះ។ **កៀងអ៊ុយ**នឹងហែកទម្លាយចូលទៅក៏មិនបាន ទើបឲ្យទាហានទៅកាត់ឈើ ជញ្ជូនសិលាមកតាំងបន្ទាយភ្ជាប់ ទាហាន**តេងងាយ**លើកចេញមក ដេញវាយចាក់កាប់សម្លាប់ទាហាន**កៀងអ៊ុយ**រឹករវរចលាចល នឹងតាំងបន្ទាយក៏មិនបាន ក៏ថយទ័ពត្រឡប់ទៅបន្ទាយដើមវិញ។ លុះវេលាព្រឹកឡើង **កៀងអ៊ុយ**ក៏លើកទាហានទៅតាំងបន្ទាយនៅភ្នំបូសៀងសាន់

បន្ទាយនៅធ្វើមិនទាន់ខ្ជាប់។ លុះពេលយាមមួយយប់ **តេងងាយ**ក៏ឱ្យទាហានប្រាំរយយកផ្នួនភ្លើងទៅដុតបន្ទាយឆេះឡើងបាន ក៏ចូលវាយប្រកាប់ជ្រួលច្របល់ឡើង តាំងបន្ទាយក៏មិនបាន ឯ**កៀងអ៊ុយ**ក៏លើកទ័ពទៅ ហើយប្រឹក្សានឹង**ហែហ្សប៉ា**ថា យើងនឹងលើកទៅវាយស្រុកឡាំអាន់ឃើញនឹងមិនបានហើយ យើងច្បាំងយកស្រុកសៀងថេងចុះ ដើម្បីទុកជាស្បៀងអាហារ វាយបានហើយនឹងបានជាកម្លាំង ស្រុកឡាំអាន់ក៏នឹងភ្លយបានដោយងាយ។ ខ្ញុំនឹងលើកទៅវាយស្រុកសៀងថេង អ្នកចូរខស្សាហ៍តាំងបន្ទាយឱ្យមាំពីចម្ងាយ ឱ្យ**តេងងាយ**រវាំងរវល់ក្រោយ ថាហើយ**កៀងអ៊ុយ**ក៏លើកទាហានទៅទាំងពេលកណ្តាលអាធ្រាត្រនោះ។ លុះព្រឹកភ្លឺស្រាង ក្រឡេកឃើញភ្នំជាប្រហបទៀបគ្នាឆ្ងាយស្រយាលណាស់ ទើបសួរអ្នកនាំផ្លូវថា ភ្នំនោះឈ្មោះអ្វី? អ្នកនាំផ្លូវប្រាប់ថា ឈ្មោះភ្នំទួនកោះ។ **កៀងអ៊ុយ**ឮដូច្នោះក៏ភ័យណាស់ ទើបនិយាយថា ភ្នំនេះជាទីចំណាប់ចំនួន ឈ្មោះសំឡេងក៏កាចមិនល្អ បើសត្រូវមកស្កាត់នៅផ្លូវដែលនឹងត្រឡប់ទៅ យើងនឹងមិនលំបាកទេឬ? ថាហើយក៏អល់អែកនៅទីនោះ មានពួកកងល្បាតមកប្រាប់ថា ឃើញធូលីហុយផុសឡើងខាងក្រោយភ្នំ ប្រហែលនឹងមានកងទ័ពលើកមក។ **កៀងអ៊ុយ**បានឮដូច្នោះក៏ថយទ័ពមកវិញ ឯ**សុមៅ** និង**តេងអង**លើកទាហានចេញវាយខ្ទប់ប្រសព្វមក។ **កៀងអ៊ុយ**ក៏ច្បាំងភ្លាងរត់ថយភ្លាងបង្អង់ថយទៅ ឯ**តេងងាយ**ក៏លើកទ័ពវាយស្កាត់ទុក កងទ័ពទាំងបីវាយចម្រុះចូលមកព្រមគ្នា ទាហាន**កៀងអ៊ុយ**ក៏បែកខ្ញែកស្លាប់ជាច្រើន ទទួល**ហែហ្សប៉ា**លើកទ័ពមកខ្ទប់ពីម្ខាង ទ័ព**តេងងាយ**ក៏ថយទៅ **កៀងអ៊ុយ**ក៏ចេញទៅរក**ហែហ្សប៉ា**និយាយថា **តាន់ថាយ**លើកទ័ពមកវាយបន្ទាយភ្នំគីសាន់បែកទៅហើយ **ប៉ៅនៅ**នាយទាហានខាងយើងក៏ស្លាប់ កងទ័ពក៏ត្រឡប់រត់បែកទៅស្រុកហាន់តុងអស់ហើយ។ **កៀងអ៊ុយ**ឮដូច្នោះក៏ទាល់គំនិតមិនដឹងបើនឹងគិតការតទៅយ៉ាងណា ក៏ឱ្យថយទ័ពត្រឡប់ទៅតាមផ្លូវតូចក្បែរនឹងភ្នំ **តេងងាយ**ក៏លើកទ័ពដេញដិតតាម។ **កៀងអ៊ុយ**ឱ្យកងទ័ពទាំងអស់ដើរទៅមុខ ខ្លួនឯងនៅរាំងពីក្រោយ លុះលើកថយទៅដល់ក្បែរភ្នំ **តាន់ថាយ**បង្កប់ទាហាននៅទីនោះ លុះឃើញកងទ័ព**កៀងអ៊ុយ**លើកមក ក៏នាំទាហានចេញវាយស្កាត់ទុក ទាហាន**តេងងាយ, តាន់ថាយ**ព័ទ្ធទ័ព**កៀងអ៊ុយ**លើកមក

នោះទុក សម្លាប់ទាហាន**កៀងអ៊ុយ**ស្លាប់ជាច្រើន ឯ**កៀងអ៊ុយ**នឹងហែកទម្លាយចេញទៅខាងច្រកណាក៏មិនបាន **ទៀវងី**ទាហាន**កៀងអ៊ុយ**លើកមកដល់បានឃើញដូច្នោះ ក៏នាំពលប្រហែលបីរយចូលចោមវាយជួយ**កៀងអ៊ុយ** ៗក៏ទម្លាយចេញទៅបាន។ **ទៀវងី**ត្រូវព្រួញស្លាប់ក្នុងទីចម្បាំង។ **កៀងអ៊ុយ**ក៏នាំទាហានដែលសល់ពីស្លាប់នោះរត់ទៅស្រុកហាន់តុង ហើយរឭកដល់គុណ**ទៀវងី**ណាស់ ថាជាមនុស្សស័ត្យទៀងត្រង់ មានចិត្តស្វាមីភក្តិធ្វើរាជការត្រាតែស្លាប់ខ្លួនក្នុងសង្គ្រាម ទើបឲ្យរង្វាន់បំណាច់ដល់បុត្រភរិយាតចៅផៅសន្តាន ហើយចាត់ចែងឈ្មោះអ្នកដែលធ្វើការបានមកតាំងធ្វើជានាយទាហានជំនួស**ទៀវងី**។

**កៀងអ៊ុយ**ក៏ប្រឹក្សាទោសខ្លួនឯងថា យើងលើកទ័ពទៅធ្វើការគ្រានេះខូចខាតទាហាន និងសេះគ្រឿងសាស្ត្រាវុធច្រើនណាស់ ទោសទាំងនេះក៏ជាទម្ងន់មហិមា យើងត្រូវតែផ្តន្ទាធ្វើទោសខ្លួន ឲ្យដូចយ៉ាងមហាឧបរាជកាលខូចកេតេងនឹងដៃ**សុម៉ាអ៊ី**ទើបសមគួរ ថាហើយក៏តែងរឿងរ៉ាវកាត់សេចក្តីធ្វើទោសខ្លួនឯង ដកហូតងារចេញពីតំណែងយសស័ក្តិ តែឲ្យនៅធ្វើរាជការត្រឹមតែទីនាយទាហានវិញ ហើយឲ្យបម្រើនាំទៅថ្វាយព្រះចៅ**ឡៅសៀន**។

ឯ**តេងងាយ** និង**តាន់ថាយ** លុះកងទ័ពស្រុកសែឈ្លួនបែករត់ទៅហើយ ក៏ឲ្យតែងតុលៀងនាយទ័ពនាយកង ហើយឲ្យបំណាច់រង្វាន់ដល់ទាហានទាំងពួងតាមសមគួរ **តាន់ថាយ**ទើបធ្វើជាសំបុត្របកលើកសេចក្តីគាប់ប្រសើរនៃ**តេងងាយ**ទៅដល់**សុម៉ាចៀវ** ៗក៏ឲ្យមានត្រាទៅតាំង**តេងងាយ**លឿនខិតទៅ បុត្រ**តេងងាយ**ក៏តាំងឲ្យជាមន្ត្រីធំ គ្រានោះព្រះចៅ**ចូម៉**សោយរាជ្យបានបីឆ្នាំ (ព.ស ៧៩៩) ឈ្មោះស្រុកពីដើមនោះ ឈ្មោះថា "កៃចេងៗ ក្នុងសម័យនោះប្រែឈ្មោះប្លែងជាថ្មីឲ្យហៅថាស្រុក "កាំឡូ"វិញ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៨១

**ចារឹកឡើងវិញដោយ ៖ ឈុល ដាក៉**

*(តាំងពី**សុម៉ាចៀវ**តម្កើងអំណាចមិនខ្លាចព្រះចៅ**ចូម៉** គិតតែដណ្ដើមយករាជសម្បត្តិ **ជូកាត់អៀន**បះគិតកម្ចាត់**សុម៉ាចៀវ** ១ទូលឲ្យស្ដេចចេញច្បាំងដោយកលឧបាយ ទ័ព**សុម៉ាចៀវ**ក៏សម្លាប់**ជូកាត់អៀន**ស្លាប់ សម្លាប់បុត្រភរិយាអស់បីជួរគោត្រនិងបក្សពួកបីរយនាក់ មានមនុស្សស្ម័គ្រនៅនឹង**សុម៉ាចៀវ**ជាច្រើន)។*

**ឯសុម៉ាចៀវ** បាននិយាយរាជការក្នុងស្រុកវុយកុកទូទាំងផែនដី កិច្ចការអ្វីៗក៏សិទ្ធិលើខ្លួនតែម្នាក់ឯង មិនបាច់នឹងក្រាបពិតទូលព្រះចៅ**ចូម៉**ឡើយ ទោះបីនឹងចូលចេញក្នុងព្រះរាជវាំងក៏ឲ្យមានទាហានបីពាន់នាក់ កាន់សាស្ត្រាវុធហែមុខហែក្រោយ សម្រាប់ការពាររក្សាខ្លួន លុះឃើញថាគ្មាននរណាស្មើជាគូហើយ ក៏រឹតតែស្រវឹងនឹងយសផ្គាបណ្ដាស័ក្តិជាខ្លាំង តាំងចិត្តគិតតែនឹងដណ្ដើយយករាជសម្បត្តិ មានមនុស្សស្និទ្ធម្នាក់ឈ្មោះ**កែឆុង** ជាកូន**កែគុយ**ជាទីទុកចិត្ត**សុម៉ាចៀវ** ឈ្មោះនេះក៏ទៅនិយាយនឹង**សុម៉ាចៀវ**ក្នុងទីស្ងាត់ថា ប្រសាសន៍មានយសផ្គាបណ្ដាស័ក្តិខ្ពស់ធំពេញនៅក្នុងទិសទាំងបួនហើយ ម្ដេចឡើយមិនគិតយករាជសម្បត្តិនេះ ឃើញថានៅក្នុងកណ្ដាប់ដៃប្រសាសន៍ទាំងអស់ បើនឹងធ្វើការវេលានេះ ក្រែងមនុស្សទាំងពួងនឹងមិនស្ម័គ្រព្រមចិត្តគ្នា ចាំនឹងស្ដាប់ដំណឹងព័ត៌មានមើលចិត្តថ្លើមមនុស្សទាំងពួងសិន ទើបនឹងបានគិតការធំតទៅ។

**សុម៉ាចៀវ**ថា ខ្ញុំបានគិតទុកយូរហើយ តែថាមិនដឹងដែលនឹងរកនរណានឹងហាមាត់ប្រាប់គ្មាន បើថាស្រឡាញ់យើងជួយរិះគិតដូច្នេះបាន ជាសេចក្ដីគាប់ប្រសើរណាស់ណា បើដូច្នោះត្រូវចៅជួយដើរទៅស្រុកហ្វៃយឡាំ ហើយនិយាយមើលទឹកចិត្តពួកចៅហ្វាយស្រុក តែថាធ្វើជាថាខ្ញុំប្រើឲ្យហៅទៅទទួលរង្វាន់មកចែកពួកទាហានមានឈ្មោះ ក្នុងការធ្វើសង្គ្រាមមានសេចក្ដីគាប់ប្រសើរ ហើយ

ស្តាប់មើលបែបលែបខាយ តើគេនឹងចូលចិត្តនឹងយើងឬទេ? **កែផុង**ទទួលពាក្យ **សុម៉ាចៀវ**ហើយ ក៏ចេញទៅស្រុកហ៊្សយឡាំ។

ឯ**ជូកាត់អៀន**ចៅហ្វាយស្រុកហ៊្សយឡាំ ពីដើមនៅស្រុកឡាំអៀងក្នុងខេត្ត ឡុកសេ ជាកូនបងកូនប្អូននឹង**ខុងបេង** បានធ្វើរាជការនៅស្រុកវុយកុក កាល **ខុងបេង**រស់នៅជាមហាឧបរាជក្នុងស្រុកសៃឈួន ឈ្មោះនេះក៏មិនបានស័ក្តិយសជា អ្វី ព្រោះមនុស្សទាំងពួងក្រែងថានឹងទៅចូលនឹងបងប្អូន លុះ**ខុងបេង**ស្លាប់ទៅ ទើប បានយសស័ក្តិជានាហ្មឺនធំ បានស្តីរាជការជាចៅហ្វាយស្រុកហ៊្សយឡាំ និងហ៊្សយខេ ទាំងពីរមណ្ឌល ជាធំលើសទាហានទាំងពួង លុះ**កែផុង**ទៅរកក៏អញ្ជើញឱ្យស៊ីលៀង តាំងតែសេពសុរា **កែផុង**ឃើញ**ជូកាត់អៀន**ស្រវឹងសុរាជោកក្នុងខ្លួនហើយ ក៏ក្លែង និយាយល្បងមើលទឹកចិត្តថា សព្វថ្ងៃនេះប្រជារាស្ត្រតិះដៀលអម្ចាស់ផែនដីថាជា មនុស្សល្ងង់ខ្លៅមិនដឹងសេចក្តីអ្វីសោះ មិនសមគួរធ្វើម្ចាស់ផែនដីវង្ស **សុម៉ាចៀវ**បាន ជាមហាឧបរាជបម្រុងផែនដីមកបីតហើយ បានរក្សារាស្ត្រឱ្យនៅជាសុខស្រណុក សប្បាយមិនមានអន្តរាយអ្វីនោះ ឃើញថាជាសេចក្តីគាប់ប្រសើរយ៉ាងធំ គួរនឹង ជំនួសម្ចាស់ស្រុកវុយកុកបាន តើលោកយល់ឃើញប្រការម្តេច?

**ជូកាត់អៀន**ឮដូច្នោះខឹងខ្លាំងណាស់ថា ចៅជាកូន**កែគុយ** បានស៊ីបៀវត្តឆ្នាំ ក្នុងរាជការស្រុកវុយកុកដរាបមក គួរហើយនឹងមានចិត្តស័ត្យទៀងត្រង់នឹងផែនដី ម្តេចអ្វីចៅមកចរចាមិនគប្បីដូច្នេះ មិនគួរសោះ។ **កែផុង**បានឮដូច្នោះក៏ភ័យណាស់ ទើបកែថា ខ្ញុំបាទបានឮអ្នកដទៃគេនិយាយឱ្យទាស់ចិត្តណាស់ បានជានាំមក ដំណាលឱ្យលោកជ្រាបផង។

**ជូកាត់អៀន**ថា បើអន្តរាយមកដល់ម្ចាស់ផែនដី យើងជាខ្ញុំរាជការនឹងអាសា ស្នងព្រះតេជះព្រះគុណត្រាតែអស់ជីវិត។ **កែផុង**បានឮដូច្នោះក៏នៅស្ងៀម ឈប់ ដេកនឹង**ជូកាត់អៀន**មួយយប់ លុះព្រឹកឡើងក៏លាចេញទៅ លុះទៅដល់ទីក្រុងហើយ ក៏សាស្រាយរឿងរ៉ាវ ដែលចរចានឹង**ជូកាត់អៀន**នោះឱ្យ**សុម៉ាចៀវ**ស្តាប់គ្រប់ប្រការ។ **សុម៉ាចៀវ**បានឮដូច្នោះក៏ខឹងខ្លាំងណាស់ថា គួរឬវាមកបង្អាចចរចាយ៉ាងនេះ? **កែផុង** ឆ្លើយថា **ជូកាត់អៀន**នោះជានាហ្មឺនធំ ចេះអបអរយកចិត្តទាហានទាំងពួង ទាហាន

ក៏ស្រឡាញ់ យូរទៅមុខជាមានភ័យជាប្រាកដ កុំបង្អង់ឲ្យយូរឡើយ ចូរលោកស្រូតរូតគិតរំលាងជីវិត**ជូកាត់អៀន**ចេញឲ្យបាន។ **សុម៉ាចៀវ**យល់ឃើញត្រូវ ក៏ឲ្យមានសំបុត្រស្ងាត់ទៅដល់**ងាក់លឹម**ចៅហ្វាយស្រុកអេងជីវ ហើយទើបឲ្យមានត្រាព្រះតម្រាស់ទៅដកងារ**ជូកាត់អៀន**ចេញចាកទីចៅហ្វាយស្រុកហ៊្វយឡាំ និងយកមកតាំងជានាហ្មឺនធំគាប់បម្រើធ្វើរាជការខាងក្នុងស្រុកហ្លួង។

ឯបម្រើកាន់ព្រះតម្រាស់លុះទៅដល់ហើយ **ជូកាត់អៀន**ដឹងក្នុងខព្រះតម្រាស់ហើយដឹងថា **កែតុង**នាំយករឿងរ៉ាវដែលនិយាយគ្នានោះទៅប្រាប់ដល់ទៅ**សុម៉ាចៀវ**ទើបរិះគិតធ្វើដូច្នេះ ដើម្បីនឹងធ្វើអន្តរាយដល់យើង ទើបឲ្យយកបម្រើដែលកាន់ព្រះតម្រាស់នោះទៅសាកសួរយកសេចក្តី។ បម្រើកាន់ព្រះតម្រាស់ឲ្យការថា សេចក្តីដូច្នោះខ្ញុំបាទមិនដឹងទេ។ **ងាក់លឹម**ចៅហ្វាយស្រុកនោះឯងឃើញថាមុខជានឹងដឹង។ **ជូកាត់អៀន**សួរថា គេនឹងដឹងដោយហេតុអ្វី? បម្រើកាន់ព្រះតម្រាស់ប្រាប់ថា **ងាក់លឹម**នោះអាចដឹងទាំងអស់ ព្រោះ**សុម៉ាចៀវ**ឲ្យសំបុត្រស្ងាត់ទៅដល់មួយច្បាប់។ **ជូកាត់អៀន**ក៏ឲ្យយកបម្រើកាន់ព្រះតម្រាស់នោះទៅសម្លាប់ចេញ ហើយលើកទាហានមួយពាន់ទៅវាយស្រុកអេងជីវ លុះទៅដល់ទ្វារខាងទិសឯត្បូង ឃើញមាត់ទ្វារកំពែងបើក **ជូកាត់អៀន**ចូលទៅដល់ជើងកំពែង ក៏ស្រែកឲ្យបើកទ្វារទទួលតែគ្មាននរណាបើក។ **ជូកាត់អៀន**ខឹងណាស់ស្រែកជេរថា **អាងាក់លឹម**នេះជាមនុស្សឆោតខ្លៅបង្កាច់មកគិតប្រទូសរ៉ាយអញ ទាហានល្អមានថ្វីដៃប្រមាណដប់នាក់លោតចុះពីលើខ្នងសេះ ហែលឆ្លងគូឡើងកំពែងទៅបាន ហើយដេញកាប់សម្លាប់ទាហានលើសើនបន្ទាយរត់អស់ ហើយក៏បើកទ្វារស្រុកចេញមក។

**ជូកាត់អៀន**ក៏នាំទាហានចូលទៅក្នុងស្រុក ហើយឲ្យទាហានយកភ្លើងដុតផ្ទះ **ងាក់លឹម** ៗភ័យណាស់ ស្ទុះរត់ឡើងទៅនៅក្នុងបន្ទប់ថ្នាក់ជាន់លើ **ជូកាត់អៀន**កាន់គ្របីបរពលដេញស្រាវជ្រាវរកខ្លួន ជួបប្រទះក៏ស្រែកគំហកថា បិតារបស់អ្នកឯងពីដើមក៏ជាខ្ញុំផែនដីស្រុករុយកុក លុះដល់មកខ្លួនឯងទៀតក៏ជាខ្ញុំរាជការតមក គួរឃើញឧបការគុណច្រើនណាស់ ព្រោះម្ចាស់ផែនដីបានទំនុកបម្រុងក្នុងផ្លូវសង្គ្រោះខ្លួនជាមនុស្សត្រូវតែកតញ្ញូស្គាល់គុណម្ចាស់ គួរហើយឬមកប្រែក្រឡាស់ជាក្បត់

ចូលគំនិតនឹង**សុម៉ាចៀវ**ជាមនុស្សទុរយស? **ងាក់លឹម**ក៏នៅមិនទាន់នឹងឆ្លើយតបសោះ **ជូកាត់អៀន**ក៏កាប់នឹងគ្រប៊ីត្រូវ**ងាក់លឹម**ដាច់កស្លាប់។

**ជូកាត់អៀន**មានសំបុត្រពោលទោស**សុម៉ាចៀវ** ឲ្យនាំចូលទៅក្រាបទូលព្រះចៅ**ចូម៉**ឯក្រុងឡកអៀង ហើយក៏កេណ្ឌរេហ៍ពលក្នុងស្រុកហ៊្វយឡាំ ស្រុកហ៊្វយខេបានពលដប់ម៉ឺនប្លាយ ហើយឲ្យប្រមូលទៅត្រៀមព្រមទាំងសេះនិងគ្រឿងសាស្ត្រាវុធ ស្រូវអង្ករស្បៀងអាហារហើយតាំង**ង៉ំកុង**ជាទីប្រឹក្សាធំ ឲ្យនាំ**ជូកាត់ចេង**ជាបុត្រទៅស្រុកកាំងតាំង ដើម្បីប្រគល់ទុកជារបស់បញ្ចាំចិត្ត សុំឲ្យជួយកងទ័ពលើកទៅព្រួតវាយកម្ចាត់**សុម៉ាចៀវ** ដែលជាសត្រូវរាជសម្បត្តិ។

គ្រានោះ**ស៊ុនជុន**ដែលជាមហាឧបរាជស្រុកកាំងតាំងស្លាប់ហើយ បាន**ស៊ុនលឹម**ជាប្អូនទទួលស្តីទីជាមហាឧបរាជជំនួសបង **ស៊ុនលឹម**សម្លាប់**តេងអ៊ិន**ជានាហ្មឺនធំនិងពួកទាហានឈ្មោះ**លីគី, អងទុន**ស្លាប់ ទើបតាំងខ្លួនបានជាធំជាងមន្ត្រីទាំងពួង ឯព្រះចៅ**ស៊ុនលៀង**ក៏មានសតិបញ្ញា តែមិនដឹងនឹងថាដូចម្តេច ព្រោះរាជការផែនដីស្រេចដាច់ខាតលើឈ្មោះ**ស៊ុនលឹម**តែម្នាក់ឯង។ **ង៉ំកុង**បានទៅដល់ស្រុកចោថៅសៀ ក៏ចូលទៅគំនាប់**ស៊ុនលឹម** ៗក៏សួរថា អ្នកមកនេះមានកិច្ចធុរៈការអ្វី? **ង៉ំកុង**ជម្រាបថា **ជូកាត់អៀន**ជាបងប្អូន**ខុងបេង**ធ្វើរាជការខាងស្រុកវុយកុកឃើញ**សុម៉ាចៀវ**លើកយកម្ចាស់ផែនដីចេញ ដោយគិតនឹងចង់ដណ្ដើមយករាជសម្បត្តិខ្លួនឯង បានជា**ជូកាត់អៀន**ឈឺចិត្តគិតកម្ចាត់សត្រូវផែនដីចេញ ឃើញថាកម្លាំងរេហ៍ពលរបស់ខ្លួនតិចមិនធូនការ ទើបប្រើខ្ញុំបាទឲ្យនាំបុត្រមកប្រណិប័តន៍លោក ដើម្បីសុំកងទ័ពលោកទៅជួយ ក្រែងលោកថានៅមិនជឿចិត្ត ក្រែងពុំពិតដូចសញ្ញា សូមទុកបុត្រាឈ្មោះ**ជូកាត់ចេង**ឲ្យនៅនឹងលោកជារូបបញ្ចាំ សូមឲ្យតែលោកលើកទាហានទៅជួយ។ **ស៊ុនលឹម**ក៏ជឿទើបចាត់ទាហានឈ្មោះ**ជួនតេក, ជួនទុន**ទាំងពីរនាក់នេះជាមេទ័ពរបស់ហ្លួង។ **អ៊ិនជួន**ជាមេទ័ពជូន **ជូអ៊ី, តងអ៊ូ** ពីរនាក់នេះជានាយកងមុខ ឲ្យ**ប៊ុនឃីម**នាំផ្លូវទាហានទាំងបីកងនោះ រួមពលបានប្រាំពីរម៉ឺនលើកទៅជួយ**ជូកាត់អៀន** ឯ**ង៉ំកុង**ក៏លា**ស៊ុនលឹម**មកស្រុកហ៊្វយឡាំវិញ ហើយចូល

ទៅជម្រាប**ជូកាត់អៀន**ថា បានកងទ័ពស្រុកកាំងតាំងមកហើយ។ **ជូកាត់អៀន**មានសេចក្ដីអំណរណាស់ ក៏ចាត់ចែងកងទ័ពហើយលើកទៅ។

ឯ**សុម៉ាចៀវ** បានដឹងសំបុត្រដែល**ជូកាត់អៀន**ឲ្យនាំទៅទូលព្រះចៅ**ចូម៉**នោះក៏មានសេចក្ដីខឹងណាស់ តាំងតែរិះគិតនឹងលើកទ័ពទៅវាយ**ជូកាត់អៀន**។ **កែឆុង** និយាយថា វង្សរបស់លោកបានឧបត្ថម្ភទំនុកបម្រុងផែនដីពីបិតានិងបងតមកដល់លោកទៀត គុណនេះជាទម្ងន់ណាស់ណាទៅហើយ តែថានៅឡើយព្រោះមិនទាន់ទូទៅក្នុងទិសទាំងពួង បានជាមានមនុស្សនាំបះបោរជាក្បត់យ៉ាងនេះ ដែលលោកនឹងចេញទៅបង្ក្រាបសត្រូវដោយខ្លួនឯងនោះ ខ្ញុំបាទយល់ឃើញថាមិនត្រូវសោះ ព្រោះក្រែងសត្រូវនឹងនាំចលាចលច្របល់ឡើងក្នុងស្រុកក្រុង ដែលជាទីព្រះរាជសាន្ត បើកាលណាកើតវរវើកហើយ លោកនឹងវិលត្រឡប់មកប្រាបប្រាមជាក្រោយក៏នឹងមានសេចក្ដីលំបាក។ បើលោកអញ្ជើញព្រះនាង**គួយថាយហៅ** និងព្រះចៅ**ចូម៉**ចេញទៅប្រាបប្រាមសត្រូវវិញមុខជាស្ងប់ដោយងាយ។ **សុម៉ាចៀវ**បានឮដូច្នោះក៏មានសេចក្ដីត្រេកអរណាស់ ទើបឆ្លើយឡើងថា អ្នកនិយាយនេះត្រូវនឹងគំនិតគិតរបស់យើង ថាហើយក៏ចូលទៅទូលព្រះនាង**គួយថាយហៅ**ថា **ជូកាត់អៀន**គិតក្បត់ទូលព្រះបង្គំនូវអស់នាហ្មឺនមុខមន្ត្រីទាំងពួង បានប្រឹក្សាយល់ព្រមគ្នាសូមអញ្ជើញព្រះអង្គនិងព្រះចៅ**ចូម៉**ចេញទៅផង នឹងបានបង្ក្រាបសត្រូវឲ្យរាបទាបរក្សាផែនដីទុកកុំបីឲ្យជាអន្តរាយ ដូចព្រះបន្ទូលព្រះចៅ**ចូយ៉យ**ដែលទ្រង់បណ្ដាំទុកនោះ។ ព្រះនាង**គួយថាយហៅ**ខ្លាចអំណាចមិនអាចនឹងទទឹងបាន ក៏ទទូចថានឹងទៅ លុះព្រឹកឡើងថ្ងៃមួយ **សុម៉ាចៀវ**ក៏ចូលទៅទូលព្រះចៅ**ចូម៉**ថា សូមអញ្ជើញព្រះអង្គស្ដេចចេញទ័ព។

ព្រះចៅ**ចូម៉**ឆ្លើយថា អ្នកជាមហាឧបរាជបានស្ដីរាជការទាំងផែនដី ជាសិទ្ធិដាច់ស្រេចលើអ្នកហើយ ទោះបីនឹងបង្គាប់បញ្ជា នរណាក៏មិនអាចប៊ានរឹងទទឹងបាន គួរតែអ្នកទៅវិញទើបស្រួល ដែលនឹងឲ្យខ្ញុំឯងទៅនោះតើជាប្រការម្ដេច? **សុម៉ាចៀវ**ថា បើព្រះអង្គនឹងមិនព្រមស្ដេចទៅវិញមិនគួរទេ កាលគ្រាព្រះចៅ**ចូឆ្វ**ស្ដេចក៏បានត្រាច់រង្កាត់ទៅប្រាបប្រាមរាជសត្រូវទាល់តែដល់ផ្ទៃមហាសមុទ្រ លុះមកផែនដីព្រះចៅ**ចូភី**, ព្រះចៅ**ចូយ៉យ**ក៏គិតចង់ឲ្យផែនដីរាបទាប បើរាជសត្រូវ

បង្កើតនៅទីណា ក៏ទ្រង់ព្រះឧស្សាហ៍ស្តេចទៅបង្ក្រាបនៅទីនោះ ហេតុនេះសូមឲ្យព្រះអង្គស្តេចចេញទៅ ដេញរំលាងសត្រូវតាមបែបយ៉ាងព្រះបរមវង្សតមកនោះចុះ ដែលព្រះអង្គមកញញើតខ្លាចនោះមិនគួរទេ។ ព្រះចៅ**ចូម៉**ទទឹងមិនបាន ក៏ទទួលថានឹងទៅ ទើបមានត្រាព្រះតម្រាស់ឲ្យកេណ្ឌរេហ៍ពលក្នុងព្រះនគរទាំងពីរអន្លើ ក៏បានពលម្ភៃប្រាំមួយម៉ឺន តាំង**អងគី**ជាមេទ័ពមុខ **តាំងខៀន**ជាបាឡាត់ទ័ពមុខ **ចោប៉ា**ជាប៉ែកស្តាំ **ជីវថាយ**ចៅហ្វាយស្រុកគុនជីវជាប៉ែកឆ្វេង ព្រះចៅ**ចូម៉**ក៏ទ្រង់ព្រះទីនាំងរាជរថលើកទ័ពទៅតាមផ្លូវស្រុកហ៊្វយឡាំ ក៏ទៅដល់ប្រទល់នឹងកងទ័ពស្រុកកាំងតាំងដែលជាកងទ័ពមុខមកជួយ**ជូកាត់អៀន**នោះ។ **ជូអ៊ី**ដែលជាមេទ័ពស្រុកកាំងតាំងក៏លើកទាហានចេញត **អងគី**ជិះសេះនាំទាហានចេញច្បាំង **ជូអ៊ី**ច្បាំងនឹង**អងគី**មិនទាន់បានមួយភ្លែង ក៏ទន់កម្លាំងប្រុងនឹងភ្លាត់ **ជូអ៊ី**ក៏រត់ **តងអ៊ូ**ជិះសេះចេញមកជំនួសឡើង មិនទាន់បានបីភ្លែងក៏រត់ថយទៅ តាមផ្លូវចម្ងាយប្រហែលប្រាំរយសិន (២០ គ.ម) ក៏តាំងបោះបន្ទាយនៅទីនោះ ទើបឲ្យបម្រើសេះកាន់សំបុត្រប្តឹងចូលទៅដល់**ជូកាត់អៀន**ដែលទៅតាំងនៅស្រុកឈីវឈុន។ **ជូកាត់អៀន**ក៏លើកទ័ពមកជាមួយនឹង**ប៊ុនឃីម** ឯ**ប៊ុនអេង**ជាបុត្រច្បង **ប៊ុនហៅ**បុត្របន្ទាប់ទាំងពីរនាក់ក៏មកជាមួយនឹងបិតា។

**សុម៉ាចៀវ**ដឹងថា ទ័ព**ជូកាត់អៀន**លើកទៅបញ្ចូលគ្នានឹងទ័ពស្រុកកាំងតាំងហើយ ទើបឲ្យប្រមូលមន្ត្រីធំតូចពីរនាក់ ឈ្មោះ**ប៉ោស៊ី១, ចុងហោយ១** មកប្រឹក្សារាជការសង្គ្រាម។ **ចុងហោយ**ថា កងទ័ពស្រុកកាំងតាំងលើកមកជួយគេគ្រានេះ ព្រោះលោភមានលាភសក្ការៈ បើដូច្នោះត្រូវយើងយករបស់ទ្រព្យទៅបោះវាយចោល ជាការបញ្ឆោតឲ្យបរាជ័យដល់យើង។ **សុម៉ាចៀវ**យល់ឃើញត្រូវផង ទើបបង្គាប់**ចោប៉ោ, ជីវថាយ**ឲ្យនាំទាហានជាពីរកងទៅបង្កប់នៅដើមផ្លូវស្រុកចោចៅសៀ ឲ្យ**អងគី** និង**តាំងខៀន**នាំទាហានទៅបង្កប់នៅចុងផ្លូវនោះ ហើយប្រើឲ្យ**សេងជុយ**ទៅល្បួងបញ្ឆោតឲ្យចេញមកច្បាំង ហើយបង្គាប់ថា បើគេមកវាយហើយ ឲ្យធ្វើជារត់ទៅតាមផ្លូវចោចៅសៀ ឲ្យ**តាន់ជុន**នាំហ្វូងសេះនិងរទេះគោផ្ទុករបស់ទ្រព្យទៅ

ទម្លាក់ចោលនៅផ្លូវនោះ ហើយបង្គាប់ថា បើសត្រូវលើកមកឲ្យបាចសាចរបស់ទ្រព្យទាំងនោះ ហើយឲ្យរត់ចេញ។

ឯ**ជូកាត់អៀន**ប្រើ**ជូអ៊ី**ទាហានស្រុកកាំងតាំងជាប៉ែកស្តាំ **ប៊ុនឃឹម**ជាប៉ែកឆ្វេងលើកចេញ លុះឃើញកងទ័ពស្រុកវុយកុកមិនបានប្រុងប្រៀបរៀបរយ មានមនុស្សនិងសេះចោលរាយផ្តេសផ្តាស ក៏បរពលចូលវាយ **ស៊ុនជុន**ក៏នាំទាហានរត់ទៅ **តាន់ជុន**ដែលនាំរបស់មកនោះ លុះឃើញ**ជូកាត់អៀន**លើកទ័ពមកហើយ ចោលរបស់ទ្រព្យរាត់រាយនាំគ្នារត់ នោះពួកទាហាន**ជូកាត់អៀន**ឃើញរបស់ជ្រុះចោលដោយផ្លូវច្រើនណាស់ ទាំងអស់គ្នាក៏នាំគ្នារើសជញ្ជូនយករបស់ទ្រព្យ និងគោសេះមិនបានប្រុងប្រយ័ត្នរវាំងខ្លួន នោះស្រាប់តែឮសូរកាំភ្លោះ និងផាវឡើង ក្រឡេកទៅឃើញ**ចោប៉ា** និង**ជីវថាយ** នាំទាហានពីរកងវាយសង្កុញចូលមក **ជូកាត់អៀន**ភ័យខ្លាចពេកណាស់ ក៏ថយទ័ព ឃើញ**អងគី** និង**តាំងខៀន**ចាំវាយខ្ទប់ប្រសព្វចូលមក ឯ**សុម៉ាចៀវ**ក៏លើកទាហានជូនថែមមកទៀត។ **ជូកាត់អៀន**ឃើញលើសកម្លាំងដែលនឹងតស៊ូច្បាំងពុំបាន ក៏ថយទ័ពរត់ទៅដល់ស្រុកឈីវឈុន ហើយឲ្យទាហានឡើងរក្សានាទីសើនបន្ទាយ ឯ**សុម៉ាចៀវ**ក៏ឲ្យចូលចោមព័ទ្ធវាយប្រសព្វទាំងបួនទិស នោះទាហានក្នុងកងទ័ពស្រុកកាំងតាំងក៏ថយទៅនៅឯតំបន់តាន់ឆង ព្រះចៅ**ចូម៉**ក៏ទៅតាំងទ័ពប្រថាប់នៅស្រុកហាងសៀ។

វេលានោះ **ចុងហោយ**និង**សុម៉ាចៀវ**ថា ក្នុងស្រុកឈីវឈុននោះ ស្រូវអង្ករស្បៀងអាហារក៏នៅមានបរិបូរ បើយើងនឹងព័ទ្ធទុកយូរក៏គង់មិនដាច់ខ្វះឲ្យលំបាក ក្រែងតែទាហានស្រុកកាំងតាំងនឹងលើកមកវាយទ័ពពីក្រោយ យើងនឹងវរវឹកលំបាក ដែលយើងព័ទ្ធទុកទាំងបួនទិសដូច្នេះនេះ នឹងនាំឲ្យថ្លោះការនឹងសុំឲ្យព័ទ្ធទុកតែបីទិស បើកចំហទិសខាងត្បូង បើរត់ចេញពីស្រុកហើយ សឹមយើងឲ្យទាហានយើងលើកដេញប្រទេះពីក្រោយទៅឲ្យយ៉ាងមាំ មុខជានឹងបានជ័យជម្នះតែម្តង ឯកងទ័ពកាំងតាំងនោះ គឺលើកពីផ្លូវឆ្ងាយ ទោះនឹងនាំស្បៀងអាហារជាប់មកក៏តិចតួចដែលនឹងបញ្ជូនមកទៀតក៏មិនទាន់ សូមឲ្យលើកកងទ័ពទៅស្កាត់ពីខាងក្រោយ នៅមិនទាន់ចូលវាយក៏នឹងផ្អើលភ្ញាក់រត់ទៅឯង។

ឯ**សុម៉ាចៀវ**បានឮដូច្នោះក៏លើកដៃឡើងស្ទាបអង្កែលខ្នង**ចុងហើយ** ហើយសរសើរថា អ្នកឯងមានគំនិតចេះរិះគិតច្រើនណាស់ វិស័យដូចបញ្ញានិងគំនិតរបស់**ទៀវលៀង** ក្នុងគ្រាព្រះចៅ**ហាន់កោចោ** ថាហើយក៏ឱ្យ**អងគី**លើកបន្ថយទាហានដែលព័ទ្ធខាងទិសឯត្បូងនោះចេញ។

ឯ**ស៊ុនលឹម**ស្រុកកាំងតាំង ក៏ឱ្យយកខ្លួន**ជូអ៊ី**នាយទ័ពមុខទៅកាត់ផ្ដន្ទាទោសថា គ្រាន់តែឱ្យទៅសង្កត់ដំណួចប៉ុនស្រុកឈើវឈុនប៉ុណ្ណោះ នៅធ្វើមិនបានរាជការចំណង់បើនឹងទៅគិតវាយយកស្រុកវុយកុកទាំងមូល តើធ្វើម្ដេចនឹងបាន? បើធ្វើការគ្រានេះមិនឈ្នះដល់សត្រូវទេ យើងនឹងត្រូវប្រហារជីវិតបង់។ **ជូអ៊ី**ក៏គំនាប់លាត្រឡប់ទៅបន្ទាយហើយប្រឹក្សានឹងនាយទ័ពទាំងពួង។ **អ៊ីជួន**នាយទ័ពជូនថា ទិសខាងត្បូងសត្រូវមិនបានព័ទ្ធទេ ខ្ញុំបាទសូមលើកកងទ័ពចូលទៅជួយ**ជូកាត់អៀន** ដើម្បីនឹងរក្សាពួកស្រុកទុក លោកត្រូវលើកទាហានចូលវាយកងទ័ពស្រុកវុយកុកចុះ ខ្ញុំបាទនឹងលើកទាហានពីក្នុងចេញមកវាយប្រសព្វទៀត មុខជាកងទ័ពវុយកុកនឹងបែកជាប្រាកដ។ **ជូអ៊ី**យល់ឃើញត្រូវទើបចាប់**អ៊ីច, ជួនតេក, ជួនទូន, ប៊ុនឃឹម** នាយទាហានទាំងបួននាក់នេះនាំពលមួយម៉ឺនលើកចូលទៅតាមផ្លូវទិសឯត្បូង។

ឯទាហានស្រុកវុយកុកមិនមានបង្គាប់ឱ្យវាយស្កាត់ទុក ក៏បណ្ដោយឱ្យកងទ័ពស្រុកកាំងតាំង លើកចូលទៅក្នុងស្រុក ទើបយកសេចក្ដីទៅជម្រាបដល់**សុម៉ាចៀវ** ។ដឹងហើយទើបថា កងទ័ពស្រុកកាំងតាំងបែកគ្នាចូលទៅជួយរក្សាស្រុកទុក **ជូអ៊ី**ក៏លើកចូលវាយយើង សមគួរដែលយើងគិតទុកហើយ ទើបឱ្យរក**អងគី**និង**តាន់កៀន**នាយទាហានពីរនាក់បង្គាប់ថា អ្នកឯងត្រូវលើកទាហានទៅបង្កប់ក្បែរផ្លូវដែលកងទ័ព**ជូអ៊ី**នឹងលើកមក បើគេបណ្ដោយចូលមកបន្តិចហើយ ត្រូវឱ្យទាហានស្រែកហ៊ោដេញកាប់សម្លាប់តាមក្រោយចូលទៅ។ **អងគី, តាន់កៀន**ក៏នាំទាហានទៅបង្កប់តាមបង្គាប់ លុះកងទ័ព**ជូអ៊ី**លើកគ្នាបណ្ដោយចូលទៅស្រុកហើយក៏លើកពលចេញវាយពីក្រោយតាមទៅ កងទ័ពស្រុកកាំងតាំងក៏បែក ខ្លួន**ជូអ៊ី**ក៏បែកទៅរក**ស៊ុនលឹម** ។ខឹងណាស់ថា ឯងជាមេទ័ពបែក នឹងយកទុកមិនបាន ក៏បង្គាប់ឱ្យទាហាននាំទៅសម្លាប់ ទើបឱ្យហៅ**ជួនហ៊ុយ**ជាបុត្រ**ជួនទូន**មកបង្គាប់ថា អ្នកឯង

ត្រូវស្រូតលើកទ័ពទៅវាយស្រុកវុយកុកឲ្យថយទៅឲ្យបាន បើមិនបានទេ ទាំងអាពុកទាំងកូនកុំវិលឲ្យឃើញមុខយើងឡើយ។ **ស៊ុនលឹម**បង្គាប់ហើយក៏លើកទៅតំបន់កៀនងៀប។

**ចុងហោយ**ជម្រាប**សុម៉ាចៀវ**ថា កងទ័ពដែលមកជួយនោះបែកទៅហើយ យើងត្រូវលើកទាហានទៅព័ទ្ធឲ្យជុំវិញទាំងបួនទិសចុះ។ **សុម៉ាចៀវ**យល់ឃើញត្រូវក៏ឲ្យទាហានចេញទៅវាយទាំងបួនទិស ឯ**ជួនហ៊ុយ**លើកទាហានមក ឃើញទាហានស្រុកវុយកុកច្រើនណាស់ នឹងទម្លាយចូលទៅមិនបាន នឹងថយក្រោយទៅក៏ខ្លាច**ស៊ុនលឹម** ក៏ស្ម័គ្រចូលទៅនៅនឹង**សុម៉ាចៀវ** ៗក៏តាំងឲ្យ**ជួយហ៊ុយ**ជាទាហានរង។ **ជួនហ៊ុយ**មានសេចក្ដីត្រេកអរណាស់ រិះគិតកតញ្ញូគុណ**សុម៉ាចៀវ** ទើបសរសេរសំបុត្រជាសេចក្ដីថា ឲ្យ**ជួនទួន**បិតានិង**ជួនតេក**ជាមាស្ម័គ្រចូលទៅនៅនឹង**សុម៉ាចៀវ**ចុះ **ស៊ុនលឹម**នោះមនុស្សអាក្រក់ គ្មានសេចក្ដីមេត្តាករុណាសោះ ខ្ញុំបាទក៏បានចូលទៅនៅនឹង**សុម៉ាចៀវ**ហើយ លុះសរសេរហើយ ក៏ចងសំបុត្រនោះនឹងព្រួញធ្នូហើយបាញ់ទម្លាក់ទៅក្នុងស្រុក **ជួនតេក**បានសំបុត្រហើយក៏នាំទៅបង្ហាញ**ជួនទួន**ហើយក៏លបនាំបក្ខពួករបស់ខ្លួនបើកទ្វារចេញទៅនៅខាង**សុម៉ាចៀវ**។

ឯ**ជូកាត់អៀន**ជាទុក្ខណាស់ គិតរកឧបាយដែលនឹងកែខ្លួនឲ្យរួច **ចៀវប៉ាន់**និង**ចៀវអ៊ី**ជាទីប្រឹក្សាទើបនិយាយនឹង**ជូកាត់អៀន**ថា ស្បៀងអាហារក្នុងស្រុកក៏ស្ដើងស្ដួចណាស់ហើយ ពលទាហានក៏ច្រើន ដែលនឹងស៊ីយូរទៅក៏ប្រហែលមិនគ្រប់គ្រាន់ នឹងឲ្យគេព័ទ្ធទុកយូរណាស់មុខជាមិនស្រួល ខ្ញុំបាទគិតថានឹងឲ្យលើកទាហានយើងនិងទាហានស្រុកកាំងតាំងពារទម្លាយចេញទៅឲ្យបាន ក៏ត្រូវតែប្រថុយច្បាំងឲ្យអស់ថ្វីដៃ ត្រាតែស្លាប់ទាំងអស់គ្នាទៅចុះ **ជូកាត់អៀន**បានឮដូច្នោះក៏ខឹងណាស់ថា ខ្ញុំឃើញល្មមនឹងរក្សាទុកនៅបាន ដែលអ្នកមកគិតយ៉ាងនេះ ឃើញថាស្រួលហើយឬ? ថាយ៉ាងនេះគឺក្លែងឲ្យចាញ់សត្រូវ បើតទៅមុខហើយអ្នកឯងមកនិយាយយ៉ាងនេះទៀត យើងនឹងឲ្យយកខ្លួនទៅប្រហារជីវិត។

**ចៀវប៉ាន់, ចៀវអ៊ី**បានឮដូច្នោះក៏ទាល់គំនិត ងើយមុខឡើងហើយដកដង្ហើមធំ នាំគ្នាថយចេញទៅហើយប្រឹក្សាគ្នាថា **ជូកាត់អៀន**វេលានេះមុខជានឹងដល់នូវ

សេចក្ដីស្លាប់ហើយ យើងត្រូវស្រូតរូតគិតទៅចូលនៅខាង**សុម៉ាចៀវ**ចុះ ទើបនឹងរួចពីសេចក្ដីស្លាប់។ លុះពេលយាមមួយប្លាយ **ចៀវប៉ាន់, ចៀវអ៊ុ** ឡើងពារកំពែងចេញទៅនៅខាង**សុម៉ាចៀវ** ៗក៏យកទុកប្រើការរាជការ។ តាំងពីនោះទៅទាហានដែលមានថ្វីដៃក្នុងស្រុកឈីវឈុន គ្មាននរណានឹងរិះគិតចេញទៅច្បាំងឡើយ **ជូកាត់អៀន**ក្រឡេកឃើញកងទ័ព**សុម៉ាចៀវ**ពូនដីជាស្នាមភ្លោះឡើងរាំងទឹក ដោយខ្លាចទឹកក្នុងទន្លេហាយស៊ុំនឹងលិចក៏ត្រេកអរណាស់ ព្រោះគិតថា ទន្លេហាយស៊ុំទឹកជន់ធំលិចទាហាន**សុម៉ាចៀវ**ហើយ យើងនឹងលើកចេញវាយមុខជាមានជ័យជម្នះ តាំងពីរដូវភ្លៀងលុះដល់រដូវរងាគ្មានភ្លៀងធ្លាក់ម្ដងសោះ ទឹកទន្លេហាយស៊ុំស្រកតិចទៅ ស្បៀងក្នុងស្រុកក៏អស់ហើយ។

ឯ**ប៊ុនយឹម**និងបុត្រពីរនាក់ ក៏នាំទាហានរក្សានាទី លុះឃើញទាហានកាន់តែអត់ឃ្លានណាស់ ក៏ចូលទៅជម្រាប**ជូកាត់អៀន**ថា ស្បៀងអាហារអស់ហើយ ទាហានអត់ឃ្លានណាស់ សុំឲ្យបើកទាហានហ្វ៊ួយឡាំដែលជាពួកអ្នកស្រុក ឲ្យចេញទៅស្វែងរកស្រូវអង្ករស្បៀងអាហារខាងក្រៅ ដើម្បីឲ្យចម្រើនស្បៀងរបស់យើងទុកខ្លះ **ជូកាត់អៀន**ខឹងច្រឡោតឡើងថា អ្នកឯងនិយាយនេះក្លែងគិតប្រទូសរ៉ាយយើងឬ? ថាហើយក៏បង្គាប់ឲ្យយក**ប៊ុនយឹម**ទៅសម្លាប់ចេញ។

ឯ**ប៊ុនអេង, ប៊ុនហោ** ឃើញគេសម្លាប់បិតាក៏ខឹងខ្លាំងណាស់ ហូតដាវដេញកាប់ទាហានលើសើនបន្ទាយសម្លាប់ជាងដប់នាក់ ហើយលោតចុះពីលើកំពែងឆ្លងគូទៅចូលខាង**សុម៉ាចៀវ** ហើយពណ៌នាសេចក្ដីទាំងពួងឲ្យ**សុម៉ាចៀវ**ស្ដាប់ **សុម៉ាចៀវ**ឃើញ**ប៊ុនអេង, ប៊ុនហោ**ចូលទៅស្វាមីភក្ដិក៏មានចិត្តក្ដៅណាស់ ព្រោះ**ប៊ុនអេង**វាយទ័ព**សុម៉ាស៊ូ**បែកពីគ្រាមុននោះ គិតនឹងឲ្យសម្លាប់ចេញ។ **ចុងហោយ**ជម្រាបហាមឃាត់ថា ដែលទោសខុសពីគ្រាមុននោះ ព្រោះ**ប៊ុនយឹម**ជាអាពុក ឥឡូវនេះ**ប៊ុនយឹម**ស្លាប់ទៅហើយ **ប៊ុនអេង, ប៊ុនហោ**ដល់ទីអាប់ចុនហើយ ព្រមស្ម័គ្រចូលមកនៅនឹងយើង បើលោកយកទៅសម្លាប់ចេញ ថ្ងៃមុខនឹងមានសត្រូវណាអាចហ៊ានចូលមកនៅនឹងយើងឡើយ។ **សុម៉ាចៀវ**យល់ឃើញត្រូវ ទើបឲ្យហៅ**ប៊ុនអេង, ប៊ុនហោ**ចូល

ទៅជិតនិយាយលួងលោមដោយពាក្យពីរោះ ហើយតាំងឲ្យធ្វើជានាយទាហានរង រួចឲ្យសេះជំនិះនិងអាវជាបំណាច់រង្វាន់ថែមទៀត។

**ប៊ុនអេង**, **ប៊ុនហោ**ធ្វើសេចក្ដីគាប់ដោយគោរព ហើយថយទៅស្រែកថា យើងទាំងពីរនាក់នេះស្ម័គ្រចូលមកនៅនឹងលោកមហាឧបរាជ ៗក៏ប្រោសមេត្តាមិនបានយកទោសដែលយើងធ្វើខុសពីដើមនោះ លោកថែមទាំងឲ្យទានរង្វាន់ហើយតាំងឲ្យមានយសស័ក្ដិទៀត អស់អ្នករាល់គ្នាហេតុអ្វីមិនគិតនឹងដកខ្លួនចូលមកនៅពឹងបុណ្យមហាឧបរាជឯណេះវិញ? នោះពួកទាហានក្នុងស្រុកបានឮដូច្នោះទើបប្រឹក្សាគ្នាថា **ប៊ុនអេង**ជាមនុស្សអារិគ្នានឹង**សុម៉ាចៀវ**មកពីដើម **សុម៉ាចៀវ**នៅមិនយកទោស ក៏គួរហើយដែលយើងរាល់គ្នាទៅសុំស្ម័គ្រនៅនឹង**សុម៉ាចៀវ**វិញចុះ។ **ជូកាត់អៀន**បានដឹងថាពួកពលទាហានគិតគ្នាដូច្នោះ លុះនឹងយកទោសក៏ឃើញថាច្រើនជាងច្រើន តាំងតែមិនទុកចិត្តទាហានទាំងពួងសោះ ទើបចេញត្រួតត្រាខ្លួនឯងគ្រប់នាទី ទាំងយប់ទាំងថ្ងៃ ហើយធ្វើអាជ្ញាកាប់សម្លាប់វាយដំច្រំធាក់កំហែងកំចោករោកយ៉ាងសហ័ស រឹតតែធ្ងន់ឡើងលើសដើម។

ឯ**ចុងហោយ**ឃើញទាហានខាង**ជូកាត់អៀន**ដែលនៅក្នុងស្រុកនោះ បែបប្រែចិត្តចេញទាំងអស់ដូច្នោះ ក៏ជម្រាប**សុម៉ាចៀវ**ថា លោកត្រូវបង្ខំកងទ័ពឲ្យចូលវាយជាប្រញាប់ចុះ មនុស្សក្នុងស្រុកប្រែប្រួលអស់ហើយ **សុម៉ាចៀវ**មានសេចក្ដីត្រេកអរណាស់ ក៏បង្ខំឲ្យទាហានចូលវាយប្រពាក់ប្រពូនព្រមគ្នាទាំងបួនទិស ឯ**ចេងសួន**ដែលរក្សាទ្វារទិសខាងជើងបានចំណាប់ ក៏បើកទ្វារទទួលកងទ័ពស្រុកវុយកុកឲ្យចូលទៅ។ **ជូកាត់អៀន**ដឹងថា ទាហានស្រុកវុយកុកចូលស្រុកបានហើយ ក៏នាំបក្ខពួករបស់ខ្លួនប្រមាណបីរយនាក់ រត់ចេញពីក្នុងស្រុកឆ្លងស្ពានប្រាំមួយទៅជួបនឹង**ហៅហ៊ុន**នាយទាហាន**សុម៉ាចៀវ**។ **ហៅហ៊ុន**ក៏កាប់នឹងដាវត្រូវ**ជូកាត់អៀន**ធ្លាក់ពីលើសេះស្លាប់ ហើយឲ្យទាហានព័ទ្ធចាប់ទាហាន**ជូកាត់អៀន**បានទាំងបីរយ។

ឯ**អងគី**នាំទាហានវាយចូលទៅតាមផ្លូវទិសឯលិច ប្រទះនឹង**អ៊ីជួន**នាយទាហានស្រុកកាំងតាំង ទើបស្រែកថា អ្នកឯងនៅខំច្បាំងដល់ណាទៅទៀតត្រូវចូលមកសុំស្ម័គ្រនៅនឹងយើងទៅវិញចុះទើបនឹងរួចជីវិត។ **អ៊ីជួន**បានឮដូច្នោះខឹងណាស់

ស្រែកថា យើងទទួលពាក្យចៅហ្វាយនាយយើងលើកទ័ពមកជួយ**ជូកាត់អៀន** យើងមកជួយក៏មិនបាន ដែលនឹងឲ្យយើងស្ម័គ្រចូលទៅនៅនឹងអ្នកឯងនោះ យើងមិនត្រូវការទេ ព្រោះយើងជាមនុស្សមានសេចក្ដីសត្យានុស័ត្យ។ ថាហើយក៏ដោះម្កូកចោលចុះទៅលើផែនដី ហើយស្រែកថា បើធ្វើសឹកស្លាប់ក្នុងរណរង្គសង្គ្រាមទើបមានល្បីឈ្មោះនាមប្រាកដទុកក្នុងផែនដី ថាហើយក៏រាំលំពែងបរសេះចូលតយុទ្ធនឹង**អងគី** បានប្រមាណសាមសិបភ្លែង លើសកម្លាំងណាស់ដួលក្រាបទាំងសេះ ទាំងមនុស្សក៏ស្លាប់ក្នុងស្នាមចម្បាំងនោះ។

ឯ**សុម៉ាចៀវ**ចូលស្រុកបានហើយ ក៏បង្គាប់ឲ្យចាប់បុត្រភរិយា**ជូកាត់អៀន** មកស្រាវជ្រាវរកកូនចៅផៅសន្ដានដែលជាសាលោហិតខាងបិតា និងនិត្យមាតាភរិយា ជាបីគោត្រមកសម្លាប់ទាំងអស់ ហើយឲ្យយកទាហានបីរយនាក់នោះមកពិចារណាសួរថា នរណានឹងស្ម័គ្រចូលនៅនឹងយើងខ្លះ យើងនឹងទុកជីវិត។ ទាហានទាំងអស់នោះឆ្លើយថា យើងខ្ញុំទាំងអស់គ្នាមិនស្ម័គ្រចូលនៅទេ នឹងសុំស្លាប់តាម**ជូកាត់អៀន**ជាចៅហ្វាយនាយ។ **សុម៉ាចៀវ**ឮដូច្នោះខឹងណាស់ ក៏ឲ្យទាហាននាំពួកនោះទៅសម្លាប់ទាំងអស់ លុះនាំទៅដល់ក្រៅស្រុកហើយ ក៏ហៅសួរម្នាក់ម្ដងទៀតបើនរណាស្ម័គ្រចូលនៅនឹងទុកជីវិត។ ពួកទាហាននោះឆ្លើយដូចគ្នាថា មិនព្រមស្ម័គ្រចូលនៅសោះ សុខចិត្តតែស្លាប់តាមចៅហ្វាយនាយ។ **សុម៉ាចៀវ**ក៏បង្គាប់ឲ្យសម្លាប់ទាំងអស់ ហើយត្រឡប់គិតអាណិតថា មនុស្សពួកនោះត្រង់សុចរិតនឹងចៅហ្វាយនាយណាស់ ទើបបង្គាប់ឲ្យតែងការសពបញ្ចុះតាមទំនៀម។ កាល**ជូកាត់អៀន**ស្លាប់ហើយ ពួកពលទាំងឡាយក៏នាំគ្នាចំណុះចុះចូលនៅនឹង**សុម៉ាចៀវ**ច្រើនណាស់។

**ប៉ោយស៊ីវ**ជម្រាប**សុម៉ាចៀវ**ថា ដែលទាហានស្រុកកាំងតាំងមកស្ម័គ្រនៅនឹងយើងនេះ ស្ម័គ្របក្ខពួកបងប្អូន និងភរិយាបុត្រនៅក្នុងស្រុកកាំងតាំងទាំងអស់នឹងទុកចិត្តឯណាបាន។ **ចុងហោយ**ឮដូច្នោះឆ្លើយថា ពាក្យបុរាណពោលទុកថា នាយទ័ពនាយកងដែលប្រុងនឹងតាំងខ្លួនធ្វើធំ ទោះបីទៅវាយស្រុកណាបាន បើមានឈ្មោះណាជាចម្រូងចម្រាសសត្រូវខ្លាំង ត្រូវតែធ្វើអន្តរាយចំពោះតែរូបអ្នកនោះ ដែលនឹង

ឲ្យសម្លាប់កូនទាហានទាំងពួងចេញនោះ ខ្ញុំបាទមិនយល់ឃើញផងទេ។ តាមត្រូវគួរតែបើកលែងឲ្យពួកអស់នេះវិលទៅស្រុកទេសវិញទើបគួរ ទើបនឹងបានឮល្បីកិត្តិសព្ទឈ្មោះជាល្អតទៅ។ **សុម៉ាចៀវ**តយល់ឃើញត្រូវ ទើបឲ្យបើកលែងពួកទាហានស្រុកកាំងតាំងទៅស្រុកវិញទាំងអស់។

**កឹងជូ**ទាហានឯកជម្រាបថា ខ្ញុំបាទសូមស្ម័គ្រនៅនឹងលោកតទៅ ដែលនឹងត្រឡប់វិលទៅស្រុកកាំងតាំងវេលានេះ **ស៊ុនលឹម**ដឹងគង់នឹងសង្ស័យត្រឡប់យកទោសខ្ញុំបាទវិញពុំខាន។ **សុម៉ាចៀវ**ឮដូច្នោះក៏មានអំណរណាស់ ទើបតាំង**កឹងជូ**ជានាហ្មឺននៅស្រុកឈីវឈុន ហើយក៏ចាត់ចែងទាហានរៀបដំណើរលើកទ័ពត្រឡប់ទៅទីក្រុងវិញ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៨២

**ចារឹកឡើងវិញដោយ ៖ ឈុល ជាង**

*(តាំងពី**កៀងអ៊ុយ**មេទ័ពស្រុកសែឈួន លើកទ័ពទៅវាយស្រុកវុយកុក **តេងងាយ**មេទ័ពខាងស្រុកវុយកុកចេញច្បាំងគ្នា **តេងងាយ**ប្រើប្រាជ្ញាមិនចេញច្បាំងនឹង**កៀងអ៊ុយ** ៗថយទ័ពហើយឲ្យសំបុត្រទៅសុំកងទ័ពស្រុកកាំងតាំងមកជួយ ព្រះចៅ**ស៊ុនលៀង**គិតសម្លាប់**ស៊ុនលីម**មហាឧបរាជ ៗលើកពលទៅព័ទ្ធព្រះរាជវាំង ហើយដកហូតរាជសម្បត្តិពី**ស៊ុនលៀង** លើក**ស៊ុនហ៊ីវ**រាជបុត្រ**ស៊ុនគួន**ទីប្រាំមួយឲ្យសោយរាជសម្បត្តិ ព្រះចៅ**ស៊ុនហ៊ីវ**សម្លាប់**ស៊ុនលីម**ជាក្បត់ **កៀងអ៊ុយ**ចេញច្បាំងនឹងស្រុកវុយកុក **តេងងាយ**ប្រើឧបាយឲ្យព្រះចៅ**ឡៅសៀន**ហៅខ្លួន**កៀងអ៊ុយ**ទៅវិញ)។*

**ខណៈកាលសុម៉ាចៀវ** និង**ជូកាត់អៀន**កំពុងច្បាំងជាប់ដៃគ្នានោះ ពួកល្បាតស៊ើបដឹងការណ៍ក៏នាំសេចក្តីនោះទៅជម្រាប**កៀងអ៊ុយ**ថា ឥឡូវ**ជូកាត់អៀន**លើកទ័ពទៅច្បាំងនឹង**សុម៉ាចៀវ** **ស៊ុនលីម**លើកកងទ័ពជំនួយទៅជួយជាច្រើន ឃើញថា **សុម៉ាចៀវ**នោះទុរន់ទុរាណាស់ទៅហើយ បានជាព្រះនាង**គួយថាយហៅ** និងព្រះចៅ**ចូម៉**ក៏លើកទ័ពចេញមកព្រះអង្គឯងជួយច្បាំងទៀត។ **កៀងអ៊ុយ**បានឮដូច្នោះមានអំណរណាស់ថា បើដូច្នោះឃើញថា យើងនឹងធ្វើការធំសម្រេចគ្រានេះជាប្រាកដហើយ។ ទើបប្រឹក្សានឹង**តាជីវ**មន្ត្រីធំថា យើងត្រូវធ្វើរឿងរ៉ាវឡើងក្រាបទូលព្រះចៅ**ឡៅសៀន**សេចក្តីថា នឹងសុំអាសាទៅវាយស្រុកវុយកុកថ្វាយ តើអ្នកនឹងយល់ឃើញប្រការម្តេច? **តាជីវ**ដកដង្ហើមធំហើយថា វេលានេះព្រះចៅ**ឡៅសៀន**ក៏លះបង់កិច្ចរាជការស្រុកទេសសោះ ព្រោះទ្រង់ជឿស្តាប់តែពាក្យ**ហ៊ុយហោ**ខន្ទី បបួលស្តេចសេពសុរារាល់ពេលមិនដែលដាច់ មួយទៀតដូចខ្លួនលោកសព្វថ្ងៃ តាំងពីខានធ្វើ

សង្គ្រាមរៀងមក ចេះតែថ្លោះការរាល់ក្តារ បើយើងខំគិតត្រួតត្រារក្សាតែស្រុកទេសរបស់យើងវិញដូចជាប្រសើរជាជាង។

**កៀងអ៊ុយ**ឮដូច្នោះខឹងណាស់ថា អ្នកចរចាដូច្នេះមិនត្រូវសោះ ឃើញថាបង់កំណើតដែលកើតមកជាបុរស នឹងរស់នៅថ្វីឲ្យធ្ងន់ទឹកដីឥតអំពើ ខ្លួនយើងនេះព្រះចៅ**ឡៅសៀន**ជប់លៀងមានព្រះតេជគុណដល់យើងជាច្រើន យើងនឹងធ្វើរាជការស្នងព្រះតេជព្រះគុណត្រាតែអស់ជីវិត ហើយក៏ធ្វើរឿងរ៉ាវចូលក្រាបទូលព្រះចៅ**ឡៅសៀន** ចាត់ចែងទាហាន ហើយចាត់ឲ្យ**បឆៀម** និង**ចៀវឈី**ជានាយទ័ពមុខ ហើយប្រឹក្សាថា យើងនឹងទៅធ្វើការគ្រានេះ នឹងវាយយកស្រុកឯណាជាមុនទើបនឹងល្អ? **បឆៀម**ថា សូមឲ្យលោកលើកទៅភ្នំសិនឆៀវាយស្រុកទៀងស៊ា កាត់យកស្បៀង**សុម៉ាចៀវ**ជាមុន ទើបស្រួតលើកទៅវាយយកស្រុកជីវឈួនឲ្យបានស្រុកឡុកអៀងក៏គង់នឹងបានដោយងាយ។ **កៀងអ៊ុយ**ថា អ្នកនិយាយនេះត្រូវណាស់ត្រូវនឹងគំនិតគិតរបស់យើង ហើយក៏លើកទាហានចេញចាកស្រុកសែឈួន តម្រង់ទៅស្រុកទៀងស៊ា។

ឯ**សុម៉ាប៉ង**ចៅហ្វាយស្រុកទៀងស៊ា ក្នុងស្រុកនោះស្បៀងអាហារមានច្រើនតែពលទាហានមានតិច លុះដឹងថា**កៀងអ៊ុយ**លើកទ័ពមកក៏នាំ**អងជិន, លីពេង**លើកទាហានចេញតាំងបន្ទាយ ទទួលនៅក្រៅស្រុកចម្ងាយផ្លូវពីររយសិន (៨ គ.ម) លុះ**កៀងអ៊ុយ**លើកទៅដល់ **សុម៉ាប៉ង**និងទាហានឯកពីរនាក់ក៏លើកទាហានចេញទៅនៅក្រៅបន្ទាយ **កៀងអ៊ុយ**ឃើញដូច្នោះក៏បរសេះចេញទៅមុខទាហានហើយស្រែកថា**សុម៉ាចៀវ**នាំទាំងម្ចាស់ទាំងបាវចេញមកច្បាំង គឺធ្វើដូច**លីឈុយ, គុយគី**ឬ? ព្រះចៅ**ឡៅសៀន**ឃើញខុសទម្លាប់ទំនៀម ទើបឲ្យយើងលើកទ័ពមកចុះអាជ្ញា**សុម៉ាចៀវ**ខ្លួនអ្នកឯងជាស្ម័គ្របក្ខពួក**សុម៉ាចៀវ** បើដឹងច្បាស់ទោសខ្លួនហើយ ក៏ឲ្យស្រួតចេញមករកយើងដោយល្អ បើនៅកាន់ខ្លួនថាត្រឹមត្រូវជាមួយនឹង**សុម៉ាចៀវ**ហើយ យើងនឹងសម្លាប់ឲ្យអស់ទាំងគោត្រ។

**សុម៉ាប៉ង**បានឮដូច្នោះក៏ខឹងខ្លាំងណាស់ ហើយស្រែកគំហកថា អាចោរឯងបង្អាចមើលងាយកន្លងចូលមកក្នុងដែនអញ ឯងចូរថយទាហានទៅឲ្យឆាប់ បើមិន

ស្លាប់ទេ ជីវិតឯងនិងទាហានទាំងពួងនឹងស្លាប់នៅទីនេះទាំងអស់ ហើយឲ្យ**អងជិន**បំផាយសេះវាំលំពែងចេញច្បាំង **បផៀម**ឃើញដូច្នោះក៏ញាក់សេះចូលច្បាំងនឹង**អងជិន**បានបីភ្លែង **បផៀម**ធ្វើជាចាញ់ញាក់សេះរត់ **អងជិន**បំផាយសេះដេញតាមនឹងទាន់ក៏យកលំពែងពួយទៅ **បផៀម**គេចហើយត្រឡប់សេះនៅអែបចាប់ខ្លួន**អងជិន**បាន **លីពេង**ឃើញដូច្នោះក៏ខឹងណាស់ បំផាយសេះមកនឹងជួយដោះ**អងជិន** **បផៀម**ឃើញ**លីពេង**បំផាយសេះមកដល់ ក៏យក**អងជិន**ទម្លាក់ផ្តេកទៅលើដី ហើយបំផាយសេះចូលទៅ យកដំបងដែកវាយ**លីពេង**ធ្លាក់ពីលើសេះស្លាប់។ **កៀងអ៊ុយ**ឃើញបានចំណាប់ក៏បរពលចូលកាប់ចាក់ពល**សុម៉ាប៉ង** ៗឃើញលើសកម្លាំងក៏លើកទ័ពចូលស្រុក ឲ្យទាហានបិទទ្វារស្រុកជិតជាប់ ហើយឲ្យឡើងរក្សាសើនបន្ទាយជាមាំមួន។ លុះវេលាព្រឹក **កៀងអ៊ុយ**ក៏បរពលចូលព័ទ្ធស្រុកជុំវិញ ហើយយកផាវចងព្រួញបាញ់ចូលទៅធ្លាក់លើដំបូលផ្ទះក្នុងស្រុកឆេះឡើងជាច្រើន ហើយឲ្យយកអុសគរពីជើងកំពែងដល់ទៅស្លឹកសីមា យកភ្លើងដុតឲ្យអណ្តាតភ្លើងក្តៅចូលទៅក្នុងស្រុក។

ទទួលពេលនោះ**តេងងាយ**លើកទ័ពមកដល់ **កៀងអ៊ុយ**ក៏នាំទាហានចេញទៅរវាំងទប់ ឯខ្លួន**កៀងអ៊ុយ**នៅលើសេះបរទៅបញ្ឈរនៅមុខទាហាន ឃើញ**តេងតុង**បុត្រ**តេងងាយ**កំឡោះតូចមុខស បបូរមាត់ក្រហម ជិះសេះកាន់លំពែងចេញមកក៏សម្គាល់ថា**តេងងាយ** ហើយបំផាយសេះតម្រង់ចូលទៅច្បាំងនឹង**តេងតុង**បានសែសិបភ្លែង នៅមិនទាន់ចាញ់ឈ្នះគ្នា **កៀងអ៊ុយ**ថា ទាហានកំឡោះតូចម្នាក់នេះមានថ្វីដៃខ្លាំងពូកែមែន យើងត្រូវគិតកលឧបាយបញ្ឆោតយកជ័យជម្នះឲ្យបាន ហើយ**កៀងអ៊ុយ**ធ្វើជាចាញ់ញាក់សេះរត់ **តេងតុង**ក៏បំផាយសេះដេញតាម**កៀងអ៊ុយ** ៗឃើញបានការក៏យឹតធ្នូបាញ់ទៅ **តេងតុង**គេចបានក៏បំផាយសេះដេញខ្ពាន់តាមចូលទៅ ហើយលើកលំពែងឡើងចាក់ **កៀងអ៊ុយ**ដណ្តើមយកលំពែងបាន ត្រឡប់សេះមកនឹងចាប់ខ្លួន**តេងតុង** ៗក៏ផាយសេះរត់ត្រឡប់ចូលកងទ័ព **កៀងអ៊ុយ**ក៏ដេញតាមទៅ។

**តេងងាយ**ឃើញដូច្នោះ ក៏បំផាយសេះរាំងាវចេញមកមុខទាហានហើយស្រែកថា អញឈ្មោះ**តេងងាយ** ឯងមិនស្រឡាញ់ជីវិតទេឬ ទើបបង្អាចដេញបុត្រអញចូលមក? **កៀងអ៊ុយ**ឮដូច្នោះដឹងថា **តេងតុង**បុត្រ**តេងងាយ**ក៏ឲ្យនឹកភ័យគិតថា វេលាថ្ងៃនេះយើងច្បាំងច្រើនណាស់ណា ឃើញថាកម្លាំងសេះកាន់តែហបហត់ខ្លាំងណាស់ បើនឹងបំពារទម្លាយទៅច្បាំងនឹង**តេងងាយ**វេលានេះ ខ្លាចក្រែងភ្លាត់ភ្លាំងបង់ការ ទើបស្រែកប្រាប់**តេងងាយ**ថា ពេលនេះល្ងាចត្រជាក់ហើយ អ្នកចាត់ចែងទាហានទុកឲ្យព្រមចុះ ព្រឹកស្អែកយើងនឹងចេញច្បាំងគ្នាឲ្យអស់ថ្វីដៃ។

**តេងងាយ**ឮដូច្នោះក៏ឆ្លើយតបថា អ្នកនិយាយនេះគាប់ប្រពៃ តែយើងត្រូវសន្យាគ្នាទុក បើនរណាគិតកលឧបាយបញ្ឆោតគ្នា គឺមិនមែនកូនប្រុស ហើយ**តេងងាយ**ក៏ថយទ័ពទៅតាំងបន្ទាយនៅឆ្នេរមាត់ទន្លេហ៊ុយស៊ុយ **កៀងអ៊ុយ**លើកកងទ័ពចេញពីស្រុកទៀងស៊ា ទៅតាំងបន្ទាយនៅក្បែរជើងភ្នំមួយអន្លើ ក្រឡេកទៅឃើញបន្ទាយ**តេងងាយ** ៗឃើញបន្ទាយ**កៀងអ៊ុយ**មាំមួនណាស់ ទើបសរសេរសំបុត្រឲ្យ**តេងតុង**ជាបុត្រចេញទៅជួយរក្សាស្រុកទៀងស៊ា ក្នុងសំបុត្រនោះសេចក្ដីថា ឲ្យ**សុម៉ាប៉ង**រក្សាស្រុកទុកឲ្យមាំមួនចុះ ឲ្យកងទ័ព**កៀងអ៊ុយ**អស់ស្បៀងអាហារហើយ បើ**សុម៉ាចៀវ**មកដល់យើងនឹងចេញព័ទ្ធខ្ទប់ប្រសព្វគ្នា មុខជា**កៀងអ៊ុយ**នឹងថ្លោះការដល់យើងជាប្រាកដ។ **តេងតុង**ក៏លាបិតាចេញទៅស្រុកទៀងស៊ា **តេងងាយ**ក៏ឲ្យបម្រើកាន់សំបុត្រទៅឲ្យដំណឹងទាំងពួងដល់**សុម៉ាចៀវ** ឲ្យលើកកងទ័ពមកជួយ។

ឯ**កៀងអ៊ុយ**លុះតាំងបន្ទាយខ្ជាប់ហើយ ក៏ឲ្យទាហានកាន់សំបុត្រទៅឲ្យ**តេងងាយ**ថា ពេលព្រឹកស្អែកយើងនឹងចេញច្បាំងគ្នា **តេងងាយ**ក៏ទទួលពាក្យ។ លុះវេលាជិតភ្លឺ **កៀងអ៊ុយ**ឲ្យទាហានទាំងពួងស៊ីបាយត្រៀមខ្លួនព្រមគ្នាហើយ ក៏លើកជាក្បួនទ័ពចេញទៅរង់ចាំច្បាំងគ្នានៅមុខបន្ទាយ ឯ**តេងងាយ**ក៏បញ្ឈប់ទាហាននៅក្នុងបន្ទាយ មិនបានចេញច្បាំងតាមសញ្ញា **កៀងអ៊ុយ**រង់ចាំទាល់តែដល់ពេលល្ងាចត្រជាក់ក៏នាំទាហានវិលចូលបន្ទាយ ហើយឲ្យទាហានកាន់សំបុត្រសញ្ញាទៅដល់**តេងងាយ**ទៀត **តេងងាយ**ឲ្យអ្នកកាន់សំបុត្រនោះបរិភោគលៀងតុផឹកសុរាហើយថា

ខ្លួនយើងនេះមិនមែនជាគិតវៀចទេ តែយើងកើតរោគបច្ចុប្បន្នឲ្យចុកសៀតខ្លាំង ទើបមិនបានចេញច្បាំងតាមសញ្ញា អ្នកឯងវិលទៅប្រាប់**កៀងអ៊ុយ**វិញចុះ វេលាព្រឹកស្អែកយើងនឹងចេញឲ្យបាន។ អ្នកកាន់សំបុត្រក៏លាត្រឡប់ទៅប្រាប់**កៀងអ៊ុយ**វិញ។ លុះវេលាព្រឹក **កៀងអ៊ុយ**ក៏លើកទាហានចេញទៅតាំងនៅក្រៅបន្ទាយ **តេងងាយ**ក៏មិនបានចេញច្បាំងតាមសញ្ញា ត្រឹមតែ**តេងងាយ**បញ្ឆោត**កៀងអ៊ុយ**ដូច្នេះដល់ប្រាំមួយគ្រា។

**បង្អៀម**និយាយនឹង**កៀងអ៊ុយ**ថា ខ្ញុំបាទឃើញ**តេងងាយ**បញ្ឆោតធ្វើកលឧបាយជាប្រាកដ ប្រាថ្នានឹងអែអង់រង់ចាំកងទ័ព**សុម៉ាចៀវ**លើកមក ទើបនឹងច្បាំងវាយយើងជាបីផ្លូវ បើដូច្នេះត្រូវយើងប្រើបម្រើនាំសំបុត្រទៅស្រុកកាំងតាំង ឲ្យ**ស៊ុនលឹម**ចេញស្ទាក់ផ្លូវច្បាំងនឹង**សុម៉ាចៀវ**។ **កៀងអ៊ុយ**បានស្តាប់ដូច្នេះក៏យល់ឃើញត្រូវទើបឆ្លើយតបថា តម្រិះរិះគិតរបស់អ្នកនោះត្រូវនឹងចិត្តរបស់យើងគ្រប់ប្រការ។ ហើយឲ្យបម្រើកាន់សំបុត្រទៅដល់**ស៊ុនលឹម**ឯស្រុកកាំងតាំង សេចក្តីថា យើងលើកកងទ័ពទៅវាយស្រុកទៀងស៊ាហើយ សុំឲ្យអ្នកជួយលើកទាហានមកវាយ**សុម៉ាចៀវ**។

ឯ**សុម៉ាចៀវ**នោះ លុះសម្រេចរាជការហើយ ទើបចាត់ចែងទាហាននឹងលើកទៅស្រុកឡុកអៀង ទទួលបម្រើ**តេងងាយ**កាន់សំបុត្រទៅដល់ **សុម៉ាចៀវ**ក៏ស្តុតចិត្តប្រញាប់លើកទ័ពទៅស្រុកទៀងស៊ា ទាហានល្បាតដឹងសេចក្តីក៏ចូលទៅជម្រាប**កៀងអ៊ុយ**ថា **សុម៉ាចៀវ**វាយស្រុកឈីវឈុនហើយ ទាហានស្រុកកាំងតាំងក៏ស្ទ្រគចូលទៅខាង**សុម៉ាចៀវ**ជាច្រើន ឥឡូវលើកកងទ័ពមកទៀបនឹងដល់ស្រុកទៀងស៊ាហើយ។ **កៀងអ៊ុយ**បានឮដូច្នោះក៏ភ័យណាស់ថា ពីដើមយើងគិតថានឹងធ្វើការឲ្យបានស្រុកឡុកអៀង ឥឡូវឃើញថាមិនសមដូចសេចក្តីគិតហើយ ត្រូវយើងថយកងទ័ពត្រឡប់ទៅស្រុកសិន ដើម្បីនឹងស្តាប់មើលកលការ ថាហើយ**កៀងអ៊ុយ**ក៏ចាត់ចែងទាហានដើរជើងលើកកន្លងទៅមុន ឯទាហានសេះឲ្យនៅការពារពីខាងក្រោយ ដោយក្រែងសត្រូវនឹងលើកដិតដោយតាម លុះលើកទៅដល់ផ្លូវតូចក្បែរជើងភ្នំសិនផៀ **កៀងអ៊ុយ**ក៏ឲ្យទាហានជញ្ជូនខស និងឆ្នួនភ្លើងត្រៀមទុកជាច្រើន។

ឯ**តេងងាយ** លុះដឹងថា**កៀងអ៊ុយ**លើកទ័ពរត់ទៅហើយ ក៏អស់សំណើច ហើយថា **កៀងអ៊ុយ**ដឹងថាកងទ័ពយើងលើកជួយថែមទៀត បានជាប្រញាប់លើករត់ទៅ យើងកុំតាមឡើយ មុខជា**កៀងអ៊ុយ**ធ្វើកលឧបាយទុកជាប្រាកដ ទទួលទាហានម្នាក់ចូលមកប្រាប់ថា ទាហានល្បាតមកឲ្យដំណឹងថា **កៀងអ៊ុយ**លើកទៅដល់ផ្លូវតូចក្បែរជើងភ្នំសិនឆៀ ឲ្យទាហានជញ្ជូនឧសនិងឆ្នួនភ្លើងត្រៀមទុកជាច្រើន បើយើងដេញតាមទៅមុខជានឹងយកភ្លើងដុតយើងជាប្រាកដ។ ទាហានទាំងពួងបានឮដូច្នោះក៏សរសើរ**តេងងាយ**ថា លោកមានប្រសាសន៍គ្រានេះដូចទេពតាតាមបញ្ជូលចិត្ត។ **តេងងាយ**ក៏នាំសេចក្ដីចូលទៅជម្រាប**សុម៉ាចៀវ**គ្រប់ប្រការ។ **សុម៉ាចៀវ**បានឮដូច្នោះក៏មានសេចក្ដីត្រេកអរ ឲ្យហៅ**តេងងាយ**ចូលទៅឲ្យបំណាច់រង្វាន់ជាច្រើន។

ឯ**ស៊ុនលឹម**នៅស្រុកកាំងតាំង លុះដឹងថា**កឹងជូ**ស្ម័គ្រចូលទៅនៅខាង**សុម៉ាចៀវ**ក៏ខឹងណាស់ ទើបប្រើទាហានទៅចាប់យកបក្ខពួក**កឹងជូ**ទៅសម្លាប់ទាំងអស់។ ខណៈនោះព្រះចៅ**ស៊ុនលៀង**ព្រះជន្មបាន១៧ឆ្នាំ ឃើញ**ស៊ុនលឹម**សម្លាប់បងប្អូន**កឹងជូ**អស់ដូច្នោះ ក៏ទ្រង់សង្វេគក្នុងព្រះទ័យណាស់។ ថ្ងៃមួយចេញយាងទៅប្រពាតសួនខាងទិសបូព៌ គិតនឹងសោយទឹកឃ្មុំ ទើបត្រាស់ប្រើ**អងប៉ុន**ទៅយកទឹកឃ្មុំមកថ្វាយ នោះ**អងប៉ុន**ទៅបើកទឹកឃ្មុំពីឃ្លាំង ដែលមានចៅភ្នាក់ងាររក្សា កាលនឹងថ្វាយទើបយកអាចម៍កណ្ដុរដាក់ចុះក្នុងទឹកឃ្មុំពីរគ្រាប់។ ព្រះចៅ**ស៊ុនលៀង**ឃើញដូច្នោះក៏ទ្រង់ខ្ញាល់ ទើបឲ្យយកចៅភ្នាក់ងារមកពិចារណាសួរថា ហេតុម្ដេចខ្លួនរក្សាទឹកឃ្មុំឲ្យអាចម៍កណ្ដុរធ្លាក់ចុះបាន? ទោសខ្លួនដល់ស្លាប់ហើយ ខ្លួនដឹងឬទេ? ចៅភ្នាក់ងារនោះទូលថា ទឹកឃ្មុំនេះ ទូលព្រះបង្គំជាខ្ញុំរក្សាបិទបាំងជាមាំមួនណាស់ កាល**អងប៉ុន**ទៅបើកយកមកនោះ ទូលព្រះបង្គំជាខ្ញុំក៏បានពិនិត្យមើលដោយហ្មត់ចត់ណាស់។ ព្រះចៅ**ស៊ុនលៀង**ត្រាស់សួរថា **អងប៉ុន**នេះធ្លាប់ទៅសុំទឹកឃ្មុំពីអ្នកឯងដែរឬទេកាលពីថ្ងៃមុនៗ? ចៅភ្នាក់ងារទូលថា កាលគ្រាមុន**អងប៉ុន**ទៅសុំទូលព្រះបង្គំជាខ្ញុំម្ដង ទូលព្រះបង្គំជាខ្ញុំប្រាប់ថា ទឹកឃ្មុំសម្រាប់ក្រយាស្ងោយនៅតិចណាស់ នឹងឲ្យមិនបានទេ។ **អងប៉ុន**ខឹងព្យាបាទទូលព្រះបង្គំជាខ្ញុំជាប់មក។ ព្រះចៅ**ស៊ុនលៀង**ត្រាស់ថា សេចក្ដីតែប៉ុណ្ណោះ យើងនឹងពិចារណារកឲ្យឃើញវៀចនិងត្រង់បាន។

ទើបត្រាស់ឲ្យហៅអស់នាហ្មឺនមុខមន្ត្រីធំតូចចូលទៅគាល់ព្រមគ្នា ទើបទ្រង់ឲ្យចាប់យកអាចម៍កណ្ដុរមកចិតមើលខាងក្នុងបន្តិចក៏ឃើញស្លួត។ ព្រះចៅ**ស៊ុនលៀង**ទើបត្រាស់ថា អាចម៍កណ្ដុរនេះបើសិនណាមនុស្សត្រាំឬធ្លាក់ពីអ្នករក្សាយូរហើយ ទឹកឃ្មុំក៏គង់ជ្រាបសើមចូលទៅក្នុងគ្រាប់ខ្លះ នេះគឺ**អងប៉ុន**ទើបក្លែងដាក់ថ្មីៗប្រាកដ។ **អងប៉ុន**បានឮព្រះក្រសែថាដូច្នោះក៏ភ័យណាស់ ក្រាបថ្វាយបង្គំចុះ ហើយក៏ទទួលសារភាពសូមថ្វាយជីវិត អស់មុខមន្ត្រីឃើញដូច្នោះ ក៏សរសើរព្រះប្រាជ្ញារបស់ព្រះចៅ**ស៊ុនលៀង**ច្រើនណាស់។ ព្រះចៅ**ស៊ុនលៀង**ក៏ស្ដេចត្រឡប់ចូលវាំង។ ថ្ងៃមួយស្ដេចចេញពីព្រះទីនាំងត្រជាក់ នោះ**ជួនគី**ជាអាពុកធំព្រះចៅ**ស៊ុនលៀង** និង**អងប៉ុន**ចូលទៅគាល់ ព្រះចៅ**ស៊ុនលៀង**ត្រាស់ថា **ស៊ុនលឹម**សព្វថ្ងៃនេះតាំងនាហ្មឺនធំតូចច្រើនណាស់ ហើយក៏ធ្វើការតែតាមអំពើចិត្ត យូរទៅមុខជានឹងក្បត់ដណ្ដើមយករាជសម្បត្តិពុំខាន យើងត្រូវរិះគិតអានសម្លាប់**ស៊ុនលឹម**ចេញទើបស្រួល ត្រាស់ហើយក៏ទ្រង់ព្រះកន្សែងសោកា។

**ជួនគី**ទូលថា ព្រះអង្គកុំវិតក្កឡើយ បើព្រះអង្គនឹងឲ្យទូលព្រះបង្គំជាខ្ញុំធ្វើប្រការម្ដេច ក៏នឹងសុំអាសាថ្វាយស្នងព្រះគុណត្រាតែអស់ជីវិត។ ព្រះចៅ**ស៊ុនលៀង**ត្រាស់ថា បើដូច្នោះអ្នកទៅហៅ**ឡៅសេង**នាយតម្រួតឲ្យមកគិតគូរគ្នាចាត់ចែងមនុស្សឲ្យបានច្រើន ហើយត្រូវបង្កប់គ្នាក្នុងទ្វារវាំង បើកាលណា**ស៊ុនលឹម**ចូលមកគាល់ក៏ឲ្យព្រួតគ្នាចាប់ខ្លួនសម្លាប់ចេញ តែថាការទាំងនេះអ្នកត្រូវបិទឲ្យជិតកុំបែកធ្លាយឡើយ។ **ស៊ុនលឹម**ជាប្អូនមាតាអ្នក បើដឹងសេចក្ដីហើយនឹងខូចការយើងទៅ។ **ជួនគី**ទូលថា ទូលព្រះបង្គំជាខ្ញុំនឹងធ្វើការគ្រានេះ ត្រូវសុំព្រះតម្រាស់ជាសំខាន់ផងដើម្បីនឹងឲ្យសេនាទាហានទាំងពួងពេញចិត្តខំធ្វើការ។ ព្រះចៅ**ស៊ុនលៀង**ក៏យល់ឃើញត្រូវទើបទ្រង់ព្រះសុភអក្សរបង្គាប់**ជួនគី** ៗថ្វាយបង្គំលាត្រឡប់ទៅផ្ទះ ហើយពណ៌នាសេចក្ដីនោះឲ្យបិតាជ្រាបគ្រប់ប្រការ។ បិតា**ជួនគី**ក៏យកសេចក្ដីនោះទៅដំណាលប្រាប់ភរិយាថា ព្រះចៅ**ស៊ុនលៀង**ឲ្យសម្លាប់**ស៊ុនលឹម**ក្នុងរវាងបីថ្ងៃនេះហើយ។ ភរិយាបានឮដូច្នោះក៏ភ័យណាស់ ប្រើមនុស្សស្និទ្ធឲ្យលបទៅប្រាប់**ស៊ុនលឹម** ៗដឹងដូច្នោះក៏ខឹងណាស់ ទើបហៅប្អូនប្រុសបួននាក់ ដែលតាំងជានាហ្មឺន

ធំឲ្យមកជួបប្រាប់អាថ៌សេចក្ដីទាំងពួង ហើយចាត់ចែងទាហានឲ្យវាយគងឃ្មោះស្គរ ទើបទាហានទៅព័ទ្ធឡោមព្រះរាជវាំងព្រះចៅ**ស៊ុនលៀង**ទុកដោយជុំវិញ។

**ឡៅសេង**នាយតម្រួតឃើញដូច្នោះ ក៏ចូលទៅទូលព្រះចៅ**ស៊ុនលៀង**ក្នុងវេលាកណ្ដាលយប់នោះ ព្រះចៅ**ស៊ុនលៀង**ទ្រង់បន្ទំស្កល់បានឮសំឡេងគងស្គរឃ្មោះអឺងកង ក៏តក់ស្ដុតព្រះទ័យពន់ប្រមាណណាស់ ទើបតើនចាកក្រឡាព្រះបន្ទំ ទទួល**ឡៅសេង**ចូលទៅទូលថា **ស៊ុនលឹម**លើកទាហានមកព័ទ្ធព្រះរាជវាំងហើយ ព្រះចៅ**ស៊ុនលៀង**បានទ្រង់ព្រះសណ្ដាប់ក៏ខឹងខ្ញាល់ណាស់ ស្ដេចចូលទៅខាងក្នុងត្រាស់ទូលព្រះមាតាថា គ្រានេះបងប្អូនរបស់អ្នកម្ដាយ ធ្វើការជាខ្មាំងប្រុងនឹងប្រទូសរ៉ាយខ្ញុំហើយ ៗក៏ទ្រង់ចាប់ព្រះសែងគ្រប៊ីនឹងចេញតស៊ូដោយសត្រូវតាមកម្លាំងទោសោ។ មាតានិងខន្ទីទាំងពួងឃើញដូច្នោះ ក៏ភ័យណាស់រត់ទៅចាប់ជាយឆ្លងព្រះអង្គទុក យំសោកាហើយទូលហាមឃាត់ជាច្រើន។

លុះវេលាព្រឹក **ស៊ុនលឹម**ទម្លាយចូលទៅក្នុងព្រះរាជវាំង បានឃើញ**ឡៅសេង**និង**ជួនសៀង**នាំទាហានរក្សានាទីត្រៀបត្រា ក៏ឲ្យទាហានចូលទៅចាប់ខ្លួនសម្លាប់ចេញអស់ ហើយឲ្យហៅអស់នាហ្មឺនមុខមន្ត្រីធំតូចទាំងពួងមកប្រាប់ថា ឥឡូវព្រះចៅ**ស៊ុនលៀង**គិតការមិនត្រូវហើយ គឺមិនយកព្រះទ័យទុកដាក់ក្នុងរាជកិច្ចទាំងពួងក្នុងស្រុកទេស មួម៉ៅទៅដោយស្ត្រី យើងត្រូវនិរទេសចេញពីរាជសម្បត្តិ តើអស់អ្នកទាំងឡាយនឹងយល់ឃើញប្រការម្ដេច?

**ហ៊្លួនអ៊ី**នាហ្មឺនធំបានឮដូច្នោះខឹងណាស់ ស្រែកជេរ**ស៊ុនលឹម**ថា អាចោរ! ព្រះចៅ**ស៊ុនលៀង**មានតម្រិះប្រាជ្ញាស្រួចស្រស់ម្ល៉េះ អាឯងចេះក្លែងយកសេចក្ដីអាក្រក់មកដាក់ ប្រាថ្នានឹងដណ្ដើមយករាជសម្បត្តិ ខ្លួនអញទោះបីនឹងស្លាប់អញក៏មិនចូលនឹងអាឯងទេ។ **ស៊ុនលឹម**ឮដូច្នោះក៏ខឹងណាស់ ហូតគ្រប៊ីស្ទុះទៅកាប់**ហ៊្លួនអ៊ី**ស្លាប់នៅទីនោះ។ អស់នាហ្មឺនមុខមន្ត្រីឃើញដូច្នោះ ក៏នាំគ្នាខ្លាចអាជ្ញា**ស៊ុនលឹម** បបួលគ្នាគំនាប់ក្រាបចុះហើយជម្រាបថា យើងខ្ញុំទាំងអស់គ្នាយល់ឃើញថា បើលោកនឹងធ្វើប្រការម្ដេច ក៏យល់ព្រមតាមអធ្យាស្រ័យលោកទាំងអស់។

**ស៊ុនលឹម**ក៏ដើរចូលទៅដល់ព្រះដំណាក់ ឃើញព្រះចៅ**ស៊ុនលៀង**គង់នៅក៏ខឹងណាស់ លើកដៃចង្អុលព្រះភក្ត្រព្រះអង្គហើយថា ព្រះអង្គនេះជាមនុស្សកម្លៅគ្មានតម្រិះប្រាជ្ញាអ្វីសោះ ប្រកាន់ខុសជាត្រូវ នេះហាក់តែយើងជាអ្នកចិត្តបុណ្យគិតដល់ព្រះតេជព្រះគុណព្រះចៅ**ស៊ុនគួន**បានជាទុកឲ្យព្រះអង្គគង់ជីវិត វេលានេះយើងនឹងឲ្យលោកទៅនៅធ្វើចៅហ្វាយស្រុកហយខេ ត្រូវលោកប្រញាប់រៀបខ្លួនចេញទៅឲ្យផុតសេចក្តីស្លាប់ចុះ។ **ស៊ុនលឹម**ក៏អូសយកត្រាសម្រាប់រាជ្យ និងគ្រឿងឥស្សរិយយសសម្រាប់ក្សត្រ ប្រគល់ឲ្យ**តេងចៀវ**រក្សាទុកក្នុងឃ្លាំង។

ព្រះចៅ**ស៊ុនលៀង**ឃើញដូច្នោះក៏នឹកតូចព្រះទ័យពេកណាស់ ទ្រង់ព្រះកន្សែងសោកាហើយស្តេចចេញចាកព្រះរាជវាំងតម្រង់ទៅស្រុកហយខេ **ស៊ុនលឹម**ទើបតែងសំបុត្រមួយច្បាប់ ឲ្យ**ស៊ុនខេ** និង**តាំងទៀវ**ទៅអញ្ជើញ**ស៊ុនហ៊ីវ** ដែលជាព្រះរាជបុត្រ**ស៊ុនគួន**ទី៦នៅស្រុកហាងលឹមឲ្យមកគ្រងរាជសម្បត្តិ។ ឯ**ស៊ុនហ៊ីវ**វេលាយប់នោះមានសុបិននិមិត្តឃើញបានជិះមករ ហោះទៅលើអាកាស ក្រឡេកមើលមកក្រោយឃើញមករកន្ទុយកំបុត ក៏ភ័យភ្ញាក់ឡើង ទទួលពេលព្រឹកនោះ **ស៊ុនខេ** និង**តាំងទៀវ**ទៅដល់ ចូលទៅគំនាប់ដឹងសេចក្តីសព្វគ្រប់ហើយ យកសំបុត្រដែល**ស៊ុនលឹម**ឲ្យទៅអញ្ជើញចូលមកទទួលរាជសម្បត្តិឲ្យទៅ**ស៊ុនហ៊ីវ** ៗបានដឹងដូច្នោះក៏គិតសង្ស័យអល់អែក នោះមានទេពារក្សដែលសម្រាប់រក្សាស្រុក ប្លែងខ្លួនជាមនុស្សចាស់ដើរត្រង់ចូលមករក**ស៊ុនហ៊ីវ**ប្រាប់ថា ការនេះឲ្យលោកប្រញាប់ទៅចុះ បើបង្អង់ឲ្យយូរការនឹងប្រែត្រឡប់ ហើយទេពារក្សនោះក៏បាត់ទៅ។ **ស៊ុនហ៊ីវ**ឃើញដូច្នោះក៏មានសេចក្តីអំណរណាស់ ចាត់ចែងទាហាន ហើយក៏ឡើងជិះរទេះចេញចាកទៅដល់តំបន់បសេក ក៏តាំងទីប្រថាប់កណ្តាលផ្លូវ។ **ស៊ុនលឹម**ដឹងក៏ចាត់រថនិងគ្រឿងហែសម្រាប់ក្សត្រ នាំអស់នាហ្មឺនមន្ត្រីធំតូចទៅទទួលស្តេច។ **ស៊ុនហ៊ីវ**ក៏មិនបានឡើងជិះរថ ដើរតម្រង់ចូលទៅក្នុងស្រុកកាំងតាំង។ **ស៊ុនលឹម**និងនាហ្មឺនទាំងពួងអញ្ជើញ**ស៊ុនហ៊ីវ**ឡើងគង់លើព្រះទែនហើយក្រាបថ្វាយបង្គំព្រមគ្នា ហើយយកត្រា និងគ្រឿងសម្រាប់ឥស្សរិយយសថ្វាយ (ព.ស ៨០៣) ព្រះចៅ**ស៊ុនហ៊ីវ**បានទទួលគ្រងរាជសម្បត្តិហើយ ទើបតាំង**ស៊ុនលឹម**ជាមហាឧបរាជ ហើយព្រះរាជទាន

បំណាច់រង្វាន់ដល់**ស៊ុនលឹម** និងអស់មន្ត្រីនាហ្មឺនទាំងពួងដែលមានសេចក្តីគាប់ប្រសើរជាច្រើន ហើយតាំងប្អូនប្រុស**ស៊ុនលឹម**បួននាក់ និងក្មួយម្នាក់ឲ្យជានាហ្មឺនធំនៅក្នុងក្រុង ដែលព្រះចៅ**ស៊ុនហ៊ីវ**ធ្វើការទាំងនោះ មិនមែននឹងទុកព្រះទ័យ**ស៊ុនលឹម**ដោយសុចរិត គ្មានគិតសង្ស័យនោះទេ រិះរវាំងរក្សាព្រះអង្គជាដរាប។

លុះដល់ខែបុស្សចុងឆ្នាំ ជាថ្ងៃប្រសូតព្រះចៅ**ស៊ុនហ៊ីវ ស៊ុនលឹម**ក៏តែងរបស់គ្រឿងតង្វាយនាំចូលទៅថ្វាយតាមទំនៀមជាច្រើន។ ព្រះចៅ**ស៊ុនហ៊ីវ**ទ្រង់រង្កៀសព្រះទ័យមិនបានសោយ ក៏បញ្ជូនត្រឡប់វិលទៅឲ្យវិញ **ស៊ុនលឹម**ឃើញដូច្នោះក៏ខឹងណាស់ យកតុដែលដាក់របស់ទាំងនោះត្រឡប់ទៅក្នុងផ្ទះ ហើយឲ្យទៅអញ្ជើញ**ទៀវប៉**ជាមន្ត្រីធំមកស៊ីលៀង។ ខណៈកាលបរិភោគអាហារសេពសុរានោះ **ស៊ុនលឹម**និយាយនឹង**ទៀវប៉**ថា កាលព្រះចៅ**ស៊ុនលៀង**ធ្វើសេចក្តីខុស យើងនិរទេសចេញទៅនោះ អស់នាហ្មឺនមុខមន្ត្រីស្ម័គ្រចិត្តឲ្យយើងឡើងធ្វើម្ចាស់ផែនដី យើងគិតដល់គុណព្រះចៅ**ស៊ុនគួន** បានជាឲ្យទៅអញ្ជើញព្រះចៅ**ស៊ុនហ៊ីវ**មកគ្រងរាជសម្បត្តិ ឥឡូវជាថ្ងៃប្រសូត យើងតាក់តែងរបស់តង្វាយទៅថ្វាយតាមទំនៀមមិនព្រមទទួល ដែលព្រះចៅ**ស៊ុនហ៊ីវ**ធ្វើដូច្នេះ គឺមិនមានគួរសមនិងដឹងយើង ចូលក្នុងមើលងាយ គ្មានសេចក្តីមេត្រីអ្វីសោះ នេះគួរឲ្យអ្នកមើលចុះ មិនយូរទេគង់នឹងឃើញគ្នា។ **ទៀវប៉**ធ្វើជាញាក់មុខ តែមិនតបថាអ្វី ហើយក៏គំនាប់លា**ស៊ុនលឹម**ចេញទៅវិញ។

លុះពេលព្រឹកឡើង **ទៀវប៉**ក៏ចូលទៅគាល់ព្រះចៅ**ស៊ុនហ៊ីវ** ហើយក្រាបទូលរឿងរ៉ាវដែល**ស៊ុនលឹម**និយាយនោះថ្វាយទ្រង់ព្រះសណ្តាប់គ្រប់ប្រការ។ ព្រះចៅ**ស៊ុនហ៊ីវ**បានទ្រង់ព្រះសណ្តាប់ក៏ទ្រង់ព្រះវិតក្កណាស់ ឯ**ស៊ុនលឹម**ចេះតែប្រុងប្រៀបរៀបគិតការឲ្យ**បេងចេង**នាំទាហានដប់ប្រាំពាន់ ព្រមដោយគ្រឿងសាស្ត្រាវុធចេញទៅតាំងនៅតំបន់បូឆៀងក្រៅស្រុកកាំងតាំង **ងុយពៀវ**និង**ស៊ីស៊ក**ដែលជាមន្ត្រីក្រុមព្រះ**សេងឆួន** ក៏ចូលទៅទូលព្រះចៅ**ស៊ុនហ៊ីវ**ថា ឥឡូវ**ស៊ុនលឹម**ត្រៀមទាហានច្រើនណាស់ ហើយមកបើកយកគ្រឿងសាស្ត្រាវុធពីក្នុងឃ្លាំងទៅទុកជាច្រើន មុខជានឹងគិតប្រទូសរ៉ាយដល់ព្រះអង្គជាប្រាកដហើយ ព្រះចៅ**ស៊ុនហ៊ីវ**ទ្រង់ព្រះសណ្តាប់ក៏ភ័យណាស់ ទើបត្រាស់ឲ្យហៅ**ទៀវប៉**ចូលទៅប្រឹក្សាការរាជការ។ **ទៀវប៉**ក្រាបទូល

ថា ទូលព្រះបង្គំជាខ្ញុំតម្រិះប្រាជ្ញាតិចណាស់ បើ**តេងហង**ជាមន្ត្រីចាស់ទុំគេធ្លាប់ធ្វើសឹកសង្គ្រាមតាំងពីរាជ្យព្រះវរបិតាមានសតិបញ្ញាច្រើន សូមព្រះអង្គឲ្យហៅ**តេងហង**ចូលមកពិគ្រោះការរាជការ ឃើញនឹងកាត់សេចក្ដីនេះធ្វើ**ស៊ុនលឹម**វិញបាន។ ព្រះចៅ**ស៊ុនហ៊ឺវ**ក៏ឲ្យហៅខ្លួន**តេងហង**ចូលទៅគាល់ ហើយត្រាស់ប្រឹក្សាការទាំងពួង។

**តេងហង**ក្រាបទូលថា រឿងនេះសុំកុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កឡើយ ងារទូលព្រះបង្គំជាខ្ញុំហើយនឹងឧបាយគិតថ្វាយ ដើម្បីធ្វើឲ្យអន្តរាយ**ស៊ុនលឹម**វិញឲ្យបាន។ ព្រះចៅ**ស៊ុនហ៊ឺវ**ត្រាស់សួរថា អ្នកនឹងធ្វើប្រការម្ដេច? **តេងហង**ទូលថា ពេលព្រឹកស្អែកជារដូវចូលឆ្នាំថ្មី ចូរព្រះអង្គរៀបតុលៀងអាហារអស់បណ្ដានាហ្មឺនមុខមន្ត្រីទាំងពួងតាមទំនៀម ហើយសូមទ្រង់ប្រើមនុស្សស្និទ្ធឲ្យទៅអញ្ជើញ**ស៊ុនលឹម**មកទទួលព្រះរាជទានអាហារក្នុងព្រះតំណាក់ ទូលព្រះបង្គំជាខ្ញុំនឹងឲ្យ**ទៀវប៉**អែបទៅចាំចាប់ខ្លួន**ស៊ុនលឹម**សម្លាប់ចេញ គង់នឹងបានដោយងាយ។ ព្រះចៅ**ស៊ុនហ៊ឺវ**យល់ឃើញត្រូវ ទើបត្រាស់ប្រើ**តេងហង, ងុយពៀវ, ស៊ីស៊ុក** នាំទាហានប្រចាំការរក្សាខាងក្រៅ ឲ្យ**ទៀវប៉**នាំទាហានទៅពួនបង្កប់ក្នុងឆាក។ លុះវេលាកណ្ដាលអាធ្រាត្រថ្ងៃនោះ បង្កើតព្យុះខ្យល់ខ្លាំងណាស់ បោកបក់ដើមឈើធំដែលដុះនៅមុខផ្ទះ**ស៊ុនលឹម**រលំរលើងចុះ ហើយបក់ផាត់ដីខ្សាច់និងដុំថ្មគ្រួសអណ្ដែតឡើង ព្រះចៅ**ស៊ុនហ៊ឺវ**ឃើញអស្ចារ្យដូច្នោះក៏មានព្រះទ័យត្រេកអរណាស់ លុះព្រឹកឡើងទើបប្រើឲ្យខន្ទីទៅអញ្ជើញ**ស៊ុនលឹម**តាមសញ្ញាដែលគិតទុកនោះ។ ខន្ទីទៅដល់ផ្ទះ**ស៊ុនលឹម**គំនាប់ហើយជម្រាបថា មានព្រះតម្រាស់ព្រះចៅ**ស៊ុនហ៊ឺវ** ត្រាស់ប្រើខ្ញុំបាទឲ្យមកអញ្ជើញលោកទៅពិសាលៀង។ **ស៊ុនលឹម**បានឮដូច្នោះក៏ក្រោកឡើងរឹងទៅតែងខ្លួនក៏ត្រឡប់ឲ្យវិលមុខដួលផ្កាប់មុខនៅទីនោះ ក៏គិតប្លែកក្នុងចិត្តណាស់ ទទួលខន្ទីមកដល់ទៀត ម្នាក់ចូលទៅជម្រាប**ស៊ុនលឹម**ថា អស់នាហ្មឺនមុខមន្ត្រីទៅជួបជុំអស់ហើយ ព្រះចៅ**ស៊ុនហ៊ឺវ**នៅរង់ចាំលោក សូមឲ្យលោកប្រញាប់អញ្ជើញ។ **ស៊ុនលឹម**បានស្ដាប់ដូច្នោះ ក៏តែងសម្លៀកបំពាក់ពេញយសជាមហាឧបរាជ នោះមានមនុស្សស្និទ្ធក្នុងផ្ទះហាមឃាត់ថា ដ្បិតពីយប់កើតអស្ចារ្យវិបរិតប្លែកណាស់ ហើយអម្បាញ់មិញនេះ លោកក្រោកឡើងកើតវិលមុខដួលចុះ ខ្ញុំបាទយល់ឃើញសង្ស័យណាស់

ដែលមានព្រះតម្រាស់ឲ្យហៅលោកនោះ សូមឲ្យតម្រិះឲ្យហ្មត់ចត់សិន។ **ស៊ុនលឹម**ថា ខ្លួនយើងជាមហាឧបរាជ មានបងប្អូនធ្វើជានាហ្មឺនធំដល់ប្រាំនាក់ នរណានឹងអាចប៉ានគិតប្រទូសរ៉ាយដល់យើង ទោះបីនឹងមានសត្រូវប្រទូសរ៉ាយយើង ពិតជាយើងក៏មិនខ្លាចនឹងយកតែភ្លើងសញ្ញាដុតឡើង ទាហានយើងនឹងលើកទៅជួយ ហើយ **ស៊ុនលឹម**ក៏ឡើងរថតម្រង់ចូលទៅក្នុងវាំង។ ព្រះចៅ**ស៊ុនហ៊ីវ**ក៏ចេញទៅទទួលដល់ទ្វារព្រះដំណាក់ ចាប់ដឹកដៃ**ស៊ុនលឹម**ចូលទៅឲ្យអង្គុយលើកៅអីសេពសុរា។ ខណៈកាល**ស៊ុនលឹម**អង្គុយសេពសុរានោះ **ងុយពៀន** និង**ស៊ីស៊ុក**ក៏អុជភ្លើងសញ្ញាឡើង ហើយចាប់ស្ម័គ្របក្សពួក**ស៊ុនលឹម**សម្លាប់ចេញខ្លះទុកខ្លះ **ស៊ុនលឹម**បានឮទ្រហឹងអឺងកងខាងក្រៅក៏ភ័យណាស់ ស្ទុះក្រោកចេញទៅ ព្រះចៅ**ស៊ុនហ៊ីវ**ចាប់ដៃឃាត់ទុក ហើយថា មហាឧបរាជកុំភ័យខ្លាច អញ្ជើញសេពសុរាឲ្យសប្បាយចុះ ព្រោះអស់នាហ្មឺនមុខមន្ត្រី និងទាហានដែលសេពសុរានៅខាងក្រៅស្រវឹងហើយប្រហែលជាទាស់វិវាទគ្នាតាមទឹកន្លែងវាទេដឹង? ខណៈនោះ**ទៀវប៉**ក៏កាន់គ្រប៊ីនាំទាហានប្រមាណ ៣០នាក់ ដើរចេញមកពីក្នុងឆាកហើយស្រែកថា ព្រះតម្រាស់ឲ្យចាប់អាក្បត់ឲ្យខាងតែបាន។ **ស៊ុនលឹម**បានឮដូច្នោះក៏ភ័យស្លុតព្រលឹងគិតនឹងស្ទុះរត់ ទាហានទាំងពួងក៏ស្ទុះស្រចេញមកព័ទ្ធរុំជុំជិត ចូលចាប់ខ្លួន**ស៊ុនលឹម**បាន។ **ស៊ុនលឹម**អស់សេចក្តីគិតហើយ ទើបក្រាបទូលព្រះចៅ**ស៊ុនហ៊ីវ**ថា ព្រះអង្គអើយ សូមទ្រង់ប្រោសឲ្យទានជីវិតទូលព្រះបង្គំជាខ្ញុំចុះ ទូលព្រះបង្គំជាខ្ញុំលែងប្រព្រឹត្តអាក្រក់ទៀតហើយ នឹងសូមថ្វាយបង្គំលាទៅធ្វើស្រែរកទទួលព្រះរាជទាននៅស្រុកកំណើតវិញ។ ព្រះចៅ**ស៊ុនហ៊ីវ**ស្រែកគំហកថា កាល**តេងអ៊ិន** និង**លីគី, អងទុន**ក៏អង្វរលន់តួសុំជីវិត និងលាទៅនៅស្រុកកំណើត ហេតុម្តេចបានជាខ្លួនសម្លាប់ចេញសោត? ត្រាស់ហើយក៏បង្គាប់**ទៀវប៉**ឲ្យនាំខ្លួន**ស៊ុនលឹម**ទៅប្រហារជីវិត។ **ទៀវប៉**ក៏ស្រែកប្រកាសប្រាប់ទាហានទាំងពួងថា **ស៊ុនលឹម**គិតក្បត់ផែនដី ឥឡូវមានព្រះតម្រាស់ឲ្យសម្លាប់ចេញហើយ បើអស់អ្នកទាំងឡាយមិនទាន់ដឹងការណ៍ ក៏កុំភ័យខ្លាចអ្វីឡើយ។ ខណៈនោះ **តេងហាង, ងុយពៀវ** និង**ស៊ីស៊ុក**ក៏ចាប់យកបងប្អូនស្ម័គ្របក្សពួក**ស៊ុនលឹម**ប្រមាណមួយរយប្លាយនាំចូលមកថ្វាយ ព្រះចៅ**ស៊ុនហ៊ីវ**ក៏ឲ្យនាំទៅសម្លាប់ចេញនៅទីផ្លូវ

បំបែក ហើយឲ្យពិចារណាយកបងប្អូន**ស៊ុនលឹម**ទៅសម្លាប់ទាំងគោត្រ សូម្បីទាំងសព**ស៊ុនជុន**ជាបិតា**ស៊ុនលឹម**ដែលបញ្ចុះក្នុងម៉ុង ក៏ទ្រង់ឲ្យគាស់រំលើងឡើងជាផ្កាលជាអស្ចារ្យ តែបណ្ដានាហ្មឺនមន្ត្រីដែលមានចិត្តសុចរិតស័ត្យត្រង់ទាំងពួង ដែល**ស៊ុនលឹម**ឲ្យសម្លាប់ចេញពីមុនមកនោះ ក៏ទ្រង់ឲ្យតែងការសពកប់បញ្ចុះតាមប្រវេណីតាមទីបណ្ដាស័ក្តិ ឯនាហ្មឺនដែល**ស៊ុនលឹម**ឲ្យឃុំទុកនោះក៏ឲ្យដោះចេញ ហើយតាំងឲ្យគង់ទីតំណែងតាមដើមទាំងអស់ ទើបព្រះចៅ**ស៊ុនហ៊ីវ**ឲ្យតែងព្រះរាជសារថ្វាយដំណឹងទាំងពួង ឲ្យ**ឈីហ៊ូ**ជារាជទូតនាំទៅថ្វាយព្រះចៅ**ឡៅសៀន**ឯស្រុកសែឈួន។

ព្រះចៅ**ឡៅសៀន** បានទទួលរាជសារក៏មានព្រះទ័យត្រេកអរណាស់ ទើបចាត់ចែងរាជបណ្ណាការ ឲ្យ**ឈីហ៊ូ**នាំទៅថ្វាយព្រះចៅ**ស៊ុនហ៊ីវ** ៗត្រាស់សួរ**ឈីហ៊ូ**ថា ក្នុងស្រុកសែឈួននោះ តើអ្នកឯងឃើញព្រះចៅ**ឡៅសៀន**គិតកិច្ចរាជការអ្វីខ្លះ? អាណាប្រជានុរាស្ត្របានសេចក្ដីសុខទេឬ? **ឈីហ៊ូ**ទូលថា ឃើញព្រះចៅ**ឡៅសៀន**រាប់អានជឿស្ដាប់ពាក្យ**ហ៊ុយហោ**ខន្ទី បើនរណាមានទ្រព្យសម្បត្តិច្រើនយកទៅសូកឲ្យ**ហ៊ុយហោ**ខន្ទីហើយ ក៏បានតាំងជាទីនាហ្មឺនធំទាំងអស់។ ទូលព្រះបង្គំជាខ្ញុំឃើញរាជការផែនដីស្រុកសែឈួនវឹកវរពេកណាស់ អស់នាហ្មឺនធំតូចនិងបណ្ដារាស្ត្រទាំងពួងក៏មិនមានសប្បាយ មានតែសេចក្ដីក្ដៅក្រហាយគ្រប់គ្នា។

ព្រះចៅ**ស៊ុនហ៊ីវ**ឮដូច្នោះក៏ដកដង្ហើមធំហើយថា បើ**ខុងបេង**នៅមានជីវិតកាលណា ការផែនដីស្រុកសែឈួននឹងមិនប្រែប្រួលដល់ម្ល៉េះឡើយ។ ហើយឲ្យតែងព្រះរាជសារជាសេចក្ដីថា ឥឡូវនេះ**សុម៉ាចៀវ**គិតការធំណាស់ នឹងដណ្ដើមយករាជសម្បត្តិស្រុកឡុកអៀង បើ**សុម៉ាចៀវ**សម្រេចការតាមប្រាថ្នាហើយ មុខជានឹងលើកកងទ័ពទៅវាយយកស្រុកកាំងតាំងនិងស្រុកសែឈួនជាប្រាកដ សុំឲ្យព្រះចៅ**ឡៅសៀន**រិះគិតប្រុងប្រយ័ត្នស្រុកទេសត្រៀមរេហ៍ពល បង្ការឲ្យព្រមកុំប្រហែសធ្វេសឡើយ លុះតែងហើយក៏ឲ្យរាជបម្រើនាំទៅថ្វាយព្រះចៅ**ឡៅសៀន**ឯស្រុកសែឈួន។

ខណៈនោះ **កៀងអ៊ុយ**បានដឹងក្នុងរាជសារព្រះចៅ**ស៊ុនហ៊ីវ**ដូច្នោះ ក៏ត្រូវចិត្តណាស់ចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន** នឹងសុំអាសាលើកទ័ពទៅវាយស្រុកឡុកអៀង កាត់សឹក**សុម៉ាចៀវ**ជាមុន ព្រះចៅ**ឡៅសៀន**ក៏យល់តាម **កៀងអ៊ុយ**ក៏ចាត់

ចែងកេណ្ឌកងទ័ពឲ្យ**លៀវហ្វ៊ូ** និង**ទៀវអេក**ជានាយកងទ័ពមុខ ឲ្យ**អងហាំ** និង**ចៀវពិន**ជាប៉ែកស្តាំ ឲ្យ**ចៀវឈី** និង**បឆៀម**ជាប៉ែកឆ្វេង ឲ្យ**អចេក** និង**ហ៊្វូស៊ិប**ជាកងក្រោយ ខ្លួន**កៀងអ៊ុយ**និង**ហែហ៊្វូប៉ា**នាំទាហានម្ភៃម៉ឺនជាទ័ពហ្លួង។ លុះថ្ងៃល្អបានឫក្ស ក៏ចូលក្រាបបង្គំលាព្រះចៅ**ឡៅសៀន**លើកទ័ពតម្រង់ទៅស្រុកហាន់តុង។ **កៀងអ៊ុយ**ក៏ប្រឹក្សានឹង**ហែហ៊្វូប៉ា**ថា តំបន់ភ្នំគីសាន់នោះឃើញជាទីសំខាន់រាបទាប**ខុងបេង**លើកទ័ពទៅច្បាំងដល់ប្រាំមួយគ្រាហើយ ក៏ទៅតាំងតែត្រង់តំបន់នោះ ហេតុនេះត្រូវតែយើងលើកទៅតាំងនៅទីនោះជាមុន ទើបនឹងគិតការតទៅ។ **ហែហ៊្វូប៉ា**យល់ឃើញត្រូវ ក៏លើកទ័ពទៅដល់ភ្នំគីសាន់ ទើបតាំងបន្ទាយនៅក្បែរទួលភ្នំមួយអន្លើ ធ្វើជាបន្ទាយបីប៉ែកប្របរៀងគ្នា។

ឯ**តេងងាយ**ក៏តាំងបន្ទាយនៅតំបន់ទីភ្នំគីសាន់ លុះមានបម្រើសេះទៅប្រាប់ថា **កៀងអ៊ុយ**លើកទ័ពមកជាច្រើន **តេងងាយ**ក៏ឡើងឈរមើលលើកំពូលភ្នំឃើញ**កៀងអ៊ុយ**តាំងបន្ទាយនៅក្បែរទួលមួយអន្លើ ក៏មានអំណរណាស់ថា យើងបានគិតទុកថា **កៀងអ៊ុយ**នឹងលើកមកសមនឹងសេចក្តីគិតមែន ទើបកេណ្ឌពលឲ្យជីកទួលនោះជាឧម្មង្គចូលទៅខាងក្រោយបន្ទាយ**កៀងអ៊ុយ** លុះជីកទៅជិតទៀបនឹងដល់ផ្ទះក្រោយបន្ទាយ **អងហាំ, ចៀវពិន**។ **តេងងាយ**ក៏ឲ្យ**តេងតុង**ជាបុត្រ និង**ស៊ូគី**នាំទាហានមួយម៉ឺនទៅច្បាំងពីមុខបន្ទាយ។ លុះដល់ពេលយាមបីយប់ ឲ្យ**តេងលុន**នាំទាហានប្រាំរយចូលទៅក្នុងឧម្មង្គ ឲ្យបង្ខំជីកទម្លុះចេញដណ្តើមយកបន្ទាយ។ **តេងលុន**ក៏នាំទាហានចុះទៅ។

ឯ**អងហាំ** និង**ចៀវពិន**នៅក្នុងបន្ទាយ ឃើញ**តេងតុង**និង**ស៊ូគី**លើកទាហានចេញមុខបន្ទាយក៏រវាំងខ្លួនណាស់ ឲ្យទាហានទាំងអស់ពាក់ក្រើសកាន់អាវុធដែរ។ លុះដល់យាមបី **តេងលុន**នាំទាហានជីកទម្លុះឧម្មង្គចូលទៅក្នុងបន្ទាយ ដេញចាក់កាប់គ្នាជ្រួលច្របល់ច្រាលឡើង **អងហាំ**និង**ចៀវពិន**ឃើញដូច្នោះក៏ភ័យភ្ញាក់ ឲ្យទាហានកាន់អាវុធឡើងសេះ **តេងតុង** និង**ស៊ូគី**ក៏លើកទាហានសង្គ្រុញចូលទៅ**អងហាំ** និង**ចៀវពិន**ឃើញលើសកម្លាំងក៏នាំទាហានរត់ចេញពីបន្ទាយ **កៀងអ៊ុយ**នៅបន្ទាយកណ្តាល បានឮសំឡេងក្នុងបន្ទាយស្តាំអឹងកងឡើង ក៏ជិះសេះឈរមើល

ហើយបង្គាប់ទាហានថា ឱ្យរក្សាបន្ទាយឱ្យមាំមួន បើទាហាន**តេងងាយ**លើកមកច្បាំង ក៏ឱ្យយកធ្នូបាញ់ទាល់ទុកកុំចេញត។

ឯ**តេងតុង**និង**ស៊ូគី** លុះបានបន្ទាយស្តាំហើយ ក៏លើកទ័ពទៅកាច់យកបន្ទាយ**កៀងអ៊ុយ**ទៀតជាច្រើនគ្រា **កៀងអ៊ុយ**ក៏ឱ្យបាញ់នឹងធ្នូចម្រុះចេញទៅ ត្រូវទាហាន**តេងតុង**ស្លាប់វិនាសច្រើនណាស់។ លុះវេលាព្រឹកឡើង **តេងតុង**ក៏នាំទាហានទៅបន្ទាយវិញ **តេងងាយ**ថា **កៀងអ៊ុយ**នោះមានសតិបញ្ញាស្រួចចំណាប់ចំណានក្នុងការសង្គ្រាមណាស់ ទើបរក្សាបន្ទាយទុកបាន បើគំនិតស្រាលលើកទៅជួយបន្ទាយស្តាំហើយ គង់នឹងថ្លោះការរបស់យើង។

ឯ**អងហាំ** និង**ចៀវពិន** លុះព្រឹកឡើងក៏នាំទាហានទៅរក**កៀងអ៊ុយ**ក្នុងបន្ទាយគំនាប់ក្រាបចុះហើយក៏អង្វរសុំទោស **កៀងអ៊ុយ**ថា អ្នកកុំវិតក្កឡើយ ដែលថ្លោះការទាំងនេះ ព្រោះយើងគិតទុកខុសឯងទេ ហើយក៏ចាត់ចែងទាហានឱ្យ**អងហាំ** និង**ចៀវពិន**លើកទៅតាំងនៅបន្ទាយចាស់វិញ។ **អងហាំ**ប្រើពលឱ្យយកដីលុបរណ្ដៅឧម្មង្គជិតទៅវិញ ហើយក៏លឿនចេញទៅតាំងនៅកន្សៃភ្នំ។

ឯ**កៀងអ៊ុយ**ឱ្យបម្រើកាន់សំបុត្រទៅឱ្យ**តេងងាយ** វេលាព្រឹកស្អែកឱ្យលើកទាហានចេញទៅច្បាំងគ្នា **តេងងាយ**ក៏ទទួលពាក្យ។ លុះវេលាព្រឹកឡើង ទាហានទាំងសងខាង ក៏លើកចេញតាំងក្បួននៅមុខភ្នំគីសាន់ព្រមគ្នា។ **កៀងអ៊ុយ**ក៏ចាត់ទាហានចេញជាប្រាំបីកង ទាំងប្រាំបីទិស មានទ្វារចេញចូលដល់គ្នាទៅវិញទៅមកគ្រប់កង កងមួយឱ្យទាហានឈរជារូបមករ កងមួយជារូបខ្លា កងមួយជារូបស្តេចនាគ កងមួយជារូបបក្សី កងមួយឱ្យទាហានសេះលើកទង់ជ័យតាំងជាក្បួនរូបខែពេញវង់ កងមួយជាខ្យល់ កងមួយជាដី ឯខ្លួន**កៀងអ៊ុយ**ឯង ចេញទៅបញ្ឈរសេះកាន់ទង់សម្គាល់នៅមុខទាហាន ឃើញ**តេងងាយ**បញ្ឈរសេះនៅមុខទាហាន ក៏ស្រែកសួរថា យើងតាំងក្បួនសឹកប៉ាក់គួទិន នេះអ្នកដឹងឬទេ ថាយើងនឹងធ្វើជាប្រការម្តេច?

**តេងងាយ**អស់សំណើចហើយថា អ្នកសម្គាល់ថាក្បួនសឹកនេះដឹងស្គាល់តែអ្នកម្នាក់ឯងទេឬ? យើងក៏ចូលចិត្តថា នឹងធ្វើឱ្យអ្នកមើលវិញដែរ **តេងងាយ**ក៏បោក

ទង់ចាត់ទាហានឲ្យញែកចេញ តាំងក្បួនដូច**កៀងអ៊ុយ**ឃើញញែកចេញជាមួយកង ប្រាំបីកង ជាហុកសិបបួនកង មានទ្វារហុកសិបបួន **តេងងាយ**ក៏ស្រែកសួរ **កៀងអ៊ុយ**ថា យើងញែកចេញប្រហែលដូច្នោះ អ្នកឃើញខុសនិងត្រូវប្រការម្តេច? **កៀងអ៊ុយ**ថា អ្នកធ្វើនេះក៏ត្រូវតាមតម្រាហើយ បើអ្នកចំណានពិត ក៏ឲ្យលើកទាហានចូលមកក្នុងក្បួនសឹកយើងឲ្យបានចុះ ឯ**តេងងាយ**ថា អ្នកកុំវិតក្កឡើយ យើងនឹងលើកចូលទៅឲ្យអ្នកមើល **តេងងាយ**ក៏ជិះសេះកាន់ទង់នាំទាហានចូលទៅក្នុងកងទ័ព**កៀងអ៊ុយ** ដើរពិតព័ទ្ធតាមរបៀបក្បួនសឹកក៏មិនមានភ្លាត់ភ្លាំង។

**កៀងអ៊ុយ**បំផាយសេះចូលទៅក្នុងកណ្តាលទ័ព បោកទង់ឲ្យទាហានប្រាំបីកងរួបរួមគ្នាចូលជារូបស្តេចនាគ **តេងងាយ**លោតទៅនៅកណ្តាលខ្លួន **កៀងអ៊ុយ**ឲ្យទាហានដែលជាកន្ទុយវង់ព័ទ្ធចូលទៅ ទាហាននៅខាងក្រោយក៏វាយឃ្មោះគោះគងទូងភេរីអឺងកងឡើងហើយស្រែកថា ឲ្យ**តេងងាយ**បោះអាវុធចេញ ហើយចូលមករកយើងឲ្យល្អ បើស្ទៀមនៅយើងនឹងចាប់ខ្លួនឲ្យបានហើយសម្លាប់ចេញ **តេងងាយ** និងទាហាននៅក្នុងទីឡោម ឃើញក្បួនសឹក**កៀងអ៊ុយ**ត្រឡប់ក្លាយមិនដឹងដែលនឹងកែខៃប្រការម្តេច ងើយមុខមើលទៅលើអាកាសហើយដកដង្ហើមធំថា ដែលយើងចាញ់កលចូលមកនៅក្នុងចំណោមសត្រូវគ្រានេះ ក៏ព្រោះមើលងាយទ្រនង់អង់អាចក្នុងសង្គ្រាម ទទួលក្រឡេកទៅខាងទិសឯលិច ឃើញ**សុម៉ាប៉ង**នាំទាហានពុំទម្លាយចូលមកជួយ **តេងងាយ**ក៏ត្រេកអរណាស់ នាំទាហានចេញចាកទីឡោមបាន នាំ **សុម៉ាប៉ង** និងទាហានទៅតាំងបន្ទាយនៅក្បែរឆ្នេរទន្លេអ៊ុយស៊ុយ **កៀងអ៊ុយ**ក៏លើកទាហានចូលតាំងនៅក្នុងបន្ទាយ**តេងងាយ**ទាំងប្រាំបួនបន្ទាយ។

ឯ**តេងងាយ**ក៏សួរ**សុម៉ាប៉ង**ថា ហេតុម្តេចទើបអ្នកចូលចិត្តក្នុងក្បួនសឹកយ៉ាងនោះ ហើយចៅពុះទម្លាយចូលទៅជួយយើងក្នុងទីឡោមបាន? **សុម៉ាប៉ង**ឆ្លើយថា កាលខ្ញុំបាទនៅពីក្មេងបានទៅរៀនវិជ្ជានៅឯស្រុកតេងជីវ ស្រុកឡុកអៀង **ឈើជីវ** និង**ប៉េងចៀ**។ **កងងួន**ដែលជាភឿនសំឡាញ់របស់**ខុងបេង**ប្រាប់កលសឹកយ៉ាងនេះឲ្យខ្ញុំបាទដឹង ក្បួនសឹកដែល**កៀងអ៊ុយ**ក្លាយចេញនោះឈ្មោះទៀងជូទិន ប្រែថា ក្បួនសឹកពស់លូន បើនរណាមិនដឹងលោតចូលទៅក៏នឹងថ្លោះការ។ ខ្ញុំបាទចូលចិត្តយល់

ឃើញថាក្បួនសឹកនោះ តាំងក្បាលខាងទិសឯលិច ខ្ញុំបាទទើបវាយត្រង់ចូលទៅកាត់ក្បាលចេញមុន។ **តេងងាយ**បានស្តាប់ដូច្នោះ មានអំណរណាស់ថា ខ្ញុំឯងក៏បានរៀនក្បួនសឹកមកជាច្រើន តែក្បួនសឹកដែលក្លាយចេញនោះ នៅមិនទាន់ចូលចិត្ត ឥឡូវយើងដឹងដល់គំនិត**កៀងអ៊ុយ** ហើយវេលាព្រឹកស្អែកយើងនឹងលើកទៅច្បាំងដណ្តើមយកបន្ទាយឲ្យបាន ទើបនឹងអស់កំហឹង។

**សុម៉ាប៉ង**ថា ខ្ញុំបាទបានរៀនវិជ្ជាដឹងក្បួនសឹកមែន តែមិនដឹងដល់គំនិត**កៀងអ៊ុយ** ដែលនឹងលើកទៅច្បាំងនោះ ខ្លាចក្រែងថ្លោះការសូមលោកគិតមើលឲ្យគួរសិន។ **តេងងាយ**ថា អ្នកកុំព្រួយគិតឡើយ ឲ្យអ្នកលើកទាហានចេញទៅតាំងក្បួនសឹកនឹង**កៀងអ៊ុយ** យើងនឹងលើកទាហានទៅខាងក្រោយភ្នំ បើ**កៀងអ៊ុយ**លើកចេញពីបន្ទាយហើយ យើងនឹងលើកចូលដណ្តើមយកបន្ទាយឲ្យបាន ហើយ**តេងងាយ**ក៏ឲ្យ**តេងលុន**ជាកងមុខលើកទៅតាំងបង្កប់នៅក្រោយភ្នំគីសាន់។ **សុម៉ាប៉ង**ក៏ឲ្យទាហានកាន់សំបុត្រទៅឲ្យ**កៀងអ៊ុយ**ថា ពេលព្រឹកស្អែកនេះ ឲ្យទាហានចេញទៅតាំងក្បួនសឹកតគ្នាទៀត។ **កៀងអ៊ុយ**ក៏សរសេរការខ្នងត្រឡប់ឲ្យទៅវិញថា ឲ្យលើកមកចុះ ហើយ**កៀងអ៊ុយ**និយាយនឹងទាហានទាំងពួងថា យើងធ្លាប់ធ្វើសឹកមកនឹង**ខុងបេង** ចំណានក្នុងក្បួនសឹកជាច្រើន កាលពីម្សិលមិញយើងក៏បែងក្បួនសឹកដល់៣៧៥ក្បួន **តេងងាយ**ក៏ឃើញថ្វីដៃយើងហើយ ដែលឲ្យសំបុត្រមកថានឹងចេញតាំងក្បួនសឹកនឹងយើងទៀតនេះ បីដូចយកស្មៅមកតស៊ូនឹងមុខដាវដ៏មុតថ្លា យើងថាពាក្យនេះជាកលឧបាយបញ្ឆោតយើងទេ អ្នកទាំងពួងនឹងឃើញខ្លះឬទេ?

**លៀវហ៊្វ**ឆ្លើយថា ឯកលឧបាយ**តេងងាយ**នោះ ឃើញនឹងបញ្ឆោតយើងឲ្យចេញតាំងក្បួនសឹក ហើយនឹងបង្កប់ទាហានចាំដណ្តើមយកបន្ទាយយើងជាក្រោយប្រាកដ **កៀងអ៊ុយ**ក៏យល់ឃើញត្រូវ ទើបឆ្លើយថា អ្នកនិយាយនេះត្រូវចិត្តយើងណាស់ ដូចគំនិតយើងគិតទុក ហើយក៏ឲ្យ**លៀវហ៊្វ**និង**ទៀវអេក**នាំទាហានមួយម៉ឺនទៅនៅក្រោយភ្នំគីសាន់។ លុះវេលាព្រឹកឡើង**សុម៉ាប៉ង**លើកពលទៅតាំងនៅភ្នំគីសាន់ **កៀងអ៊ុយ**ក៏លើកទាហានចេញពីបន្ទាយទៅតាំងទទឹងគ្នា **កៀងអ៊ុយ**បរសេះចេញទៅមុខទាហានស្រែកហៅ**សុម៉ាប៉ង**ថា ឲ្យតាំងក្បួនសឹកឲ្យយើងមើលម្តងចុះ។

**សុម៉ាប៉ង**ក៏ញែកទាហានចេញតាំងជាក្បួនសឹកបាក់គួទិន **កៀងអ៊ុយ**អស់សំណើចហើយថា ក្បួនសឹកនេះយើងតាំងឲ្យមើលយ៉ាងពីម្សិលមិញនោះហើយ យើងគិតថាអ្នកនឹងមានវិជ្ជាប្លែកទើបឧស្សាហ៍ចេញមក។ **សុម៉ាប៉ង**ថា ទោះខ្លួនអ្នកដឹងក៏មិនជាអ្វី យើងក៏បានរៀនវិជ្ជាដូចគ្នា **កៀងអ៊ុយ**ថា ក្បួននេះអ្នកក្លាយទៅយ៉ាងម្ដេចបានខ្លះ? **សុម៉ាប៉ង**អស់សំណើចហើយថា ក្បួនសឹកយ៉ាងនេះយើងក្លាយបានដល់៨១យ៉ាង **សុម៉ាប៉ង**ក៏បោកទង់ឲ្យទាហានប្រែសឹកនោះចេញជាក្បួនផ្សេងៗ ហើយស្រែកថា អ្នកឃើញសេចក្ដីចេះដឹងយើងឬទេ? **កៀងអ៊ុយ**អស់សំណើចហើយថា ក្បួនសឹកយ៉ាងនេះ យើងក្លាយចេញបានដល់៣៦៥យ៉ាង ហើយយើងចំណានក្នុងឫទ្ធិជាច្រើនយ៉ាងណាស់។ **សុម៉ាប៉ង**ថា អ្នកអួតខ្លួនលើសណាស់ បើចេះមែនចូរសម្ដែងចេញឲ្យយើងមើល។ **កៀងអ៊ុយ**ថា បើអ្នកនឹងចង់រៀនវិជ្ជារបស់យើងជាយ៉ាងម្ដេចត្រូវឲ្យហៅ**តេងងាយ**ចេញមកចុះ យើងនឹងធ្វើឲ្យមើល។ **សុម៉ាប៉ង**ថា មេទ័ពធំណាស់ **តេងងាយ**នោះមិនសមគួរច្បាំងគ្នានឹងអ្នកទេ បានជាមិនចេញមក **កៀងអ៊ុយ**អស់សំណើចហើយថា ដែល**តេងងាយ**ធ្វើកលឧបាយឲ្យអ្នកមកបញ្ឆោតប្រាថ្នានឹងយកបន្ទាយដើមនោះវិញ យើងក៏ដឹងអស់ហើយ។ **សុម៉ាប៉ង**ដឹងថា**កៀងអ៊ុយ**ដឹងដល់ក៏ខឹងណាស់ បរពលឲ្យចូលច្បាំង**កៀងអ៊ុយ** ៗក៏បោកទង់ឲ្យទាហានចេញច្បាំងជាសន្ធឹកសន្ធាប់ កាប់សម្លាប់ទាហាន**សុម៉ាប៉ង**ស្លាប់ជាច្រើនណាស់។ **សុម៉ាប៉ង**ឃើញលើសកម្លាំងក៏នាំទាហានបែករត់ទៅ។

ឯ**តេងងាយ**និង**តេងលុន**លើកទាហានពីបន្ទាយទៅខាងក្រោយភ្នំ នឹងទៅដណ្ដើមយកបន្ទាយ**កៀងអ៊ុយ** ទទួលងាកចេញទៅខាងក្រោយភ្នំជិតនឹងដល់បន្ទាយឃើញទាហានមួយកងស្កាត់ចេញមក **លៀវហ្វ៊ូ**ក៏បំផាយសេះចេញច្បាំងនឹង**តេងលុន** **លៀវហ្វ៊ូ**យកដាវកាប់ត្រូវ**តេងលុន**ធ្លាក់ពីលើសេះស្លាប់ **តេងងាយ**ឃើញដូច្នោះភ័យណាស់ បំផាយសេះនាំទាហានរត់ **ទៀវអេក**ក៏លើកទាហានដេញតាមទៅ ហើយលើកធ្នូបាញ់ចម្រុះពីក្រោយ ត្រូវទាហាន**តេងងាយ**ស្លាប់ច្រើនណាស់ ខ្លួន**តេងងាយ**នោះក៏ត្រូវព្រួញបួនអន្លើនាំទាហានរត់ទៅចូលបន្ទាយ ទទួល**សុម៉ាប៉ង**ទៅដល់**តេងងាយ**និយាយថា យើងនឹងធ្វើប្រការម្ដេច ទើប**កៀងអ៊ុយ**នឹងថយទ័ពទៅវិញ?

**សុម៉ាប៉ង**ថា ក្នុងស្រុកសែឈ្នួនសព្វថ្ងៃនេះ ព្រះចៅ**ឡៅសៀន**មិននាំពារនឹងធ្វើរាជការ រាប់អានជឿស្តាប់តែពាក្យ**ហ៊ុយហោ**ខន្ទីម្នាក់ សូមលោកតែងសំបុត្រ និងទ្រព្យរបស់គ្រឿងបណ្ណាការឲ្យច្រើនទៅគំនាប់**ហ៊ុយហោ** ទូលព្រះចៅ**ឡៅសៀន**ឲ្យមានសំបុត្រព្រះតម្រាស់ ចេញមកហៅ**កៀងអ៊ុយ**ឲ្យលើកទ័ពត្រឡប់ចូលទៅវិញ ទើបយើងនឹងធ្វើការបានចំណាប់ចំនួន ទើប**តេងងាយ**ប្រកាសប្រាប់ទាហានទាំងពួងថា នរណាអាចយកអាសាទៅនិយាយនឹង**ហ៊ុយហោ**បានខ្លះ? **តងជិន**ក៏ទទួលថា ខ្ញុំបាទនឹងសុំអាសាទៅឯង។ **តេងងាយ**មានសេចក្តីត្រេកអរណាស់ ទើបចាត់មាសប្រាក់ និងត្បូងដ៏មានតម្លៃ នូវកែវកងគ្រឿងប្រដាប់ដែលល្អៗជាច្រើនប្រគល់ឲ្យ**តងជិន** ៗក៏លា**តេងងាយ**ទៅដល់ស្រុកសែឈ្នួន ហើយចូលទៅជួប**ហ៊ុយហោ** ហើយជូនគ្រឿងបណ្ណាការនូវសំបុត្រ ហើយអង្វរថា សុំឲ្យលោកគិតដូចម្តេច ដើម្បីឲ្យ**កៀងអ៊ុយ**លើកកងទ័ពត្រឡប់មកវិញ នោះ**ហ៊ុយហោ**ជាមនុស្សលោភឃើញតែទ្រព្យរបស់ ទើបគិតកលឧបាយឲ្យមនុស្សស្និទ្ធដើរនិយាយថា **កៀងអ៊ុយ**គិតយកកងទ័ពទៅចូលខាង**សុម៉ាចៀវ** កិត្តិស័ព្ទក៏ឮល្បីពេញស្រុកសែឈ្នួន **ហ៊ុយហោ**ក៏ត្រឡប់រើសយកព័ត៌មាននោះឡើងក្រាបទូលព្រះចៅ**ឡៅសៀន** ៗបានទ្រង់ព្រះសណ្តាប់ ក៏ឆ្ងល់ក្នុងព្រះទ័យណាស់ ព្រោះ**កៀងអ៊ុយ**ជាពួក**ចូយ៉យ**មកពីដើម ទើបមានសំបុត្រត្រា តម្រាស់ចាត់រាជបម្រើឲ្យស្រូតទៅហៅ**កៀងអ៊ុយ**លើកទ័ពត្រឡប់ចូលមក។

ឯ**កៀងអ៊ុយ**ឃើញ**តេងងាយ**ចាញ់រត់ទៅ ក៏លើកកងទ័ពទៅបោះភ្ជាប់គ្នាជាយូរថ្ងៃ មិនបានឃើញ**តេងងាយ**ចេញមកច្បាំងសោះ ក៏ឲ្យទាហានទៅស្រែកជេរជាពាក្យទ្រគោះ វេលានោះស្រាប់តែបម្រើកាន់ព្រះតម្រាស់ទៅដល់ **កៀងអ៊ុយ**មិនបានដឹងថាព្រះចៅ**ឡៅសៀន**នឹងមានកិច្ចធុរៈពីអ្វី ក៏ប្រមូលកងទ័ពនឹងទៅស្រុកសែឈ្នួន **លៀវហ៊្វ**ជម្រាបថា លោកជាមហាឧបរាជ កាលនឹងលើកកងទ័ពចេញមកក៏បានទូលលាព្រះចៅ**ឡៅសៀន**ថានឹងធ្វើការឲ្យបានសម្រេច ដែលមានសំបុត្រព្រះតម្រាស់នេះ សូមឲ្យលោកបង្អែបង្អង់ហើយទូលតបទៅសិន **ទៀវអេក**និយាយនឹង**លៀវហ៊្វ**ថា ដែលអ្នកនឹងឲ្យទទឹងនឹងព្រះតម្រាស់នោះមិនត្រូវទេ ប្រការមួយ តាំងពីយើងគិត

លើកកងទ័ពមកធ្វើការនៅតំបន់នេះក៏ថ្លោះការច្រើនគ្រា ឥឡូវយើងបានជ័យជម្នះ ថាឫក្សល្អហើយ បើត្រឡប់ទៅស្រុកសិន ដើម្បីយកចិត្តពលទាហាន ហើយនឹង ប្រមូលផ្សំឲ្យបានច្រើនឡើងទៀត នឹងមិនស្រួលឬ? រួចសឹមលើកត្រឡប់មកធ្វើការ ទៀត ក៏ឃើញថាមិនជាការលំបាកប៉ុន្មាន។

**កៀងអ៊ុយ**បានឮដូច្នោះក៏យល់ឃើញត្រូវ ទើបចាត់ចែងរៀបលើកទាហាន ចេញពីបន្ទាយ ឲ្យ**លៀវហ៊្វ**និង**ទៀវអេក**នាំទាហានការពារពីក្រោយ ឯ**តេងងាយ** និង **សុម៉ាប៉ង**ដឹងថា **កៀងអ៊ុយ**លើកទ័ពត្រឡប់ទៅស្រុកសៃឈួនហើយ ក៏លើកទាហាន ដេញតាមទៅ លុះឃើញកងទ័ព**លៀវហ៊្វ** និង**ទៀវអេក**ដែលការពារពីក្រោយនោះ មាំមួនណាស់ នឹងលើកដេញតាមទៅមិនបាន ក៏ឲ្យថយកងទ័ពលើកត្រឡប់មក បន្ទាយភ្នំគីសាន់វិញ។

ឯ**កៀងអ៊ុយ**នោះ លុះលើកទ័ពទៅដល់ស្រុកសៃឈួនហើយ ទើបចូលទៅ គាល់ព្រះចៅ**ឡៅសៀន** ហើយទូលសួរថា ព្រះអង្គឲ្យហៅទូលព្រះបង្គំជាខ្ញុំមកនេះ ដោយមានកិច្ចធុរៈពីការអ្វី? ព្រះចៅ**ឡៅសៀន**ត្រាស់ថា យើងឃើញថាអ្នកលើកទ័ព ទៅគ្រានេះយូរលង់ណាស់ ក្រែងពលរេហ៍មានសេចក្ដីលំបាក បានជាហៅមកប្រាថ្នា នឹងឲ្យបម្រុងសេនាទាហានឲ្យស្រួលបួលសិន។

**កៀងអ៊ុយ**ទូលថា ទូលព្រះបង្គំជាខ្ញុំទៅធ្វើការគ្រានេះកំពុងតែបានកល ចំណាប់ណាស់ គិតថាមុខជាធ្វើការបានគាប់ប្រសើរហើយ ដែលត្រូវថយទ័ពមក ឯណេះវិញ គឺជាកលឧបាយ**តេងងាយ**វាបញ្ឆោតជាប្រាកដ។ ព្រះចៅ**ឡៅសៀន**ទ្រង់ គង់ស្ងៀមមិនបានត្រាស់តបថាអ្វីសោះ។ **កៀងអ៊ុយ**ក្រាបទូលថា ខ្លួនទូលព្រះបង្គំ នេះតាំងចិត្តនឹងធ្វើរាជការស្នងព្រះតេជព្រះគុណឲ្យអស់ពីចិត្ត នឹងបំបាត់សត្រូវឲ្យ បាន គួរឬព្រះអង្គមកជឿស្ដាប់ពាក្យអាមនុស្សប្រចុប វាយកសម្ដីអ្នកផ្សារក្មេងក្មាង វានិយាយ ឲ្យព្រះអង្គសង្ស័យនឹងទូលព្រះបង្គំជាខ្ញុំទទេៗ។ ព្រះចៅ**ឡៅសៀន**បាន ទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ដូចជាគាប់ព្រះទ័យហើយត្រាស់ថា យើងនឹងបានគិត សង្ស័យអ្វីដល់អ្នកក៏ទេ បើអ្នកបានចំណាប់ និងធ្វើការចម្រើនការហើយ នឹងលើក ទ័ពទៅតាំងនៅស្រុកហាន់តុង ចាំវាយយកស្រុកវុយកុកក៏តាមត្រូវការចុះ **កៀងអ៊ុយ**

បានស្តាប់ព្រះតម្រាស់ដូច្នោះ  ក៏ដកកងង្វើមធំថ្វាយបង្គំលាចេញមក  ហើយចាត់ចែងកងទ័ពលើកទៅស្រុកហាន់តុង។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៨៣

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពីព្រះចៅ**ចូម៉** និង**សុម៉ាចៀវ**កើតអារិទាស់ចិត្តជាខ្លាំង លើកទាហានទៅព័ទ្ធព្រះរាជវាំង ហើយសម្លាប់ព្រះចៅ**ចូម៉**ក្ស័យព្រះជន្ម **សុម៉ាចៀវ**លើក**ចូហ្វិន**ឡើងសោយរាជសម្បត្តិ។ ព្រះចៅ**ឡៅសៀន**លះបង់ការរាជការមិនរក្សាព្រះនគរសោះ ជឿស្ដាប់តែពាក្យ**ហ៊ុយហោ**ខន្ទី កាន់ល្បែងស្រា ល្បែងស្រីរាល់ថ្ងៃ មាន**កៀងអ៊ុយ**ម្នាក់គិតរក្សាស្រុក លើកទ័ពទៅច្បាំងនឹងស្រុកវុយកុកច្រើនគ្រា)។*

**ឯតខតិន**ត្រឡប់ទៅដល់ទើបនិយាយប្រាប់**តេងងាយ**ថា ក្នុងស្រុកសៃឈួននោះ រាជការទាំងពួងប្រែប្រួលខ្លាំងណាស់ មិនបានរៀបរយតាមទម្លាប់ទំនៀមធម្មតា ម្ចាស់ផែនដីនិងខុំរាជការមិនមានទុកចិត្តគ្នាទៅវិញទៅមកសោះ អំណឹះតទៅគង់នឹងកើតជាសឹកឡើងឯង។ **តេងងាយ**បានឮដូច្នោះមានអំណរណាស់ ឱ្យ**តងគិន**នាំស្រូតព័ត៌មាននោះទៅព្រមានដល់**សុម៉ាចៀវ**ឯស្រុកឡុកអៀង **សុម៉ាចៀវ**ដឹងហើយក៏គិតថា គ្រានេះមុខជាយើងនឹងធ្វើបានស្រុកសៃឈួនប្រាកដហើយ ទើបសួរ**កែផុង**នាយទាហានធំថា វេលានេះយើងចង់នឹងលើកទ័ពទៅវាយស្រុកសៃឈួន តើអ្នកនឹងយល់ឃើញប្រការម្ដេច?

**កែផុង**ថា វេលានេះព្រះចៅ**ចូម៉**ក៏មានសេចក្ដីមន្ទិលសង្ស័យនឹងយើង មិនជាទីទុកចិត្តសោះ ដែលលោកនឹងលើកកងទ័ពទៅវេលានេះ ក៏ឃើញថាអាការមិនទាន់ស្រួល មួយទៀតកាលឆ្នាំដែលកន្លងទៅហើយនោះ មានមករចុះមកហែលនៅក្នុងស្រះលេង។ អស់នាហ្មឺនមុខមន្ត្រីបានក្រាបទូលព្រះចៅ**ចូម៉**ថា នឹងជាមង្គលដល់ស្រុកទេស ព្រះចៅ**ចូម៉**ក៏ត្រាស់ថា ឯធម្មតាមករនោះមានតែសម្ដែងឫទ្ធិអំណាចនៅលើអាកាស និងកណ្ដាលព្រះមហាសមុទ្រ ឥឡូវមកធ្លាក់នៅក្នុងស្រះតូចដូច្នេះ អស់

អ្នកទាំងឡាយនឹងថាជាមង្គលនោះ យើងមិនទាន់ឃើញផងសោះ វេលានោះព្រះចៅ**ចូម៉**ក៏តែងឃ្លោងបួនបទ ប្រៀបទុកជាសេចក្តីថា៖

មករមង្គលមានពលឫទ្ធិ		តែងតែនិមិត្តវិទ្យា
ក្នុងលោកសាគរអាកាសា		ជាទីអស្ចារ្យគួរស្ញប់ស្ញែង។
ឥឡូវម្តេចត្រូវមកនៅស្ទះ		ក្នុងស្រះត្រពាំងបង់កន្លែង
ឲ្យត្រីតូចតាចមិនខ្លាចក្រែង		នេះឯងដូចអង្គយើងសព្វថ្ងៃ។
មានតែអ្នកតូចល្ងួចអំណាច		ពុំខ្លាចពុំកោតមឹតពួតដៃ
មុខជាឈើចាប់សព្វសរសៃ		គិតក្រៃកើតក្រំនាំឲ្យក្តៅ។

**សុម៉ាចៀវ**បានឃើញសេចក្តីឃ្លោងដូច្នោះក៏ខឹងណាស់ និយាយនឹង**កែអុង**ថា ឯ**ចូម៉**នេះបើនឹងទុកឲ្យនៅយូរទៅក៏គង់ដូច**ចូហាង** បើដូច្នោះយើងត្រូវតែគិតកម្ចាត់ចេញទើបស្រួល។ **កែអុង**ថា លោកគិតនេះត្រូវណាស់ ខ្ញុំបាទនឹងគិតសុំទទួលអាសាទៅកម្ចាត់**ចូម៉**ចេញឲ្យត្រាតែបាន។ ខណៈនោះ ព្រះចៅ**ចូម៉**គ្រងរាជសម្បត្តិបានប្រាំឆ្នាំ ដល់ខែជេស្ឋចេញនិយាយរាជការ អស់នាហ្មឺនមុខមន្ត្រីចូលគាល់គ្រប់គ្នា **សុម៉ាចៀវ**ក៏កាន់គ្របីចូលទៅគាល់ អស់នាហ្មឺនមុខមន្ត្រីក៏ក្រាបទូលព្រះចៅ**ចូម៉**ថា **សុម៉ាចៀវ**មានសេចក្តីគាប់ប្រសើរក្នុងរាជការជាច្រើន សូមឲ្យព្រះអង្គតាំង**សុម៉ាចៀវ**ជាមហាឧបរាជចុះ នឹងបានជួយនិយាយរាជការតទៅ។ ព្រះចៅ**ចូម៉**មិនបានត្រាស់តបថាប្រការម្តេច។

**សុម៉ាចៀវ**ឃើញកិរិយាព្រះចៅ**ចូម៉**ដូច្នោះក៏ខឹងណាស់ ទើបស្រែកឡើងថា បិតាយើងនិងបងយើងមានគុណបំណាច់ក្នុងផែនដីច្រើនណាស់ ខ្លួនយើងនេះមិនគួរនឹងជាមហាឧបរាជប៉ុណ្ណឹងឬ? ព្រះចៅ**ចូម៉**ត្រាស់តបបន្ទាន់ថា អ្នកមានគុណបំណាច់មែនហើយ បើនឹងចង់ធ្វើមហាឧបរាជក៏តាមការចុះ គ្មាននរណានឹងទទឹងទាស់ទេ។ **សុម៉ាចៀវ**បានឮដូច្នោះក៏រឹតតែខឹងណាស់ និយាយឲ្យព្រះចៅ**ចូម៉**ថា ខ្លួនយើងបានធ្វើរាជការមានគុណបំណាច់ច្រើនណាស់ អ្នកឯងនេះពេញជាមនុស្សមិនស្គាល់គុណគេ ប៉ានធ្វើពាក្យឃ្លោងប្រៀបធៀបចំអកឡកឲ្យយើងផ្សេងៗ អ្នកឯងធ្វើដូច្នោះជាត្រូវ

ហើយឬ? ព្រះចៅ**ចូម៉**ស្ងៀមមិនតបឆ្លើយសោះ **សុម៉ាចៀវ**មិនបានក្រាបថ្វាយបង្គំលាព្រះចៅ**ចូម៉**ដូចធម្មតា ធ្វើជាអស់សំណើចហើយក៏ក្រោកដើរចេញពីទីគាល់ទៅ។

ព្រះចៅ**ចូម៉**ក៏ស្ដេចយាងចូលទៅទីខាងក្នុង ទើបត្រាស់ឲ្យហៅ**អងស៊ឹម១, អងកេង១, អងង៉ៀប១** ដែលជានាហ្មឺនធំឲ្យចូលមកគាល់ ហើយត្រាស់ប្រារព្វថា ឥឡូវនេះ**សុម៉ាចៀវ**ធ្វើការជាអាក្រក់ណាស់ មុខជានឹងក្បត់ដណ្ដើមយករាជសម្បត្តិយើងជាប្រាកដ តើអ្នកទាំងពួងនឹងយល់ឃើញប្រការម្ដេច? **អងកេង**ឆ្លើយទូលតបថា ព្រះអង្គកុំអាលធ្វើឲ្យបែកផ្សាយខូចការឡើយ ត្បិត**សុម៉ាចៀវ**ជានាហ្មឺនធំ មានសតិបញ្ញា និងកម្លាំងពលំជាច្រើន អស់ទាំងនាហ្មឺនមុខមន្ត្រី និងសេនាទាហានទាំងអស់ សឹងនៅក្នុងអំណាច**សុម៉ាចៀវ**ទាំងអស់ បើ**សុម៉ាចៀវ**ដឹងសេចក្ដីហើយ ក៏នឹងកើតហេតុជាធំមិនសមប្រកបនឹងសេចក្ដីរិះគិតរបស់យើង។ ព្រះចៅ**ចូម៉**ត្រាស់ថា ដែល**សុម៉ាចៀវ**ធ្វើការអាក្រក់មាក់ងាយដូច្នេះ យើងមានសេចក្ដីតូចចិត្តណាស់ ទោះបីនឹងស្លាប់ក៏មិនស្ដាយជីវិត វេលានេះយើងត្រូវតែធ្វើតបឲ្យអស់កំហឹងឲ្យបាន ហើយព្រះចៅ**ចូម៉**ក៏ស្ដេចចូលទៅជួបនឹងមាតា ហើយពណ៌នាសេចក្ដីទុក្ខក្ដៅឲ្យទ្រង់ព្រះសណ្ដាប់គ្រប់ប្រការ។

កាលព្រះចៅ**ចូម៉**យាងចូលទៅនោះ **អងស៊ឹម**និង**អងង៉ៀប**ថា ព្រះចៅ**ចូម៉**មានព្រះទ័យក្ដៅខ្វាល់នឹង**សុម៉ាចៀវ**ខ្លាំងណាស់ មុខជានឹងធ្វើការពុះពារដោយអំណាចទោសោ បើ**សុម៉ាចៀវ**ដឹងស៊ើបដំណឹងបានសេចក្ដីថា យើងរួមគំនិតគ្នាដូច្នេះ មុខជាយើងនឹងនាំគ្នាស្លាប់អសារអស់ទាំងជួរគោត្រ យើងត្រូវរិះគិតនាំយកសេចក្ដីនេះទៅប្រាប់**សុម៉ាចៀវ**ជាមុនទើបត្រូវ ហើយយើងគង់នឹងបានសេចក្ដីគាប់ប្រសើរផង **អងង៉ៀប**បានឮដូច្នោះក៏យល់ឃើញត្រូវផង **អងកេង**និយាយនឹង**អងស៊ឹម**ថា ព្រះចៅ**ចូម៉**ជាម្ចាស់យើងមានសេចក្ដីក្ដៅក្រហាយ គួរយើងនឹងគិតស្នងព្រះតេជព្រះគុណត្រាតែអស់ជីវិត ដែលនឹងទុរយសធ្វើចិត្តពីរដូច្នេះមិនសមគួរសោះ យើងមិនយល់ផងទេ ហើយ**អងកេង**ក៏ឃាត់ហាមជាច្រើនដង **អងស៊ឹម, អងង៉ៀប**មិនស្ដាប់ ក៏នាំគ្នាចូលទៅរក**សុម៉ាចៀវ** ហើយពណ៌នាសេចក្ដីទាំងពួងឲ្យ**សុម៉ាចៀវ**ស្ដាប់គ្រប់ប្រការ។

ឯព្រះចៅ**ចូម៉**នោះ លុះប្រឹក្សានឹងព្រះមាតាហើយ ក៏ឡើងរថកាន់គ្រប៊ីហៅអស់នាហ្មឺនមុខមន្ត្រី នូវពួកទាហានប្រមាណបីរយថ្លាយលើកទៅផ្ទះ**សុម៉ាចៀវ**។ **អងកេង**ឃើញដូច្នោះក៏ក្រាបចុះហើយយំទូលថា ដែលព្រះអង្គលើកទាហានបីរយទៅច្បាំងនឹង**សុម៉ាចៀវ**នោះ បីដូចពពែចូលទៅក្នុងមាត់ខ្លា សូមព្រះអង្គចូរបង្អង់នៅសិន ទូលព្រះបង្គំជាខ្ញុំមិនមែននឹងស្រឡាញ់ជីវិតប៉ុន្មានទេ តាំងចិត្តនឹងធ្វើរាជការតបស្នងសងព្រះតេជព្រះគុណត្រាតែអស់ជីវិត តែទូលព្រះបង្គំជាខ្ញុំគិតថា បើនឹងធ្វើការវេលានេះ ក៏នឹងនាំគ្នាអន្តរាយដោយការនេះជាប្រាកដ។ ព្រះចៅ**ចូម៉**ក៏មិនស្ដាប់ប្រញាប់ឲ្យលើកទាហានចេញពីព្រះរាជវាំងដោយកម្លាំងទោសោ លុះចេញទៅដល់មាត់ទ្វារវាំងឃើញ**កែផុង**ជិះសេះកាន់លំពែង **សេងជុយ**នៅស្ដាំ **សេងចេ**នៅឆ្វេង នាំទាហានមួយពាន់វាយទម្លាយចូលមក ព្រះចៅ**ចូម៉**ភ័យណាស់ចាប់គ្រប៊ីឡើងគ្រវីស្រែកថា ខ្លួនយើងជាក្សត្រិយ៍ អាពួកនេះម្ដេចហ៊ានបង្អាចហៅហានទន្ទ្រានចូលមកនឹងប្រទូសរ៉ាយយើងឬ? អស់ពលរេហ៍ឮដូច្នោះក៏នឹកកោតខ្លាចចេស្ដាមិនហ៊ានពុះពារចូលទៅប៉ងប្រមាថ ក៏នាំគ្នាថយឃ្លាតទៅក្រោយវិញ។

**កែផុង**និយាយនឹង**សេងចេ**ថា ដែលមហាឧបរាជបានជប់លៀងខ្លួនមកក៏ប្រាថ្នាដើម្បីដោយការប៉ុណ្ណោះ វេលានេះបានចន្លោះឱកាសហើយម្ដេចឡើយមកស្ទៀមនៅព្រងើយវិញ មិនបង្ខំធ្វើឲ្យបានការ។ **សេងចេ**សួរថា លោកនឹងឲ្យសម្លាប់ចេញឬនឹងចាប់ខ្លួនយកទៅ? **កែផុង**ថា **សុម៉ាចៀវ**បង្គាប់មកថា បើបានចំណាប់ហើយត្រូវឲ្យសម្លាប់ចេញទៅចុះ។ **សេងចេ**បានឮដូច្នោះក៏កាន់ដាវបំផាយសេះត្រង់ចូលទៅដល់មុខរថព្រះទីនាំង។ ព្រះចៅ**ចូម៉**ស្រែកគំហកថា ឯងនឹងគិតក្បត់អញឬ? **សេងចេ**ក៏យកដាវចាក់ព្រះចៅ**ចូម៉**ត្រូវពាក់កណ្ដាលដើមទ្រូង ភ្លាត់ធ្លាក់ពីលើរថហើយក៏យកដាវនោះកាប់ថែមទាល់តែស្លាប់ព្រះចៅ**ចូម៉**នៅក្បែររថនោះ **ចៀវប៉េក**ដែលជានាហ្មឺនធំឃើញដូច្នោះក៏ខឹងណាស់ បំផាយសេះចេញទៅប៉ងតស៊ូគ្នានឹង**សេងចេ** ៗក៏លើកដាវកាប់ត្រូវ**ចៀវប៉េក**ធ្លាក់ពីលើសេះស្លាប់ អស់ពលទាហានក៏បែកខ្ចាត់ខ្ចាយទៅ **អងកេង**ឃើញដូច្នោះក៏ស្រែកជេរថា អាចោរក្បត់ អាឯងហ៊ានសម្លាប់ព្រះមហាក្សត្រិយ៍ម្ល៉េះមឹងឬ? **កែផុង**ខឹងណាស់បង្គាប់ទាហានឲ្យចូលទៅ

ចាប់ខ្លួន**អងកេង**ទៅឲ្យ**សុម៉ាចៀវ** ហើយពណ៌នាសេចក្ដីទាំងពួងឲ្យស្ដាប់គ្រប់ប្រការ។

**សុម៉ាចៀវ**បានឮដូច្នោះ ក៏ធ្វើជាតក់ស្លុតភិតភ័យណាស់ ឡើងសេះនាំទាហានចូលទៅក្នុងវាំង ឃើញព្រះចៅ**ចូម៉**ក្សយព្រះជន្មនៅក្បែររថ **សុម៉ាចៀវ**គំនាប់បង្គំហើយក៏ធ្វើជាយំសោកាល័យច្រើន ហើយបង្គាប់ឲ្យអស់មុខមន្ត្រីធំតូចមកប្រជុំគ្នា **សុម៉ាហ៊ូ**ជាមន្ត្រីធំឃើញដូច្នោះក៏យំសោកាគំនាប់សពព្រះចៅ**ចូម៉**ហើយថា ដែលមានមនុស្សកំណាចមកប្រទូសរ៉ាយអម្ចាស់ផែនដីដូច្នោះ ទោសខ្ញុំក៏ខុសច្រើនណាស់ ហើយនាំគ្នាតែងការព្រះបរមសពតាមប្រវេណីក្សត្រិយ៍ អញ្ជើញទៅតម្កល់ទុកលើប្រាសាទធំខាងទិសបស្ចិម។ **សុម៉ាចៀវ**ក៏នាំអស់នាហ្មឺនមុខមន្ត្រីចូលទៅក្នុងទីស្ដេចចេញ។

វេលានោះ **តាន់ថាយ**ពាក់អាវចូលទៅគំនាប់ព្រះបរមសព ហើយក៏ចូលទៅក្នុងទីប្រជុំមុខមន្ត្រីទាំងពួង **សុម៉ាចៀវ**សួរថា វេលានេះមានមនុស្សកំណាចមកប្រទូសរ៉ាយព្រះចៅ**ចូម៉**ទិវង្គតទៅ តើអស់លោកទាំងពួងនឹងប្រឹក្សាទោសប្រការម្ដេច? **តាន់ថាយ**ឆ្លើយថា ដែលកើតហេតុទាំងនេះព្រោះ**កែឆុង**តែម្នាក់ឯង សុំឲ្យលោកយកខ្លួន**កែឆុង**ទៅសម្លាប់ចេញទើបត្រូវ **សុម៉ាចៀវ**បានឮដូច្នោះទាស់ចិត្តណាស់នៅស្ងៀមមិនស្ដី ហើយថា ដែលនឹងឲ្យសម្លាប់**កែឆុង**នោះ ត្រូវឲ្យគិតមើលហ្មត់ចត់សិន។

**តាន់ថាយ**ថា ខ្ញុំបាទពិចារណាមើលតាមទំនៀមក៏ឃើញតែប៉ុណ្ណោះ **សុម៉ាចៀវ**ថា **កែឆុង**ក្នុងវេលាកើតហេតុនោះផងក៏មែន តែមិនបានទៅចុះដៃធ្វើខ្លួនឯងទេ **សេងចេ**ទេតើដែលជាតួដៃដល់ គួរតែនឹងសម្លាប់តែឈ្មោះនោះឲ្យអស់បីជួរគោត្រទើបត្រូវ។ **សេងចេ**បានឮដូច្នោះខឹងណាស់ ស្រែកតបទៅឲ្យ**សុម៉ាចៀវ**ថាហេតុម្ដេចលោកយកទោសឯខ្លួនយើងវិញ **កែឆុង**ជាអ្នកបង្គាប់ឲ្យខ្ញុំធ្វើ គឺថាខ្លួនលោកជាចៅបង្គាប់ឲ្យសម្លាប់ព្រះចៅ**ចូម៉**ចេញ យើងខ្លាចអាជ្ញាលោកបានជាទទួលធ្វើតាម ឯ**សុម៉ាចៀវ**ថា ខ្លួនឯងជាអ្នកក្បត់ដល់ម្ចាស់ផែនដីហើយនៅត្រឡប់មកនិយាយយ៉ាងនេះវិញ ថាហើយក៏ឲ្យទាហានចាប់ខ្លួន**សេងចេ**ទៅកាត់សេចក្ដី ហើយឲ្យសម្លាប់

ចេញ។ **សេងចេ**ស្រែកដេរ**សុម៉ាចៀវ**ទាល់តែគេប្រហារដាច់ខ្យល់ស្លាប់ទើបបាត់មាត់។ **សុម៉ាចៀវ**ក៏ឲ្យទាហានទៅយកខ្លួន**សេងជុយ**ជាប្អូន**សេងចេ** និងស្ន័គ្របក្សពួកទាំងអស់ទៅប្រហារជីវិតអស់ដល់បីជួរគោត្រ ហើយឲ្យទៅយកខ្លួន**អងកេង**និងស្ន័គ្របក្សពួកទាំងអស់មកទៀត។

**អងកេង**គំនាប់មាតាហើយក៏យំសោកាថា ខ្ញុំបាទជាកូននៅមិនទាន់បានតបគុណអ្នកម្ដាយសោះ វេលានេះមកត្រូវជាមួយនឹងគេទទេៗទៅ មាតា**អងកេង**អស់សំណើចហើយថា កើតមកជារូបហើយនឹងរត់ទៅណាឲ្យផុតពីសេចក្ដីស្លាប់នោះដូចជាគ្មាន ខ្លួនយើងនេះបើទោះបីនឹងស្លាប់ក៏មិនត្រូវស្ដាយជីវិតទេ ព្រោះយើងមានសេចក្ដីស័ត្យកតញ្ញូនឹងអម្ចាស់ផែនដី ដើម្បីនឹងទុកកេរ្ដិ៍ឈ្មោះឲ្យឮល្បីទៅខាងមុខចុះ។ **សុម៉ាចៀវ**ក៏ឲ្យយកខ្លួន**អងកេង**និងស្ន័គ្របក្សពួកទៅសម្លាប់អស់ទាំងគោត្រ អស់បណ្ដាអ្នកស្រុកឃើញដូច្នោះ ក៏នាំគ្នាយំសោកាអាណិតគ្រប់គ្នា **សុម៉ាចៀវ**ក៏អញ្ជើញសពព្រះចៅ**ចូម៉**ទៅបញ្ចុះតាមប្រពៃណីក្សត្រិយ៍។ **កែឆុង**ទើបប្រឹក្សានឹងមន្ត្រីទាំងពួងថា យើងត្រូវអញ្ជើញ**សុម៉ាចៀវ**ឲ្យឡើងគ្រងរាជសម្បត្តិចុះ។ **សុម៉ាចៀវ**ថាកាលព្រះចៅ**វុយអេង**ជាធំនោះ ក៏មិនមែនដណ្ដើមរាជសម្បត្តិទេ វេលានេះយើងត្រូវតែជួយទំនុកបម្រុងផែនដី ឲ្យដូចព្រះចៅ**វុយអេង**នោះទៅចុះ។ **កែឆុង**ដឹងគំនិត**សុម៉ាចៀវ**ថានឹងយករាជសម្បត្តិទុកឲ្យ**សុម៉ាអៀន**ជាបុត្រក៏ស្ងៀម នៅមិនបានតបថាប្រការម្ដេច។

ខណៈកាលព្រះចៅ**ចូម៉**ទិវង្គតនោះ ក្នុងខែស្រាពណ៍ខាងខ្នើត **សុម៉ាចៀវ**ក៏អញ្ជើញ**ចូហ្វួន**ជាចៅ**ចូឆូ**ឡើងគ្រងរាជសម្បត្តិ រាប់សករាជឆ្នាំនោះជាដើមវង្សតមក (ព.ស ៨០៣) ព្រះចៅ**ចូហ្វួន**ក៏តាំង**សុម៉ាចៀវ**ជាមហាឧបរាជ ព្រះរាជទានប្រាក់ដប់ម៉ឺនជញ្ជីង ព្រែយ៉ាងល្អដប់ម៉ឺនផាប់ និងគ្រឿងសម្រាប់យស ហើយតាំងទាហានដែលមានគុណបំណាច់គាប់ប្រសើរឲ្យធ្វើជានាហ្មឺនតូចធំតាមលំដាប់ រួចទ្រង់ប្រោសព្រះរាជទានបំណាច់រង្វាន់ជាច្រើន។ វេលានោះមានទាហានល្បាតនាំយកព័ត៌មានដែល**សុម៉ាចៀវ**សម្លាប់**ចូម៉** ហើយលើក**ចូហ្វួន**សោយរាជសម្បត្តិនោះទៅសារស័ព្ទប្រាប់**កៀងអ៊ុយ**ខាងស្រុកសៃឈួនគ្រប់ប្រការ។

**កៀងអ៊ុយ**បានដឹងកិច្ចដូច្នោះក៏មានអំណរណាស់ ទើបតែងសំបុត្រចាត់បម្រើឲ្យនាំទៅស្រុកកាំងតាំង មានសេចក្តីថា ដែលយើងគិតនឹងលើកទ័ពទៅវាយស្រុកឡុកអៀងនោះក៏សមគួរណាស់ហើយ ព្រោះវេលានេះ**សុម៉ាចៀវ**ចេញជាក្បត់ផែនដីសម្លាប់ព្រះចៅ**ចូម៉** ហើយតាំង**ចូហ៊្វន**ឡើងជាស្តេច សុំឲ្យលើកទ័ពទៅប្រសព្វគ្នានឹងយើងដើម្បីនឹងលើកខឡើងចុះទោស**សុម៉ាចៀវ**។ នោះបម្រើកាន់សំបុត្រក៏ចេញទៅស្រុកកាំងតាំង វេលានោះ**កៀងអ៊ុយ**ក៏ចូលទៅគាល់ព្រះចៅ**ឡៅសៀន** ក្រាបទូលព័ត៌មានគ្រប់ប្រការ ហើយសុំលើកកងយោធាទៅវាយស្រុកឡុកអៀង។ ព្រះចៅ**ឡៅសៀន**ក៏ព្រមអនុញ្ញាតឲ្យ**កៀងអ៊ុយ**លើកទ័ពទៅ **កៀងអ៊ុយ**ក៏ឲ្យប្រមូលពលទាហានបានដប់ប្រាំម៉ឺន បានទាំងរទេះបន្ទុកសម្រាប់ធ្វើការសង្គ្រាម២០ ចាត់ឲ្យ**លៀវហ៊្វ**នាំទាហានប្រាំម៉ឺនទៅខាងផ្លូវជួងអកុក ចាត់ឲ្យ**ទៀវអេក**នាំទាហានប្រាំម៉ឺនលើកទៅតាមផ្លូវឡុកុក ខ្លួន**កៀងអ៊ុយ**ឯងក៏រៀបលើកពលទៅតាមផ្លូវសៀកុក លុះបានថ្ងៃឫក្សល្អក៏លើកទាហានចេញចាកស្រុកសៃឈ្វនជាបីផ្លូវ ទៅប្រសព្វគ្នានៅភ្នំគីសាន់។

ឯ**តេងងាយ**ក៏តាំងបន្ទាយនៅភ្នំគីសាន់ លុះដឹងព័ត៌មានថា **កៀងអ៊ុយ**លើកទ័ពទៅជាបីផ្លូវដូច្នោះក៏ខឹងណាស់ ទើបប្រមូលអស់នាយទ័ពនាយកងទាំងពួងទៅប្រជុំប្រឹក្សា **អងក្វន**ឆ្លើយថា កលឧបាយរបស់ខ្ញុំបាទគិតឃើញសេចក្តីម្យ៉ាង តែនឹងនិយាយវេលានេះក្រែងបែកការ ទើបលិខិតជាអក្សរហុចឲ្យទៅ**តេងងាយ**សេចក្តីថា ឲ្យធ្វើកលចូលស្ម័គ្រទៅខាង**កៀងអ៊ុយ** ហើយសឹមគិតយកជ័យជម្នះជាក្រោយ។ **តេងងាយ**ឃើញសេចក្តីនោះក៏អស់សំណើចហើយថា

តម្រិះរិះគិតរបស់អ្នកនោះល្អមែនៗ តែថាក្រែង**កៀងអ៊ុយ**នឹងដឹងដល់។ **អងក្វន**ថា លោកកុំគិតព្រួយអ្វីឡើយ បើលោកឃើញផងហើយ ខ្ញុំបាទនឹងសុំទទួលអាសាទៅខ្លួនឯង។ **តេងងាយ**ឆ្លើយថា បើចិត្តអ្នកត្រង់ប្រាកដដូច្នោះ មុខជាសម្រេចការនេះជាប្រាកដ ខ្លួនអ្នកក៏នឹងបានសេចក្តីគាប់ប្រសើរ ហើយក៏ប្រមូលពលទាហានបានប្រាំពាន់ប្រគល់ឲ្យ**អងក្វន** ៗក៏លើកចេញទៅទាំងកណ្តាលយប់ លុះទោដល់បន្ទាយ**កៀងអ៊ុយ** ក៏ស្រែកប្រាប់

ទាហានក្នុងបន្ទាយនោះថា យើងជាទាហានរបស់**តេងងាយ**នឹងស្ម័គ្រចូលមកធ្វើការខាងលោកឯណោះ។ នោះអ្នកយាមក៏ចូលទៅជម្រាបដល់**កៀងអ៊ុយ** ៗដឹងដូច្នោះក៏ឲ្យទាហានទាំងអស់នៅខាងក្រៅបន្ទាយ ឲ្យតែខ្លួន**អងក្លួន**ចូលទៅ។

**អងក្លួន**គំនាប់**កៀងអ៊ុយ**ហើយថា ខ្ញុំបាទនេះជាក្មួយ**អងកេង** **សុម៉ាចៀវ**សម្លាប់ព្រះចៅ**ចូម៉**នោះ មាខ្ញុំបាទជាមនុស្សស័ត្យត្រង់ណាស់ **សុម៉ាចៀវ**ក៏សម្លាប់អស់ទាំងគោត្រ ខ្ញុំបាទមានសេចក្ដីខឹងណាស់ វេលានេះខ្ញុំបាទដឹងថាលោកលើកទ័ពមកនឹងចុះទោស**សុម៉ាចៀវ** បានជាខ្ញុំនាំស្ម័គ្របក្សពួកប្រាំពាន់មកចូលនៅធ្វើការនឹងលោក ដើម្បីសុំអាសាទៅធ្វើការសងសឹក**សុម៉ាចៀវ**វិញឲ្យបាន។ **កៀងអ៊ុយ**ឮដូច្នោះ ក៏អស់សំណើចហើយថា ដែលអ្នកនិងស្ម័គ្របក្សពួកមកចុះចូលនឹងយើងគ្រានេះ យើងក៏មានសេចក្ដីត្រេកអរសាទរណាស់ហើយ វេលានេះរទេះស្បៀងរបស់យើងមកតាមក្រោយ អ្នកចូរនាំទាហានឃុំគ្រងរក្សាជួយការពារឲ្យស្រួតរូតមកបានឆាប់ចុះ យើងនៅខាងក្រោយនឹងលើកចូលវាយបន្ទាយ**តេងងាយ**ឲ្យបាន។

**អងក្លួន**មានសេចក្ដីត្រេកអរណាស់ លា**កៀងអ៊ុយ**ថយចេញទៅ **កៀងអ៊ុយ**ថាអ្នកនឹងទៅវេលានេះគ្រាន់ជាការតឿនបង្ខំឲ្យនាំស្បៀងទេ នឹងយកទាហានច្រើនក៏ជាការឥតប្រយោជន៍ យើងសុំដកទុកពីរពាន់ ដើម្បីជួយនាំផ្លូវធ្វើការនៅអាយ។ **អងក្លួន**ឮដូច្នោះ លុះនឹងមិនឲ្យទាហានទុកក៏នឹកខ្លាច**កៀងអ៊ុយ**នឹងចាប់ពិរុទ្ធបាន ទើបគំនាប់លា**កៀងអ៊ុយ**នាំទាហានមួយពាន់ចេញទៅ **កៀងអ៊ុយ**កាត់យកទាហានពីរពាន់ទុកហើយប្រគល់ឲ្យ**បផៀម** ហើយនិយាយនឹង**ហែហ៊្ហប៉ា**ឲ្យចូលទៅជួបនឹង**កៀងអ៊ុយ**ហើយថា ហេតុម្ដេចបានជាមហាឧបរាជជឿស្ដាប់ពាក្យ**អងក្លួន** ៗនេះតាំងពីខ្ញុំបាទធ្វើរាជការនៅស្រុកឡុកអៀង ក៏មិនប្រាកដជាក្មួយ**អងកេង**ពិតប្រាកដទេ ដែល**អងក្លួន**ស្ម័គ្រមកនៅផងនេះ ឃើញថាជាកលឧបាយ សូមឲ្យមហាឧបរាជតម្រិះគិតឲ្យមាំមួនសិន។

**កៀងអ៊ុយ**អស់សំណើចហើយថា កលនេះយើងក៏អាចដឹងដល់អស់ហើយ បើ**អងក្លួន**ជាក្មួយ**អងកេង**ពិត **សុម៉ាចៀវ**ឬនឹងបណ្ដោយឲ្យមកប្រមូលទាហាននៅក្រៅស្រុកច្រើនដល់ម្ល៉េះ ហេតុនេះបានជាយើងបែងទាហានទុក ប្រាថ្នានឹងត្រួតកល

**អងក្លួន**វិញឲ្យបាន។ **ហៃហ៊្វប៉ា**ថា គំនិតលោកគិតនេះត្រូវនឹងចិត្តខ្ញុំបាទណាស់ ទើប**កៀងអ៊ុយ**ប្រមូលទាហានឲ្យចេញស្កាត់ផ្លូវចាំរវាំងមើល**អងក្លួន** នឹងលបប្រើបម្រើឲ្យទៅមករក**តេងងាយ** ក៏ប្រទះចាប់បាននាំខ្លួនទៅឲ្យ**កៀងអ៊ុយ** ៗក៏យកសំបុត្រមកមើលឃើញសេចក្ដីថា ឲ្យ**តេងងាយ**លើកទ័ពមកទទួលប្រហាបភ្នំហ៊ុយសាន់នៅថ្ងៃ១៥រោចខែភទ្របទចុះ ខ្ញុំបាទនឹងនាំស្បៀងទៅតាមផ្លូវនោះ។

**កៀងអ៊ុយ**ឃើញសំបុត្រដូច្នោះហើយ ទើបយកអ្នកកាន់សំបុត្រនោះទៅសម្លាប់ចេញ ហើយសរសេរសំបុត្រមួយច្បាប់សេចក្ដីថា នៅថ្ងៃ១៥កើតខែភទ្របទឲ្យ**តេងងាយ**នាំទាហានទៅចាំនៅប្រហាបភ្នំហ៊ុយសាន់ ខ្ញុំបាទ**អងក្លួន**នឹងនាំស្បៀង**កៀងអ៊ុយ**ទៅឲ្យលោកនៅទីនោះ ហើយក៏ចាត់ទាហានបន្លំ ជាទាហាន**អងក្លួន**កាន់សំបុត្រនោះទៅឲ្យ**តេងងាយ**ឯបន្ទាយ។ ទាហាននោះក៏លា**កៀងអ៊ុយ**ទៅ ទើប**កៀងអ៊ុយ**ឲ្យ**បផៀម**នាំទាហានពីរពាន់យករទេះមួយរយបន្ទុកខស និងផ្នួនភ្លើងទៅបង្កប់នៅប្រហាបភ្នំនោះ ហើយឲ្យ**ចៀវឈី** និង**ទៀវអេក, លៀវហ៊្វ**នាំទាហានទៅវាយបន្ទាយ**តេងងាយ** ឯខ្លួន**កៀងអ៊ុយ**និង**ហៃហ៊្វប៉ា**នាំទាហានឡើងទៅលើកំពូលភ្នំ។

ឯ**តេងងាយ**នោះ លុះបានទទួលសំបុត្រហើយក៏មានសេចក្ដីត្រេកអរណាស់ ទើបសរសេរសំបុត្រតបទៅ**អងក្លួន**វិញ សេចក្ដីថា ឲ្យ**អងក្លួន**ប្រញាប់បញ្ជូនស្បៀងមកឲ្យឆាប់ចុះ យើងនឹងនាំទាហានទៅចាំតាមសញ្ញា បម្រើនោះក៏នាំសំបុត្រទៅឲ្យ**កៀងអ៊ុយ** លុះដល់កំណត់ថ្ងៃ១៤កើតខែភទ្របទ **តេងងាយ**ក៏លើទាហានប្រាំម៉ឺនចេញពីបន្ទាយតម្រង់ទៅដល់ប្រហាបភ្នំហ៊ុយសាន់។ ទាហានល្បាតស្រូតទៅមុខឃើញរទេះផ្ទុកផ្នួនភ្លើងបង្កប់នៅច្រើន សម្គាល់ថា**អងក្លួន**បររទេះស្បៀងមក ក៏ស្រូតត្រឡប់ទៅប្រាប់**តេងងាយ** ៗក៏ប្រញាប់លើកទ័ពទៅដល់ប្រហាបភ្នំនោះ ឃើញទាហាន**អងក្លួន**នៅជាច្រើនក៏មានអំណរណាស់ អស់ពលទាហាននិយាយនឹង**តេងងាយ**ថា ពេលនេះល្ងាចណាស់ហើយ សុំឲ្យលោកស្រូតទៅបរនាំយករទេះស្បៀងមក។

**តេងងាយ**ថា ភ្នំខាងមុខយើងនោះញឹកស្បាតខ្លាំងណាស់ ខ្លាចក្រែង**កៀងអ៊ុយ**ដឹងដល់នឹងលើកទាហានមកបង្កប់ទុក យើងនឹងបានសេចក្ដីលំបាកព្រួយ យើងត្រូវរង់ចាំមើលឲ្យ**អងក្លួន**នាំរទេះស្បៀងមកដល់ សឹមយើងនាំគ្នាវិលទៅបន្ទាយវិញ

នោះមានទាហានមកប្រាប់ថា **អងក្លួន**នាំរទេះស្បៀងមកដល់ហើយ មានកងទ័ពលើកដេញពីក្រោយជាច្រើន សុំឲ្យលោកប្រញាប់លើកទាហានទៅ។ **តេងងាយ**ឮដូច្នោះក៏ស្រូតលើកទាហានទៅ ដល់យប់ប្រហែលយាមមួយ ស្រាប់តែឮសំឡេងស្រែកហ៊ោគឹកកងពីក្រោយខ្នង ក៏សម្គាល់ថា **អងក្លួន**លើកតាមមកជាពួកជាមួយគ្នា ក៏ខំស្រូតលើកទាហានលើកឆ្លងភ្នំទៅដល់ព្រៃញឹកមួយអន្លើ **បផៀម**កាន់លំពែងបំផាយសេះចេញមកស្រែកថា ឯងចាញ់កលថៅហ្វាយអញត្រួតលើកលងឯងហើយ ឯងនឹងរត់ទៅណា? ចូរវិលមកសុំចំណុះអញដោយស្រួលទៅ អញនឹងចងឯងនាំទៅឲ្យ**កៀងអ៊ុយ**ថៅហ្វាយអញ។

**តេងងាយ**ឮដូច្នោះភ័យណាស់លោះអស់ព្រលឹង ខំប្រឹងបំផាយសេះវេះទៅក្រោយ នោះអស់ទាហានដែលពួនបង្កប់ក៏យកភ្លើងដុតផ្នួនព័ទ្ធឡើងជុំវិញ ហើយដេញសម្រុកចូលទៅប្រកាប់ប្រចាក់ពួក**តេងងាយ**ស្លាប់ច្រើនណាស់ ខ្លះក៏ស្រែកថា បើនរណាចាប់**តេងងាយ**បាននឹងឲ្យរង្វាន់ជាមាសមួយរយដំឡឹង ហើយតាំងឲ្យធ្វើជានាហ្មឺនធំ។ **តេងងាយ**ឮដូច្នោះក៏ដោះក្រឹសចោលអស់ពីខ្លួន លោតចុះពីលើសេះទៅចូលបន្លំជាកូនទាហាន ចេញទន្ទ្រានពីក្នុងចំណោមរួចបានហើយរត់ទៅ **កៀងអ៊ុយ**និង**ហេហ្វ៊ប៉ា**សម្គាល់ថា **តេងងាយ**ជាប់នៅក្នុងចំណោម ក៏ឲ្យទាហានជ្រែកស្រាវជ្រាវរកសព្វក៏មិនប្រទះ។

និយាយពី**អងក្លួន** កាលប្រើបម្រើទាហាននាំសំបុត្រទៅឲ្យ**តេងងាយ**ហើយ ក៏តាំងតែចាត់ចែងរទេះស្បៀងនឹងលើកទៅតាមសញ្ញា លុះលើកមកដល់ជិតប្រហបភ្នំហ៊ុយសាន់ ទាហានសេះរុលទៅប្រាប់ថា **កៀងអ៊ុយ**ដឹងកលឧបាយ ឥឡូវកងទ័ព**តេងងាយ**ដែលលើកមកក៏បរាជ័យនឹង**កៀងអ៊ុយ** តើលោកនឹងគិតប្រការម្ដេចវិញ? ពេលដែលកំពុងតែនិយាយនោះ ទទួល**កៀងអ៊ុយ**លើកទាហានព័ទ្ធចូលមក ពុះទម្លាយរត់តម្រង់ទៅស្រុកហាន់តុង **កៀងអ៊ុយ**ឲ្យលើកទាហានស្កាត់ផ្លូវខាងទៅបន្ទាយ**តេងងាយ** ហើយក៏ស្រូតលើកតាមទៅស្រុកហាន់តុង ឯ**អងក្លួន**លើកទាហានរត់ទៅតាមផ្លូវតូចដល់មាត់ទន្លេមួយអន្លើ ទទួល**កៀងអ៊ុយ**លើកតាមទៅទាន់ ក៏បរពលចូលព័ទ្ធជុំវិញ **អងក្លួន**ឃើញលើសកម្លាំងនឹងតច្បាំងពុំបាន ក៏លោតទឹកស្លាប់

នៅទីនោះ **កៀងអ៊ុយ**ក៏បង្ខំទាហានចូលចាក់កាប់សម្លាប់ទាហាន**អងកួន**ស្លាប់នៅទីនោះទាំងអស់ ហើយក៏លើកចូលស្រុកហាន់តុង។

**តេងងាយ**ក៏នាំទាហានដែលសល់រត់ទៅចូលបន្ទាយភ្នំគីសាន់ ទើបចាត់បម្រើនាំសំបុត្រចូលទៅស្រុកក្រុង ពណ៌នាសេចក្ដីប្ដឹងដល់**សុម៉ាចៀវ**គ្រប់ប្រការ **សុម៉ាចៀវ**ដឹងដំណឹងតាមសំបុត្រហើយក៏ថា **តេងងាយ**មានសេចក្ដីគាប់ប្រសើរក្នុងរាជការច្រើនណាស់ វេលានេះធ្វើការឲ្យធ្លោះការ គួរយើងនឹងសង្គ្រោះលើកទោសចោលទៅចុះ ត្រូវតែជប់លៀងឲ្យធ្វើរាជការតទៅទៀតទើបត្រូវ ហើយ**សុម៉ាចៀវ**ក៏ចាត់ចែងរបស់ទ្រព្យមាសប្រាក់ជាច្រើន ឲ្យនាំទៅឲ្យជាបំណាច់រង្វាន់**តេងងាយ** ហើយបញ្ជូនទាហានប្រាំម៉ឺនទៅជួយថែមទៀត។

ខណៈនោះ ព្រះចៅ**ឡៅសៀន**សោយរាជ្យបាន១៧ឆ្នាំ (ព.ស ៧៨២) ក្នុងខែកត្តិក **កៀងអ៊ុយ**មេទ័ពដែលតាំងនៅស្រុកហាន់តុងនោះ កេណ្ឌទាហានឲ្យធ្វើផ្លូវចៀងតោទាំងកណ្ដាលយប់កណ្ដាលថ្ងៃ ហើយប្រមូលរេហ៍ពលទាំងទ័ពគោកទ័ពទឹកទូកចម្បាំង និងគ្រឿងសាស្ត្រាវុធទុកព្រម ហើយបកសំបុត្រចូលទៅក្រុងសែឈួនទូលព្រះចៅ**ឡៅសៀន**ថា តាំងពីទូលព្រះបង្គំជាខ្ញុំធ្វើសឹកសង្គ្រាមមកក៏យូរហើយនៅមិនទាន់បានសេចក្ដីគាប់ប្រសើរជាមាំមួនសោះ ឥឡូវទូលព្រះព្រះបង្គំជាខ្ញុំឃើញថាទាហានព្រះចៅ**ចូហ្ស៊ីន**នោះ ក៏កាន់តែរៀវរោយអស់ហើយ ទូលព្រះបង្គំជាខ្ញុំនិងទាហានទាំងពួងនឹងសុំអាសាទៅវាយយកនោះឲ្យបាន បើមិនបានទេនឹងសុំថ្វាយជីវិត។

ព្រះចៅ**ឡៅសៀន**បានជ្រាបតាមសំបុត្រដូច្នោះ ក៏គង់ស្ងៀមមិនត្រាស់ថាប្រការម្ដេច **ទៀវចៀវ**ក្រាបទូលថា វេលាយប់មិញទូលព្រះបង្គំជាខ្ញុំពិគ្រោះឃើញផ្កាយប្រចាំស្រុកយើងវិបរិតឫក្សខាងលើមិនល្អសោះ ដែល**កៀងអ៊ុយ**នឹងអាសាលើកទ័ពទៅនោះ ឃើញថាមិនមានជ័យជម្នះទេ សូមព្រះអង្គទ្រង់ឃាត់ហាមសិន។ ព្រះចៅ**ឡៅសៀន**ត្រាស់តបថា ឥឡូវគេមកសុំទទួលអាសាយើងហើយ បើនឹងឃាត់ហាមដូចមិនគួរ ត្រូវតែឲ្យគេទៅចុះ បើក្រោយទៀតឃើញភ្លាំងភ្លាត់ប្រការម្ដេចសឹមយើងឃាត់ហាម។ **ទៀវចៀវ**ក៏ទូលបន្ថែមទទឹងទាស់ដល់បីសា ឃើញថា

ព្រះចៅ**ឡៅសៀន**មិនស្តាប់ពាក្យហើយក៏លាថយទៅ នឹកទោមនស្សតូចចិត្តណាស់ ធ្វើជាឈឺមិនបានមកគិតធ្វើការរាជការឡើយ។

កាល**កៀងអ៊ុយ**បកសំបុត្រហើយ ក៏ចេះតែកេណ្ឌប្រមូលពលទាហាននឹងលើកកងទ័ពទៅ ទើបប្រឹក្សានឹង**លៀវហ៊្វ**ថា យើងនឹងទៅវាយស្រុករុយកុកដែលជាស្រុកធំនោះ តើយើងនឹងលើកទៅវាយយកស្រុកណាជាមុនទើបស្រួល? **លៀវហ៊្វ**ថា តាំងពីលោកបានធ្វើការសឹកសង្គ្រាមមកនោះក៏ច្រើនឆ្នាំមកហើយ អស់រេហ៍ពលនិងរាស្ត្រមិនមានសេចក្តីសប្បាយសោះ ឯ**តេងងាយ**ដែលនៅស្រុករុយកុកនោះ គេក៏មានថ្វីដៃនិងសតិបញ្ញាច្រើន គ្មាននរណាតទល់បានទេ ដែលលោកនឹងលើកទៅធ្វើការគ្រានេះ ខ្ញុំបាទដូចមិនដឹងគិតផងសោះឡើយ។ **កៀងអ៊ុយ**ថា កាលគ្រា**ខុងបេង**នៅជាមហាឧបរាជ បានលើកទ័ពទៅធ្វើការសឹកនៅទីភ្នំគីសាន់ដល់ប្រាំមួយលើក ទាល់តែស្លាប់ក៏ព្រោះឃើញដល់ផ្លូវរាជការ ដូចខ្លួនយើងក៏មានសេចក្តីឧស្សាហ៍ធ្វើការសង្គ្រាមបានដល់ប្រាំបីលើកហើយ ព្រោះគិតឃើញថា ខ្លួននៅជាខ្ញុំរាជការផែនដីលោក មិនមែនឃើញដោយលាភយស នូវគ្រឿងសក្ការៈជាប្រយោជន៍ដល់ខ្លួននោះទេ វេលានេះយើងនឹងលើកទ័ពទៅវាយយកស្រុកទៀវចៀងឲ្យបាន បើអ្នកឯងណាមកទទឹងទាស់យើង ៗនឹងសម្លាប់អ្នកនោះចេញ ហើយក៏ឲ្យ**លៀវហ៊្វ**នៅរក្សាស្រុកហាន់តុង **កៀងអ៊ុយ**ក៏លើកទាហានសាមសិបម៉ឺនតម្រង់ទៅស្រុកទៀវចៀង។

**តេងងាយ** និង**សុម៉ាប៉ង**ដែលតាំងបន្ទាយនៅភ្នំគីសាន់ លុះបម្រើទាហានល្បាតចូលមកប្រាប់ថា **កៀងអ៊ុយ**លើកកងទ័ពទៅលើផ្លូវស្រុកទៀវចៀងហើយ។ **សុម៉ាប៉ង**ឮដូច្នោះក៏និយាយនឹង**តេងងាយ**ថា **កៀងអ៊ុយ**នោះជាជាមនុស្សមានគំនិតគិតច្រើនណាស់ ដែលលើកទ័ពមកគ្រានេះមិនមែននឹងវាយយកស្រុកទៀវចៀងទេ ឃើញថាមុខជាដណ្តើមយកភ្នំគីសាន់វិញជាប្រាកដ។ **តេងងាយ**ថា អ្នកនិយាយនេះមិនត្រូវទេ យើងអាចដឹងថា **កៀងអ៊ុយ**មុខជាទៅវាយយកស្រុកទៀវចៀង ឯ**កៀងអ៊ុយ**នោះធ្លាប់មកច្បាំងនឹងយើងច្រើនគ្រាហើយ រមែងដឹងថាយើងតាំងខ្ជាប់ខ្លួននៅទីនេះ មានស្បៀងអាហារក៏ច្រើន ពលទាហានក៏មានព្រមព្រៀង បានជាមិនអាចមកយកខាងណោះ ឯស្រុកទៀវចៀងនោះស្បៀងអាហារក៏តិចណាស់ ពល

ទាហានក៏ស្លួចស្តើង មុខជានឹងលើកទៅវាយខាងនោះជាមុនប្រាកដ ដោយមានប្រយោជន៍នឹងបានបញ្ចុះបញ្ចូលអ្នកស្រុកកៀងស៊ាផង។

**សុម៉ាប៉ង**ថា បើ**កៀងអ៊ុយ**ទៅធ្វើការដូចប្រសាសន៍ថាដូច្នោះ តើយើងនឹងគិតប្រការម្តេចទៅវិញ? **តេងងាយ**ឆ្លើយថា យើងគិតឧបាយទុកហើយ អ្នកចូរលើកទាហានទៅបង្កប់នៅស្រុកទៀវចៀងចុះ ហើយឲ្យដករំលំទង់ដែលដោតសម្រាប់ស្រុកនោះចេញ ទាំងស្គរ និងត្រែក៏កុំឲ្យវាយកុំផ្លុំ ឲ្យបើកទ្វារស្រុកទុកទាំងបួនទិសចុះ ឯពួកគ្រួសារទាំងឡាយក៏ឲ្យនាំគ្នាចេញទៅនៅក្រៅកំពែងស្រុក បើកាលណាឃើញសត្រូវខ្មាំងលើកមកដល់ហើយ ត្រូវឲ្យនាំគ្នារត់យកតែរួចខ្លួនទៅចុះ ខ្មាំងក៏នឹងសម្គាល់ថាមានតែស្រុកទទេគ្មានមនុស្សនៅ គង់នឹងលើកទ័ពស្រចូលទៅព្រមគ្នា រួចត្រូវឲ្យអ្នកឯងវាយត្រឡប់ចូលមក សត្រូវមិនដឹងខ្លួន យើងគង់នឹងបានជ័យជម្នះជាប្រាកដ ឯខ្លួនយើងៗនឹងលើកទៅតាំងស្កាត់នៅស្រុកហៅហោ តើអ្នកនឹងយល់ឃើញប្រការម្តេច? **សុម៉ាប៉ង**ក៏យល់ឃើញត្រូវផង លុះប្រឹក្សាឃើញព្រមគ្នាដូច្នេះហើយ ទើបចាត់ឲ្យ**ស៊ូប៉ៅ**នាំទាហាននៅរក្សាភ្នំគីសាន់ ទាំងពីរនាយក៏លើកទ័ពទៅចាត់ការតាមប្រឹក្សាគ្នានោះគ្រប់ប្រការ។

ឯ**ហែហ៊្វប៉ា**ជានាយទ័ពមុខ**កៀងអ៊ុយ** លុះលើកទាហានទៅដល់ស្រុកទៀវចៀងក្រឡេកទៅឃើញចំហទ្វារស្ងាត់ឥតមនុស្សម្នា ទាំងទង់ជ័យលើសើនបន្ទាយក៏គ្មាន មានចិត្តប្លែកណាស់ មិនអាចនឹងរូតរះលើកចូលទៅ ទើបប្រឹក្សានឹងទាហានទាំងពួង នាយទាហានទាំងពួងឆ្លើយថា អស់យើងខ្ញុំយល់ឃើញថាមិនមែនជាកលឧបាយអ្វីទេ ដែលនៅស្រុកទទេដូច្នេះ ព្រោះវាដឹងថាយើងលើកទ័ពមក អ្នកស្រុកមិនអាចប៉ានតស៊ូនឹងយើង បានជានាំគ្នារត់ទៅ **ហែហ៊្វប៉ា**ឮអស់នាយទាហានថាដូច្នោះ ក៏ក្រឡេកទៅខាងក្រោយស្រុកឃើញគ្រប់គ្រួអ្នកស្រុកប្រជុំគ្នានៅខ្មៅខ្លួលជាច្រើន ទើបបំផាយសេះតម្រង់ទៅមើល។

ខណៈនោះ គ្រួសារអ្នកស្រុកឃើញ**ហែហ៊្វប៉ា**បំផាយសេះត្រង់ទៅ ក៏ភ័យណាស់នាំគ្នារត់ព្រាត់ព្រាយទៅតាមផ្លូវទិសខាងលិច តាមពាក្យ**សុម៉ាប៉ង**បង្គាប់ **ហែហ៊្វប៉ា**ឃើញគ្រួសាររត់ទៅដូច្នោះ ក៏សម្គាល់ថាអ្នកស្រុកចោលទីកន្លែងអស់

ហើយ មានអំណរណាស់ មិនបានដឹងថាកលឧបាយអ្វីសោះ នាំទាហានចូលទៅក្នុងស្រុកនោះ **សុម៉ាប៉ង**តាំងបង្កប់នៅក្នុងស្រុក លុះឃើញសត្រូវកន្លងចូលទៅដល់ទ្វារស្រុកហើយបានចំណាប់ពេញទី ក៏ឱ្យទាហានអុចផាវសញ្ញាស្រែកហ៊ោ ហើយលើកទង់ជ័យឡើងគ្រប់ទិសព្រមគ្នា **ហែហ្ស៊ូប៉ា**ឃើញដូច្នោះក៏ភ័យណាស់ នាំទាហានចេញទៅដល់ជើងកំពែងជាន់ក្រៅ ពួកទាហានក្នុងក៏បាញ់ធ្នូចម្រុះចោលដុំថ្មពីលើទៅត្រូវ**ហែហ្ស៊ូប៉ា**និងទាហានទាំងប្រាំរយស្លាប់នៅទីនោះទាំងអស់។

**សុម៉ាប៉ង**មានជ័យជម្នះហើយ ក៏លើកទាហានចេញទៅក្រៅស្រុក ទទួល**កៀងអ៊ុយ**លើកទ័ពហ្លួងតាម**ហែហ្ស៊ូប៉ា**ទៅដល់ប្រទះគ្នានឹង**សុម៉ាប៉ង** ក៏តាំងបរពលចូលប្រយុទ្ធគ្នា **សុម៉ាប៉ង**តស៊ូមិនបានក៏ថយទ័ពត្រឡប់ចូលក្នុងស្រុកហើយបិទទ្វារជាមាំមួន **កៀងអ៊ុយ**បានចំណាប់ក៏ដេញដិតប្រកិតតាមទៅដល់ជើងកំពែង ហើយព័ទ្ធទុក ក្រឡេកឃើញ**ហែហ្ស៊ូប៉ា**និងទាហានប្រាំរយស្លាប់គរលើគ្នាក៏នឹកខឹងណាស់ កំជាប់ទាហានឱ្យព័ទ្ធមាំមួន។

ឯ**តេងងាយ**ដែលតាំងកងទ័ពនៅស្រុកហៅហោ លុះដឹងថា**កៀងអ៊ុយ**លើកទ័ពចូលទៅព័ទ្ធកំពែងស្រុកទៀវចៀងទុកដូច្នោះ លុះពេលយប់ប្រហែលយាមមួយប្លាយ **តេងងាយ**ក៏លើកទ័ពទៅជួយ**សុម៉ាប៉ង** ៗដែលនៅខាងក្នុង លុះឃើញ**តេងងាយ**លើកទ័ពទៅដល់ ក៏ឱ្យទាហានស្រែកហ៊ោលើកចេញមកវាយប្រសព្វទាំងខាងក្នុងខាងក្រៅ **កៀងអ៊ុយ**នឹងទ្រាំតពុំបាន ក៏បែកទ័ពថយត្រឡប់ទៅតាំងបន្ទាយផ្លូវ២០០សិន (៨ គ.ម) នោះអស់រេហ៍ពលក៏បង្កើតសេចក្ដីកោតញញើតដល់សត្រូវណាស់ **កៀងអ៊ុយ**យល់ន័យជាទាហានទាំងអស់គ្នាកាន់តែរសាប់រសាយទៅដូច្នោះក៏ប្រកាសថា ឯប្រវេណីធ្វើការសឹកសង្គ្រាមនេះរមែងមានចាញ់មានឈ្នះជាធម្មតា គ្រានេះបើនរណាចេញវាចាថាខ្លាចញញើតសត្រូវ មិនសូវតាំងចិត្តនឹងខំធ្វើរាជការដោយសុចរិតទេ យើងត្រូវប្រហារជីវិត។

ខណៈនោះ**ទៀវអេក**នាយទ័ពនិយាយនឹង**កៀងអ៊ុយ**ថា ឥឡូវខ្ញុំបាទយល់ឃើញថា សត្រូវនឹងលើកមកធ្វើការតនឹងលោកនៅទីនេះអស់ហើយ ឃើញថានៅភ្នំគីសាន់គ្មាននរណានៅរក្សាជាមាំមួនទេ ខ្ញុំបាទនឹងសុំទាហានមួយកងលើកតម្រង់

ទៅភ្នំគីសាន់ សត្រូវអាល័យតែរវល់តដៃនឹងលោក មុខជាខ្ញុំបាទវាយយកបានបន្ទាយទាំងប្រាំបួនវិញ បើបានទាហានជាច្រើនហើយ ខ្ញុំបាទនឹងលើកទៅវាយយកស្រុកទៀងអាន គង់នឹងបាន ដោយ**កៀងអ៊ុយ**យល់ឃើញត្រូវផង ទើបបំបែកទាហានឲ្យ**ទៀវអេក**លើកទៅភ្នំគីសាន់ ឯចំណែក**កៀងអ៊ុយ**នោះក៏លើកទាហានត្រឡប់ទៅច្បាំងនឹង**តេងងាយ** ។ឃើញ**កៀងអ៊ុយ**លើកមកទៀតដូច្នោះ ក៏ចេញតនឹង**កៀងអ៊ុយ**បានដប់ភ្លែងមិនទាន់ចាញ់ឈ្នះគ្នា ទទួលពេលល្ងាចព្រលប់ក៏នាំគ្នាឈប់ចូលបន្ទាយទាំងសងខាង លុះព្រឹកឡើង**កៀងអ៊ុយ**ក៏លើកទៅប្រទល់គ្នានៅមុខបន្ទាយ មិនឃើញ**តេងងាយ**ចេញច្បាំង ក៏ឲ្យទាហានស្រែកជេរទ្រគោះ។

ឯ**តេងងាយ**ក៏ស្ងៀមនៅក្នុងបន្ទាយមិនបានចេញច្បាំងហើយថា ពួកទាហានស្រុកសៃឈ្នួននេះ តែលើកមកធ្វើសង្គ្រាមវេលាណា ក៏ចេះតែចាញ់យើងរាល់គ្រានៅតែមិនទាន់កោតញញើតត្រឡប់មកជេរប្រមាថយើងទៀតដូច្នេះ យើងឃើញថា**ស៊ូប៉ៅ**ដែលនៅរក្សាភ្នំគីសាន់នោះ មានទាហានតិចណាស់ មុខជាសត្រូវនឹងលើកកាត់ទៅវាយយកជាប្រាកដ ទើបហៅ**តេងតុង**ជាបុត្រមកប្រាប់ថា យើងនឹងលើកទៅជួយបន្ទាយភ្នំគីសាន់ហើយ ចៅត្រូវឃុំទាហាននៅរក្សាបន្ទាយនេះ បើសត្រូវនឹងចូលមកធ្វើប្រការម្ដេច ត្រូវនៅស្ងៀម ខំរក្សាខ្លួនក្នុងបន្ទាយ កុំចេញច្បាំងឡើយ។

នោះមានទាហានល្បាតទៅប្រាប់**កៀងអ៊ុយ**ថា ឥឡូវ**តេងងាយ**លើកទ័ពចេញពីបន្ទាយហើយ ប្រហែលជាលើកមកវាយយើងជាប្រាកដ **កៀងអ៊ុយ**ថា វេលានេះជាពេលកណ្ដាលយប់ មិនដឹងសត្រូវលើកមកជាឧបាយយ៉ាងណា យើងត្រូវតាំងទ័ពឲ្យនៅហ្មឹងក្នុងបន្ទាយសិន ឯ**តេងងាយ**នោះ លុះលើកទាហានទៅដល់មុខបន្ទាយ**កៀងអ៊ុយ**ហើយ ក៏មិនឃើញ**កៀងអ៊ុយ**ចេញមកច្បាំងតគ្នា ទើបឲ្យទាហានស្រែកហ៊ោសន្ធាប់ឡើងអឹងកងក៏លើកកាត់តម្រង់ទៅភ្នំគីសាន់ លុះវេលាព្រឹក **កៀងអ៊ុយ**ក៏ឲ្យប្រមូលមុខមន្ត្រីមកព្រមគ្នាថា **តេងងាយ**លើកកងទ័ពមកយប់មិញមិនមែនតាំងចិត្តមកច្បាំងនឹងយើងទេ គឺក្លែងធ្វើឲ្យយើងទុកចិត្ត ឥឡូវលើកទៅភ្នំគីសាន់ហើយ យើងនឹងលើកតាមទៅជួយ**ទៀវអេក**ទើបស្រួល ទើបបង្គាប់**ហ៊ូយៀប**ឲ្យនៅរក្សា

បន្ទាយ **កៀងអ៊ុយ**ក៏នាំទាហានបីពាន់ លើកតាមទៅជួយ**ទៀវអេក**ឯបន្ទាយភ្នំគីសាន់។

ឯ**ទៀវអេក**លុះនាំទាហានទៅដល់ភ្នំគីសាន់ហើយ ក៏ចូលវាយបន្ទាយ**ស៊ូប៉ៅ**ជាច្រើនគ្រា ឯ**ស៊ូប៉ៅ**នោះមានតម្រិះរិះគិតតិចជាង**ទៀវអេក** ទាំងទាហានក៏កាន់តែស្រាលស្តើងជិតនឹងខូចបន្ទាយហើយ ដោយថ្វីដៃ**ទៀវអេក** ទទួល**តេងងាយ**លើកទាហានទៅទាន់ ឃើញ**ទៀវអេក**លើកទៅប្រកិតវាយបន្ទាយ**ស៊ូប៉ៅ**នៅនោះ **តេងងាយ**ក៏លើកទាហានចូលចោមវាយ **ទៀវអេក**បែករត់ទៅនៅខាងក្រោយភ្នំ **តេងងាយ**ក៏លើកដិតដាមតាមស្កាត់ផ្លូវទុក ខណៈនោះទទួល**កៀងអ៊ុយ**លើកទ័ពទៅដល់ **ទៀវអេក**ដែលរត់ទៅនៅក្រោយភ្នំនោះ លុះដឹងថា**កៀងអ៊ុយ**លើកតាមទៅក៏មានអំណរណាស់ ទើបឲ្យទាហានស្រែកហ៊ោត្រឡប់វាយខ្ទប់ចេញមក **តេងងាយ**ចាញ់ដៃតស៊ូមិនបាន ក៏បែករត់ទៅចូលបន្ទាយភ្នំគីសាន់ ឯ**កៀងអ៊ុយ**ឃើញ**តេងងាយ**បែកចូលបន្ទាយ ក៏បង្គាប់ទាហានឲ្យញែកចេញជាបួនកង តាំងប្រជិតគ្នាព័ទ្ធបន្ទាយ**តេងងាយ**ទុកជាមាំមួនណាស់។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ៨៤

**ចារឹកឡើងវិញដោយ ៖ ឈុល ជាង**

*(តាំងពីព្រះចៅ**ឡៅសៀន** វង្វេងស្ដាប់ពាក្យ**ហ៊ុយហោ**ខន្ទី លែងចេញនិយាយរាជការ អស់នាហ្មឺនមុខមន្ត្រីដែលល្អក៏ចៀសខ្លួនចេញអស់ ព្រោះរំពឹកស្ដេចពុំស្ដាប់ **ហ៊ុយហោ**ខន្ទីញុះស្ដេច ឱ្យហៅ**កៀងអ៊ុយ**លើកទ័ពត្រឡប់មកវិញ គិតតាំង**ងៀមអ៊ូ**ជាមេទ័ពជំនួស **កៀងអ៊ុយ**តូចចិត្ត លាស្ដេចទៅធ្វើស្រែឯស្រុកឡុងសេ។ ព្រះចៅ**ឡៅសៀន**រឹតតែវង្វេងខ្លាំងនឹងល្បែងពាលា **សុម៉ាចៀវ**ចាត់**ចុងហោយ**ជាមេទ័ព តាំង**តេងងាយ**ជាបាឡាត់ទ័ព លើកទៅវាយស្រុកសែឈួន **កៀងអ៊ុយ**លើកទ័ពទៅជួយ)។*

**ឯព្រះចៅឡៅសៀន**នៅក្នុងស្រុកសែឈួននោះ ចេះតែជឿស្ដាប់ពាក្យ**ហ៊ុយហោ**ខន្ទីជាធំនោះសេពសុរាស្រវឹងជានិច្ចកាលមិនដាច់ វង្វេងដោយស្រីស្នំក្រមការ មិនបានចេញត្រួតត្រារក្សាសេចក្ដីសុខនៃអាណាប្រជានុរាស្ត្រទាសករ នោះអស់នាហ្មឺនមុខមន្ត្រី ដែលមានសតិបញ្ញាធ្លាប់ធ្វើរាជការត្រឹមត្រូវតាមផ្លូវសុចរិតមកពីដើម ក៏សឹងនាំគ្នាទោមនស្សតូចចិត្ត គិតតែដោះខ្លួនចេញរលោះរាល់ថ្ងៃ មានសុទ្ធតែមនុស្សថ្មីដែលចូលទៅប្រចុបប្រចែង**ហ៊ុយហោ**ខន្ទី នោះក៏មាននាទីជានាហ្មឺនមុខមន្ត្រីឡើង។

ឈ្មោះ**ងៀមអ៊ូ**ម្នាក់ធ្វើជានាហ្មឺនធំ ត្រូវអធ្យាស្រ័យ**ហ៊ុយហោ**ខន្ទីគិតថា យើងទើបបានធ្វើជានាហ្មឺនថ្មីមិនទាន់បានមានអ្វីជាគាប់ប្រសើរក្នុងរាជការ ទើបនិយាយនឹង**ហ៊ុយហោ**ថា សូមឱ្យលោកអាណិតមេត្តាខ្ញុំបាទ ជួយទូលសុំព្រះចៅ**ឡៅសៀន**ឱ្យទ្រង់តាំងខ្ញុំបាទធ្វើជាមេទ័ពជំនួស**កៀងអ៊ុយ**ផងចុះ ខ្ញុំបាទនឹងជួយរបស់ទ្រព្យឱ្យលោកពេញចិត្ត។ **ហ៊ុយហោ**ឮដូច្នោះក៏ទទួលពាក្យទើបចូលទៅទូលព្រះចៅ**ឡៅសៀន** តាំងពី**កៀងអ៊ុយ**អាសាចេញទៅធ្វើការសង្គ្រាមជាច្រើនគ្រា

ណាស់មកហើយ មិនបានជ័យជម្នះឲ្យចម្រើនប្រយោជន៍អ្វីសោះ វេលានេះសូមឲ្យព្រះអង្គហៅខ្លួនឲ្យត្រឡប់ទ័ពមកវិញ សូមទ្រង់តាំង**ងៀមអ៊ូ**ចេញទៅជាមេទ័ពជំនួសវិញ ដើម្បីនឹងបានឲ្យទៅធ្វើការយកជ័យជម្នះឲ្យបាន។ ព្រះចៅ**ឡៅសៀន**បានទ្រង់ព្រះសណ្ដាប់ក៏យល់ឃើញត្រូវ ទើបឲ្យត្រាតម្រាស់ទៅហៅ**កៀងអ៊ុយ**ឲ្យចូលមក វេលានោះ**កៀងអ៊ុយ**កំពុងតែតាំងទ័ពខ្ទប់ព័ទ្ធបន្ទាយភ្នំគីសាន់មួនមាំណាស់ លុះមានព្រះតម្រាស់ឲ្យលើកទ័ពត្រឡប់មកវិញដល់បីសាហើយ ទទឹងមិនបានក៏នាំទាហានទាំងពួងលើកត្រឡប់មកតាមព្រះតម្រាស់ លុះវេលាព្រឹកទាហានល្បាតចូលទៅប្រាប់**តេងងាយ**ថា ឥឡូវ**កៀងអ៊ុយ**ចោលបន្ទាយអស់រត់ទៅហើយ **តេងងាយ**បានឮដូច្នោះក៏គិតថាជាកលឧបាយ**កៀងអ៊ុយ** ទើបមិនបានលើកទ័ពដេញដិតតាម ឯ**កៀងអ៊ុយ**លើកទ័ពទៅដល់ស្រុកហាន់តុងហើយ ក៏ឲ្យពលរេហ៍ឈប់បង្អង់នៅទីនោះ ហើយខ្លួន**កៀងអ៊ុយ**ក៏ចូលទៅក្រុងសេឈ្សួន។

ខណៈនោះ ព្រះចៅ**ឡៅសៀន**បានជ្រាបថា**កៀងអ៊ុយ**មកហើយ ក៏មិនបានស្ដេចយាងចេញនិយាយរាជការ ត្រឹមតែគង់នៅក្នុងព្រះរាជវាំងអស់រយៈ៨០ថ្ងៃ **កៀងអ៊ុយ**យល់ឃើញថាព្រះចៅ**ឡៅសៀន**មិនបានស្ដេចយាងចេញដូច្នោះ ក៏គិតសង្ស័យក្នុងចិត្តណាស់។ លុះថ្ងៃមួយបានទៅជួបនឹង**ខាប់ចេង**ទើបសួរថា យើងចេញទៅធ្វើសង្គ្រាម ហើយព្រះចៅ**ឡៅសៀន**ត្រាស់ឲ្យហៅចូលមកវិញដូច្នេះ អ្នកបានដឹងថាជាមានការអ្វីដែរឬទេ? តើជាការធ្ងន់ឬស្រាលប្រការម្ដេច? **ខាប់ចេង**ថា ឥឡូវនេះ**ហ៊ុយហោ**ខន្ទីចេះតែក្រាបទូលញុះញង់ព្រះចៅ**ឡៅសៀន** បានជាត្រាស់ហៅឲ្យលោកមក គឺប្រាថ្នានឹងចង់ឲ្យ**ងៀមអ៊ូ**ចេញទៅធ្វើមេទ័ពជំនួសលោកវិញ។ ឯ**កៀងអ៊ុយ**បានឮដូច្នោះក៏មានសេចក្ដីខឹងណាស់ថា បើដូច្នោះយើងត្រូវតែគិតសម្លាប់អា**ហ៊ុយហោ**នោះចេញឲ្យបាន។ **ខាប់ចេង**ឮដូច្នោះក៏និយាយឃាត់ហាមថា ព្រះចៅ**ឡៅសៀន**តាំងលោកឲ្យធ្វើមេទ័ពធំដល់ប៉ុណ្ណោះហើយ ហើយលោកមកធ្វើចិត្តស្រាលរហ័សដូច្នេះ គិតសម្លាប់**ហ៊ុយហោ**នោះ បើជ្រាបដឹងដល់ព្រះចៅ**ឡៅសៀន**ហើយ មុខជានឹងទ្រង់ព្រះក្រោធចុះអាជ្ញាដល់លោក ៗក៏នឹងបានទទួលនូវសេចក្ដីអប្បយសដល់ខ្ញុំរាជការទាំងពួង។

**កៀងអ៊ុយ**ថា អ្នកមកទទឹងទាស់ឲ្យបានជាសេចក្ដីរំពួកសតិយើងដូច្នេះ ជាការត្រូវណាស់ យើងសុំអរគុណអ្នកច្រើនពេក និយាយហើយក៏បែកគ្នាទៅដោយសព្វខ្លួន។ លុះនៅមកមួយថ្ងៃ **កៀងអ៊ុយ**ដឹងថាព្រះចៅ**ឡៅសៀន**សោយសុរាស្រវឹងជាមួយនឹង**ហ៊ុយហោ**ខន្ទី ក្នុងទីដំណាក់សួន **កៀងអ៊ុយ**ក៏នាំបក្សពួកចូលទៅ ប្រាថ្នានឹងចាប់**ហ៊ុយហោ**សម្លាប់ចេញ ឯ**ហ៊ុយហោ**នោះលុះឃើញ**កៀងអ៊ុយ**នាំទាហានដើរចូលទៅពីចម្ងាយ ក៏ឲ្យគិតខ្លាចណាស់ ក្រោកដោះវេះចេញទៅអែបទៅខាងភ្នំដែលធ្វើទុកក្នុងសួន **កៀងអ៊ុយ**លុះចូលទៅដល់ព្រះចៅ**ឡៅសៀន**ក្រាបបង្គំហើយយំទូលថា គ្រានេះទូលព្រះបង្គំជាខ្ញុំចេញទៅធ្វើការសង្គ្រាមនៅភ្នំគីសាន់ ជិតហៀបនឹងបានជ័យជម្នះហើយ ហេតុម្ដេចបានជាព្រះអង្គមានព្រះតម្រាស់ឲ្យទៅហៅទូលព្រះបង្គំជាខ្ញុំឲ្យចូលមក ដែលព្រះអង្គទ្រង់ហៅដូច្នេះជាច្រើនដងហើយ តើព្រះអង្គធ្វើនេះដោយប្រការម្ដេច? ព្រះចៅ**ឡៅសៀន**ទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ទាល់ព្រះទ័យមិនតបឆ្លើយថាអ្វីសោះ **កៀងអ៊ុយ**ក៏ក្រាបទូលថា ព្រះអង្គមកទ្រង់ជឿស្ដាប់ពាក្យអា**ហ៊ុយហោ**ខន្ទី វាគិតការទ្រើសទ្រនង់អាងព្រោះព្រះអង្គទ្រង់រាប់អាន ដែលព្រះអង្គទ្រង់គិតដូច្នេះ គង់ដូចគ្រាព្រះចៅ**ឡេនតេ** កាលមានខន្ទីដប់នាក់នោះមិនខាន សូមព្រះអង្គទ្រង់កម្ចាត់អា**ហ៊ុយហោ**ចេញឲ្យឆាប់ ទើបស្រុកសែឈួននឹងបាននៅឋិតថេរជាសុខ ឯខាងស្រុកវុយកុកក៏គង់នឹងបានដោយងាយ។

ព្រះចៅ**ឡៅសៀន**ត្រាស់ថា អា**ហ៊ុយហោ**នោះ វាគ្រាន់តែជាខន្ទីបម្រើបម្រាស់យើងនៅខាងក្នុង អ្នកមកថាវាទ្រើសទ្រង់អង់អាចនឹងអ្វីនោះ យើងមិនឃើញផងសោះ អ្នកថាមិនត្រូវទេ! កាលគ្រា**តាំងអ៊ុន**មានសេចក្ដីឫស្យាពោលទោសវានោះ យើងក៏ទាស់ចិត្តណាស់ម្ដងទៅហើយ ឥឡូវម្ដេចហើយអ្នកមកថាទៀតដូច្នេះ? យើងមិនជឿស្ដាប់អ្នកទេ។ **កៀងអ៊ុយ**ឮព្រះក្រសែដូច្នេះក៏ឲ្យនឹកតូចចិត្តខ្លាំងណាស់ ក្រាបក្បាលចុះទៅទង្គិចនឹងផែនដីហើយថា ដែលព្រះអង្គមិនទ្រង់ស្ដាប់ពាក្យទូលព្រះបង្គំជាខ្ញុំហើយក៏វាហីទៅចុះ តែឃើញថា ការអន្តរាយមុខជានឹងមានមកដល់ព្រះអង្គជាប្រាកដពុំខាន។ ព្រះចៅ**ឡៅសៀន**ត្រាស់ថា ប្រវេណីមនុស្សទាំងពួងនេះបើស្រឡាញ់គ្នាហើយក៏សរសើរថាល្អ បើស្អប់ហើយក៏ថាអាក្រក់ ដែលអ្នក

មកគិតឥឡូវអា**ហ៊ុយហោ**នេះ តើនឹងប្រាថ្នាអ្វី? ត្រាស់ហើយក៏បក់ដៃហៅ**ហ៊ុយហោ**ឲ្យចូលមកគំនាប់**កៀងអ៊ុយ**។

ខណៈនោះ **ហ៊ុយហោ**ក៏ចូលមកក្រាបសំពះ**កៀងអ៊ុយ**ហើយយំថា ខ្លួនខ្ញុំបាទនេះគ្រាន់តែជាមនុស្សបម្រើបម្រាស់ព្រះករុណាខាងក្នុង មិនបានអង់អាចកន្លងទៅនិយាយរាជការអ្វីក៏ទេ សូមប្រសាសន៍ចូរប្រោសអនុគ្រោះ កុំគប្បីជឿស្តាប់ពាក្យមនុស្សនាំញុះញង់ឡើយ គឺជីវិតខ្ញុំបាទនេះសូមផ្ញើលើព្រះតេជព្រះគុណ។ ថាហើយក៏ឱនមុខចុះ ហើយយំនៅក្រាបទីនោះ **កៀងអ៊ុយ**លុះឃើញ**ហ៊ុយហោ**យំនិយាយសាទោសខ្លួនដូច្នោះក៏អន់ខឹង ទើបបង្គំលាព្រះចៅ**ឡៅសៀន**ចេញមកវិញ ទៅពណ៌នាសេចក្តីឲ្យ**ខាប់ចេង**ស្តាប់តាមតម្រាស់ព្រះចៅ**ឡៅសៀន**គ្រប់ប្រការ។

**ខាប់ចេង**ថា កាលពីដើមខ្ញុំបាទទទឹងទាស់លោកហើយ លោកមិនព្រមស្តាប់ពាក្យខ្ញុំរំឭកបានជាកើតហេតុដូច្នេះ ខ្ញុំឃើញថា ខ្លួនលោកមុខជាមិនផុតពីសេចក្តីអន្តរាយជាប្រាកដ លោកចូរប្រញាប់ប្រែផ្លាស់រវាំងខ្លួនចុះ **កៀងអ៊ុយ**ភ័យណាស់ទើបនិយាយថា អ្នកបានហាមរំឭកខ្ញុំ ៗមិនព្រមស្តាប់អ្នកក៏ឃើញថាខុសទៅហើយ អ្នកនឹងជួយរិះគិតខ្ញុំយ៉ាងម្តេចឲ្យរួចពីភ័យនេះ? **ខាប់ចេង**ថា ដែលលោកនឹងនៅក្នុងស្រុកសៃឈួន មុខជាមិនរួចពីភ័យអន្តរាយទេ លោកចូរទូលលាព្រះចៅ**ឡៅសៀន**ទៅនៅតាំងក្នុងតំបន់ឡុងសេចុះ នឹងរួចពីភ័យអន្តរាយ ថាបើដល់រដូវធ្វើស្រែស្រូវភោជន៍សាលីចេញក្តួរវេលាណា ក៏នឹងបានប្រាស្រ័យជាកម្លាំងដល់ទាហានទាំងពួងម្យ៉ាងទៀតក៏នឹងបានគិតធ្វើការចម្បាំងនឹងស្រុកវុយកុក លោកក៏មានអាជ្ញាសិទ្ធិជាតិហើយនឹងការពារអន្តរាយបាន។ **កៀងអ៊ុយ**ថា អ្នកនិយាយនេះជាគុណធ្ងន់ណាស់គួរនឹងចារឹកទុកក្នុងផែនមាស ថាហើយក៏លា**ខាប់ចេង**ទៅ។ លុះវេលាព្រឹក**កៀងអ៊ុយ**ក៏ចូលទៅថ្វាយបង្គំគាល់ព្រះចៅ**ឡៅសៀន**ហើយទូលថា តាំងពីទូលព្រះបង្គំជាខ្ញុំចេញទៅធ្វើការសង្គ្រាមរៀងមកក៏យូរណាស់ហើយ ទាហានទាំងពួងក៏កាន់តែនឿយហត់ណាស់ ទូលព្រះបង្គំជាខ្ញុំនឹងសុំថ្វាយបង្គំលាព្រះអង្គចេញទៅតាំងនៅតំបន់ឡុងសេ នឹងបានធ្វើស្រែជាស្បៀងលៀងទាហាន ហើយក៏នឹងបានហ្វឹក

ហាត់ទាហានឲ្យចំណានក្នុងក្បួនពិជ័យសង្គ្រាមតទៅ ព្រះចៅ**ឡៅសៀន**ក៏យល់ឃើញត្រូវផង ទើបទ្រង់អនុញ្ញាតតាមតែគំនិតប្រាជ្ញារបស់អ្នកគិតចុះ។

**កៀងអ៊ុយ**ទទួលព្រះតម្រាស់ហើយ ក៏ថ្វាយបង្គំលាចេញទៅស្រុកហាន់តុង ទើបឲ្យហៅនាហ្មឺនមុខមន្ត្រីនិងនាយទាហានចូលព្រមគ្នាហើយថា ឥឡូវព្រះចៅ**ឡៅសៀន**ទ្រង់ប្រោសឲ្យយើងលើកពលទៅតាំងនៅតំបន់ឡុងសេ ឲ្យធ្វើស្រែចម្ការ ហាត់ប្រៀនទាហានឲ្យចំណាន ចូរត្រៀមខ្លួនឲ្យព្រមគ្នាហើយយើងនឹងលើកទ័ពទៅ លុះប្រាប់ទាហានទាំងពួងហើយក៏ចាត់ឲ្យ**អៅចេ**ទៅនៅរក្សាស្រុកសៀវសេ ឲ្យ**ចៀវពិន**ទៅនៅរក្សាស្រុកហាន់សៀ ហើយឲ្យ**អៀវស៊ឺ**និង**ឧយៀម**នាំទាហានចេញទៅជាកងល្បាតតាមផ្លូវគ្រប់តំបន់ ឯខ្លួន**កៀងអ៊ុយ**នោះក៏នាំពលប្រាំបីម៉ឺនលើកទៅតំបន់ឡុងសេ។

និយាយពី**តេងងាយ**ដែលតាំងទ័ពនៅតំបន់ភ្នំគីសាន់នោះ លុះដឹងថា**កៀងអ៊ុយ**លើកទ័ពត្រឡប់ទៅតាំងនៅតំបន់ឡុងសេដប់ពីរបន្ទាយ ទើបប្រើទាហានឲ្យទៅគូរជាផែនទីតាមដែល**កៀងអ៊ុយ**តាំងបន្ទាយនៅតំបន់ឡុងសេនោះ ហើយឲ្យស្រូតប្រញាប់នាំទៅឲ្យ**សុម៉ាចៀវ**។ ឯ**សុម៉ាចៀវ**លុះឃើញផែនទីដូច្នោះ ក៏មានសេចក្ដីខឹងណាស់ថា អា**កៀងអ៊ុយ**នេះវាធ្លាប់មកធ្វើការសឹកនឹងយើងរឿយៗ គ្រានេះយើងត្រូវគិតកម្ចាត់វាចេញឲ្យបាន។

ខណៈនោះ **ស៊ុនចោយ**និយាយថា ឯស្រុកសែឈ្នួននោះសព្វថ្ងៃនេះ ព្រះចៅ**ឡៅសៀន**មានចិត្តងងឹតវង្វេងស្រឡាញ់ស្ត្រី និងសេពសុរាជានិច្ចកាល ជឿស្ដាប់ពាក្យសម្ដី**ហ៊ុយហោ**ខន្ទីម្នាក់ នោះអស់នាហ្មឺនមុខមន្ត្រីដែលមានសតិបញ្ញាក្នុងស្រុកសែឈ្នួនទាំងប៉ុន្មាន សឹងមានសេចក្ដីតូចទោមនស្សចិត្ត នាំគ្នាគិតដោះខ្លួនចេញអស់ហើយ ដែល**កៀងអ៊ុយ**ទៅតាំងបន្ទាយនៅតំបន់ឡុងសេ ក៏ប្រាថ្នានឹងឲ្យរួចភ័យន្តរាយ សូមលោកស្រូតប្រញាប់លើកទ័ពទៅវាយយកស្រុកសែឈ្នួនចុះ មុខជានឹងបានដោយងាយ។ **សុម៉ាចៀវ**មានអំណរណាស់អស់សំណើចហើយថា ពាក្យដែលអ្នកនិយាយនេះ យើងក៏បានគិតឃើញត្រូវណាស់ ព្រោះចិត្តរបស់យើងប៉ងប្រាថ្នានឹងទៅវាយយកស្រុកសែឈ្នួនជាយូរមកហើយ។ **ស៊ុនចោយ**ថា ឥឡូវនេះ

សម្លឹងមើលទៅឃើញតែ**តេងងាយ**ប្រកបដោយសេចក្តីត្រិះរិះគិតច្រើន សូមលោកតាំង**តេងងាយ**ជាបាឡាត់ទ័ព តាំង**ចុងហោយ**ជាមេទ័ពឲ្យលើកទៅ មុខជានឹងវាយយកស្រុកសៃឈ្នួនបានហើយ។

**សុម៉ាចៀវ**ក៏យល់ឃើញត្រូវផង ទើបឲ្យហៅ**ចុងហោយ**ចូលទៅនិយាយថា យើងនឹងប្រើអ្នកឲ្យទៅធ្វើមេកងទ័ពធំ នាំរេហ៍ពលទៅវាយយកស្រុកកាំងតាំងតើនឹងបានឬមិនបាន? **ចុងហោយ**ឆ្លើយតបថា ខ្ញុំបាទដឹងថាលោកក្លែងមានប្រសាសន៍ទេ គឺប្រុងនឹងប្រើខ្ញុំបាទឲ្យទៅវាយយកស្រុកសៃឈ្នួនទេ តែក្លែងថា ឲ្យទៅវាយស្រុកកាំងតាំងវិញ។ **សុម៉ាចៀវ**បានឮដូច្នោះក៏អស់សំណើចហើយថា អ្នកនេះកន្លងដឹងចិត្តយើង ឥឡូវយើងនឹងប្រើអ្នកទៅវាយយកស្រុកសៃឈ្នួន តើអ្នកនឹងគិតយ៉ាងម្តេចទើបនឹងវាយយកស្រុកសៃឈ្នួនបាន? **ចុងហោយ**ថា ដែលនឹងគិតវាយស្រុកសៃឈ្នួននោះ ខ្ញុំបាទដឹងទំនងផ្លូវនឹងទៅវាយយកឲ្យដោយងាយ ថាហើយក៏យកផែនទីស្រុកសៃឈ្នួនមកបង្ហាញឲ្យ**សុម៉ាចៀវ**មើល។ **សុម៉ាចៀវ**ឃើញផែនទីហើយថា គំនិតតម្រិះប្រាជ្ញារបស់អ្នកយ៉ាងនេះ សមគួរនឹងបានធ្វើមេកងទ័ពធំតទៅបាន។ បើដូច្នេះ ចូរអ្នកលើកកងទ័ពទៅបញ្ចូលប្រសព្វគ្នានឹង**តេងងាយ** វាយយកស្រុកសៃឈ្នួនចុះ។ **ចុងហោយ**ថា ឯស្រុកសៃឈ្នួននោះជាស្រុកធំ បើនឹងលើកកងទ័ពទៅតាមផ្លូវមួយឃើញថាជាមិនស្រួលទេ ត្រូវតែញែកកងទ័ពទៅឲ្យច្រើនផ្លូវទើបបានវាយយកស្រុកសៃឈ្នួននោះដោយងាយ។

**សុម៉ាចៀវ**ក៏តាំង**ចុងហោយ**ជាទីចេងសៃចុងកុន ប្រែថា ស្តេចប្រាបសឹកទិសបស្ចិម ហើយឲ្យកេណ្ឌទាហានប្រាំមួយមណ្ឌលប្រគល់ឲ្យ**ចុងហោយ** ហើយសរសេរសំបុត្រមួយច្បាប់ទៅដល់**តេងងាយ** តាំងឲ្យធ្វើជាចេងសៃចុងកុនដូចគ្នានឹង**ចុងហោយ** យើយឲ្យកេណ្ឌទាហានស្រុកឡុងសេមកបញ្ចូលនឹងកងទ័ព**ចុងហោយ**វាយយកស្រុកសៃឈ្នួនឲ្យបាន។ លុះ**ចុងហោយ**ទទួលត្រាតាំង ហើយក៏គំនាប់លា**សុម៉ាចៀវ**ចេញទៅ ហើយបង្គាប់ឲ្យទាហានប្រាំមួយមណ្ឌលលើកចេញទៅព្រមគ្នាដល់ស្រុកកេងជីវ និងស្រុកឡាប់ជីវ ដែលនៅប្របឆ្នេរសមុទ្រនោះ ឲ្យស្រួត

ប្រញាប់តទូកចម្បាំងទុកឲ្យព្រម ឲ្យផ្សាយកិត្តិសព្ទឲ្យល្បីឮទៅថា នឹងលើកទៅវាយយកស្រុកកាំងតាំងវិញ។

**សុម៉ាចៀវ**នោះ លុះបានឮ**ចុងហោយ**ឲ្យទាហានទៅតទូកចម្បាំងនៅឆ្នេរសមុទ្រដូច្នោះក៏ឲ្យហៅខ្លួន**ចុងហោយ**ទៅសួរថា យើងគ្រាន់តែប្រើអ្នកឲ្យទៅវាយស្រុកសៃឈ្នួនគឺជាផ្លូវគោកទេ ហេតុម្ដេចបានជាអ្នកឲ្យទាហានទៅតទូកចម្បាំងវិញដូច្នោះ? **ចុងហោយ**ថា ដែលនឹងទៅវាយយកស្រុកសៃឈ្នួនគ្រានេះ ខ្ញុំបាទយល់ឃើញថា ស្រុកកាំងតាំងមុខជានឹងលើកកងទ័ពមកជួយជាប្រាកដ ហេតុនេះបានជាខ្ញុំបាទឲ្យតទូកចម្បាំង ប្រាថ្នានឹងឲ្យកិត្តិសព្ទល្បីឮទៅដល់ស្រុកកាំងតាំង ថាយើងនឹងលើកទ័ពទៅវាយស្រុកកាំងតាំងវិញ ពួកស្រុកកាំងតាំងនឹងប្រុងប្រៀបរៀបកងទ័ពនៅប្រចាំការ មិនបានលើកទៅជួយស្រុកសៃឈ្នួនវិញឡើយ បើយើងនឹងលើកទៅវាយស្រុកសៃឈ្នួនហើយ គង់នឹងបានដោយងាយ បើស្រុកសៃឈ្នួនបែកទម្លាយវេលាណា ទើបខ្ញុំបាទវិលទៅយកទូកចម្បាំងដែលធ្វើទុកនោះ លើកទៅវាយយកស្រុកកាំងតាំងទៀត។ **សុម៉ាចៀវ**ឮ**ចុងហោយ**និយាយដូច្នោះ ក៏មានអំណរណាស់ថា អ្នកគិតការទាំងនេះយើងពេញចិត្តណាស់ លុះដល់ថ្ងៃកំណត់ឫក្ស **ចុងហោយ**ក៏គំនាប់លា**សុម៉ាចៀវ**លើកទ័ពទៅ។

ឯ**សៀវខា**ជានាហ្មឺនធំម្នាក់ កាលឃើញ**ចុងហោយ**លើកទ័ពចេញទៅហើយ ក៏ចូលទៅនិយាយជម្រាប**សុម៉ាចៀវ**ថា ប្រសាសន៍ចាត់ប្រើ**ចុងហោយ**ជាមេកងទ័ពធំ ឲ្យលើកទ័ពកាន់អាជ្ញាសិទ្ធិចេញទៅវាយស្រុកសៃឈ្នួនគ្រានេះ ខ្ញុំបាទយល់ឃើញថា **ចុងហោយ**នោះមានចិត្តកំរើបគិតការធំលើសហួសរួចខ្លួនច្រើនណាស់ ខ្ញុំបាទមិនបានពេញចិត្តសោះ។ **សុម៉ាចៀវ**ថា ឯចិត្ត**ចុងហោយ**នោះពីដើមមកយើងធ្លាប់ស្គាល់ប្រាកដ។ **សៀវខា**ថា បើប្រសាសន៍បានជ្រាបចិត្ត**ចុងហោយ**ប្រាកដ ហេតុម្ដេចមិនចាត់មន្ត្រីដែលមានចិត្តស័ត្យសុចរិត ឲ្យចេញទៅធ្វើការជាមួយផង? **សុម៉ាចៀវ**ថា ឯ**ចុងហោយ**នោះប្រកបទៅដោយចិត្តរឹងរូសមុតមាំក្នុងការសង្គ្រាមណាស់ ឃើញថាគ្រានេះមុខជានឹងវាយយកស្រុកសៃឈ្នួនបានជាប្រាកដ បើប្រសិនជាយើងនឹងឲ្យមានមន្ត្រីម្នាក់ទៅកាន់កាប់ជាមួយផង មុខជា**ចុងហោយ**មិនលែងតូច

ចិត្ត នឹងធ្វើការសង្គ្រាមមិនពេញដៃ បើវាយបានស្រុកសែឈ្នួនហើយ ពួកទាហាន ទាំងពួងដែលទៅផងនោះ សុទ្ធតែជាពួកស្រុកយើង ម្ដេចក៏គង់មានខ្លះ នឹងចង់យក សេចក្ដីគាប់ប្រសើរ ហើយនឹងចង់វិលមករកភរិយាបុត្រពុំខាន ទោះបី**ចុងហោយ** នឹងប្រែចិត្តក្បត់ដល់យើង ក៏ឃើញថាពួកទាហានទាំងអស់នោះមិនមែនចូលដៃផង ទេ អ្នកកុំវិតក្កព្រួយឡើយ ហើយកំជាប់ថាពាក្យដែលយើងនិយាយនេះ កុំឲ្យអ្នកនាំ ទៅនិយាយឲ្យបែកការណ៍ឲ្យនរណាដឹងឮឡើយ។

ឯ**ចុងហោយ**លើកទ័ពទៅឈប់កណ្ដាលផ្លូវ ហើយហៅនាយទាហានជាធំ៨០ នាក់ឲ្យចូលទៅប្រជុំព្រមគ្នា ហើយថា វេលានេះយើងលើកទ័ពមកនឹងទៅវាយស្រុក សែឈ្នួន យើងត្រូវចាត់ទ័ពមួយកងមុខសម្រាប់នាំផ្លូវ បើប្រទះភ្នំនៅទទឹងពីមុខ ត្រូវឲ្យពុះទម្លាយភ្នំនោះដើរទៅឲ្យបាន ឬបើប្រទះស្ទឹងទន្លេនៅពីមុខក្ដី ក៏ត្រូវធ្វើ ស្ពានឆ្លងទៅឲ្យបាន កុំឲ្យអស់ទាហានដែលមកធ្វើរណរង្គសង្គ្រាមនេះបានសេចក្ដី លំបាកព្រួយ នរណានឹងអាសាយើងធ្វើដូច្នេះបានខ្លះ? **ខៅងី**ជាបុត្រ**ខៅធូ**ឆ្លើយថា ខ្ញុំបាទនឹងសុំអាសាលោកនាំទាហានចេញទៅជាកងមុខចុះ ទាហានទាំងពួងបានឮ **ខៅងី**ថាដូច្នោះ ក៏ជម្រាប**ចុងហោយ**ថា **ខៅងី**នេះមានថ្វីដៃខ្លាំងពូកែណាស់ សមគួរ ជានាយកងទ័ពមុខបានហើយ។

**ចុងហោយ**និយាយនឹង**ខៅងី**ថា **ខៅធូ**ជាបិតារបស់អ្នកនោះ ក៏ជាទាហានមាន ថ្វីដៃខ្លាំងពូកែណាស់ គ្រានេះត្រូវអ្នកឃុំនាំទាហានប្រាំពាន់ ទៅជានាយកងទ័ពមុខ ទៅជម្រះបង្ក្រាបផ្លូវ ឲ្យទាហានកងទ័ពយើងដើរទៅបានស្រួល អ្នកឧស្សាហ៍ខំធ្វើ រាជការឲ្យបានដូចបិតាអ្នកចុះ បើធ្វើរាជការខ្ជីខ្ជាឲ្យខូចរាជការ យើងនឹងយក ទោសអ្នកតាមអយ្យការសឹក។ **ខៅងី**ក៏ទទួលបង្គាប់តាមពាក្យគ្រប់ប្រការ លុះ **ចុងហោយ**រៀបចាត់ការស្រេចហើយ ទើបសរសេរសំបុត្រមួយច្បាប់ ចាត់បម្រើឲ្យ នាំយកទៅឲ្យ**តេងងាយ** សេចក្ដីថា យើងបានលើកកងទ័ពមកហើយ ឲ្យអ្នកស្រុក លើកទ័ពខាងណោះទៅឯស្រុកហាន់តុងព្រមគ្នាចុះ ហើយត្រូវលើកទៅតាមផ្លូវ ស្រុកសែឈ្នួន។

ចំណែកឯ**តេងងាយ**ក៏លើកទ័ពទៅតាំងនៅស្រុកឡុងសេ លុះបានឃើញសំបុត្រ**សុម៉ាចៀវ**ឲ្យមកដូច្នោះ ក៏ឲ្យ**សុម៉ាប៉ង**លើកទ័ពមួយកងទៅតាំងស្កាត់នៅផ្លូវស្រុកសែកៀង ប្រាថ្នាមិនឲ្យស្រុកនេះលើកទៅជួយស្រុកសែឈ្នួនបាន ហើយឲ្យទាហានទៅហៅ**ជូកាត់ស៊ូ**ចៅហ្វាយស្រុកយ៉ុងជីវ និង**អងកិន**ចៅហ្វាយស្រុកធៀនស៊ុយ **ខាន់ហង**ចៅហ្វាយស្រុកឡុងសេ **អៀវហ៊ូ**ចៅហ្វាយស្រុកគឹមសៀ ទាំងបួនខេត្តនេះឲ្យស្រូតលើកទាហានមកព្រមគ្នាដល់បន្ទាយ ដើម្បីនឹងបានគិតរាជការកេណ្ឌប្រមូលទាហាន។ នោះខេត្តទាំងបួនដែលបានដឹងថា**តេងងាយ**ឲ្យហៅដូច្នោះ ក៏ប្រញាប់កេណ្ឌទាហានលើកចូលទៅតាមបង្គាប់។

មានថ្ងៃមួយវេលាអាធ្រាត្រ **តេងងាយ**ដេកលក់ក្នុងបន្ទាយ យល់សប្តិឃើញថាខ្លួនបានឈរលើកំពូលភ្នំមួយខ្ពស់ ក្រឡេកទៅស្រុកហាន់តុងហើយឡើង។ លុះវេលាព្រឹកឡើងក៏ឲ្យហៅ**សៀវលួន**ចូលទៅ ហើយពណ៌នាអំពីយល់សប្តិនោះឲ្យស្តាប់ **សៀវលួន**ទំនាយថា យល់សប្តិនេះជាមង្គលល្អណាស់ ទៅវាយស្រុកសែឈ្នួនវេលានេះមុខជាបានប្រាកដ តែថាដែលឃើញទឹកពុះហូរចេញពីភ្នំនោះ ឃើញថាគ្រានេះខ្លួនលោកនឹងមិនបានត្រឡប់ទៅស្រុកឡកអៀងវិញទេ។

**តេងងាយ**ឮ**សៀវលួន**ទំនាយសប្តិដូច្នោះ ក៏មានសេចក្តីក្រោធឡើង ផ្ដាក់ទឹកមុខនៅស្ងៀមមិនស្រដីថាអ្វីសោះ ទទួលមានបម្រើនាំសំបុត្រទៅដល់ប្រាប់ថា**ចុងហោយ**ឲ្យស្រូតលើកកងទ័ពទៅព្រមគ្នាឲ្យដល់ស្រុកហាន់តុង **តេងងាយ**ដឹងដូច្នោះ ក៏ចាត់**ជូកាត់ស៊ូ**នាំទាហានដប់ប្រាំពាន់ ទៅតាំងស្កាត់ដើមផ្លូវ**កៀងអ៊ុយ** ទុកមួយអន្លើមិនឲ្យកន្លងចូលទៅស្រុកសែឈ្នួនបាន ហើយឲ្យ**អងកិន**នាំទាហានដប់ប្រាំពាន់ស្រូតលើកទៅវាយទ័ព**កៀងអ៊ុយ**ពីខាងស្តាំ ហើយឲ្យ**ខាន់ហង**នាំទាហានដប់ប្រាំពាន់ជាកងសម្រាប់ជួនវាយទ័ព**កៀងអ៊ុយ**ខ្ទប់ពីខាងក្រោយ លុះចាត់ចែងបែងកងទ័ពដូច្នោះរួចហើយ ខ្លួន**តេងងាយ**ក៏នាំទាហានបីម៉ឺនលើកចេញទៅ។

ឯទាហានកងល្បាតក៏នាំព័ត៏មានទៅប្រាប់**កៀងអ៊ុយ**ថា ឥឡូវកងទ័ពស្រុកវុយកុកលើកមកហើយ **កៀងអ៊ុយ**ដឹងដូច្នោះ ក៏ធ្វើសំបុត្រចាត់បម្រើឲ្យនាំចូលទៅស្រុកសែឈ្នួន សេចក្តីថា វេលានេះមានកងទ័ពស្រុកវុយកុកលើកមកជាទ័ពធំ

ណាស់ សូមឲ្យរាជការខាងក្នុងចាត់**ទៀវអេក**ឲ្យនាំទាហានចេញទៅរក្សាគយដានហែប៉េងកួន ហើយឲ្យចាត់**លៀវហ៊ួ**នាំទាហានទៅតាំងនៅស្ពានអ៊ឹមប៉េងកៀវ កុំឲ្យសត្រូវកន្លងចូលមកបាន មួយទៀត ចូរឲ្យបម្រើកាន់សំបុត្រទៅស្រុកកាំងតាំងឲ្យស្រួតលើកទ័ពមកជួយ។

ក្នុងសម័យនោះ ព្រះចៅ**ឡៅសៀន**មានព្រះទ័យប្រោសប្រាណ**ហ៊ុយហោ**ណាស់ ចេះតែនាំគ្នាសេពសុរាជានិច្ចកាល លែងត្រេកអរនឹងចេញនិយាយរាជការ លុះនាហ្មឺនធំនាំយកសេចក្ដីទៅក្រាបទូល ថ្វាយទាំងសំបុត្រ**កៀងអ៊ុយ**ដែលបកមកនោះថ្វាយទៅផង ព្រះចៅ**ឡៅសៀន**ក៏ហៅ**ហ៊ុយហោ**ចូលទៅប្រឹក្សាថា ឥឡូវនេះ**កៀងអ៊ុយ**បកសំបុត្រមកដល់ថា សត្រូវខ្មាំងខាងស្រុកវុយកុកលើកទ័ពមកធ្វើសង្គ្រាម **កៀងអ៊ុយ**សុំយើងចាត់ការឲ្យទាហានទៅត្រួតត្រារក្សាគយដាន តើអ្នកនឹងយល់ឃើញប្រការម្ដេច? **ហ៊ុយហោ**ទូលថា ដែល**កៀងអ៊ុយ**បកដំណឹងមកជាផ្លូវរាជការយ៉ាងនេះ ដើម្បីប្រាថ្នារកសេចក្ដីគាប់ដាក់ជាប្រយោជន៍ផ្ទាល់ខ្លួនប៉ុណ្ណោះ មិនមែនជាការពិតប្រាកដទេ សូមកុំឲ្យព្រះអង្គទ្រង់ព្រះវិតក្កឡើយ ទូលព្រះបង្គំជាខ្ញុំដឹងច្បាស់ថា មានយាយទាវម្នាក់ឈ្មោះ**ស៊ូប៉ៅ**បញ្ចូលខ្មោចអារក្សពិតប្រាកដណាស់ ទូលព្រះបង្គំជាខ្ញុំនឹងទៅនាំយាយទាវនោះមកបញ្ជាន់សួរល្បងមើល បើវៀចត្រង់ប្រការម្ដេចគង់តែនឹងដឹងបាន។ ព្រះចៅ**ឡៅសៀន**លុះដោយអំពើល្ងង់វង្វេង បានឮដូច្នោះក៏ទ្រង់ព្រះអំណរណាស់ ទើបឲ្យ**ហ៊ុយហោ**ទៅនាំយាយទាវនោះចូលមកក្នុងវាំង។ ព្រះចៅ**ឡៅសៀន**ឃើញយាយទាវមកដល់ ក៏ស្ដេចយាងចេញទៅអុជធូបទៀនគំនាប់យាយទាវទទួលគ្រឿងសក្ការៈសង្វើយក៏រំសាយសក់ រាំភ្លេងគ្របីផ្សេងៗតាមវិស័យដែលធ្លាប់ធ្វើមកពីដើម។ លុះអារក្សមកចូលស៊ប់ហើយក៏និយាយថា មហាឧបរាជ យើងនេះជាខ្មោចអន្ទាស្រុករបស់មហាឧបរាជ ៗឲ្យអញ្ជើញយើងមកដោយមានកិច្ចធុរៈអ្វី? ព្រះចៅ**ឡៅសៀន**ថា ត្បិតវេលានេះមានសំបុត្រគេបកមកថា មានខ្មាំងសត្រូវលើកមកនឹងវាយយកស្រុកយើងហើយ តើដំណឹងនោះជាពិតឬមិនពិតប្រការម្ដេច? យាយទាវប្រាប់ថា ដែលថាសត្រូវខ្មាំងលើកទ័ពមកនោះមិនមែនទេ មហាឧបរាជកុំគិតវិតក្កឡើយ ឯស្រុកទេសរបស់យើងនេះ នៅយឺនយូរជា

សុខឥតភ័យន្តរាយអ្វីទេ យូរទៅស្រុកវុយកុកនឹងបានមកជាចំណុះរបស់មហាឧប-រាជទាំងអស់ ថាដូច្នោះហើយយាយទាវក៏ដួលចុះ អារ័ក្សក៏ចេញពីខ្លួនអស់ទៅ។

ព្រះចៅ**ឡៅសៀន**បានឮយាយទាវថាដូច្នោះ ក៏មានព្រះអំណរណាស់ទើបប្រទានគ្រឿងសម្លៀកបំពាក់តាមសមគួរ ដែលមានសំបុត្រមកនោះក៏មិនជឿស្ដាប់ មិនបានគិតបម្រុងការតទៅឡើយ ចេះតែនាំ**ហ៊ុយហោ**សេពសុរារាល់ពេលមិនឈប់ នោះ**កៀងអ៊ុយ**តាំងតែបកសំបុត្រមករឿយៗ **ហ៊ុយហោ**ក៏បិទលាក់មិនបានយកសេចក្ដីក្រាបបង្គំទូលព្រះចៅ**ឡៅសៀន**ឲ្យជ្រាប។

ឯ**ខៅងី**ដែលឃុំនាំទាហានជាទ័ពមុខ**ចុងហោយ** ក៏ស្រូតលើកទៅដល់គយស្រុកឡាំតេង ហើយនិយាយប្រាប់ទាហានទាំងពួងថា ត្រូវខំចូលវាយគយនេះឲ្យបាន ហើយនឹងបានស្រុកហាន់តុងដោយងាយ អស់ទាហានបានឮ**ខៅងី**ថាដូច្នោះ ក៏នាំគ្នាស្រែកប៉ោចូលវាយគយឡាំតេង។

និយាយពី**ឡស៊ីន**នោះ លុះដឹងថា កងទ័ពស្រុកវុយកុកលើកមកហើយ ក៏បង្ខំកេណ្ឌប្រមូលទាហានឲ្យកាន់ធ្នូទៅតាំងបង្កប់នៅក្បែរប៉ុនកៀរពីមុខគយ លុះ**ខៅងី**លើកទាហានកន្លងចូលមក ពួកទាហានកងបង្កប់ឃើញហើយក៏ដុតផាវជាសញ្ញាឡើង ហើយលើកគ្នាចេញខ្ទប់ប្រសព្វបាញ់ធ្នូចម្រុះចេញទៅ ទាហាន**ខៅងី**មិនទាន់ដឹងខ្លួន ក៏បែកបាក់ទ័ពរត់ខ្ចាត់ខ្ចាយវិលទៅចូលទ័ពធំ ហើយពណ៌នាសេចក្ដីឲ្យ**ចុងហោយ**ស្ដាប់គ្រប់ប្រការ។

**ចុងហោយ**បានឮដូច្នោះក៏មានសេចក្ដីសង្ស័យណាស់ ទើបនាំទាហានសេះមួយពាន់ស្រូតចូលទៅមើល ឯទាហានក្នុងគយឃើញសេះបំផាយចូលទៅត្រង់ក៏បាញ់ធ្នូតម្រង់តទល់ពីមុខ ទាហានសេះក៏ថយលើកត្រឡប់ទៅវិញ **ឡស៊ីន**នៅក្នុងគយឃើញបានចំណាប់ដូច្នោះ ក៏បរពលដេញចេញមកដល់ចុងស្ពានគយ ឯ**ស៊ុនខៃ**ទាហាន**ចុងហោយ**ឃើញពួកគយដេញសម្រុកចេញមកដូច្នោះ ក៏គេចចេញទៅឈរអែបនៅក្បែរផ្លូវ យល់បានចំណាប់ក៏បាញ់ធ្នូទៅត្រូវ**ឡស៊ីន**ធ្លាក់ពីលើសេះស្លាប់ ទាហានពួកគយភ័យជ្រួលច្របល់នាំគ្នាបែករត់ទៅ **ចុងហោយ**ក៏លើកដេញជិតទៅប្រទះនឹងកងទ័ពជូនលើកមកព្រមគ្នា ក៏ចូលទៅវាយស្រុកឡាំតេងបាន **ចុងហោយ**

នោះ លុះចូលទៅក្នុងគយបានព្រមទាំងនាយទ័ពនាយកងមកជួបជុំគ្នា ទើប**ចុងហោយ**និយាយនិង**ខៅងី**ថា ខ្លួនទទួលអាសាយើងថាជានាយកងទ័ពមុខ ហើយទៅធ្វើការឲ្យថ្លោះការដល់សត្រូវខ្លាំង យ៉ាងនេះហាក់ថាបាន**ស៊ុនខៃ**ជួយទប់ទល់បាន ទើបយើងមិនអន្តរាយ ទោសខ្លួនគ្រានេះត្រូវស្លាប់ហើយ ទើប**ចុងហោយ**បង្គាប់ទាហានឲ្យចាប់ខ្លួន**ខៅងី**ទៅកាត់ក្បាលចេញ នោះអស់នាយទ័ពនាយកងជម្រាបសុំទោសថា ត្បិត**ខៅងី**នេះជាបុត្រ**ខៅធូ** បានធ្វើរាជការមានគុណបំណាច់មកច្រើនណាស់ ដែលលោកនឹងឲ្យសម្លាប់**ខៅងី**នេះ យើងខ្ញុំទាំងឡាយនឹងសូមអង្វរលន់តួឲ្យលោកលើកទោសម្តងចុះ។

**ចុងហោយ**ថា ដែលអស់អ្នកមកសុំទោស**ខៅងី**ដែលធ្វើការខុសទុកវិញនោះមិនបានទេ ព្រោះអាជ្ញាសិទ្ធិនឹងខូចទៅ ព្រោះបើមានទាហានឯណានីមួយធ្វើសង្គ្រាម ថ្ងៃមុខហើយល្មើសខុសក៏នឹងយកយឿងយ៉ាងតាមគ្នា ក៏ឲ្យនាំយកខ្លួន**ខៅងី**ទៅកាត់ក្បាលដោតផ្កាល ហើយ**ចុងហោយ**ឲ្យហៅ**ស៊ុនខៃ**មកប្រាប់ថា ក្នុងគ្រានេះខ្លួនអ្នកមានសេចក្តីគាប់ប្រសើរច្រើនណាស់ ហើយក៏ឲ្យសេះនិងក្រឹសដល់**ស៊ុនខៃ**ជាបំណាច់រង្វាន់ថ្វីដៃ ហើយ**ចុងហោយ**ចាត់ឲ្យ**លីជូន**នាំទាហានមួយកងលើកទៅវាយស្រុកកាត់សៀ ចាត់ឲ្យ**ស៊ុនខៃ**ទៅវាយស្រុកហាន់សៀ ខ្លួន**ចុងហោយ**ឯងក៏លើកកងទ័ពតម្រង់ទៅគយហែប៉េងក្ហួន។

ឯ**ហ៊្វយៀម**នាយគយហែប៉េងក្ហួន លុះដឹងដំណឹងថាកងទ័ពលើកមកក៏ប្រឹក្សានឹង**ចៀវស៊ី**ថា គ្រានេះយើងនឹងរិះគិតធ្វើការតស៊ូនឹងសត្រូវយ៉ាងម៉េច ទើបនឹងបានស្រួល? **ចៀវស៊ី**ថា កងទ័ពស្រុករុយកុកលើកមកគ្រានេះធំសន្ធឹកណាស់ ដែលនឹងចេញតច្បាំងនឹងគេមិនបានទេ ត្រូវតែតាំងនៅក្នុងបន្ទាយ។ **ហ៊្វយៀម**ថា ដែលអ្នកថាត្រូវតែតាំងនៅក្នុងបន្ទាយនោះ មុខជាសត្រូវនឹងរុករានលើករំលងទៅវាយស្រុកហាន់សៀ និងស្រុកតុកសៀទាំងពីរស្រុកនេះខូចហើយ ដែលអ្នកគិតដូច្នេះយើងមិនយល់ផងសោះ។ **ចៀវស៊ី**ឮដូច្នោះក៏នៅស្ងៀមមិនតបឆ្លើយថាអ្វី ខណៈកាល**ហ៊្វយៀម** និង**ចៀវស៊ី**និយាយពិគ្រោះគ្នានោះមានទាហានល្បាតចូលទៅប្រាប់ថា ឥឡូវកងទ័ពស្រុករុយកុកវាយទន្ទ្រានមកដល់ក្បែរគយហើយ។

**ហ៊ួយៀម**បានឮដូច្នោះក៏ភ័យណាស់ ទើបនាំ**ចៀវស៊ី**ឡើងទៅនៅលើសើនបន្ទាយ ក្រឡេកឃើញ**ចុងហោយ**ជាមេកងទ័ពធំ ជិះសេះបញ្ឈរយកស៊ៃចង្អុលថា ឲ្យពួកគយប្រញាប់រៀបខ្លួនចេញមកចំណុះចុះចូលយើងចុះ យើងនឹងចិញ្ចឹមរក្សាទុកជាខ្ញុំរាជការបំណាច់រង្វាន់តទៅ បើខំនៅទទឹងរឹងមិនចេញមកតាមស្រួល កាលណាយើងវាយធ្លាយគយនេះហើយ នឹងកាត់ក្បាលទាំងអស់គ្នាមិនឲ្យសល់ **ហ៊ួយៀម**មានសេចក្តីខឹងខ្លាំងណាស់ ទើបឲ្យ**ចៀវស៊ី**នៅក្នុងបន្ទាយគយ ខ្លួន**ហ៊ួយៀម**នោះនាំទាហានបីរយស្រែកហ៊ោដេញវាយទ័ព**ចុងហោយ**ចេញមក ឯ**ចុងហោយ**នេះលុះឃើញពួកគយរត់ដេញចេញមកដូច្នោះ ក៏ឲ្យទាហានទាំងពួងវាយគ្នាចេញជាកងៗក្លែងធ្វើជាបែករត់ **ហ៊ួយៀម**ឃើញដូច្នោះក៏មានអំណរណាស់ ស្រូតលើកទាហានដេញតាមខ្ជាន់ៗ **ចុងហោយ**ឃើញបានចំណាប់ ក៏បោកទង់ឲ្យទាហានចូលចោមខ្ទប់ព្រមគ្នា **ហ៊ួយៀម**មិនអាចនឹងតស៊ូបានក៏ថយចូលបន្ទាយ។

**ចៀវស៊ី**ឃើញ**ហ៊ួយៀម**បែកទ័ពត្រឡប់មកវិញ ក៏ឲ្យបើកទ្វារគយចំហ ហើយស្រែកប្រាប់ទៅ**ហ៊ួយៀម**ថា ឥឡូវយើងចូលខាងសត្រូវហើយ អ្នកកុំត្រឡប់ចូលមកជាមួយនឹងយើងឡើយ **ហ៊ួយៀម**ឃើញ**ចៀវស៊ី**បើកទ្វារគយចំហ ហើយស្រែកប្រាប់មកដូច្នោះក៏ខឹងណាស់ ស្រែកជេរថាអាចោរក្បត់ អាឯងមិនគិតដល់គុណអម្ចាស់ផែនដី អាឯងជាមនុស្សអប្រិយមិនមែនជាជាតិទាហាន ថាហើយក៏ត្រឡប់ទាហានចូលតស៊ូនឹង**ចុងហោយ** លុះឃើញទាហានកាន់តែហត់ហបខ្លាំងណាស់ ក៏ដកដង្ហើមធំហើយថា បើយើងមានជីវិតរស់នៅ យើងក៏ជាខ្ញុំព្រះចៅ**ឡៅសៀន** បើយើងអស់ជីវិតទៅ ក៏សុំនៅកើតជាខ្មោចបិសាចក្នុងផែនដីព្រះចៅ**ឡៅសៀន** លុះស្រែកថាដូច្នោះហើយ ក៏យកលំពែងចាក់កខ្លួនឯងស្លាប់នៅទីនោះ អស់ពួកទាហានឃើញនាយស្លាប់ដូច្នោះ ក៏រត់បែកខ្ចាត់ខ្ចាយទៅអស់ **ចុងហោយ**ក៏បានគយហែប៉េងក្វន ឯ**ចៀវស៊ី**ដែលនៅក្នុងគយ ក៏ចេញទៅគំនាប់សុំចុះចូលនៅនឹង**ចុងហោយ** ។ក៏ឲ្យគ្រឿងសម្លៀកបំពាក់តាមសមគួរគ្រប់គ្នាហើយ ក៏ឈប់សម្រាកទាហាននៅក្នុងគយនោះ លុះដល់ពេលកណ្តាលអាធ្រាត្រស្ងាត់ ស្រាប់តែឮសំឡេងហ៊ោកក្រើកដីទាំងអស់គ្នាក៏ភ័យជ្រួលច្របល់ ឯ**ចុងហោយ**ឃើញទាហាន

ភ័យរចល់ដូច្នោះក៏ចេញទៅ ក្រឡេកមើលទៅទិសខាងជើង ហើយក្រឡេកមើលទៅទិសខាងត្បូង ក៏មិនបានឃើញប្រាកដជាអ្វី **ចុងហោយ**សង្ស័យក្នុងចិត្តណាស់។ លុះព្រឹកឡើង **ចុងហោយ**ជិះសេះនាំទាហានមួយរយចេញទៅត្រួតមើលដល់ជើងភ្នំខាងត្បូងមួយអន្លើ ក្រឡេកមើលទៅលើភ្នំឃើញផង់ធូលីហុយទ្រលោមឡើង បីដូចជាមានកងទ័ពទៅតាំងនៅទីនោះ **ចុងហោយ**ឲ្យគេហៅមេភូមិស្រុកនោះមកដណ្ដឹងសួរថា ទីនេះឈ្មោះអ្វី? មេភូមិប្រាប់ថា ទីនេះឈ្មោះភ្នំតេងកុនសាន់ **ហៃហ៊ួអៀន**លើកកងទ័ពមកច្បាំងពីជាន់មុនស្លាប់នៅទីនេះ **ចុងហោយ**បានឮដូច្នោះក៏នាំកងទ័ពថយចេញទៅវិញ លុះទៅដល់កណ្ដាលផ្លូវក៏បង្កើតជាខ្យល់ព្យុះសង្ឃរាងងឹតជិតស្ដិប់ដូចយប់សន្ធិយា **ចុងហោយ**ម្នីម្នាបំបោលសេះរត់ លុះក្រឡេកមើលទៅក្រោយឃើញសុទ្ធតែទាហានដេញប្រផាប់តាមមកច្រើនណាស់ **ចុងហោយ**នូវអស់ទាហានក៏មានសេចក្ដីស្ញប់ស្ញែងរអែងខ្លាច ចេះតែរត់ទៅដល់គយហៃប៉េងក្ួន **ចុងហោយ**ត្រួតមើលទាហានរបស់ខ្លួនឃើញនៅគ្រប់ទាំងអស់ មិនមានសេចក្ដីអន្តរាយអ្វីសោះ អស់ទាហានទាំងនោះក៏ជម្រាប**ចុងហោយ**ថា ដែលមានទាហានលើកដេញតាមយើងមកអម្បាញ់មិញនោះ មកតាមដីក៏មានខ្លះ មកហោះលើអាកាសក៏មានខ្លះ គ្រាន់តែមកទាន់ហើយក៏បាត់អស់ទៅ គេគ្មានធ្វើអន្តរាយអ្វីដល់អស់យើងខ្ញុំទេ។ **ចុងហោយ**ក៏ហៅ**ចៀវស៊ី**ចូលទៅសួរថា នៅទីភ្នំតេងកុនសាន់នេះ មានសាលទេពារ័ក្សអ្វីនៅទីនេះខ្លះ? **ចៀវស៊ី**ប្រាប់ថា គ្មានសាលទេពារ័ក្សអ្វីទេ មានតែផ្នូរសព**ខុងបេង**បញ្ចុះទុកនៅទីនោះ។

**ចុងហោយ**លុះបានដឹងថា **ខុងបេង**ក្លែងមកលងបន្លាចដូច្នោះ លុះព្រឹកឡើង **ចុងហោយ**ក៏យកគ្រឿងសំណែនទៅគំនាប់សព**ខុងបេង** ហើយត្រឡប់មកវិញ។ លុះវេលាយប់**ចុងហោយ**ដេកលក់ទៅ យល់សប្ដិឃើញមនុស្សម្នាក់ដើរចូលមក មនុស្សនោះរូបរាងធំខ្ពស់ មុខសដូចពណ៌ស័ង្ខ ដៃម្ខាងកាន់ផ្លិត តែងខ្លួនធ្វើភេទជាអាចារ្យ ដើរចូលមកជិត **ចុងហោយ**ក្រោកឡើងគំនាប់ហើយសួរថា អ្នកឈ្មោះអ្វី? មករកខ្ញុំនេះត្រូវការប្រាថ្នាការអ្វី? មនុស្សនោះមិនប្រាប់ឈ្មោះ ថាយើងមកជួបនឹងអ្នកថ្ងៃនេះព្រោះនឹងប្រាប់ឲ្យអ្នកដឹងថា ព្រះចៅ**ឡៅសៀន**អស់បុណ្យហើយ បើអ្នកបាន

ស្រុកសែឈ្នួនហើយ ត្រូវអាណិតផងចុះ កុំសម្លាប់ធ្វើបាបអាណាប្រជានុរាស្ត្រឡើយ។

**ចុងហោយ**បានឮដូច្នោះក៏ភ័យភ្ញាក់ឡើង ដឹងថា**ខុងបេង**មកសួរហើយ ទើបស្រែកប្រកាសប្រាប់ទាហានទាំងពួងថា គ្រានេះខ្លួនយើងវាយយកស្រុកសែឈ្នួនបានហើយ កុំឲ្យទាហានណាទៅធ្វើបាបសម្លាប់អាណាប្រជានុរាស្ត្រក្នុងស្រុកឡើយ បើនរណាហើយមិនស្តាប់ យើងនឹងប្រហារជីវិតអ្នកនោះបង់ ហើយឲ្យយកទង់សមកសរសេរថា យើងជាអ្នកទំនុកបម្រុងអាណាប្រជានុរាស្ត្រទាំងពួងឲ្យនៅជាសុខ ហើយឲ្យយកទៅដោតទុកនៅមុខបន្ទាយ ខណៈនោះពួកអ្នកស្រុកហាន់តុង ស្រុកកាត់សៀ ស្រុកហាន់សៀ លុះបានដឹងថា**ចុងហោយ**ចេញមកគ្រានេះនឹងទំនុកបម្រុងរាស្ត្រឲ្យនៅជាសុខ នោះទាំងអស់គ្នាក៏មានសេចក្តីត្រេកអរ នាំគ្នាមកចំណុះចុះចូលនៅនឹង**ចុងហោយ**ជាច្រើន។

ឯ**កៀងអ៊ុយ**ដែលតាំងនៅស្រុកឡុងសេ លុះដឹងថាកងទ័ពស្រុកវុយកុកលើកមកជិតហើយ ទើបសរសេរសំបុត្រឲ្យបម្រើស្រូតទៅឲ្យ**ទៀវអេក** និង**លៀវហ៊្វ**ថា គ្រានេះសត្រូវលើកទ័ពព័ទ្ធជុំជិតហើយ ឲ្យអ្នកទាំងពីរនាយ ស្រូតលើកទ័ពទៅជួយជាការប្រញាប់ ហើយ**កៀងអ៊ុយ**ត្រៀមទាហានលើកចេញទៅតស៊ូនឹងសត្រូវ។

ឯ**អងកិន** លុះឃើញ**កៀងអ៊ុយ**លើកកងទ័ពចេញមកហើយ ក៏ឡើងសេះជិះទៅមើលខាងមុខទាហាន ហើយស្រែកហៅទៅ**កៀងអ៊ុយ**ថា ទាហានពួកយើងលើកកងទ័ពមកគ្រានេះ២០ផ្លូវ ទាហានប្រហែលមួយរយម៉ឺន ឯស្រុកសែឈ្នួននោះយើងក៏វាយបានហើយ អ្នកចូរស្រូតប្រញាប់មកចំណុះចុះចូលយើងតែម្តងទៅ ដែលមកតាំងប្រុងច្បាំងនឹងយើងនោះមិនស្រួលទេ។

**កៀងអ៊ុយ**បានឮដូច្នោះ ក៏មានសេចក្តីខឹងខ្លាំងណាស់ ទើបឡើងសេះចូលតនឹង**អងកិន** បានប្រមាណប្រាំបួន ឬដប់ភ្លែង **អងកិន**តស៊ូមិនបានក៏ថយរត់ **កៀងអ៊ុយ**ឃើញដូច្នោះក៏បង្ខំទាហានឲ្យដេញជិតតាមទៅ ចម្ងាយផ្លូវប្រហែលមួយរយសិន (៤ គ.ម) **អងកិន**គេចដោះរួចទៅខាងផ្លូវ **តាន់ហាង**បង្កប់ទាហាននៅទីនោះក៏ចេញមកស្កាត់ពីមុខ**កៀងអ៊ុយ** ៗក៏ស្រែកទៅថា ទាហានមានថ្វីដៃយ៉ាងឯងនេះ

នឹងមកតស៊ូនឹងអញមិនបានទេ ថាហើយក៏បរពលចូលត្រង់ទៅច្បាំងនឹង**តាន់ហង** បានប្រមាណដប់ភ្លែង **តាន់ហង**រងនឹង**កៀងអ៊ុយ**មិនបានក៏ថយរត់ទៅ ចម្ងាយផ្លូវប្រហែលមួយរយសិន (៤ គ.ម) **កៀងអ៊ុយ**បានចំណាប់ក៏ដេញដិតតាមទៅ លុះដល់កងទ័ព**តេងងាយ** ៗឃើញដូច្នោះក៏ចេញទៅតដៃនឹង**កៀងអ៊ុយ**បានដប់ប្រាំភ្លែង មិនទាន់ចាញ់ឈ្នះគ្នា។

ឯ**អងកិន** និង**តាន់ហង**ដែលបែកគេចរត់ទៅនោះ ក៏ចូលទៅពួននៅក្បែរផ្លូវ លុះឃើញ**កៀងអ៊ុយ**ចូលតស៊ូនឹង**តេងងាយ** ក៏ឲ្យទាហានស្រែកហ៊ោតាមក្រោយទៅ តាំងព័ទ្ធចោមជុំខ្លួន**កៀងអ៊ុយ** តច្បាំងគ្នាជាជ្រួលច្របល់ **កៀងអ៊ុយ**ឃើញលើសកម្លាំងខ្លាំងណាស់រងទប់ពុំបាន ក៏នាំទាហានពុះទម្លាយរត់ទៅចូលបន្ទាយ តាំងខ្ជាប់ខ្លួនទុក មិនបានចេញតស៊ូប្រាថ្នាចាំកងទ័ពខាងក្រោយនឹងលើកមកជួយ។

មានបម្រើល្បាតសេះនាំដំណឹងមកប្រាប់**កៀងអ៊ុយ**ថា ឥឡូវ**ចុងហោយ**លើកកងទ័ពចូលវាយបន្ទាយហែប៉េងក្វន សម្លាប់**ហ៊្វូយៀម**ស្លាប់ **ចៀវស៊ី**ស្ម័គ្រចូលទៅនៅខាងសត្រូវ ហើយលើកគយហែប៉េងក្វនឲ្យទៅ**ចុងហោយ** ឯស្រុកកាត់សៀ និងស្រុកហាន់សៀនោះ ដឹងថាគយហែប៉េងក្វនបានទៅ**ចុងហោយ**ហើយក៏នាំគ្នាចូលទៅខាងសត្រូវទាំងអស់ **ចុងហោយ**បានទាំងស្រុកហាន់តុងផងហើយ។ **កៀងអ៊ុយ**ឮដូច្នោះក៏រឹតតែតូចចិត្តពេកណាស់ នឹងតាំងនៅទីនោះពុំបាន លុះវេលាយប់**កៀងអ៊ុយ**ក៏លើកទ័ពរត់នឹងទៅស្រុកសែឈ្វន លុះទៅដល់កណ្តាលផ្លូវ ប្រទះនឹងកងទ័ពមួយកងនៅស្កាត់ពីមុខ ឈ្មោះថា**អៀវហ៊្វូ**។ **កៀងអ៊ុយ**នឹងទម្លាយទៅមិនបានក៏មានសេចក្តីខឹងណាស់ បំផាយសេះវាំលំពែងចូលតនឹង**អៀវហ៊្វូ**។ **កៀងអ៊ុយ**និង**អៀវហ៊្វូ** ប្រយុទ្ធគ្នាបានបីភ្លែង។ **អៀវហ៊្វូ** តនឹង**កៀងអ៊ុយ**មិនបានក៏បាក់ទ័ពរត់ទៅ **កៀងអ៊ុយ**បានចំណាប់ក៏បំផាយសេះដេញបាញ់ធ្នូទៅបីដង តែមិនត្រូវ**អៀវហ៊្វូ**។ **កៀងអ៊ុយ**មានសេចក្តីទាល់ចិត្តណាស់ ក៏ចោលធ្នូចេញ វាំលំពែងដេញតាមផ្លូវទៅទៀត ទទួលសេះរអិលភ្លាត់ដួលទៅ **កៀងអ៊ុយ**ក៏ភ្លាត់ធ្លាក់ពីលើសេះ **អៀវហ៊្វូ**ក៏ញាក់សេះត្រឡប់មកលើកលំពែងឡើងនឹងចាក់ ទទួល**កៀងអ៊ុយ**ក្រោកឡើងបានទាត់ផាត់ទាន់ ហើយលើកលំពែងចាក់ត្រូវសេះ**អៀវហ៊្វូ** ៗញាក់សេះរត់ទៅ **កៀងអ៊ុយ**ត្រឡប់ឡើងសេះ

របស់ខ្លួនក៏ដេញ**អៀវហ៊្វ**ទៅទៀត នោះ**តេងងាយ**ដឹងថា**កៀងអ៊ុយ**លើកទ័ពរត់ទៅហើយ ក៏ស្រូតលើកទាហានតាមបន្ទាន់ទៅប្រទះគ្នានៅទីនោះ ក៏ដេញទាហានចូលតនឹង**កៀងអ៊ុយ** ៗឃើញលើសកម្លាំងដែលនឹងតទល់ ក៏រត់ចូលស្រុកសៃឈ្នួនមិនបាន ក៏ញាក់សេះគេចរត់កាត់ច្រូតផ្លូវរត់គិតនឹងទៅវាយយកស្រុកហាន់តុងវិញ លុះទៅដល់កណ្ដាលផ្លូវប្រទះនឹងបម្រើសេះបំផាយមកប្រាប់ថា លោកនឹងទៅផ្លូវនោះមិនបានទេ ព្រោះឃើញ**ជូកាត់ស៊្វ**ចៅហ្វាយស្រុកអេងជីវដែលជានាយកងទ័ពស្រុកវុយកុក តាំងទ័ពស្កាត់នៅស្ពានអ៊ឹមប៉េងកៀវ **កៀងអ៊ុយ**ឮដូច្នោះក៏ដកដង្ហើមធំហើយថា ខាងមុខក៏ស្ទាក់ស្កាត់អស់ ខាងក្រោយក៏លើកទន្ទ្រានពានតាមមកគ្រប់ចន្លោះគ្មានសល់ឡើយ ឱ! ទេវតាអើយ គ្រានេះឃើញថាជាកម្មទេពតាតាមមកបំផ្លាញជីវិតយើងឲ្យវិនាសហើយ។ **បេងស៊ុយ**ឆ្លើយថា ឯ**ជូកាត់ស៊្វ**នោះនៅស្រុកអេងជីវ ឥឡូវចោលស្រុកទុកទីនោះ ខ្លួនគេលើកទាហានមកធ្វើការឯណេះ សុំឲ្យស្រូតច្រូតកាត់ផ្លូវតម្រង់ទៅវាយយកស្រុកអេងជីវឲ្យបានចុះ បើ**ជូកាត់ស៊្វ**ដឹងវានឹងលើកការពារស្រុក យើងនឹងគេចមកលុកយកគយកៀមកោះ ដើម្បីនឹងតាំងរិះគិតវាយយកស្រុកហាន់តុងវិញឲ្យបាន **កៀងអ៊ុយ**ក៏យល់ឃើញត្រូវ ទើបលើកទ័ពត្រឡប់ទៅតាមពាក្យ**បេងស៊ុយ**ថា។

ឯ**ជូកាត់ស៊្វ**នោះ មានបម្រើសេះមកប្រាប់ថា ឥឡូវសត្រូវលើកទ័ពគេចទៅវាយយកស្រុកអេងជីវហើយ **ជូកាត់ស៊្វ**ឮដូច្នោះក៏ភ័យណាស់ ទើបឲ្យទាហាននៅរក្សាគយពីររយនាក់ ហើយក៏លើកទ័ពច្រូតកាត់តម្រង់ទៅស្រុកអេងជីវ។

ឯ**កៀងអ៊ុយ**នោះ លុះលើកទ័ពទៅដល់ផ្លូវប្រមាណបីរយសិន (១២ គ.ម) ក៏គិតថា **ជូកាត់ស៊្វ**នោះមុខជាដឹងថាយើងនឹងលើកទៅវាយស្រុកអេងជីវហើយ គង់នឹងលើកទ័ពច្រូតកាត់ទៅរក្សាស្រុកអេងជីវជាប្រាកដ លុះ**កៀងអ៊ុយ**គិតដូច្នោះហើយ ក៏លើកទាហានច្រូតត្រឡប់ទៅស្ពានអ៊ឹមប៉េងកៀវ ទីបន្ទាយចាស់ **កៀងអ៊ុយ**ឃើញមានទាហានរក្សាបន្ទាយប្រមាណពីររយនាក់ **កៀងអ៊ុយ**ឲ្យទាហានចូលវាយយកបន្ទាយបាន ហើយឲ្យយកភ្លើងដុតបន្ទាយនោះឆេះវិនាសអស់រួចស្រូតលើកទៅតាមផ្លូវកៀមកោះ។

ឯ**ជូកាត់ស៊ូ**ដែលលើកទៅស្រុកអេងជីវនោះ លុះក្រឡេកទៅឃើញភ្លើងឆេះបន្ទាយខាងក្រោយឡើង ក៏ដឹងថាភ្លើងនេះឆេះបន្ទាយរបស់ខ្លួន ចូលចិត្តថាគឺ**កៀងអ៊ុយ**ធ្វើកលបញ្ឆោតដុតបន្ទាយ **ជូកាត់ស៊ូ**មានសេចក្ដីខឹងខ្លាំងណាស់ ក៏លែងគិតនឹងលើកទ័ពទៅស្រុកអេងជីវ ត្រឡប់លើកទ័ពមកគយអ៊ឹមប៉េងកៀវវិញ ស្រាប់តែឃើញភ្លើងឆេះរលើងអស់ ឯខ្លួន**កៀងអ៊ុយ**រត់រួចទៅបាន ក៏មិនបានឲ្យលើកដេញដិតតាម ទើបឲ្យទាហានតាំងបន្ទាយនៅទីនោះទៀត។ **កៀងអ៊ុយ**ក៏លើកទៅគយកៀមកោះ លុះទៅដល់ពាក់កណ្ដាលផ្លូវក៏ប្រទះនឹងកងទ័ព**ទៀវអេក**និង**លៀវហ៊្វ**ទាំងពីរនាយ ក៏មានសេចក្ដីត្រេកអរណាស់ហើយពណ៌នារឿងឲ្យស្ដាប់ថា ឥឡូវសត្រូវស្រុកវុយកុកលើកមកជាច្រើនផ្លូវ វាយយកអាណាខេត្តរបស់យើងបានជាច្រើនតំបន់ហើយ តាំងពីយើងប្ដឹងសំបុត្រចូលទៅក្រាបទូលព្រះចៅ**ឡៅសៀន** ឲ្យកេណ្ឌទាហានលើកកងទ័ពមកជួយ ហេតុម្ដេចទើបមិនឃើញលើកទ័ពមកសោះ? **ទៀវអេក** និង**លៀវហ៊្វ**ឆ្លើយថា ព្រះចៅ**ឡៅសៀន**សព្វថ្ងៃនេះវង្វេងស្មារតីស្រឡាញ់**ហ៊ុយហោ**ណាស់ នាំតែគ្នាសេពសុរាមិនដែលដាច់ មិននាំពារដែលនឹងគិតការរាជការផែនដីនោះ គ្មានសោះឡើយ ដែលខ្ញុំបាទលើកកងទ័ពមកនេះ ព្រោះដឹងថាសត្រូវព័ទ្ធចោមលោកនៅក្នុងចំណោម បានជាខំលើកមកជួយ មិនមែនព្រះចៅ**ឡៅសៀន**ត្រាស់ប្រើឲ្យមកក៏ទេ។

**កៀងអ៊ុយ**បានស្ដាប់ដូច្នោះក៏គាប់ចិត្តណាស់ ទើបនិយាយនឹង**ទៀវអេក, លៀវហ៊្វ**ថា គ្រានេះសត្រូវវាយធ្វើចលាចលដល់ពួកយើងខ្លាំងណាស់ វេលានេះតើយើងនឹងទៅតាំងនៅទីណាទើបស្រួល? **ទៀវអេក**និង**លៀវហ៊្វ**ឆ្លើយថា សុំឲ្យលោកលើកទៅតាំងនៅតំបន់គយកៀមកោះចុះ ខ្ញុំបាទឃើញថាទីនោះមានភូមិឋានស្រួលបួលមួនមាំល្អណាស់ យើងនឹងចាត់ចែងហ្វឹកហាត់ទាហានគ្រប់កងឲ្យស្រួល បើបានឱកាសគ្រាណាជាចំណាប់ហើយ នឹងរិះគិតធ្វើការវាយយកស្រុកហាន់តុងវិញ។ **កៀងអ៊ុយ**យល់ឃើញត្រូវ ទើបលើកទាហានចេញទៅ។

ឯ**តាំងឃ្លួត**នាយគយឃើញ**កៀងអ៊ុយ**លើកទ័ពទៅដល់ មិនដឹងថា**កៀងអ៊ុយ** ក៏ភ័យស្លុតស្លាំងក្នុងវិញ្ញាណ សម្គាល់ថាសត្រូវលើកទ័ពមក ក៏ប្រុងប្រៀបរៀប

ទាហាននឹងចេញច្បាំង មានបម្រើសេះទៅប្រាប់ **កៀងអ៊ុយ**លើកទ័ពមកទេ ក៏មានសេចក្តីត្រេកអរណាស់ ទើបរលះរលាំងចេញទៅទទួលគំនាប់ ហើយអញ្ជើញ **កៀងអ៊ុយ**ចូលទៅក្នុងបន្ទាយ។ **តាំងឃួត**អង្គុយយំហើយថា ឥឡូវព្រះចៅ**ឡៅសៀន** ជាម្ចាស់យើងចេះតែជឿស្តាប់ពាក្យសម្តី**ហ៊ុយហោ** រវល់តែសោយស្រាស្រវឹងជានិច្ច កិច្ចការរាជការផែនដីក៏មិនចេញស្តីត្រួតត្រា ទាល់តែកើតបរាជ័យដល់ម្ល៉េះហើយ មិនដឹងនឹងគិតធ្វើយ៉ាងណាឡើយ។

**កៀងអ៊ុយ**ថា អ្នកកុំព្រួយបារម្ភឡើយ យើងនេះហើយឈ្មោះ**កៀងអ៊ុយ** នៅមានជីវិតមិនស្លាប់ទេ យើងនឹងគិតរិះរេធ្វើការសងសឹក វាយយកស្រុកហាន់តុងវិញឲ្យបាន តែថាពេលនេះយើងត្រូវបញ្ចុះបញ្ចូលប្រមូលពលទាហានឲ្យបានព្រមព្រៀងសិន ហើយតាំងនៅទីនេះ ចាំរិះគិតការតទៅ។ **តាំងឃួត**ថា លោកមានប្រសាសន៍នោះត្រូវណាស់ហើយ តែថាខ្ញុំបាទនៅមានព្រួយគិតទៅដល់ស្រុកសៃឈួនច្រើនណាស់ ព្រោះសត្រូវកាន់តែទន្ទ្រានចូលមកជាសន្ធឹកសន្ធាប់ណាស់ មុខជានឹងលើកទៅធ្វើអន្តរាយជាប្រាកដ។ **កៀងអ៊ុយ**ថា អ្នកបារម្ភព្រួយនេះត្រូវណាស់ តែនៅស្រុកសៃឈួនជាផ្លូវដាច់ស្រយាលឆ្ងាយ ដើរទៅច្រើនកាត់វំលងជ្រោះភ្នំជំរំស្ទឹងអូរជាច្រើនអន្លើ បើសត្រូវនឹងលើកទៅធ្វើអន្តរាយក៏ដោយលំបាក ទោះបីនឹងវាយយកស្រុកសៃឈួនបាន យើងនឹងគិតអានវាយយកបានមកវិញទេ ព្រោះតែស៊ូស្លាប់មិនឲ្យទានមុខនឹងសត្រូវស្រុកវុយកុកឡើយ។ កាលកំពុងនិយាយគ្នានោះ មានបម្រើសេះមកប្រាប់ថា ឥឡូវ**ជូកាត់ស៊ូ**លើកទ័ពតាមមកដល់ចុងគយនេះហើយ។

**កៀងអ៊ុយ**បានឮដូច្នោះ ក៏មានសេចក្តីខឹងខ្លាំងណាស់ នាំពលប្រាំពាន់ចេញទៅទទួលតច្បាំង **ជូកាត់ស៊ូ**ក៏បរពលចូលប្រយុទ្ធគ្នាជាសន្ធឹកសន្ធាប់ ពលទាហានខាង**ជូកាត់ស៊ូ**ស្លាប់វិនាស់ជាច្រើនណាស់ **ជូកាត់ស៊ូ**តស៊ូពុំបាន ក៏បាក់ទ័ពនាំទាហានរត់ត្រឡប់ថយទៅតាំងបន្ទាយឆ្ងាយពីគយនោះប្រហែលពីររយសិន (៨ គ.ម)។ **កៀងអ៊ុយ**មានជ័យជម្នះរើសយកបានគ្រឿងសាស្ត្រាវុធ និងសេះលាជាច្រើនណាស់ គឺលើកទ័ពត្រឡប់ចូលបន្ទាយវិញ។

ឯ**ជូកាត់ស៊ូ**នោះ លុះដឹងថា**ចុងហោយ**លើកពលមកដល់ហើយ ក៏នាំយកសេចក្ដីនោះទៅប្ដឹង**ចុងហោយ**គ្រប់ប្រការ។ **ចុងហោយ**ដឹងហើយក៏ខឹងខ្លាំងណាស់ថា យើងបានកំជាប់នឹងអ្នកឯងឲ្យតាំងស្កាត់ផ្លូវនៅឲ្យជាប់កុំឲ្យ**កៀងអ៊ុយ**រត់រួចតែប៉ុណ្ណោះទេ នឹងបានប្រើឲ្យអ្នកឯងលើកទៅវាយយកគយនៅផ្លូវនោះក៏ទេ ហេតុម្ដេចបានជាអ្នកឯងល្មើសមិននៅតាមបង្គាប់មេទ័ពធំ ហ៊ានចេញទៅធ្វើតាមអំពើចិត្តរបស់ខ្លួនឲ្យខូចខាតពលទាហានដូច្នេះ? មិនត្រូវសោះ! ក៏បង្គាប់ទាហានឲ្យនាំខ្លួន**ជូកាត់ស៊ូ**ទៅសម្លាប់។ វេលានោះ**អ៊ុយកួន**នាយទាហាននិយាយនឹង**ចុងហោយ**ថា ឯ**ជូកាត់ស៊ូ**នេះជាមនុស្សទំនុកទុកចិត្តរបស់**តេងងាយ** ៗរាប់អានស្រឡាញ់ណាស់ បានទាំងពិតទូលស្នើរតែងតាំងឲ្យធ្វើជានាហ្មឺនផង ទោះជាឈ្មោះនេះបានជាប្រព្រឹត្តខុសយ៉ាងម្ដេចៗក្ដី លោកនឹងសម្លាប់តាមអំពើចិត្តតែម្ដងពុំបានទេ គួរតែបកសំបុត្រឲ្យដល់ទៅ**តេងងាយ**សិន បើលោកសម្រេចសេចក្ដីជាមុនហើយ កាលណាដឹងទៅដល់**តេងងាយ** ៗគង់នឹងតូចចិត្តថាលោកមើលងាយនឹងមិនខុសចិត្តគ្នាទេឬ?

**ចុងហោយ**ថា ខ្លួនយើងជាមេកងទ័ពធំ ព្រះចៅ**ចូហ៊្វួន**បានព្រះរាជទានអាជ្ញាសិទ្ធិឲ្យយើងជាស្រេច ទាំង**សុម៉ាចៀវ**មហាឧបរាជក៏បានចាត់ការបង្គាប់មកគ្រប់ប្រការ កុំថាតែលោកនឹងសម្លាប់**ជូកាត់ស៊ូ**នេះឡើយ ទោះទាំងខ្លួន**តេងងាយ**នោះហើយបើធ្វើខុសពីបង្គាប់បញ្ជាយើងក៏ត្រូវសម្លាប់បានដូចគ្នា។ នោះអស់នាយទាហានបានឮដូច្នោះ ក៏នាំគ្នាអង្វរលន់តួសុំទោសប**ជូកាត់ស៊ូ**ទុក។ **ចុងហោយ**ឃើញនាយទ័ពនាយកងព្រួតគ្នាសុំទោសណាស់ ក៏ព្រមលើកទោសមិនសម្លាប់ ទើបបង្គាប់ឲ្យដាក់ក្ដី**ជូកាត់ស៊ូ** បញ្ជូនខ្លួនទៅឲ្យ**សុម៉ាចៀវ**មហាឧបរាជឯស្រុកឡុកអៀង។

ខណៈនោះអស់ពួកទាហានបានដឹងថា **ចុងហោយ**ឲ្យដាក់ក្ដីធ្វើទោស**ជូកាត់ស៊ូ**ដូច្នោះ ក៏នាំដំណឹងទៅពឹងដល់**តេងងាយ** ៗដឹងហើយក៏ខឹងណាស់ថា **ចុងហោយ**និងយើងក៏ជាមេទ័ពមានយសកម្ពស់គ្នា គេនឹងមានគុណបំណាច់យ៉ាងណាក៏ទេដែរ។ ឯខ្លួនយើងបានចេញមកធ្វើរាជការរងទុក្ខលំបាកនៅរក្សាគយដាន មានសេចក្ដីគាប់ប្រសើរលើសជាង**ចុងហោយ**ទៅទៀត **ចុងហោយ**បានធ្វើជាមេទ័ពនេះទើបតែមួយគ្រា ហើយតាំងខ្លួនជាធំលើស មានចិត្តកំរើបខ្លាំង ធ្វើរាជការមិនបានគិតទុកមុខ

យើងខ្លះសោះឡើយ។ **តេងតុង**ជាបុត្រដឹងថាបិតាខឹងខ្លាំងណាស់ ក៏ចូលទៅហាមរំឭកថា ការភ្លាត់ភ្លាំងតែប៉ុណ្ណោះគួរនឹងអត់ឱនទៅខ្លះចុះ ដើម្បីនឹងយករាជការសិន បើបិតាមិនរំលត់កំហឹងព្យាបាទក្នុងពេលសង្គ្រាមទេ ក៏នឹងខូចរាជការទៅ បើសម្រេចរាជការសឹកកាលណា សឹមនិយាយគ្នាតាមការចុះ។

**តេងងាយ**បានស្ដាប់បុត្រហាមរំឭកដូច្នោះក៏យល់ឃើញត្រូវ ទើបនាំទាហានប្រមាណដប់បួន ដប់ប្រាំនាក់ឡើងសេះទៅដល់បន្ទាយ**ចុងហោយ** ៗដឹងថាជាទៅមកតាមប្រក្រតី ក៏ចេញទៅទទួលតាមប្រវេណី ហើយចូលទៅក្នុងបន្ទាយ ទាំងសងខាងក៏គំនាប់គ្នាតាមប្រវេណី ហើយ**តេងងាយ**និយាយថា គ្រានេះលោកមកធ្វើការវាយបានស្រុកហាន់តុង ក៏ជាសេចក្ដីគាប់ប្រសើរធំណាស់ អស់ទាហានទាំងពួងក៏នាំគ្នាកោតសរសើរបញ្ញាត្រិះរិះគិតលោកច្រើនណាស់ សុំឲ្យលោករិះគិតធ្វើការតទៅដើម្បីនឹងវាយយកគយកៀមកោះឲ្យបាន។ **ចុងហោយ**សួរថា តម្រិះរិះគិតរបស់លោកនឹងវាយយកគយកៀមកោះនោះ តើនឹងឲ្យធ្វើការប្រការម្ដេចខ្លះ?

**តេងងាយ**ឆ្លើយថា តម្រិះប្រាជ្ញខ្ញុំមានតិចណាស់ នឹងរិះគិតធ្វើការនោះក៏ទញ់ទាល់ពេកណាស់ ខ្ញុំសុំពឹងតម្រិះប្រាជ្ញាលោកវិញទេតើ។ **ចុងហោយ**ក៏មិនស្ដាប់នៅតែសួរដល់បីគ្រាបួនគ្រា។ **តេងងាយ**ទាល់គំនិតណាស់ក៏ឆ្លើយថា ខ្ញុំយល់ឃើញថា ត្រូវតែវាយយកស្រុកសែឈ្មួនវិញ ព្រោះមានផ្លូវចូលទៅជាច្រើនប៉ែក សុំឲ្យលោកចាត់ទាហានមួយកងលើកទៅតាមផ្លូវតុកយុង បញ្ឆោតកងទ័ពស្រុកសែឈ្មួនទុកឲ្យឃើញថា នឹងចូលទៅវាយតាមផ្លូវនោះ មុខជា**ឡៅសៀន**នឹងចាត់កងទ័ពចេញមកតនឹងយើង បើ**កៀងអ៊ុយ**ដឹងគង់នឹងចោលគយមិនខាន ព្រោះឃើញថា យើងលើកកន្លងចូលទៅតាមផ្លូវនោះ នឹងទៅជួយគ្នា ត្រូវលោកចាត់ទាហានមួយកងឲ្យលបលើកចេញទៅតាមផ្លូវអ៊ឹមប៉េង ដណ្ដើមយកគយកៀមកោះ មុខជានឹងបានដោយងាយ។ បើបានគយកៀមកោះហើយ គយឯទៀតៗក៏គង់នឹងយកបានទាំងអស់យ៉ាងឆាប់។

**ចុងហោយ**បានឮដូច្នោះក៏ធ្វើជាត្រេកអរណាស់ថា បើដូច្នោះត្រូវលោកលើកទាហានបញ្ឆោតចូលទៅតាមផ្លូវអ៊ឹមប៉េងជាមុនសិន ខ្ញុំនឹងតាំងបង្អង់នៅទីនេះ។ បើ

លោកទៅហើយកើតវឹកវរប្រការម្ដេច សឹមខ្ញុំលើកទាហានជូនទៅជួយឲ្យទាន់ការ។ **តេងងាយ**បានស្ដាប់**ចុងហោយ**និយាយដូច្នោះ គំនាប់ហើយលាចេញទៅ។

ឯ**ចុងហោយ**នោះ លុះឃើញ**តេងងាយ**ចេញទៅហើយ ក៏និយាយនឹងនាយទ័ពនាយកងថា មនុស្សទាំងពួងសរសើរ**តេងងាយ**ថា មានប្រាជ្ញាចេះរិះគិតច្រើនណាស់ នោះយើងគិតឃើញថា ជាមែនណាស់កាលពីដើម តែឥឡូវនេះឃើញថាមិនមែនដូចឮសោះ ព្រោះឃើញថា**តេងងាយ**នោះ ធ្វើការទាំងពួងមើលទៅដូចជាមនុស្សល្ងង់ អ័ប្បឥតប្រាជ្ញាសោះ។ អស់ពួកទាហាននាំគ្នាសួរថា ហេតុម្ដេចបានជាលោកមានប្រសាសន៍ដូច្នេះ? **ចុងហោយ**ប្រាប់ថា ផ្លូវអ៊ឹមប៉េងនោះជាច្រកប្រហបភ្នំចង្អៀតណាស់ ចំពោះចុះតែជើងអ្នកមួយដើរទៅមក នឹងដើរកងទ័ពពិបាកណាស់ គួរឬ**តេងងាយ**មករិះគិតនឹងលើកទ័ពទៅតាមផ្លូវអ៊ឹមប៉េងនោះ! បីដូចជាដើរទៅច្រកចង្អៀតទាល់ផុតផ្លូវសោះ បើប្រសិនជាមានខ្មាំងសត្រូវលើកទ័ពមកស្កាត់ផ្លូវនោះ មិនបាច់ច្រើនប៉ុន្មានទេ សូម្បីតែត្រឹមមួយរយនាក់ ក៏មិនអាចនឹងទម្លាយចេញមកបាន ទាហានទាំងពួងក៏គង់នឹងអត់បាយអត់ទឹកស្លាប់អស់ នេះហើយឬដែលអស់លោកថាជាអ្នកមានប្រាជ្ញា បើជាមានតម្រិះចេះដឹងយ៉ាងណាដូចជាថា កាលណាឡើយ**តេងងាយ**នឹងចរចាដូច្នោះសោត? ឯតម្រិះរិះគិតនៃយើងដែលនឹងចូលទៅវាយយកស្រុកសែឈ្នួនគ្រានេះ នឹងលើកពលទាហានដើរតាមផ្លូវធំ មិនងាយទៅរកផ្លូវតូចឲ្យលំបាកទេ នឹងយកស្រុកសែឈ្នួនឲ្យបាន ថាហើយក៏បង្គាប់ទាហានទាំងពួងឲ្យធ្វើជើងជណ្ដើរហើយក៏រៀបបម្រុងទាហានទុកជាស្រេច។

ឯ**តេងងាយ**ក៏ដើរទៅតាមផ្លូវ ហើយសួរទាហានទាំងពួងថា យើងចូលទៅចរចានឹង**ចុងហោយ**អម្បាញ់មិញនោះ តើអ្នករាល់គ្នាយល់ឃើញកិរិយាអាការៈ**ចុងហោយ**នោះកោតក្រែងរាប់អានយើង នឹងខ្លាចតម្រិះប្រាជ្ញាយើងខ្លះដែរឬទេ? អស់ពួកទាហានឆ្លើយថា យើងខ្ញុំរាល់គ្នាពិគ្រោះមើលជាក់លាក់ ហើយឃើញថា**ចុងហោយ**នោះ កាលកំពុងសន្ទនានឹងលោកនោះ ឃើញដូចមិនមានសេចក្ដីរាប់អានទេ តែថានៅមានចិត្តកោតក្រែងរអែងខ្លាចណាស់ តែថាស៊ូស្លាប់រស់តែមាត់ក្រៅទេ។ **តេងងាយ**ថា **ចុងហោយ**នេះសម្គាល់ថាយើងនឹងវាយយកស្រុកសែឈ្នួនមិន

បាន ៗជាមើលងាយប្រមាថយើង ៗនឹងឧស្សាហ៍ធ្វើការកែខៃ វាយយកស្រុកនោះឲ្យត្រាតែបាន។ លុះ**តេងងាយ**ទៅដល់បន្ទាយហើយ ក៏ឲ្យត្រៀមទាហានទាំងពួងគ្រប់ពួកគ្រប់កង ហើយស្រូតលើកទៅទាំងកណ្ដាលយប់កណ្ដាលថ្ងៃ។...

# ចប់

## សូមជម្រាបមិត្តអ្នកអាន

ដោយឯកសារដើមរឿង សាមកុក នេះយើងខ្ញុំមានតែត្រឹមនេះ ដូច្នេះយើងខ្ញុំសូមបញ្ចប់រឿងតែត្រឹមនេះដែរ។ យោងតាមសង្ខេបរឿងដែលមាននៅក្នុងភាគទី១ បញ្ជាក់ថា នៅសល់តែប្រហែលតែមួយកណ្ឌទៀតប៉ុណ្ណោះ រឿងនេះនឹងត្រូវចប់។ យើងខ្ញុំមានការសោកស្ដាយណាស់ ដោយរកកណ្ឌបញ្ចប់នេះមិនបាន។ ហេតុនេះ សូមមិត្តអ្នកអានមេត្តាអភ័យទោស។

សូមអរគុណ។